## កំណត់សំគាល់

ចំណងជើងដែលត្រូវបានប្រើប្រាស់ និងការបង្ហាញខ្លឹមសារនៅក្នុងសៀវភៅនេះ មិនសំដៅដល់ការបញ្ចេញមតិយោបល់ណាមួយ ទោះជាតាមបែបណាក្តី ពីខាងផ្នែកលេខាធិការដ្ឋានអង្គការសហប្រជាជាតិ អំពីស្ថានភាពផ្លូវច្បាប់នៃប្រទេស ដែនដី ទីក្រុង ឬតំបន់ណាមួយ ឬស្ថានភាពនៃអាជ្ញាធរទីតាំងនោះ ឬអំពីការកំណត់ព្រំដែន ឬព្រំប្រទល់ផ្នែកណាមួយខាងលើនេះឡើយ។

និមិត្តសញ្ញានៃឯកសាររបស់អង្គការសហប្រជាជាតិមានអក្សរធំដែលត្រូវបានភ្ជាប់ជាមួយនឹងតួលេខ។ ការលើកឡើងនូវតួលេខបែបនេះ បង្ហាញអំពីសេចក្តីយោងទៅនឹងឯកសាររបស់អង្គការសហប្រជាជាតិ។

HR/PUB/11/02
ការបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ
បោះពុម្ពឡើងវិញនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ខែតុលា ឆ្នាំ ២០១៤
@ 2012 អង្គការសហប្រជាជាតិ
រក្សាសិទ្ធិគ្រប់យ៉ាងនៅទូទាំងពិភពលោក

# មាតិកា

អារម្ភកថា ..... 4
សេចក្តីផ្តើម ..... 10
I. គោលនយោបាយ និងក្របខ័ណ្ឌច្បាប់សម្រាប់សិទ្ធិមានលំនៅឋានសមរម្យរបស់ស្ត្រី..... 15
ក. ក្របខ័ណ្ឌបទដ្ឋានអន្តរជាតិ ..... 16
ខ. សិទ្ធិមានលំនៅឋានសមរម្យ និងការមិនរើសអើងដូចដែលបានតាមដានពិនិត្យមើលដោយស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ..... 28
គ. សន្ធិសីទជាសកល ..... 32
ឃ. លិខិតុបករណ៍ និងការអភិវឌ្ឍន៍ក្នុងតំបន់ ..... 35
II. ការរើសអើងទៅលើស្ត្រី ក្នុងវិស័យលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ ..... 37
ក. ច្បាប់ដែលមានលក្ខណៈរើសអើង ..... 42
១. បញ្ញត្តិក្នុងរដ្ឋធម្មនុញ្ញដែលមានការរើសអើង ..... 42
២. បញ្ញត្តិដែលមានលក្ខណៈរើសអើងក្នុងច្បាប់ជាក់លាក់ ..... 43
ខ. ច្បាប់ និងគោលនយោបាយដែលមិនបានពិចារណាអំពីកាលៈទេសៈជាក់លាក់របស់ស្ត្រី..... 45
គ. ច្បាប់និងការអនុវត្តតាមតាមទំនៀមទម្លាប់ ដែលមានការរើសអើង ..... 47
ឃ. ឥរិយាបថលំអៀង ..... 51
ង. កង្វះខាតសិទ្ធិទទួលបានដំណោះស្រាយ និងការយល់ដឹងអំពីសិទ្ធិ ..... 52
ច. កង្វះការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត ..... 53
III. សម្រាំងបញ្ហាសំខាន់ៗ ..... 55
ក. មរតក ..... 56
ខ. ការបណ្តេញចេញដោយបំពាន ..... 64
គ. លក្ខខណ្ឌលំនៅឋានមិនសមរម្យ ..... 69
ឃ. ទំនាក់ទំនងរវាងអំពើហិង្សាក្នុងគ្រួសារ និងសិទ្ធិមានលំនៅឋានសមរម្យរបស់ស្ត្រី..... 74
ង. មេរោគអេដស៍/ជំងឺអេដស៍ ..... 79
ច. គ្រោះមហន្តរាយធម្មជាតិ និងបម្រែបម្រួលអាកាសធាតុ ..... 82
ឆ. វិបត្តិហិរញ្ញវត្ថុ ..... 84
សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ..... 87

# ការថ្លែងអំណរគុណ

ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (ការិយាល័យ OHCHR) សូមថ្លែងអំណរគុណដល់បុគ្គលទាំងឡាយដែលបានផ្តល់មតិយោបល់ សំណូមពរ និងការគាំទ្រសម្រាប់ការរៀបចំការបោះពុម្ពផ្សាយនេះ ឬ បានចូលរួមក្នុងការប្រឹក្សាយោបល់ជាច្រើន ដែលរៀបចំឡើងដោយអ្នករាយការណ៍ពិសេស។ ជាពិសេស ការិយាល័យ OHCHR សូមថ្លែងអំណរគុណដល់ការចូលរួមចំណែកពីអាលីសុន អាហ្គាវ៉ែល (Alison Aggarwal) រេប៊េកា ប្រោន (Rebecca Brown) គ្រីស្ទៀន ខតធីស (Christian Courtis) ហ្គ្រាស៊ីអេឡា ដេដេ (Graciela Dede) ឡេឡានី ហ្វាហ៉ា (Leilani Farha) អាម៉ានដា ហ្វឡូរ៉េស (Amanda Flores) បាហ៉ាម ហ្គាហ្ស៊ី (Bahram Ghazi) មេរ៉ា ហ្គោម៉េស (Mayra Gomez) ដេនីស ហូសេ (Denise Hauser) សេស៊ីលីយ៉ា មូឡឺ (Cecilia Möller) លូស៊ីនដា អូហានឡុន (Lucinda O’Hanlon) និង បៀទ្រីស ខ្វាដ្រានទី (Beatrice Quadranti)។

# ស្ត្រី និងសិទ្ធិមានលំនៅឋានសមរម្យ

## អារម្ភកថា

ប្រទេសមួយចំនួន ត្រូវបានគេឃើញសិទ្ធិកម្មសិទ្ធិលើដីធ្លី និងអចលនទ្រព្យ មានការផ្លាស់ប្តូរជាខ្លាំង ដូចជា ប្រទេសកម្ពុជាដែរ ក្នុងរយៈពេលបួនទសវត្សចុងក្រោយនេះ។ បន្ទាប់ពីកម្មសិទ្ធិឯកជនត្រូវបានលុបបំបាត់ចោល ក្រោមរបបខ្មែរក្រហម និងដីធ្លីទាំងអស់បានក្លាយជាសម្បត្តិរដ្ឋ កម្មសិទ្ធិដីឯកជនត្រូវបានផ្តល់ឲ្យមានជាថ្មីនៅចុងទសវត្សឆ្នាំ១៩៨០។ ច្បាប់ភូមិបាល ឆ្នាំ១៩៩២ បានកំណត់នីតិវិធីច្បាប់ ដែលដាក់ឲ្យមានដំណើរការជំនួញដីធ្លី និងដោយបង្កើតនូវគ្រឹះសម្រាប់ការរីកលូតលាស់យ៉ាងខ្លាំងនៅក្នុងវិស័យនេះ ប៉ុន្តែជាការរីកលូតលាស់មួយដែលមាន ការគ្រប់គ្រងដ៏ទន់ខ្សោយ និងប្រកបដោយវិសមភាពជាខ្លាំង។ ដោយមានការអនុម័តច្បាប់ភូមិបាលឆ្នាំ២០០១ គម្រោងផ្តល់កម្មសិទ្ធិដីធ្លីទ្រង់ទ្រាយធំដែលគាំទ្រដោយម្ចាស់ជំនួយ ត្រូវបានបង្កើតឡើង ដែលបានពន្លឿនអន្តរកាល ឈានទៅកាន់សេដ្ឋកិច្ចទីផ្សារសេរី។ អង្គការមិនមែនរដ្ឋាភិបាលជាតិមួយរាយការណ៍ថា ទំនាស់ដីធ្លីដែលពាក់ព័ន្ធនឹងរដ្ឋ បានប៉ះពាល់ប្រជាជនកម្ពុជាច្រើនជាង ៥០០.០០០ នាក់ នៅចន្លោះខែមករា ឆ្នាំ២០០០ និងខែមីនា ឆ្នាំ២០១៤ នៅក្នុងខេត្តចំនួន១៣ ក្នុងចំណោម ២៤ខេត្ត ដែលបានឃ្លាំមើលប៉ុណ្ណោះ។

សមភាពនៃសិទ្ធិលើដីធ្លី និងសិទ្ធិមានលំនៅឋាន ត្រូវបានការពារយ៉ាងច្បាស់ក្នុងក្របខ័ណ្ឌច្បាប់កម្ពុជា បើទោះជាសិទ្ធិលើដីធ្លីជាក់លាក់សម្រាប់ស្ត្រី មិនត្រូវបានកំណត់ដោយឡែកពីគ្នាក្តី។ យោងតាមរដ្ឋធម្មនុញ្ញ ស្ត្រីមានសិទ្ធិតាមច្បាប់ដូចគ្នានឹងបុរស ចំពោះសិទ្ធិកម្មសិទ្ធិ ការទទួលមរតក និងការគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់ខ្លួន។ លើសពីនេះទៀត រដ្ឋធម្មនុញ្ញនេះទទួលស្គាល់សិទ្ធិមនុស្សដូចបានកំណត់ក្នុង *ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស* និងកតិកាសញ្ញា និងអនុសញ្ញាស្តីពីសិទ្ធិមនុស្ស និងសិទ្ធិស្ត្រី និង សិទ្ធិកុមារ។ ក្នុងចំណោមលិខិតុបករណ៍ដែលកម្ពុជាជាប់កាតព្វកិច្ចច្បាប់អនុវត្តតាមមាន កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ និងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងពិធីសារបន្ថែមនៃអនុសញ្ញានេះ ដែលបង្កើតជាមូលដ្ឋានសម្រាប់សៀវភៅនេះ។ ការិយាល័យ OHCHR និង UN Women ចាត់ទុកសៀវភៅនេះថា នៅមានភាពពាក់ព័ន្ធសម្រាប់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ហើយដែលយើងរីករាយនឹងរួមដៃគ្នារៀបចំការបោះពុម្ពផ្សាយសៀវភៅនេះឡើងសម្រាប់មិត្តអ្នកអានកម្ពុជា។

ការិយាល័យ OHCHR និង UN Women ទទួលស្គាល់ការប្តេជ្ញាចិត្តខាងគោលនយោបាយដ៏រឹងមាំដែលបានធ្វើឡើងនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ដើម្បីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ដោយមានគោលបំណងជាក់លាក់ក្នុងការធ្វើឲ្យប្រសើរឡើងដល់សុវត្ថិភាពនៃការកាន់កាប់ដីធ្លីរបស់ស្ត្រី។ យោងតាមតួលេខរបស់រដ្ឋាភិបាល គិតត្រឹមខែមេសា ឆ្នាំ២០១៤ មានប័ណ្ណកម្មសិទ្ធិដីជិត ៣ លាន ត្រូវបានចេញផ្តល់ជូនប្រជាពលរដ្ឋ ក្រោមកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី និងកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដទៃទៀត។ យោងតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១០ គឺមាន ២០% នៃអចលនទ្រព្យ ត្រូវបានកាន់កាប់ជាលក្ខណៈ

ឯកជនដោយស្ត្រី ផ្ទុយទៅវិញគឺមាន ៥% នៃអចលនទ្រព្យប៉ុណ្ណោះដែលត្រូវបានកាន់កាប់ដោយបុរស។ តួលេខពីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលឯករាជ្យ បញ្ជាក់ថា ចំនួនប័ណ្ណកម្មសិទ្ធិដីធ្លីដែលចេញផ្តល់ឲ្យស្ត្រីមានការកើនឡើងជាបណ្តើរៗ។ គោលដៅដែលថាយ៉ាងហោចណាស់ ១៥-២០% នៃប័ណ្ណកម្មសិទ្ធិដីធ្លីជាលក្ខណៈឯកជន នឹងត្រូវចេញផ្តល់ឲ្យទៅស្ត្រី នៅត្រឹមឆ្នាំ២០១៥ ដូចបានបានបង្ហាញនៅក្នុងផែនការសកម្មភាពរបស់កម្ពុជាសម្រាប់លើកកម្ពស់ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី អាចនឹងសម្រេចបានដោយមានការជួយឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុថែមទៀតដល់សកម្មភាពយេនឌ័រក្នុងវិស័យដីធ្លីពីដៃគូអភិវឌ្ឍន៍នានា។

ទោះជាយ៉ាងណាក៏ដោយ នៅតែមានឧបសគ្គចម្បងៗនៅឡើយ ចំពោះការទទួលបានសិទ្ធិមានលំនៅឋានសមរម្យ និងកំរិតជីវភាពរស់នៅគ្រប់គ្រាន់របស់ស្ត្រី រាប់ទាំងឧបសគ្គដែលមានចរិតលក្ខណៈសង្គម ឬសេដ្ឋកិច្ច។ ទន្ទឹមនឹងនីតិរដ្ឋមានភាពទន់ខ្សោយ និងភាពចន្លោះប្រហោងក្នុងការអនុវត្តក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ស្តីពីដីធ្លី អាចប៉ះពាល់ដល់អ្នកទាំងឡាយដែលកំពុងមានទំនាស់ដីធ្លី ផលប៉ះពាល់គឺមិនស្មើគ្នានោះទេ។ អ្នកក្រីក្រ និងជនងាយរងគ្រោះ ជាពិសេសស្ត្រីដែលស្ថិតក្នុងចំណោមនោះ ជារឿយៗ គឺជាអ្នកដែលរងគ្រោះជាងគេបំផុត។ ស្ត្រីមិនទំនងជាទទួលបានអត្ថប្រយោជន៍ពីការអប់រំក្នុងប្រព័ន្ធផ្លូវការ ហើយស្ត្រីវ័យក្មេងជាមេគ្រួសារ ជារឿយៗ មានជីវភាពរស់នៅក្រខ្សត់ជាងគ្រួសារដែលមានបុរសជាមេគ្រួសារ ដែលពួកគេមានលទ្ធភាពដ៏មានកម្រិតបំផុតក្នុងការទៅប្រើប្រាស់និតិវិធីតាមប្រព័ន្ធតុលាការ ហើយដោយសារតែការអប់រំមានកម្រិតទាប ទើបជារឿយៗ ពួកគេត្រូវពឹងផ្អែកលើសមាជិកក្រុមគ្រួសារដែលជាបុរស នៅពេលដែលពួកគេត្រូវការប្រាស្រ័យទាក់ទងជាមួយអាជ្ញាធររដ្ឋ ដើម្បីដោះស្រាយបញ្ហាផ្សេងៗ។ ស្ត្រីទំនងជាត្រូវពឹងផ្អែកលើប្រាក់កម្ចីឥណទាន ច្រើនជាងមេគ្រួសារជាបុរស។ ដោយសារជាប់បំណុលច្រើន ជាមួយនឹងប្រាក់ចំណូលដ៏មានកម្រិត ស្ត្រីទំនងជានឹងត្រូវលក់ផ្នែកខ្លះនៃដីរបស់ខ្លួនដើម្បីសងបំណុល។

ថ្វីបើមានក្របខ័ណ្ឌច្បាប់មួយសមហេតុផលក្តី ក៏ដំណើរការនៃបណ្តេញចេញ និងការតាំងទីលំនៅថ្មីនៅបន្តញាំញីដោយការរំលោភបំពានលើកម្រិតជាច្រើន ដែលប៉ះពាល់ខ្លាំងដល់ស្ត្រី និងកុមារ ដោយសារតែបញ្ហាទូទៅនៃកង្វះការអនុវត្តច្បាប់។ កន្លែងតាំងទីលំនៅថ្មី តែងតែខ្វះនូវសេវាសុខភាព អប់រំ និងអនាម័យ។ ជារឿយៗ សមាជិកគ្រួសារត្រូវរស់នៅបែកគ្នា ដោយសារតែខ្វះឱកាសការងារជាប់លាប់ នៅក្នុង និងនៅតំបន់ជិតកន្លែងតាំងទីលំនៅថ្មី។ ជាញឹកញាប់ កុមារត្រូវបោះបង់ចោលការសិក្សា ហើយតាមធម្មតាក្មេងស្រីត្រូវបោះបង់ចោលការរៀនសូត្រមុនក្មេងប្រុស ដោយសារតែគ្មានសាលារៀននៅកន្លែងតាំងទីលំនៅថ្មីនោះ ឬដោយសារតែគ្រួសារត្រូវការឱ្យពួកគេធ្វើការងារ។ កម្រិតទាបជាទូទៅនៃការសិក្សាអប់រំ និងអនក្ខរកម្មរបស់ពួកគេ រិតតែធ្វើឲ្យស្ត្រីកម្ពុជាខូចខាតអត្ថប្រយោជន៍ក្នុងការទទួលបាននូវភស្តុតាងបញ្ជាក់ពី ភាពជាម្ចាស់កម្មសិទ្ធិលើដីធ្លីរបស់ពួកគេ ដែលវាជាឧបសគ្គដល់លទ្ធភាពទទួលបានយុត្តិធម៌ និងសំណង។ បញ្ហាទាំងនេះមានលក្ខណៈធ្ងន់ធ្ងរសម្រាប់ស្ត្រីដែលមកពីសហគមន៍ជនជាតិដើមភាគតិច និងក្រុមជនភាគតិច ដែលទំនងជាកាន់តែក្រីក្រទៅៗ និងរស់នៅក្នុងទីតាំងដែលពិបាកនឹងចូលទៅដល់ ជាងប្រជាជនធម្មតា។

មិនត្រឹមតែប៉ុណ្ណោះ ទោះជាមានឧបសគ្គបែបនេះក្តី ស្ត្រីកម្ពុជាបានដើរតួនាទីនាំមុខគេក្នុងការតស៊ូប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ ជាពិសេសនៅក្នុងតំបន់ទីក្រុង។ នេះជាសញ្ញាមួយបង្ហាញពីលទ្ធភាពនៃការពង្រឹងអំណាចរបស់ពួកគេ ហើយជាពិសេសគឺភាពអង់អាចក្លាហានរបស់ពួកគេដែលជាអ្នកដួរមុខក្នុង

ការប្រឈមដោយផ្ទាល់នឹងអំពើហិង្សា ការបំភិតបំភ័យ និងការយាយីតាមផ្លូវតុលាការ។ សៀវភៅនេះគឺដើម្បីឧទ្ទិសដល់ពួកគេ។

បញ្ហាចម្បងៗទាំងនេះ គឺជាបញ្ហាអាទិភាពបំផុត សម្រាប់គណៈកម្មាធិការ ទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទរបស់អង្គការសហប្រជាជាតិ នៅពេលដែលគណៈកម្មាធិការនេះពិនិត្យរបាយការណ៍តាមកាលកំណត់លើកទី៤ និងទី៥ របស់កម្ពុជា ក្នុងឆ្នាំ២០១៣។ នៅក្នុងសេចក្តីសន្និដ្ឋានចុងក្រោយរបស់ខ្លួន គណៈកម្មាធិការទទួលស្គាល់កិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើងដោយរដ្ឋាភិបាលដើម្បីពង្រឹងលទ្ធភាពទទួលបានដីធ្លី ប៉ុន្តែបានសម្តែងកង្វល់អំពីបញ្ហាដែលស្ត្រីកំពុងប្រឈមក្នុងការទទួលបានសុវត្ថិភាពខាងការកាន់កាប់ដីធ្លី និងលំនៅឋានរបស់ខ្លួន។ គណៈកម្មាធិការនេះ បានអំពាវនាវឲ្យពង្រឹងលទ្ធភាពទទួលបានដីធ្លីសម្រាប់ស្ត្រី ការទទួលស្គាល់ពីផលប៉ះពាល់ដែលមិនសមាមាត្រនៃការបណ្តេញចេញដោយបង្ខំទៅលើពួកគេ និងការសន្យាធានាថា ការតាំងលំនៅថ្មីនឹងត្រូវអនុវត្តតាមនីតិវិធីត្រឹមត្រូវ ហើយថានៅកន្លែងតាំងទីលំនៅថ្មី នឹងត្រូវមានការផ្តល់ឲ្យនូវសេវា និងហេដ្ឋារចនាសម្ព័ន្ធសមស្រប ដើម្បីការពារដល់សិទ្ធិស្ត្រី។ គណៈកម្មាធិការនេះបានបញ្ជាក់អំពីតម្រូវការក្នុងការធានាឲ្យមានការទទួលខុសត្រូវពីមន្ត្រីអនុវត្តច្បាប់ដែលបានបំភិតបំភ័យ និងគំរាមកំហែងដល់អ្នកការពារសិទ្ធិមនុស្ស ជាស្ត្រីដែលធ្វើការតស៊ូមតិដើម្បីសិទ្ធិដីធ្លី។

ឆ្លើយតបនឹងអនុសាសន៍ទាំងនេះ គឺការគាំទ្របន្ថែមទៀតលើការងាររបស់ការិយាល័យ OHCHR និង UN Women ក្នុងការលើកកម្ពស់ និងអនុវត្តសិទ្ធិដីធ្លី និងសិទ្ធិលើទ្រព្យសម្បត្តិរបស់ស្ត្រីនៅកម្ពុជា។ តាមរយៈការលើកកម្ពស់សិទ្ធិមានលំនៅឋានសមរម្យ និងកម្រិតជីវភាពរស់នៅគ្រប់គ្រាន់របស់ស្ត្រី បង្ការការបណ្តេញចេញដោយបង្ខំ លើកកម្ពស់សុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី និងការការពារអ្នកការពារសិទ្ធិមនុស្ស ការិយាល័យ OHCHR និង UN Women ទទួលស្គាល់ថា លទ្ធភាពទទួលបានលំនៅឋានសមរម្យ រួមចំណែកដល់ការពង្រឹងសិទ្ធិអំណាចខាងសេដ្ឋកិច្ចរបស់ស្ត្រី និងជាបុរេលក្ខខណ្ឌសម្រាប់ការទទួលបានពេញលេញនូវសិទ្ធិមនុស្សជាច្រើនដទៃទៀត។

សៀវភៅនេះកំណត់អំពីក្របខ័ណ្ឌសិទ្ធិមនុស្សអន្តរជាតិដែលកំពុងអនុវត្តស្តីពី សិទ្ធិមានលំនៅឋានសមរម្យរបស់ស្ត្រី និងការការពារអ្នកការពារសិទ្ធិមនុស្សជាស្ត្រី ដែលធ្វើការងារលើបញ្ហាលំនៅឋាន និងបញ្ហាសិទ្ធិដីធ្លី និងទ្រព្យសម្បត្តិ។ សៀវភៅនេះក៏កំណត់ផងដែរអំពីភាពងាយរងគ្រោះមួយចំនួនដែលស្ត្រីនៅកម្ពុជាប្រឈមក្នុងការការពារសិទ្ធិខាងលំនៅឋាន សិទ្ធិដីធ្លី និងទ្រព្យសម្បត្តិរបស់ខ្លួន និងគំនិតផ្តួចផ្តើមនានាដែលអនុវត្តបានជោគជ័យនៅប្រទេសផ្សេងៗ ដែលអាចយកមកអនុវត្តនៅទីនេះ។ តាមរយៈការលើកកម្ពស់ និងការអនុវត្តក្របខ័ណ្ឌសិទ្ធិមនុស្សនៅកម្ពុជា សមត្ថភាពរបស់ស្ត្រីក្នុងការអនុវត្តពេញលេញនូវសិទ្ធិរបស់ខ្លួននឹងត្រូវបានពង្រីកថែមទៀត។ យើងជឿជាក់ថា ប្រជាជាតិទាំងមូលនឹងទទួលបានអត្ថប្រយោជន៍ពីសៀវភៅនេះ។ សម្រាប់ធនធានបន្ថែមសូមមើលផ្នែកខាងក្រោយនៃសៀវភៅនេះ។

Wan-Hea Lee
Representative
OHCHR-Cambodia office

Wenny Kusuma
Representative
UNWomen

# សេចក្តីសង្ខេប

សិទ្ធិមានលំនៅឋានសមរម្យ ត្រូវបានទទួលស្គាល់យ៉ាងច្បាស់ក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ក្នុងនោះរួមមានកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលចែងអំពី "សិទ្ធិរបស់ជនគ្រប់រូប ក្នុងការទទួលបានកម្រិតជីវភាពគ្រប់គ្រាន់សម្រាប់ខ្លួនផ្ទាល់ និង សម្រាប់គ្រួសារខ្លួន រួមមានចំណីអាហារ សម្លៀកបំពាក់ និង លំនៅឋានសមរម្យ ព្រមទាំងការរីកចម្រើនជាលំដាប់នៃលក្ខខណ្ឌរស់នៅរបស់គេ" (មាត្រា ១១.១)។

ក៏ប៉ុន្តែ មានប្រជាជនជាងមួយពាន់លាននាក់រស់នៅក្នុងស្ថានភាពគ្មានសុវត្ថិភាពក្នុងតំបន់ក្រីក្រតាមទីប្រជុំជន និងតំបន់រស់នៅមិនទាន់រៀបរយ ដែលមានការគំរាមកំហែងដល់សុខភាពរបស់ពួកគេ និងដល់សូម្បីតែជីវិតរបស់ពួកគេទៀតផង។ ជាងនេះទៅទៀត ប្រជាជនប្រហែល ១០០ លាននាក់អាចនឹងគ្មានផ្ទះសម្បែងនៅថ្ងៃណាមួយ។ លើសពីនេះទៀត ប្រជាជនរាប់លាននាក់ ត្រូវគេបណ្តេញចេញដោយបំពាន ឬ ចាកចេញដោយបង្ខំចិត្តចេញពីផ្ទះសម្បែងរបស់ខ្លួនជារៀងរាល់ឆ្នាំ។ ការវិភាគផ្អែកលើយេនឌ័របង្ហាញថា ស្ត្រីបានទទួលរងផលប៉ះពាល់ជាពិសេស ហើយការបោះពុម្ពផ្សាយនេះមានបំណងផ្តល់ការពន្យល់អំពីហេតុផលចម្បងៗចំពោះស្ថានភាពនេះ។

ឯកសារនេះផ្តល់នូវទិដ្ឋភាពទូទៅមួយអំពីអត្ថន័យ បំណង និងការបញ្ជាក់ពីសិទ្ធិមនុស្សក្នុងការទទួលបានលំនៅឋានសមរម្យ និងបកស្រាយពន្យល់អំពីឧបសគ្គទាំងតាមផ្លូវច្បាប់ និងតាមការអនុវត្តជាក់ស្តែងដែលកើតឡើងចំពោះស្ត្រីទូទាំងពិភពលោក ដែលនាំឲ្យខកខានមិនបានទទួលសិទ្ធិនេះប្រកបដោយប្រសិទ្ធភាព។

ក្នុងរយៈពេលជាច្រើនឆ្នាំនេះ យន្តការសិទ្ធិមនុស្សជាច្រើនបានទាញចំណាប់អារម្មណ៍ចំពោះផលប៉ះពាល់នៃវិសមភាពយេនឌ័រ និងការរើសអើងទៅលើការទទួលបានសិទ្ធិរបស់ស្ត្រីក្នុងការទទួលបានលំនៅឋានសមរម្យ។ ក្នុងឆ្នាំ២០០២ គណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ក្នុងសេចក្តីសម្រេចលេខ ២០០២/៤៩ បានប្រគល់ភារកិច្ចដល់អ្នករាយការណ៍ពិសេសដំបូងស្តីពីលំនៅឋានសមរម្យ គឺលោក មីលូន កូថារី (ឥណ្ឌា) ក្នុងការធ្វើសេចក្តីរាយការណ៍អំពីស្ត្រី និងលំនៅឋានសមរម្យ ហើយគណៈកម្មការនេះបានសម្រេចចិត្តទុកក្នុងរបៀបវារៈរបស់ខ្លួននូវបញ្ហាស្តីពី ភាពស្មើគ្នាលើកម្មសិទ្ធិ ការទទួលបាន និងការកាន់កាប់លើដីធ្លីរបស់ស្ត្រី ព្រមទាំងបញ្ហាស្តីពីសិទ្ធិស្មើភាពគ្នាក្នុងការធ្វើជាម្ចាស់ទ្រព្យសម្បត្តិ និងក្នុងការទទួលបានលំនៅឋានសមរម្យ។ ឯកសារនេះចម្រាញ់ចេញមកពីការរកឃើញរបស់គាត់អំពីសិទ្ធិស្ត្រី ដោយផ្អែកលើការពិគ្រោះយោបល់ថ្នាក់តំបន់ជាមួយអង្គការសង្គមស៊ីវិល ចន្លោះឆ្នាំ២០០២ និង ២០០៦ និង ការបំពេញបេសកកម្មតាមប្រទេសជាច្រើនលើក ការផ្តល់សក្ខីកម្ម និងព័ត៌មានដែលទទួលបានពីក្រុមទាំងឡាយនៅតាមមូលដ្ឋាន[1]។ ឯកសារនេះក៏ទាញចេញពីការងារដែលបានធ្វើឡើងដោយអ្នករាយការណ៍ពិសេសទីពីរទទួលបន្ទុកបញ្ហាលំនៅឋានសមរម្យ គឺលោកស្រី រ៉ាកែល រ៉ូលនីក (ប្រេស៊ីល) ដែលបានទទួលការតែងតាំងក្នុងឆ្នាំ២០០៨។ ក្នុងឆ្នាំ២០១១ លោកស្រីបានផ្តួចផ្តើមបង្កើតការពិគ្រោះយោបល់ទូទាំងពិភពលោកតាម

[1] សូមមើល E/CN.4/2003/55, E/CN.4/2005/43 and E/CN.4/2006/118។

ប្រព័ន្ធអ៊ីនធឺណែតអំពីស្ត្រីនិងសិទ្ធិទទួលបានលំនៅឋានសមរម្យ ហើយក្នុងឆ្នាំ ២០១២ លោកស្រីបានបង្ហាញលទ្ធផលនៅក្នុងរបាយការណ៍ ឆ្នាំ២០១២ របស់លោកស្រី ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ ការងាររបស់លោកស្រីស្តីពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុទៅលើសិទ្ធិទទួលបានលំនៅឋានសមរម្យ និងស្តីពីបម្រែបម្រួលអាកាសធាតុ ក៏មានជាប់ទាក់ទងនឹងការវិភាគអំពីស្ត្រី និងសិទ្ធិមានលំនៅឋានសមរម្យ។

ការងាររបស់យន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិផ្សេងទៀត ដូចជាគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងគណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី ក៏មានបញ្ចូលនៅក្នុងឯកសារនេះដែរ។ សម្រាប់ការវិភាគស៊ីជម្រៅបន្ថែមលើប្រធានបទជាក់លាក់ផ្សេងៗ ឯកសារនេះក៏បានទាញចេញពីឯកសារប្រគល់សិទ្ធិឲ្យ ជាពិសេសជាច្រើន។ ឯកសារនេះបង្ហាញអំពីចំណងខាងគំនិតការអនុវត្តវិជ្ជមាន និងភាពជាប់ជំពាក់ខាងគោលនយោបាយសម្រាប់រដ្ឋ សម្រាប់ទីភ្នាក់ងារ និងស្ថាប័នអង្គការសហប្រជាជាតិ និងសម្រាប់អង្គការសង្គមស៊ីវិល។

ឯកសារនេះចែកចេញជាបួនផ្នែកសំខាន់ៗ។ បន្ទាប់ពីការណែនាំ ជំពូកទី១ រៀបរាប់អំពីក្របខ័ណ្ឌច្បាប់ និងគោលនយោបាយអន្តរជាតិ សម្រាប់ការអនុវត្តសិទ្ធិស្ត្រីក្នុងការទទួលបានលំនៅឋានសមរម្យ ដោយរាប់បញ្ចូលទាំងសន្ធិសញ្ញាសិទ្ធិមនុស្ស គោលការណ៍មិនរើសអើង និងសមភាព ព្រមទាំងការសម្រេចបានជាលំដាប់នៃសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ជំពូកទី២ បង្ហាញអំពីមូលហេតុចម្បងៗ ដោយរាប់ចាប់ពីច្បាប់ដែលមានការរើសអើង រហូតដល់ច្បាប់តាមទំនៀមទម្លាប់ និងការអនុវត្ត ព្រមទាំងកង្វះខាតក្នុងការទទួលបានដំណោះស្រាយផ្នែកច្បាប់ និងដំណោះស្រាយផ្សេងៗទៀត។ ចុងក្រោយ ជំពូកទី៣ ពន្យល់អំពីបញ្ហាជ្រើសរើសមួយចំនួន ដូចជាការបណ្តេញចេញដោយបំពាន ស្ថានភាពរស់នៅក្នុងសភាពបន្ទោកបន្ទាប និងការទទួលស្គាល់ផ្នែកវប្បធម៌ និងផ្នែកសាសនាទៅលើសិទ្ធិស្ត្រី ដោយមានការគូសបញ្ជាក់អំពីភាពស្រដៀងគ្នា និងភាពខុសគ្នាក្នុងតំបន់។

បន្ថែមពីលើការរំលេចអំពីច្បាប់ជាតិដែលមានលក្ខណៈរើសអើង ឯកសារនេះពន្យល់អំពីថាតើគម្លាតរវាងការការពារសិទ្ធិស្ត្រីក្នុងការមានលំនៅឋានសមរម្យតាមផ្លូវច្បាប់ និងតាមការអនុវត្តជាក់ស្តែង ដែលនៅពេលបច្ចុប្បន្នជាឧបសគ្គយ៉ាងខ្លាំងក្លា សម្រាប់ធ្វើឲ្យសម្រេចបានសិទ្ធិក្នុងការទទួលបានលំនៅឋានសមរម្យនៅទូទាំងពិភពលោកមានលក្ខណៈដូចម្តេច។ ឯកសារនេះសង្កត់ធ្ងន់ថា នៅក្នុងប្រទេសជាច្រើន សិទ្ធិស្ត្រីត្រូវបានការពារដោយច្បាប់ ក៏ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែង ស្ត្រីទទួលរងនូវគុណវិបត្តិទាំងផ្នែកសង្គម និងផ្នែកសេដ្ឋកិច្ច ហើយប្រឈមនឹងការរើសអើងជាក់ស្តែងចំពោះសិទ្ធិខាងលំនៅឋាន សិទ្ធិដីធ្លី និងសិទ្ធិទទួលមរតក។ របៀបសំខាន់មួយក្នុងចំណោមរបៀបសំខាន់ៗជាច្រើនដែលបង្ហាញនូវឧបសគ្គនេះដោយខ្លួនឯងនោះ គឺទាក់ទងនឹងច្បាប់ដែលមានលក្ខណៈអព្យាក្រឹត្យយេនឌ័រ ដែលត្រូវគេបកស្រាយ និងអនុវត្តក្នុងន័យផ្តល់គុណវិបត្តិ និងរើសអើងចំពោះស្ត្រី។

ភាពងាយរងគ្រោះដោយសារអំពើហិង្សាមួយចំនួនរបស់ក្រុមស្ត្រីផ្សេងៗ មានដូចជា ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ ស្ត្រីមេម៉ាយ ស្ត្រីលែងលះប្តី ឬ ស្ត្រីរស់នៅបែកពីប្តី ស្ត្រីមេគ្រួសារ ជនរងគ្រោះនៃការបណ្តេញចេញដោយបំពាន ស្ត្រីជនជាតិដើមភាគតិច និងស្ត្រីកុលសម្ព័ន្ធ ស្ត្រីពិការ ស្ត្រីក្នុងស្ថានភាពជម្លោះ ឬក្រោយជម្លោះ កម្មករចំណាកស្រុក ស្ត្រីមកពីសហគមន៍ក្រីក្រដែលផ្អែកលើការងារបន្តិចបន្តួច អ្នកធ្វើការ

តាមផ្ទះ ស្ត្រីក្នុងពន្ធនាគារ អ្នកបម្រើសេវាផ្លូវភេទ ព្រមទាំងស្រីស្រលាញ់ភេទដូចគ្នា និងស្ត្រីប្តូរភេទ គឺជាឧបសគ្គចម្បងមួយផ្សេងទៀតក្នុងការសម្រេចបានសិទ្ធិមានលំនៅឋានសមរម្យ។ ដោយសារតែកត្តារួមផ្សំទាំងឡាយ ស្ត្រីទាំងនេះប្រឈមនឹងស្ថានភាពលំនៅឋានខុសៗគ្នា ហើយអាចក្លាយជាមនុស្សដែលគ្មានលំនៅឋាន ឬ អាចរស់នៅក្នុងលំនៅឋានមិនសមរម្យ។

ការរំលេចឲ្យឃើញអំពីការរំលោភបំពានទាក់ទងនឹងលំនៅឋាន ដែលក្រុមស្ត្រីងាយរងគ្រោះផ្សេងៗគ្នាបានជួបប្រទះ គឺជាការបង្ហាញឲ្យកាន់តែច្បាស់អំពីផលប៉ះពាល់នៃការរើសអើងជាច្រើនមកលើពួកគេ ដែលជាលទ្ធផលនៃយេនឌ័រ ពូជសាសន៍ វណ្ណៈ ជាតិពន្ធុ អាយុ និងកត្តាផ្សេងទៀត ប៉ុន្តែ នៅក្នុងករណីជាច្រើន ក៏វាជាលទ្ធផលនៃភាពក្រីក្រ និងកង្វះខាតការទទួលបានធនធានសង្គម និងសេដ្ឋកិច្ចដែរ។

មានឧទាហរណ៍ជាច្រើនអំពីគំនិតផ្តួចផ្តើមបង្កើតឡើងដោយស្ត្រី និងក្រុមស្ត្រីជាច្រើននៅជុំវិញពិភពលោក ដើម្បីដោះស្រាយបញ្ហាទូទៅ និងជាក់លាក់ទាំងអស់នោះ ដែលជាការពន្យល់បង្ហាញអំពីភាពខ្លាំង និងគំនិតច្នៃប្រឌិតរបស់ស្ត្រី និងសហគមន៍ ដែលបានឆ្លើយតបនឹងការរំលោភបំពានសិទ្ធិស្ត្រីក្នុងការមានលំនៅឋានសមរម្យ ដីធ្លី និងមរតក។ ហើយក៏មានឧទាហរណ៍ជាច្រើនអំពីគម្រោងដំណើរការដោយសហគមន៍ជាច្រើន ជួនកាលដំណើរការជាមួយរដ្ឋ ដើម្បីដោះស្រាយតម្រូវការ និងការរំលោភបំពានសិទ្ធិស្ត្រីឲ្យមានលក្ខណៈវិជ្ជមាន។ ឧទាហរណ៍មួយចំនួនត្រូវបានរំលេចឡើងក្នុងឯកសារនេះ។ ដូច្នេះ គោលបំណងរបស់ឯកសារនេះ មានពីរ៖ ផ្តល់ព័ត៌មានពន្យល់អំពីឧបសគ្គចម្បងៗរារាំងស្ត្រីមិនឲ្យទទួលបានសិទ្ធិពេញលេញក្នុងការទទួលបានលំនៅឋានសមរម្យ និងផ្តល់ការណែនាំអំពីវិធានការក្នុងការទប់ស្កាត់ និងលុបបំបាត់ការរើសអើង ដោយរាប់បញ្ចូលទាំងអំពើហិង្សាទៅលើស្ត្រីទាក់ទងនឹងសិទ្ធិលំនៅឋាន។

# សេចក្តីផ្តើម

*សិទ្ធិមនុស្សមានលំនៅឋានសមរម្យ គឺជាសិទ្ធិរបស់ស្ត្រី បុរស យុវជន និងកុមារគ្រប់រូប ក្នុងការទទួលបាន និងរក្សាផ្ទះសម្បែង និងសហគមន៍មួយដែលគត់មត់ និងមានសុវត្ថិភាព ដើម្បីរស់នៅបានក្នុងសន្តិភាព និងសេចក្តីថ្លៃថ្នូរ។*

**លោក មីលូន ខូថារី អតីតអ្នករាយកាណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ទទួលបន្ទុកបញ្ហាលំនៅឋានសមរម្យ**

បន្ថែមពីលើសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (មាត្រា ២៥) ការទទួលស្គាល់ជាអន្តរជាតិដ៏មានឥទ្ធិពលបំផុតទៅលើសិទ្ធិមានលំនៅឋានសមរម្យ ជាធាតុមួយនៃសិទ្ធិទទួលបានកម្រិតជីវភាពរស់នៅសមរម្យ មាននៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលចែងថា រដ្ឋភាគី "[...] ទទួលស្គាល់សិទ្ធិរបស់ជនគ្រប់រូប ក្នុងការទទួលបានកម្រិតជីវភាពគ្រប់គ្រាន់សម្រាប់ខ្លួនផ្ទាល់ និងសម្រាប់គ្រួសារខ្លួន រួមមានចំណីអាហារ សម្លៀកបំពាក់ និងលំនៅឋានគ្រប់គ្រាន់ (មាត្រា១១.១)។

ក្នុងទសវត្សឆ្នាំ១៩៧០ និង ១៩៨០ មានការលេចឡើងនូវយុទ្ធនាការ ចលនា និងការតស៊ូថ្នាក់ជាតិក្នុងប្រទេសជាច្រើន ដើម្បីកំណត់ថា ការមានលំនៅឋាន គឺជាសិទ្ធិមនុស្ស។ ឧទាហរណ៍ នៅក្នុងប្រទេសឥណ្ឌា នៅចុងទសវត្សឆ្នាំ១៩៨០ និងដើមទសវត្សឆ្នាំ១៩៩០ មានការសម្ភាសន៍ និងការប្រជុំរាប់រយលើកដែលគេបានរៀបចំឡើងជាភាសាតាមតំបន់ ដើម្បីប្រមូលព័ត៌មានអំពីអត្ថន័យ ដែលប្រជាជននិយាយសំដៅដល់ នៅពេលដែលនិយាយអំពីលំនៅឋាន។ អ្វីដែលយុទ្ធនាការនោះបានរកឃើញគឺថា សម្រាប់ប្រជាជនលំនៅឋាន គឺជាកន្លែងដែលពួកគេធ្វើជាម្ចាស់ ជាកន្លែងមានសុវត្ថិភាពសម្រាប់រស់នៅ គឺវាមានអត្ថន័យធំធេងជាងការដែលគ្រាន់តែមានជញ្ជាំងបួន និងដំបូលមួយ។ យុទ្ធនាការស្រដៀងគ្នានេះ ក៏មានកើតឡើងក្នុងប្រទេសប្រេស៊ីល ក្នុងប្រទេសជាច្រើនក្នុងទ្វីបអាហ្វ្រិក និងក្នុងចក្រភពអង់គ្លេស។ បទពិសោធន៍រួមត្រូវគេយកមកពិភាក្សា ក្រោមបរិបទនៃសន្និសីទរបស់អង្គការសហប្រជាជាតិស្តីពីការតាំងទីលំនៅឋានរបស់មនុស្សជាតិចំនួនពីរលើក (ឆ្នាំ១៩៧៦ និង ១៩៩៦) និងក្រោមបរិបទយុទ្ធសាស្ត្រពិភពលោកស្តីពីទីជម្រក (១៩៨៨-២០០០)។

សិទ្ធិមានលំនៅឋានសមរម្យ នៅតែបន្តមិនទាន់សម្រេចបាននៅឡើយនៅក្នុងគ្រប់តំបន់ទាំងអស់ជុំវិញពិភពលោក ជាពិសេសសម្រាប់ក្រុមស្ត្រីងាយរងគ្រោះ និងក្រុមបុរសមួយចំនួនដូចជាបុរសមកពីសហគមន៍ជនជាតិភាគតិច។ នៅក្នុងប៉ុន្មានទសវត្សថ្មីៗនេះ វេទិកាអន្តរជាតិជាច្រើនបានបង្វែរការចាប់អារម្មណ៍ចំពោះចំណងទាក់ទងរវាងអំពើហិង្សាលើស្ត្រី រាប់បញ្ចូលទាំងអំពើហិង្សាក្នុងគ្រួសារ ទៅនឹងកង្វះការទទួលបានសិទ្ធិមានលំនៅឋានសមរម្យ។ ក្នុងរបាយការណ៍ ឆ្នាំ ២០០០ ស្តីពីគោលនយោបាយសេដ្ឋកិច្ច និង

សង្គម និងផលប៉ះពាល់នៃអំពើហិង្សាលើស្ត្រីនោះ[2] អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្ដីពីអំពើហិង្សាលើស្ត្រី មូលហេតុ និងផលវិបាកនៃអំពើហិង្សា បានគូសបញ្ជាក់ថា ភាពក្រីក្ររបស់ស្ត្រី រួមផ្សំជាមួយនឹងកង្វះជម្រើសផ្សេងៗសម្រាប់លំនៅឋាន បានធ្វើឲ្យស្ត្រីមានការលំបាកក្នុងការចាកចេញពីស្ថានភាពគ្រួសារដែលមានអំពើហិង្សា ហើយលោកស្រីបានបញ្ជាក់ជាថ្មីឡើងវិញថា ការផ្លាស់ប្ដូរទីលំនៅដោយបង្ខំ និងការបណ្ដេញចេញដោយបំពានពីផ្ទះសម្បែង និងដីធ្លី ជះផលប៉ះពាល់ជាខ្លាំងទៅលើស្ត្រី ជាពិសេសនៅពេលដែលការរំលោភបំពានបង្កឡើងដោយសហព័ទ្ធ ឬបងប្អូនសាច់ថ្លៃ។ ក្នុងឆ្នាំ២០០៩ អ្នករាយការណ៍ពិសេសស្ដីពីអំពើហិង្សាលើស្ត្រី មូលហេតុ និងផលវិបាកនៃអំពើហិង្សា បានថ្លែងថា "ផលប៉ះពាល់នៃការបណ្ដេញចេញដោយបំពាន ដែលច្រើនធ្វើឡើងដោយកងកម្លាំងយោធា ឬកងកម្លាំងប្រដាប់អាវុធ បានធ្វើឲ្យស្ត្រីអស់សង្ឃឹមខ្លាំងមែនទែន ហើយវាបានជាប់ជំពាក់យ៉ាងស្អិតរមួតទៅនឹងការកើនឡើងនៃអាត្រាហិង្សាលើរាងកាយ ផ្លូវចិត្ត និងផ្នែកសេដ្ឋកិច្ច ទៅលើស្ត្រី ទាំងមុនពេលបណ្ដេញចេញ ក្នុងអំឡុងពេលបណ្ដេញចេញ និងក្រោយពេលបណ្ដេញចេញ។ រឿងនេះជារឿងពិត ទាំងអំពើហិង្សាទៅលើស្ត្រីដែលបង្កឡើយដោយអាជ្ញាធររដ្ឋ តួអង្គមិនមែនរដ្ឋ សមាជិកសហគមន៍ និងទាំងអំពើហិង្សាទៅលើស្ត្រីដែលបង្កឡើងដោយដៃគូ ឬសាច់ញាតិ ក្នុងគ្រួសារនោះ"[3]។

ក្នុងឆ្នាំ ២០០០ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានតែងតាំងអ្នករាយការណ៍ពិសេសលើកដំបូងទទួលបន្ទុកបញ្ហាលំនៅឋានសមរម្យ ឲ្យបំពេញអាណត្តិដែលផ្ដោតលើលំនៅឋានសមរម្យជាធាតុផ្សំមួយនៃសិទ្ធិមានកម្រិតជីវភាពគ្រប់គ្រាន់ ក្នុងបរិបទមិនមានការរើសអើង[4]។ អ្នករាយការណ៍ពិសេសត្រូវបានស្នើឲ្យធ្វើសេចក្ដីរាយការណ៍អំពីស្ថានភាពនៃការសម្រេចបានសិទ្ធិដែលមានពាក់ព័ន្ធ និងការអភិវឌ្ឍទាក់ទងនឹងសិទ្ធិទាំងនោះដោយរាប់បញ្ចូលទាំងច្បាប់ គោលនយោបាយ ការអនុវត្តល្អទាំងឡាយណាដែលបានផ្ដល់ប្រយោជន៍ច្រើនបំផុតដល់ការទទួលបានសិទ្ធិ ព្រមទាំងការលំបាក និងឧបសគ្គជាលក្ខណៈក្នុងស្រុក និងជាអន្តរជាតិ ដែលពួកគេបានជួបប្រទះ ហើយអ្នករាយការណ៍ពិសេសត្រូវរៀបចំបង្កើតឲ្យមានការសន្ទនាជាទៀងទាត់ជាមួយរដ្ឋ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងការជួយជ្រោមជ្រែងដល់រដ្ឋ ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋដើម្បីធានាឲ្យមានសិទ្ធិទាំងអស់នេះ។ អ្នករាយការណ៍ពិសេស ត្រូវបានសំណូមពរជាពិសេសឲ្យអនុវត្តទស្សនៈយេនឌ័រនៅក្នុងរាល់សកម្មភាពទាំងអស់របស់គាត់។

*នៅក្នុងការបំពេញអាណត្តិការងាររបស់ខ្ញុំ ខ្ញុំបានប្រើវិធីសាស្ត្រគ្រប់ជ្រុងជ្រោយដោយផ្អែកលើតថភាពជាក់ស្ដែង ដែលថា សិទ្ធិមនុស្សជាប់ទាក់ទងគ្នាទៅវិញទៅមក និងមិនអាចបំបែកចែកដាច់ពីគ្នា។ សិទ្ធិមានលំនៅឋានសមរម្យ មិនអាចសម្រេចបានពេញលេញទេ ប្រសិនបើវាត្រូវបានផ្ដាច់ចេញពីសិទ្ធិដទៃទៀត ដូចជាសិទ្ធិមានចំណីអាហារ ទឹកស្អាត អនាម័យ អគ្គិសនី សុខភាព ការងារ ទ្រព្យសម្បត្តិ សន្តិសុខបុគ្គលលំនៅឋានមានសុវត្ថិភាព និងការការពារប្រឆាំងនឹងអំពើអមនុស្សធម៌ និងបន្ទាបបន្ថោក។ វិធីសាស្ត្រនេះបាន*

---

[2] E/CN.4/2000/68/Add.5។

[3] A/HRC/11/6/Add.6, កថាខណ្ឌទី 85។

[4] សេចក្ដីសម្រេច 2000/9។

*តម្រូវឲ្យខ្ញុំពិនិត្យមើលបញ្ហាជាច្រើនទាក់ទងនឹងលំនៅឋានសមរម្យ ដោយរាប់បញ្ចូលទាំងបញ្ហាដីធ្លី ការបណ្តេញចេញដោយបំពាន ការទទួលបានទឹក និងអនាម័យ សុខភាព ភាពក្រីក្រ និងផលប៉ះពាល់ពីសាកលភាវូបនីយកម្ម។ នៅក្នុងក្របខ័ណ្ឌដ៏ទូលំទូលាយនេះ ការផ្តោតជាពិសេសរបស់ខ្ញុំ គឺការរៀបចំឲ្យមានទស្សនៈយេនឌ័រដ៏រឹងមាំមួយដែលមានភាពស៊ីសង្វាក់គ្នាទៅនឹងសិទ្ធិទទួលបានការមិនរើសអើង និងដែលទាក់ទងនឹងក្រុមពិសេសមួយចំនួន ដូចជា កុមារ ជនជាតិដើមភាគតិច និងជនភាគតិច។*

*ប្រភព៖* សេចក្តីថ្លែងការណ៍របស់លោក មីលូន ខូថារី អ្នករាយការណ៍ពិសេសទទួលបន្ទុកបញ្ហាលំនៅឋានសមរម្យ ថ្លែងទៅកាន់គណៈកម្មាធិការសិទ្ធិមនុស្សនៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០០៣។

នៅពេលទន្ទឹមគ្នានោះដែរ ក្នុងសេចក្តីសម្រេចស្តីពីកម្មសិទ្ធិស្មើគ្នាសម្រាប់ស្ត្រី ការទទួលបាន និងការគ្រប់គ្រងដីធ្លី និងសិទ្ធិក្នុងការកាន់កាប់ទ្រព្យសម្បត្តិ និងសិទ្ធិមានលំនៅឋានសមរម្យ គណៈកម្មាធិការសិទ្ធិមនុស្សបានបញ្ជាក់ប្រកបដោយម៉ឺងម៉ាត់ថា ការរើសអើងលើស្ត្រីដែលមាននៅក្នុងច្បាប់ ទាក់ទងនឹងការប្រើប្រាស់ ការទទួលបាន និង សុវត្ថិភាពខាងការកាន់កាប់ដីធ្លី ទ្រព្យសម្បត្តិ និងលំនៅឋាន ក៏ដូចជាការទទួលបានហិរញ្ញប្បទានសម្រាប់ដីធ្លី ទ្រព្យសម្បត្តិ និងលំនៅឋាន គឺជាការបង្កើតឲ្យមានការរំលោភបំពានទៅលើសិទ្ធិមនុស្សរបស់ស្ត្រីក្នុងការទទួលបានការការពារប្រឆាំងនឹងការរើសអើង[5]។ គណៈកម្មាធិការសិទ្ធិមនុស្សក៏បានបញ្ជាក់បន្ថែមអំពីកាតព្វកិច្ចរបស់រដ្ឋក្នុងការចាត់វិធានការសមស្របទាំងឡាយដើម្បីលុបបំបាត់ការរើសអើងលើស្ត្រី ដែលបង្កឡើងដោយបុគ្គល អង្គការ សហគ្រាស ជាពិសេសដោយស្ថាប័នផ្តល់កម្ចីហិរញ្ញវត្ថុ។ គណៈកម្មាធិការសិទ្ធិមនុស្សបានផ្តល់អនុសាសន៍ថា ស្ថាប័នផ្តល់ហិរញ្ញប្បទានសម្រាប់លំនៅឋាន និងស្ថាប័នឥណទាន គួរលើកឡើងអំពីបញ្ហានៃការរើសអើងនេះ ហើយគណៈកម្មាធិការសិទ្ធិមនុស្សបានលើកទឹកចិត្តដល់ស្ថាប័នឯកទេសជាតិ និងអង្គការសហប្រជាជាតិ ផ្តល់ធនធាន ព័ត៌មាន និងការអប់រំសិទ្ធិមនុស្សដែលទាក់ទងនឹងភាពស្មើគ្នាខាងកម្មសិទ្ធិ ការទទួលបាន និងការគ្រប់គ្រងរបស់ស្ត្រីទៅលើដីធ្លី និង ភាពស្មើគ្នាលើសិទ្ធិខាងការកាន់កាប់ទ្រព្យសម្បត្តិ និងសិទ្ធិមានលំនៅឋានសមរម្យ។ គណៈកម្មាធិការសិទ្ធិមនុស្សបានសំណូមពរឲ្យអ្នករាយការណ៍ពិសេស ធ្វើការសិក្សា និងរាយការណ៍អំពីស្ត្រី និងលំនៅឋានសមរម្យ ហើយជាពិសេសអំពីភាពស្មើគ្នាខាងកម្មសិទ្ធិ ការទទួលបាន និងការគ្រប់គ្រងរបស់ស្ត្រីទៅលើដីធ្លី និងភាពស្មើគ្នាលើសិទ្ធិខាងការកាន់កាប់ទ្រព្យសម្បត្តិ និងសិទ្ធិមានលំនៅឋានសមរម្យ។

វិធីសាស្ត្រដែលប្រើដើម្បីបំពេញការងារនេះ រួមមានការពិគ្រោះយោបល់ជាច្រើននៅថ្នាក់តំបន់ជាមួយអង្គការស្ត្រីតាមមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២ មក ការពិគ្រោះយោបល់នៅថ្នាក់តំបន់ទាំងនេះ ត្រូវបានរៀបចំឡើងនៅអាហ្វ្រិកខាងត្បូង និងខាងកើត អាស៊ី អាមេរិកកណ្តាល និងខាងត្បូង មជ្ឈិមបូព៌ា តំបន់ប៉ាស៊ីហ្វិក អាមេរិកខាងជើង អាស៊ីកណ្តាល អឺរ៉ុបខាងកើត និងតំបន់មេឌីទែរ៉ាណេ[6]។ តាមរយៈការឆ្លុះបញ្ចាំង

[5] សេចក្តីសម្រេច ២០០០/១៣ ២០០១/៣៤ ២០០២/៤៩ ២០០៣/២២ ២០០៤/២១ និង ២០០៥/២៥។

[6] ការពិគ្រោះយោបល់ថ្នាក់តំបន់៖ ការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិលថ្នាក់តំបន់នៅអាហ្វ្រិកស្តីពី ស្ត្រី និងលំនៅឋានសមរម្យ (ក្រុងណៃរ៉ូប៊ី ខែតុលា ឆ្នាំ២០០២) ការពិគ្រោះយោបល់នៅអាស៊ីស្តីពី ទំនាក់ទំនងទៅវិញទៅមករវាងអំពើហិង្សាលើស្ត្រី និងសិទ្ធិស្ត្រីក្នុងការមានលំនៅឋានសមរម្យ (ក្រុងដេលី ខែតុលា ឆ្នាំ២០០៣) ការពិគ្រោះយោបល់ថ្នាក់តំបន់អាមេរិកឡាទីន និងតំបន់

ទៅលើបរិបទតាមមូលដ្ឋាន ការពិគ្រោះយោបល់និមួយៗបានរំលេចឲ្យឃើញនូវប្រធានបទជាក់លាក់មួយចំនួនទាក់ទងនឹងលំនៅឋានសមរម្យ ដូចជាអំពើហិង្សាលើស្ត្រី ដីធ្លី និងមរតក។ ការផ្តល់សក្ខីកម្មដោយបុគ្គល និងក្រុមតាមមូលដ្ឋាន និងដោយក្រុមសង្គមស៊ីវិល បានពន្យល់បង្ហាញអំពីការរំលោភបំពានជាច្រើនដែលស្ត្រីបានជួបប្រទះទាក់ទងនឹងលំនៅឋានសមរម្យ ក៏ដូចជាបានពន្យល់បង្ហាញអំពីយុទ្ធសាស្ត្រដែលត្រូវប្រើដើម្បីសម្រេចបានសិទ្ធិមានលំនៅឋានសមរម្យ។ ការផ្តល់សក្ខីកម្មក៏បានផ្តល់ព័ត៌មានលម្អិតបន្ថែមទៀតអំពីមូលហេតុដែលនាំឲ្យមានគម្លាតរវាងច្បាប់ និងគោលនយោបាយ ជាមួយនឹងការអនុវត្ត ហើយការផ្តល់សក្ខីកម្មនេះ ក៏បានបញ្ជាក់ផងដែរថា គេត្រូវការនូវវិធីសាស្ត្រដែលមិនបែងចែកដាច់ពីគ្នាមួយ ដើម្បីដោះស្រាយឲ្យមានប្រសិទ្ធភាពចំពោះបរិបទដ៏ស្មុគស្មាញដែលស្ត្រីទទួលរងការរើសអើង និងការរំលោភបំពានសិទ្ធិមនុស្សផ្សេងទៀត[7]។

ការពិគ្រោះយោបល់តាមតំបន់ជាច្រើននោះ ក៏ជួយឲ្យក្រុមអង្គការសង្គមស៊ីវិលបានចូលរួមពាក់ព័ន្ធជាមួយដំណើរការរបស់អង្គការសហប្រជាជាតិ ដោយមានអង្គការខ្លះបានចូលរួមជាលើកដំបូង ហើយការចូលរួមនោះ គឺជាមធ្យោបាយមួយសម្រាប់ធ្វើឲ្យប្រសើរឡើងដល់ការងារនៃការចងបណ្តាញគ្នា និងការច្របាច់បញ្ចូលគ្នានូវយោបល់ស្តីពី សិទ្ធិមានលំនៅឋានសមរម្យរបស់ស្ត្រី និងរវាងក្រុមស្ត្រី និងក្រុមការងារលំនៅឋានជាច្រើន។ ប្រការដែលសំខាន់នោះ គឺក្រុមអង្គការសង្គមស៊ីវិលបានតាមដានបន្តដំណើរការនេះជាប់រហូតចាប់តាំងពីការពិគ្រោះយោបល់រួចមក។ ឧទាហរណ៍ ក្រុមក្នុងប្រទេសម៉ុងហ្គោលី បានតស៊ូមតិប្រកបដោយជោគជ័យ ក្នុងការដាក់បញ្ចូលបទប្បញ្ញត្តិអំពី ការការពារសិទ្ធិមានលំនៅឋានសមរម្យរបស់ស្ត្រី ទៅក្នុងច្បាប់ថ្មីរបស់ប្រទេសនេះស្តីពីការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ការពិគ្រោះយោបល់តាមដានបន្តត្រូវបានរៀបចំឡើងនៅក្នុងប្រទេសផ្សេងៗនៃអាមេរិកឡាទីន និងក្នុងប្រទេសអូស្ត្រាលី ព្រមទាំងសន្និសីទមួយរៀបចំឡើងដើម្បីប្រមូលផ្តុំមេរៀនដែលទទួលបានពីការពិគ្រោះយោបល់ថ្នាក់តំបន់ទាំងអស់នោះ (នៅក្នុងវេទិកាសង្គមពិភពលោកឆ្នាំ២០០៥ នៅប្រទេសប្រេស៊ីល) ដោយមានការចូលរួមរបស់ស្ត្រីដែលបានផ្តល់សក្ខីកម្មនៅក្នុងការពិគ្រោះយោបល់ទាំងនេះ។

ឯកសារនេះចម្រាញ់យករបកគំហើញក្នុងការងាររបស់អ្នករាយការណ៍ពិសេសដំបូងទទួលបន្ទុកបញ្ហាស្ត្រី និងលំនៅឋានសមរម្យ។ ឯកសារនេះក៏ដកស្រង់ពីការស្រាវជ្រាវរបស់អ្នករាយការណ៍ពិសេសចាប់តាំងពីឆ្នាំ ២០០២ មក ដោយរួមមានការបញ្ចូលចម្លើយតបដែលទទួលបានពីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋា

---

កាប៉ាបៀនស្តីពី ស្ត្រី និងលំនៅឋានសមរម្យ (ក្រុងមិកស៊ិច ខែធ្នូ ឆ្នាំ២០០៣) ការពិគ្រោះយោបល់ថ្នាក់តំបន់មជ្ឈិមបូព៌ា និងអាហ្វ្រិកខាងជើងស្តីពី សិទ្ធិស្ត្រីមានលំនៅឋានសមរម្យ និងដីធ្លី (ក្រុងអាឡិចសាន់ឌ្រៀ ប្រទេសអេហ្ស៊ីប ខែកក្កដា ឆ្នាំ២០០៤) ការពិគ្រោះយោបល់ថ្នាក់តំបន់ប៉ាស៊ីហ្វិកស្តីពី សិទ្ធិស្ត្រីមានលំនៅឋានសមរម្យ និងដីធ្លី (ក្រុងណាឌី ប្រទេសហ្វីជី ខែតុលា ឆ្នាំ២០០៤) ការពិគ្រោះយោបល់ថ្នាក់តំបន់អាមេរិកខាងជើងស្តីពី សិទ្ធិស្ត្រីមានលំនៅឋានសមរម្យ (ក្រុងវ៉ាស៊ីនតោនឌីស៊ី ខែតុលា ឆ្នាំ២០០៥) ការពិគ្រោះយោបល់ថ្នាក់តំបន់អាស៊ីកណ្តាល/អឺរ៉ុបខាងកើត ស្តីពី សិទ្ធិស្ត្រីមានលំនៅឋានសមរម្យ (ក្រុងប៊ូដាប៉េស ខែវិច្ឆិកា ឆ្នាំ២០០៥) និងការពិគ្រោះយោបល់ថ្នាក់តំបន់មេឌីទែរ៉ាណេស្តីពី សិទ្ធិស្ត្រីមានលំនៅឋានសមរម្យ (ក្រុងបាសេឡូណា ខែមីនា ឆ្នាំ២០០៦)។ របាយការណ៍អំពី ការពិគ្រោះយោបល់ទាំងនេះ អាចរកបានពីគេហទំព័រ www.ohchr.org/EN/Issues/Housing/Pages/Women And Housing.aspx( ចូលមើលថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២ )។

[7] E/CN.4/2005/43, កថាខណ្ឌទី ១៧។

ភិបាលក្នុងការឆ្លើយតបក្នុងកម្រងសំណួរមួយចំនួន ព័ត៌មានប្រមូលបានពីបេសកកម្មស្វែងរកការពិតនៅតាមប្រទេសព្រមទាំងការផ្តល់សក្ខីកម្ម និងរបាយការណ៍ដែលបានមកពីការពិគ្រោះយោបល់ថ្នាក់តំបន់ជាមួយក្រុមតាមមូលដ្ឋាន និងក្រុមសង្គមស៊ីវិលជាច្រើន។ ឯកសារនេះក៏បានប្រើប្រាស់ព័ត៌មានក្នុងរបាយការណ៍របស់អ្នករាយការណ៍ពិសេសទីពីរទទួលបន្ទុកបញ្ហាលំនៅឋានសមរម្យរបស់លោកស្រី រ៉ាកែល រ៉ូលនីក (ប្រេស៊ីល) ដែលត្រូវបានតែងតាំងក្នុងឆ្នាំ២០០៨ ដោយរួមបញ្ចូលទាំងការពិគ្រោះយោបល់ដែលលោកស្រីបានធ្វើឡើងនៅជុំវិញពិភពលោកស្តីពីស្ត្រី និងសិទ្ធិមានលំនៅឋានសមរម្យ ក្នុងឆ្នាំ២០១១ ដែលអ្នករាយការណ៍ពិសេសបានដាក់លទ្ធផលនៃការពិគ្រោះយោបល់នៅក្នុងរបាយការណ៍របស់លោកស្រីទៅក្រុមប្រឹក្សាសិទ្ធិមនុស្សនៅឆ្នាំ ២០១២។ ឯកសារនេះមានការរីកចម្រើនបន្ថែមលើការងាររបស់លោកស្រីដែលបានវិភាគពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុ និងបម្រែបម្រួលអាកាសធាតុ ទៅលើការទទួលបានសិទ្ធិមានលំនៅឋានសមរម្យ ដោយមានការយកចិត្តទុកដាក់ជាពិសេសទៅលើផលប៉ះពាល់យេនឌ័រ។ ឯកសារនេះក៏បានយោងការងារយន្តការសិទ្ធិមនុស្សផ្សេងទៀត ដូចជា គណៈកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងគណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី។ សម្រាប់ការវិភាគស៊ីជម្រៅលើបញ្ហាជាក់លាក់ផ្សេងៗនោះ ការសិក្សានេះក៏បានប្រើប្រាស់ព័ត៌មានដែលជារបកគំហើញរបស់ស្ថាប័នអង្គការសហប្រជាជាតិដទៃទៀត និងជាពិសេសឯកសារដែលត្រូវបានដាក់ឲ្យប្រើជាផ្លូវការ។

# • គោលនយោបាយ និងក្របខ័ណ្ឌច្បាប់ សម្រាប់សិទ្ធិមានលំនៅឋាន សមរម្យរបស់ស្ត្រី

ដើម្បីយល់បានពេញលេញអំពីភាពជាប់ជំពាក់គ្នានៃការរើសអើង និងវិសមភាពសម្រាប់សិទ្ធិមានលំនៅឋានរបស់ស្ត្រី វាជាការសំខាន់ក្នុងការបញ្ជាក់ឲ្យច្បាស់ថាតើសិទ្ធិមនុស្សមានលំនៅឋានសមរម្យ មានអ្វីខ្លះ។ ប្រភពឯកសារជាច្រើនផ្តល់ការពន្យល់ណែនាំ អំពីអត្ថន័យនៃ "សិទ្ធិមានលំនៅឋានសមរម្យ"។ បន្ថែមពីលើមាត្រាពាក់ព័ន្ធដែលមាននៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សជាមូលដ្ឋាន ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សដែលពិនិត្យឡើងវិញលើការអនុវត្តសន្ធិសញ្ញាសិទ្ធិមនុស្ស និងជួយជ្រោមជ្រែងរដ្ឋភាគីក្នុងការបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់របស់ខ្លួននោះបានរួមចំណែកតាមរយៈការបកស្រាយដ៏មានឥទ្ធិពលអំពីលក្ខណៈវិនិច្ឆ័យនៃសិទ្ធិមានលំនៅឋានសមរម្យ។ ស្រដៀងគ្នានេះដែរ ការប្តេជ្ញាចិត្តថ្នាក់តំបន់ និងការប្តេជ្ញាចិត្តនយោបាយកម្រិតសកលលោក ក៏បានផ្តល់ព័ត៌មានអំពីគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ផងដែរ។

## ក. ក្របខ័ណ្ឌបទដ្ឋានអន្តរជាតិ

សិទ្ធិមានលំនៅឋានសមរម្យ ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយក្នុងច្បាប់សិទ្ធិមនុស្សកម្រិតអន្តរជាតិ កម្រិតតំបន់ និងកម្រិតជាតិ[8]។ ឯកសារមួយក្នុងចំណោមឯកសារអន្តរជាតិដំបូងៗដែលបានទទួលស្គាល់សិទ្ធិនេះ គឺសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨ (មាត្រា២៥.១)។ ក្រោយមកសិទ្ធិនេះត្រូវបានចងក្រងដាក់ក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្នុងឆ្នាំ១៩៦៦ (មាត្រា១១.១) ដែលត្រូវចាត់ទុកជាប្រភពច្បាប់អន្តរជាតិសំខាន់ជាងគេបំផុតអំពីសិទ្ធិមានលំនៅឋានសមរម្យ។ សិទ្ធិមានលំនៅឋានសមរម្យ ត្រូវបានទទួលស្គាល់ទូទៅបំផុតថា ជាធាតុមួយនៃសិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ ទោះបីជាតាមធម្មតា គេយល់ថាជាសិទ្ធិមនុស្សដាច់ដោយឡែកមួយតែឯងក៏ដោយ។

យោងតាមកតិកាសញ្ញាអន្តរជាតិៈ

*រដ្ឋភាគីនៃអនុសញ្ញាទទួលស្គាល់សិទ្ធិរបស់ជនគ្រប់រូប ក្នុងការទទួលបានកម្រិតជីវភាពគ្រប់គ្រាន់សម្រាប់ខ្លួនផ្ទាល់ និងសម្រាប់គ្រួសារខ្លួន រួមមានចំណីអាហារ សម្លៀកបំពាក់ និងលំនៅឋានសមរម្យព្រមទាំងការរីកចម្រើនជាលំដាប់នៃលក្ខខ័ណ្ឌរស់នៅរបស់គេ។ រដ្ឋភាគីត្រូវចាត់វិធានការសមស្របដើម្បីធានាឲ្យសម្រេចបាននូវសិទ្ធិនេះ និងទទួលស្គាល់សារៈសំខាន់ចាំបាច់នៃសហប្រតិបត្តិការអន្តរជាតិ តាមការយល់ព្រមដោយសេរី (មាត្រា១១.១)។*

មាត្រានេះមានសារៈសំខាន់ច្រើនយ៉ាង។ ទីមួយ មាត្រានេះធានាសិទ្ធិនេះដល់ "ជនគ្រប់រូប" ដោយមិនមានការបែងចែក។ ទីពីរ មាត្រានេះ មិនមានលក្ខណៈនៅទ្រឹងមួយកន្លែងនោះទេ គឺវាធានាដល់សិទ្ធិ ក្នុងការទទួលបាន "ការរីកចម្រើនជាលំដាប់នៃលក្ខខណ្ឌរស់នៅរបស់គេ"។ ទីបី មាត្រានេះតម្រូវឲ្យរដ្ឋ "ត្រូវចាត់វិធានការសមស្រប" ដើម្បីធានាឲ្យសម្រេចបាននូវសិទ្ធិមានលំនៅឋានសមរម្យនេះ។

[8] សម្រាប់បញ្ជីដ៏ពិស្តារនៃបទដ្ឋានអន្តរជាតិពាក់ព័ន្ធ សូមមើល www.ohchr.org/EN/Issues/Housing/Pages/International Standards.aspx (ចូលមើលថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២)។

សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិភាគច្រើនបំផុត មានចែងអំពីការហាមឃាត់ការរើសអើង ដែលផ្អែកលើមូលដ្ឋានភេទ ដោយចែងថា សិទ្ធិដែលមាននៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិទាំងនោះ គួរទទួលបានដោយមិនមានការបែងចែក ដោយសារមូលដ្ឋានភេទក្នុងចំណោមមូលដ្ឋានផ្សេងៗទៀត។

បទប្បញ្ញត្តិដែលចងជាកាតព្វកិច្ចផ្លូវច្បាប់ជាលក្ខណៈអន្តរជាតិ ដែលបានទទួលស្គាល់ដោយផ្ទាល់ ឬដោយប្រយោល ចំពោះសិទ្ធិមានលំនៅឋានសមរម្យ និងសិទ្ធិស្មើភាពគ្នារបស់ស្ត្រី ក៏មាននៅក្នុង៖

- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី៖

  *រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីរស់នៅជនបទ [...] និងជាពិសេស ត្រូវធានាឱ្យស្ត្រីជនបទទាំងនោះនូវសិទ្ធិ [...] (ជ) អាស្រ័យផលលក្ខខណ្ឌរស់នៅគ្រប់គ្រាន់ ជាពិសេស ទាក់ទងនឹងការមានផ្ទះសម្បែង អនាម័យ ការផ្គត់ផ្គង់អគ្គិសនី និងទឹកស្អាត ការដឹកជញ្ជូន និងគមនាគមន៍ (មាត្រា ១៤.២)*

  *រដ្ឋភាគី ត្រូវចាត់វិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីលើរាល់បញ្ហាដែលទាក់ទងនឹងអាពាហ៍ពិពាហ៍ និងទំនាក់ទំនងគ្រួសារ និងជាពិសេស ដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រី ត្រូវធានាឱ្យស្ត្រីនូវ*(ជ) សិទ្ធិដូចគ្នា សម្រាប់ទាំងពីរនាក់ប្តី និងប្រពន្ធ ចំពោះកម្មសិទ្ធិ ការទិញ ការចាត់ចែង ការគ្រប់គ្រង ការអាស្រ័យផល និងការប្រគល់ទ្រព្យសម្បត្តិ ទោះដោយមិនគិតថ្លៃក្តី ឬគិតថ្លៃក្តី (មាត្រា ១៦.១)។*

- អនុសញ្ញាស្តីពីសិទ្ធិកុមារ

  *គ្មានកុមារណាម្នាក់ ត្រូវស្ថិតក្រោមការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ក្នុងជីវិតឯកជន គ្រួសារ លំនៅឋាន ឬការឆ្លើយឆ្លងរបស់កុមារ និងគ្មានកុមារណាម្នាក់ ត្រូវស្ថិតក្រោមការបំពារបំពានដោយខុសច្បាប់លើកិត្តិយស និងកិត្តិនាមរបស់ខ្លួនឡើយ (មាត្រា ១៦.១)។*

  *រដ្ឋភាគីទទួលស្គាល់សិទ្ធិរបស់កុមារគ្រប់រូបក្នុងការមានកម្រិតជីវភាពគ្រប់គ្រាន់ សម្រាប់ការអភិវឌ្ឍន៍រាងកាយ សតិបញ្ញា ស្មារតី សីលធម៌ និងសង្គមរបស់កុមារ។ [...] រដ្ឋភាគីដោយយោងតាមស្ថានភាពជាតិ និងតាមមធ្យោបាយដែលខ្លួនមាន ត្រូវចាត់វិធានការសមស្របនានា ដើម្បីជួយឧបត្ថម្ភដល់ឪពុកម្តាយនិងអ្នកផ្សេងទៀតដែលទទួលបន្ទុកលើកុមារ ដើម្បីអនុវត្តសិទ្ធិនេះ ហើយក្នុងករណីចាំបាច់ ត្រូវឧបត្ថម្ភសម្ភារៈ និងផ្តល់កម្មវិធីគាំទ្រនានា ជាពិសេសទាក់ទងនឹងចំណីអាហារ សម្លៀកបំពាក់ និងកន្លែងស្នាក់នៅ [...] (មាត្រា ២៧)។*

- អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍

*រដ្ឋភាគីផ្តន្ទាទោសជាពិសេសដល់ការផាត់ចេញខាងពូជសាសន៍ និងអាប៉ាថេត និងសន្យាបង្ការ ហាមឃាត់ និងលុបបំបាត់ការអនុវត្តបែបនេះ លើទឹកដីដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន (មាត្រា ៣)។*

*រដ្ឋភាគីសន្យាហាមឃាត់ និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ និងសន្យាធានាឱ្យមនុស្សម្នាក់ៗ មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ដោយគ្មានការប្រកាន់បែងចែក មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ឬដើមកំណើតជាតិ ឬជនជាតិជាពិសេសក្នុងការអាស្រ័យផលសិទ្ធិដូចខាងក្រោម [...] សិទ្ធិមានផ្ទះជ្រកកោន (មាត្រា ៥(ង))។*

- អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

  *រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាធានាសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី ក្នុងការប្រើប្រាស់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដូចមានចែងក្នុងកតិកាសញ្ញានេះ (មាត្រា ៣)។*

  *ជនគ្រប់រូប មានសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។ គ្មានជនណាម្នាក់ ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ។ គ្មានជនណាម្នាក់ ត្រូវដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់(មាត្រា ៩.១) ។*

  *គ្មានជនណាម្នាក់ ត្រូវទទួលរងការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ ក្នុងជីវិតឯកជន គ្រួសារ លំនៅឋាន សំបុត្រឆ្លើយឆ្លងរបស់ខ្លួន ឬត្រូវរងការប៉ះពាល់ដោយខុសច្បាប់ ទៅលើកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ។ ជនគ្រប់រូប មានសិទ្ធិឱ្យច្បាប់ការពារប្រឆាំងនឹងការជ្រៀតជ្រែក ឬការប៉ះពាល់បែបនេះ (មាត្រា ១៧)។*

- អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ

  *រដ្ឋភាគីទទួលស្គាល់ថា ស្ត្រីនិងកុមារីពិការ ងាយរងការរើសអើងច្រើនបែបយ៉ាង ហើយចំពោះស្ថានភាពនេះ រដ្ឋត្រូវចាត់វិធានការនានា ដើម្បីធានាឱ្យពួកគេទទួលបានសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានទាំងអស់ដោយស្មើគ្នា និងយ៉ាងពេញលេញ (មាត្រា ៦.១)។*

  *រដ្ឋភាគីត្រូវចាត់រាល់វិធានការសមស្រប ដើម្បីធានាឱ្យស្ត្រីទទួលបានការអភិវឌ្ឍន៍ វឌ្ឍនភាព និងការផ្តល់សិទ្ធិអំណាចឱ្យបានពេញលេញ ក្នុងគោលបំណងដើម្បីធានាឱ្យពួកគេអនុវត្ត និងទទួលបាននូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដូចមានចែងនៅក្នុងអនុសញ្ញានេះ(មាត្រា ៦.២)។*

*ដើម្បីជួយជនពិការឱ្យរស់នៅដោយឯករាជ្យ និងចូលរួមយ៉ាងពេញលេញក្នុងគ្រប់ទិដ្ឋភាពនៃជីវិត រដ្ឋភាគីត្រូវចាត់វិធានការសមស្រប ដើម្បីធានាដល់ជនពិការ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ទទួលបាននូវបរិស្ថានជុំវិញ មធ្យោបាយធ្វើដំណើរ ព័ត៌មាននិងទំនាក់ទំនង រួមទាំងប្រព័ន្ធនិងបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង គ្រឿងសម្ភារៈសំរួល និងសេវាកម្មផ្សេងទៀតដែលបើកចំហ ឬ ផ្តល់ឱ្យប្រើប្រាស់ជាសាធារណៈ ទាំងនៅទីក្រុង ទាំងនៅតាមទីជនបទដាច់ស្រយាល។ ដោយត្រូវរួមបញ្ចូលនូវអត្តសញ្ញាណ និងការលុបបំបាត់ឧបសគ្គនិងរបាំងទាំងឡាយដល់ការទទួលបាននូវសិទ្ធិទាំងនេះ វិធានការទាំងនេះត្រូវអនុវត្តចំពោះ៖ (ក) អាគារ ផ្លូវថ្នល់ មធ្យោបាយធ្វើដំណើរ និងគ្រឿងសំរួលក្នុងផ្ទះ និងក្រៅផ្ទះផ្សេងទៀត រួមទាំងសាលារៀន លំនៅឋាន គ្រឹះស្ថានសុខាភិបាល និងកន្លែងការងារ (មាត្រា ៩.១)។*

*រដ្ឋភាគីនៃអនុសញ្ញានេះ ទទួលស្គាល់សិទ្ធិស្មើភាពគ្នារបស់ជនពិការក្នុងការរស់នៅក្នុងសហគមន៍ ដោយមានជម្រើសដែលស្មើភាពគ្នាជាមួយអ្នកដទៃ ហើយត្រូវចាត់វិធានការសមស្រប និងមានប្រសិទ្ធិភាពដើម្បីជួយឱ្យជនពិការ ទទួលបានយ៉ាងពេញលេញនូវសិទ្ធិនេះ និងការដាក់បញ្ចូល និងការចូលរួមយ៉ាងពេញលេញរបស់ជនពិការក្នុងសហគមន៍ ដោយរួមមានការធានាថា៖ (ក) ជនពិការទទួលបានឱកាសជ្រើសរើសកន្លែងតាំងទីលំនៅ និងទីកន្លែង និងអ្នកដែលគេត្រូវរស់នៅជាមួយ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ និងមិនត្រូវបានគេតម្រូវឱ្យរស់នៅតាមការរៀបចំជាក់លាក់ណាមួយឡើយ (ខ) ជនពិការមានលទ្ធភាពទទួលបានសេវាកម្មទ្រទ្រង់ការរស់នៅកន្លែងស្នាក់អាស្រ័យ និងសេវាកម្មទ្រទ្រង់សហគមន៍ផ្សេងៗទៀត រួមទាំងជំនួយបុគ្គលដែលចាំបាច់ដើម្បីទ្រទ្រង់ការរស់នៅ និងការរួមបញ្ចូលទៅក្នុងសហគមន៍ និងបង្ការពីភាពឯកោ ឬការឃ្លាតឆ្ងាយពីសហគមន៍ (មាត្រា ១៩)។*

*រដ្ឋភាគីទទួលស្គាល់សិទ្ធិរបស់ជនពិការ ពីជីវភាពរស់នៅគ្រប់គ្រាន់សម្រាប់ខ្លួនគេផ្ទាល់ និងសម្រាប់ក្រុមគ្រួសាររបស់ពួកគេ រួមទាំងការមានអាហារហូបចុកគ្រប់គ្រាន់ មានសម្លៀកបំពាក់ និងផ្ទះសម្បែងសមរម្យ និងការកែលំអរលក្ខខ័ណ្ឌជីវភាពរស់នៅជាប្រចាំ ហើយរដ្ឋភាគីត្រូវចាត់វិធានការសមស្របដើម្បីការពារ និងលើកស្ទួយដល់ការធ្វើឱ្យបានសម្រេចនូវសិទ្ធិនេះ ដោយគ្មានការរើសអើងដោយសារពិការភាពនោះទេ (មាត្រា ២៨.១)។*

*រដ្ឋភាគីទទួលស្គាល់សិទ្ធិរបស់ជនពិការពីការការពារផ្នែកសង្គមកិច្ច និងពីការទទួលបានសិទ្ធិនេះ ដោយគ្មានការរើសអើងដោយសារពិការភាព និងត្រូវចាត់វិធានការសមស្របដើម្បីការពារ និងលើកស្ទួយដល់ការធ្វើឱ្យបានសម្រេចនូវសិទ្ធិនេះ រួមទាំងវិធានការដូចខាងក្រោម ៖ [...] (ឃ) ធានាដល់ជនពិការឱ្យទទួលបាននូវកម្មវិធីផ្ទះសម្បែងសាធារណៈ (មាត្រា២៨.២)។*

- អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ
  *ពលករទេសន្តរប្រវេសន៍ ត្រូវទទួលបានការប្រព្រឹត្តដោយស្មើភាពគ្នា ដូចប្រជាពលរដ្ឋរបស់រដ្ឋដែលទទួលឱ្យធ្វើការដែរ ពាក់ព័ន្ធជាមួយនឹង ៖ [...] (ឃ) ការទទួលបានលំនៅឋាន ដូចជាតាមរយៈកម្មវិធីលំនៅឋានសង្គម និងការការពារប្រឆាំងនឹងការកេងប្រវ័ញ្ច ដែលពាក់ព័ន្ធជាមួយនឹងការជួលផ្ទះ (មាត្រា ៤៣.១)។*

ក្រឹត្យក្រម និងគោលការណ៍សមភាពយេនឌ័រ និងការមិនរើសអើង មានចែងនៅក្នុងគ្រប់សន្ធិសញ្ញាសិទ្ធិមនុស្សជាមូលដ្ឋាន។ សិទ្ធិទទួលបានសមភាព និងជៀសផុតពីការរើសអើង មិនមានលក្ខណៈជាការសម្រេចបានជាលំដាប់នោះទេ (សូមមើលខាងក្រោម) ប៉ុន្តែ ជាកាតព្វកិច្ចចាំបាច់ដែលត្រូវតែអនុវត្តភ្លាមៗ[9]។ គោលការណ៍អនុវត្តភ្លាមៗនេះ ផ្អែកលើការយល់ឃើញថា ការអនុញ្ញាតឲ្យមានការរើសអើងកើតឡើងជាបន្តក្នុងរយៈពេលណាមួយដោយគ្មានការដោះស្រាយ មានលក្ខណៈផ្ទុយពីច្បាប់សិទ្ធិមនុស្ស និងគោលការណ៍សេចក្តីថ្លៃថ្នូរ ហើយត្រូវតែមាននូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាពភ្លាមៗដែរ។ រដ្ឋមានកាតព្វកិច្ចភ្លាមៗផងដែរ ក្នុងការមិនចូលរួមក្នុងការអនុវត្តដែលមានលក្ខណៈរើសអើងទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន។ វិធានការបែបនេះអាចរួមមានវិធានការពិសេសជាបណ្តោះអាសន្ន ប៉ុន្តែក៏ត្រូវបញ្ចូលវិធានការអចិន្ត្រៃយ៍ ដែលមានការឆ្លើយតបនឹងតម្រូវការជាក់លាក់ និងឧបសគ្គដែលស្ត្រីបានជួបប្រទះ ទាក់ទងនឹងសិទ្ធិមនុស្សនិមួយៗ។

គំនិតអំពីការសម្រេចបានជាលំដាប់ទទួលស្គាល់ថា ការសម្រេចបានពេញលេញនូវសិទ្ធិមនុស្សមួយចំនួន ដូចជា សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ អាចត្រូវការពេលវេលា និងអាចផ្តល់បន្ទុកមួយចំនួនដល់រដ្ឋក្នុងការជ្រើសរើសមធ្យោបាយដើម្បីធ្វើឲ្យសម្រេចបាននូវសិទ្ធិទាំងនោះ។

ទោះបីជាយ៉ាងណាក៏ដោយ រដ្ឋមិនអាចបែរមកប្រើវិធានការដែលមានលក្ខណៈរើសអើង ដើម្បីសម្រេចបានសិទ្ធិទាំងអស់នោះទេ៖ គោលការណ៍សមភាព និងការមិនរើសអើង រាប់បញ្ចូលទាំងដោយផ្អែកលើមូលដ្ឋានភេទ ត្រូវអនុវត្តភ្លាម ហើយត្រូវបន្ថយអំណាចឆន្ទានុសិទ្ធិរបស់រដ្ឋ នៅពេលជ្រើសរើសវិធីសម្រេចសិទ្ធិទាំងនេះឲ្យបានពេញលេញ។ ដូច្នេះ ការគិតគូរដល់បុរសមុនស្ត្រីជាលេសក្នុងការចាត់វិធានការជាជំហានៗក្នុងការសម្រេចឲ្យបានពេញលេញនូវសិទ្ធិមានលំនៅឋាននេះ ជាការមិនអាចទទួលយកបានទេ។

ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ រដ្ឋមានកាតព្វកិច្ចចាត់វិធានការសមស្របចំពោះការសម្រេចឲ្យបានពេញលេញនូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ជាអតិបរមាតាមធនធានដែលមាន ដោយរដ្ឋត្រូវទទួលស្គាល់ថា វាត្រូវការពេលវេលា ហើយថាកង្វះខាតធនធានហិរញ្ញវត្ថុ និងធនធានផ្សេងទៀត គឺជាឧបសគ្គមួយ។ ក៏ប៉ុន្តែ ប្ញើត្បិតតែសិទ្ធិដូចជា សិទ្ធិមានលំនៅឋានសមរម្យនេះ មិនអាចសម្រេចបានពេញលេញភ្លាមៗ

---

[9] គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សេចក្តីពន្យល់ទូទៅលេខ ១៦ (២០០៥) ស្តីពី សិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី ក្នុងការទទួលបានសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ទាំងអស់ ទំព័រទី ៤០។

ឧទាហរណ៍ ដោយសារតែធនធានតិចតួច យ៉ាងណាក៏ដោយ ក៏គេនៅតែត្រូវការចាត់វិធានការភ្លាមៗ ដើម្បីឲ្យសម្រេចបានគោលដៅចុងក្រោយនោះ។

ការសំខាន់ជាពិសេសនោះ គឺថាមិនថារដ្ឋមានធនធានប៉ុណ្ណានោះទេ តែជាបញ្ហាអាទិភាព រដ្ឋគួរខិតខំក្នុងការធានាថា ជនគ្រប់រូបទទួលបានសិទ្ធិនេះយ៉ាងហោចណាស់ក៏ក្នុងកម្រិតអប្បបរមាដែរ និងគួរតម្រង់ទិសដៅកម្មវិធីទៅរកអ្នកក្រ អ្នកមិនសូវទទួលបានការយកចិត្តទុកដាក់ និងអ្នកដែលទទួលប្រយោជន៍តិចតួចដែលទាំងនេះជាក្រុមដែលមានស្ត្រីច្រើននៅក្នុងនោះ។ តាមទស្សនៈនេះ រដ្ឋត្រូវបង្ហាញថា វិធីសាស្ត្រដែលមានគុណភាពសំខាន់ ត្រូវបានចាត់ឡើងនៅពេលគិតអំពីការប្រើប្រាស់ធនធានដែលរដ្ឋមាន។ គួររំលឹកផងដែរថា ខណៈពេលដែលសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ អាចសម្រេចបានជាលំដាប់ក៏ដោយ ក៏រដ្ឋមិនត្រូវចាត់វិធានការដើរថយក្រោយជាដាច់ខាត។

ចំណុចខាងលើនេះ រំលេចអំពីប្រភេទផ្សេងគ្នានៃកាតព្វកិច្ចរបស់រដ្ឋទាក់ទងនឹងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយរាប់បញ្ចូលទាំងសិទ្ធិមានលំនៅឋានសមរម្យ គឺថា ជាកាតព្វកិច្ចក្នុងការគោរព ការពារ និងបំពេញ។ ជាសង្ខេបៈ កាតព្វកិច្ចក្នុង*ការគោរព* តម្រូវឲ្យរដ្ឋជៀសវាងការជ្រៀតជ្រែករំខានរារាំងសេរីភាពបុគ្គល កាតព្វកិច្ចក្នុង*ការការពារ* តម្រូវឲ្យរដ្ឋទប់ស្កាត់បុគ្គល និងក្រុមផ្សេងទៀត (ភាគីទីបី) មិនឲ្យជ្រៀតជ្រែករំខានរារាំងសិទ្ធិបុគ្គលឡើយ ហើយកាតព្វកិច្ចក្នុង*ការបំពេញ* តម្រូវឲ្យរដ្ឋចាត់វិធានការវិជ្ជមានក្នុងការធានាធ្វើឲ្យមានការពេញចិត្តចំពោះសិទ្ធិនោះ។

ដោយសារតែការរើសអើងទៅលើស្ត្រី កើតឡើងមិនមែនត្រឹមតែក្នុងរង្វង់សាធារណៈទេ ប៉ុន្តែក៏កើតឡើងក្នុងមជ្ឈដ្ឋានឯកជន ដោយរាប់បញ្ចូលទាំងក្នុងសហគមន៍ ក្នុងគ្រួសារ និងក្នុងផ្ទះផងដែរនោះ កាតព្វកិច្ចរបស់រដ្ឋក្នុងការធានាឲ្យមានការការពារប្រកបដោយប្រសិទ្ធភាពចំពោះការរំលោភបំពានដែលបង្កឡើងដោយតួអង្គឯកជន មានសារៈសំខាន់ជាពិសេស។

ដោយសារមជ្ឈដ្ឋានឯកជនជាទីដែលស្ត្រីមួយចំនួនអាចងាយរងគ្រោះបំផុត និងមិនមានការការពារទាក់ទងនឹងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដូច្នេះ រដ្ឋមានកាតព្វកិច្ចអនុវត្តសកម្មភាពដែលត្រឹមត្រូវដោយត្រូវឆ្លើយតបឲ្យបានសមរម្យ មានប្រសិទ្ធភាព និងឆាប់រហ័ស ចំពោះការរំលោភបំពាននានា [10]។ ភារកិច្ចនេះទាក់ទងនឹងការទប់ស្កាត់ ការស៊ើបអង្កេត ការសម្របសម្រួល ការដាក់ទណ្ឌកម្ម និងការផ្តល់សំណងសម្រាប់ការរំលោភបំពានសិទ្ធិមនុស្ស និងកាតព្វកិច្ចក្នុងការទប់ស្កាត់មិនឲ្យមាននិទណ្ឌភាព។ ខណៈពេលដែលការអនុវត្តសកម្មភាពដែលត្រឹមត្រូវទាក់ទងនឹងស្ត្រី ជាធម្មតាត្រូវគេសំដៅទៅដល់កាតព្វកិច្ចក្នុងការលុបបំបាត់រាល់អំពើហិង្សាទៅលើស្ត្រីក្នុងជីវិតឯកជន ឬប្រព្រឹត្តដោយតួអង្គឯកជន[11]នោះ វិសាលភាពនៃបញ្ញត្តិនេះក៏មានការវិវត្តន៍ដែរ[12]។

[10] គណៈកម្មាធិការទទួលបន្ទុកលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី អនុសាសន៍ទូទៅលេខ ១៩ (ឆ្នាំ១៩៩២) ស្តីពីអំពើហិង្សាទៅលើស្ត្រី កថាខណ្ឌទី ៩។

[11] សេចក្តីសម្រេចរបស់មហាសន្និបាតលេខ 48/104។

[12] សូមមើល E/CN.4/2006/61។

ជាចុងក្រោយ យោងតាមអនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី ការអនុម័តវិធានការពិសេសជាបណ្ដោះអាសន្ន ដែលមានគោលបំណងពន្លឿនសមភាពជាក់ស្ដែងរវាងបុរស និងស្ត្រី មិនត្រូវចាត់ទុកថាជាការរើសអើងនោះទេ (មាត្រា ៤.១)។ ផ្ទុយទៅវិញ វិធានការបែបនេះ អាចមានសារៈសំខាន់ និងសមស្របសម្រាប់កែតម្រូវទម្រង់ និងផលប៉ះពាល់ ក្នុងអតីតកាល និងបច្ចុប្បន្នកាលទៅលើការរើសអើងលើស្ត្រី[13] ដោយរាប់បញ្ចូលទាំងផ្នែកលំនៅឋានផង។

## ឧទាហរណ៍អំពីសមភាពជាក់ស្ដែងទាក់ទងលំនៅឋាន

| ធាតុផ្សំ | និយមន័យ [ក] | លក្ខខណ្ឌរបស់ស្ត្រី | ទស្សនៈសមភាពជាក់ស្ដែង |
|---|---|---|---|
| សុវត្ថិភាពក្នុងការកាន់កាប់ | ការកាន់កាប់ មានទម្រង់ជាច្រើន រាប់ទាំងការជួល (ជាសាធារណៈនិងជាឯកជន) ការអាស្រ័យនៅ លំនៅឋានសហករណ៍ ការជួល (លក្ខណៈភតិសន្យា) ការកាន់កាប់ជាម្ចាស់ លំនៅឋានសង្គ្រោះបន្ទាន់ និងតំបន់រស់នៅមិនទាន់រៀបរយ ដូចជាការកាន់កាប់ដីធ្លី ឬទ្រព្យសម្បត្តិ។ ទោះបីជាមានប្រភេទនៃការកាន់កាប់ច្រើនទម្រង់ក៏ដោយ ក៏បុគ្គលទាំងអស់គួរមានសុវត្ថិភាពក្នុងការកាន់កាប់ក្នុងកម្រិតមួយដែលធានានូវការការពារផ្លូវច្បាប់ប្រឆាំងនឹងការបណ្ដេញចេញដោយបង្ខំ ការធ្វើទុក្ខបុកម្នេញ និងការគំរាមកំហែងផ្សេងៗ។ រដ្ឋភាគី គួរផ្ដល់សិទ្ធិកាន់កាប់ស្របច្បាប់ ដល់បុគ្គល ឬគ្រួសារដែលខ្វះខាតការការពារបែបនេះនាពេល | • បើប្រៀបធៀបជាមួយបុរស ស្ត្រីខ្វះសុវត្ថិភាពក្នុងការកាន់កាប់ក្នុងអាត្រាមួយមិនមានសមាមាត្រ។ នេះអាចមានការជាប់ទាក់ទងជាមួយបញ្ហាដូចជា ភាពក្រីក្ររបស់ស្ត្រី ភាពងាយរងគ្រោះដោយសារអំពើហិង្សា ព្រមទាំងច្បាប់ គោលនយោបាយ និងកម្មវិធីដែលមានលក្ខណៈរើសអើង ហើយប្រការទាំងអស់នេះ បានរួមចំណែកឲ្យមានវិសមភាពជាទូទៅដល់ស្ត្រី។<br>• ស្ត្រីត្រូវបានគេបណ្ដេញចេញពីលំនៅឋានដោយសារតែអំពើហិង្សាក្នុងផ្ទះ/គ្រួសារ ច្បាប់មរតក ដែលមានលក្ខណៈរើសអើង ប្រពៃណីទំនៀមទម្លាប់និងមធ្យោបាយផ្នែកហិរញ្ញវត្ថុមិនគ្រប់គ្រាន់ ដែលបណ្ដាលមកពីគោលនយោយសេដ្ឋកិច្ចដែលរដ្ឋភាគីបានអនុម័តមាន | • អ្នកដែលសុវត្ថិភាពក្នុងការកាន់កាប់របស់ខ្លួន មានហានិភ័យខ្ពស់ (រាប់ទាំងស្ត្រីនៃជនភាគតិច និងស្ត្រីជនជាតិដើមភាគតិច ស្ត្រីជាមេគ្រួសារ) ត្រូវផ្ដល់ឲ្យមានជាបន្ទាន់នូវសុវត្ថិភាពក្នុងការកាន់កាប់តាមផ្លូវច្បាប់ ។<br>• ស្ត្រីគ្រប់រូបគួរទទួលបានសុវត្ថិភាពក្នុងការកាន់កាប់តាមផ្លូវច្បាប់ ដែលធានាឲ្យមានការការពារប្រឆាំងនឹងការបណ្ដេញចេញដោយបង្ខំ ទោះជាដោយហេតុផលណាក៏ដោយ ដោយរាប់បញ្ចូលទាំងហេតុផលនៃអំពើហិង្សាក្នុងផ្ទះ/គ្រួសារ។<br>• ច្បាប់មរតក និងការអនុវត្តដែលមានលក្ខណៈរើសអើង ប៉ះពាល់ដល់សុវត្ថិភាពស្ត្រីក្នុងការកាន់កាប់ |

[13] គណៈកម្មាធិការទទួលបន្ទុកលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី អនុសាសន៍ទូទៅលេខ ២៥ (២០០៤) ស្ដីពីវិធានការពិសេសបណ្ដោះអាសន្ន កថាខណ្ឌទី១៨។

| ជាតុផ្សំ | និយមន័យ [ក] | លក្ខខណ្ឌរបស់ស្ត្រី | ទស្សនៈសមភាពជាក់ស្តែង |
|---|---|---|---|
| | បច្ចុប្បន្ន ដោយមានការពិគ្រោះយោបល់ពិតប្រាកដមួយជាមួយបុគ្គលនិងក្រុមទាំងឡាយដែលរងផលប៉ះពាល់។ | លក្ខណៈធ្វើឲ្យស្ត្រីទទួលបានប្រយោជន៍តិចតួច។ | ត្រូវធ្វើវិសោធនកម្ម ហើយការបោសសំអាតតំបន់ក្រីក្រតាមទីប្រជុំជននិងគម្រោងអភិវឌ្ឍន៍ដែលគំរាមកំហែងដល់សុវត្ថិភាពក្នុងការកាន់កាប់របស់ស្ត្រីមិនគួរឲ្យអនុវត្តទេ។<br>• ក្នុងការផ្តល់សិទ្ធិកាន់កាប់ស្របច្បាប់នេះ រដ្ឋភាគីគួរពិគ្រោះយោបល់ជាមួយបុគ្គលនិងក្រុមទាំងអស់ដែលរងផលប៉ះពាល់ ដោយរាប់បញ្ចូលទាំងស្ត្រីផង។ ប្រសិនបើចាំបាច់ គួរបង្កើតវិធានការពិសេសដើម្បីធានាឲ្យមានការចូលរួមពេញលេញរបស់ស្ត្រី។ |
| ភាពអាចលៃលកបាន | ការចំណាយនានាសម្រាប់បុគ្គលឬសម្រាប់គ្រួសារដែលទាក់ទងនឹងលំនៅឋាន មិនគួរបន្ថយកម្រិតនៃការទទួលបាននិងការពេញចិត្តនៃតម្រូវការជាមូលដ្ឋានផ្សេងទៀតនោះទេ។ រដ្ឋភាគីគួរចាត់វិធានការក្នុងការធានាថាការចំណាយទាក់ទងនឹងលំនៅឋាន ត្រូវមានភាពប្រដំប្រសងទៅនឹង កម្រិតប្រាក់ចំណូល។ រដ្ឋភាគី គួរបង្កើតការឧបត្ថម្ភធនសម្រាប់ការទទួលបានលំនៅឋានសម្រាប់អ្នកដែលគ្មានលទ្ធភាពទទួលបានលំនៅ | • ស្ត្រីដែលរស់នៅក្នុងភាពក្រីក្រ និងក្នុងស្ថានភាពគ្រោះថ្នាក់ ស្ថិតក្នុងហានិភ័យប្រឈមជាពិសេសនឹងការជំពាក់បំណុល ដែលដល់ពេលត្រូវសងគេ និងការបណ្តេញចេញ។<br>• "ចំណូលគ្រួសារ" មិនមែនជាការចាំបាច់ដើម្បីពិចារណាលើតថភាពដែលថា ស្ត្រីអាចមិនមែនជាអ្នកត្រួតត្រាលើការចំណាយក្នុងគ្រួសារ។<br>• ស្ត្រីប្រហែលជាមិនទទួលបានដោយស្មើភាពក្នុងការទទួលបានការឧបត្ថម្ភធនសម្រាប់លំនៅឋាននោះទេ។<br>• ម្ចាស់ដីដែលជាបុរស ច្រើន | • ការចំណាយសម្រាប់បុគ្គល ឬសម្រាប់គ្រួសារដែលទាក់ទងនឹងលំនៅឋាន មិនគួរបន្ថយកម្រិតនៃការទទួលបាននិងការពេញចិត្តនៃតម្រូវការជាមូលដ្ឋានផ្សេងទៀត ដូចជា អាហារ ទឹក ថ្នាំសង្កូវ និងអនាម័យ ដោយរាប់បញ្ចូលទាំងតម្រូវការ អនាម័យពេលមានរដូវ សម្រាប់សមាជិកទាំងអស់ក្នុងគ្រួសារ រាប់ទាំងស្ត្រី ។<br>• ដើម្បីធានាឲ្យមានភាពលៃលកបានសម្រាប់លំនៅឋាន រដ្ឋភាគីត្រូវ |

| ជាតុផ្សំ | និយមន័យ [ក] | លក្ខខណ្ឌរបស់ស្ត្រី | ទស្សនៈសមភាពជាក់ស្តែង |
|---|---|---|---|
| | ឋានដែលពួកគេអាចលៃលករកបាន។ អ្នកជួលគួរទទួលបានការការពារទល់នឹងកម្រិតតម្លៃជួលមិនសមហេតុផល ឬ ការកើនឡើងតម្លៃជួលដោយមិនសមហេតុផល។ | តែកេងប្រវ័ញ្ចលើស្ត្រីដោយទាមទារ "បំពេញតម្រូវការ" ផ្លូវភេទ ដើម្បីជៀសវាងការឡើងថ្លៃជួល ឬ ការបណ្តេញចេញ។ | បង្កើតយុទ្ធសាស្ត្រ ដែលពិចារណាដល់លក្ខខណ្ឌ និងស្ថានភាពសេដ្ឋកិច្ចរបស់ស្ត្រី រាប់បញ្ចូលទាំងបញ្ហាគម្លាតប្រាក់ឈ្នួលដោយសារយេនឌ័រដែរ។<br>• រដ្ឋភាគីត្រូវទទួលស្គាល់ថាស្ត្រីដែលមើលថែទាំកូនជារឿយៗ មិនមានប្រាក់ចំណូលទេ ហើយនៅក្នុងបរិបទនេះ ភាពលៃលកបានសម្រាប់លំនៅឋានត្រូវទទួលបានការពិចារណាឲ្យបានជាក់លាក់ជាចាំបាច់។<br>• រដ្ឋភាគីគួរបង្កើតការឧបត្ថម្ភធនសម្រាប់លំនៅឋាន សម្រាប់អ្នកដែលមិនអាចទទួលបានលំនៅឋានដែលអាចលៃលកបាន។ ក្នុងការធ្វើបែបនេះ រដ្ឋភាគីត្រូវធានាធ្វើយ៉ាងណាឲ្យការឧបត្ថម្ភធននេះត្រូវបានផ្តល់ក្នុងលក្ខណៈដែលមិនមានការរើសអើង ហើយត្រូវផ្តល់អាទិភាពដល់ស្ត្រីដែលកំពុងត្រូវការ។<br>• អ្នកជួលគួរទទួលបានការការពារទល់នឹងកម្រិតតម្លៃជួលមិនសមហេតុផល ឬ ការកើនឡើងតម្លៃជួលដោយមិនសមហេតុផលតាមរយៈវិធានការសម |

| ជាតុផ្សំ | និយមន័យ [ក] | លក្ខខណ្ឌរបស់ស្ត្រី | ទស្សនៈសមភាពជាក់ស្តែង |
|---|---|---|---|
| | | | ស្រប។ ដើម្បីធ្វើឲ្យបានសម្រេច រដ្ឋភាគីត្រូវធានាថា ម្ចាស់ដីដែលសុំឲ្យមាន "ការបំពេញតម្រូវការ" ផ្លូវភេទ ពីអ្នកជួលជាស្ត្រី ត្រូវទទួលទណ្ឌកម្មបទឧក្រិដ្ឋ ហើយត្រូវធានាថាមានមធ្យោបាយមានសុវត្ថិភាពសម្រាប់ឲ្យស្ត្រី ធ្វើសេចក្តីរាយការណ៍ និងដោះស្រាយឧបទ្ទវហេតុបែបនេះ។<br>• រដ្ឋភាគី ក៏ត្រូវធានាថាស្ត្រីត្រូវបានធានាឲ្យទទួលបានឥតទាននិងប្រាក់កម្ចីដែលចាំបាច់សម្រាប់តម្រូវការលំនៅឋានរបស់ពួកគេដោយស្មើភាពគ្នា។ |
| ភាពទទួលបាន | លំនៅឋានសមរម្យត្រូវតែអាចទទួលបាន។ ក្រុមដែលទទួលបានប្រយោជន៍តិចតួចត្រូវទទួលបានពេញលេញ និងមាននិរន្តរភាព ក្នុងការទទួលបានធនធានសម្រាប់ការទទួលបានលំនៅឋានសមរម្យ។ ដូច្នេះ ក្រុមដែលទទួលបានប្រយោជន៍តិចតួចនេះ ដូចជា មនុស្សចាស់ កុមារ ជនពិការរាងកាយ អ្នកមានជំងឺធ្ងន់ធ្ងរ អ្នកមានមេរោគអេដស៍ អ្នកមានបញ្ហាត្រូវប្រើថ្នាំជាប្រចាំ ជនពិការបញ្ញាស្មារតី ឬពិការខាង ការអភិវឌ្ឍន៍រាងកាយ និងសតិ | • បើនិយាយជាទូទៅ ស្ត្រីជួបប្រទះឧបសគ្គជាច្រើនក្នុងសភាពមិនមានសមាមាត្រនៅពេលទទួលបានលំនៅឋាន។<br>• ស្ត្រីដែលទទួលរងអំពើហិង្សាក្នុងផ្ទះ/គ្រួសារ ស្ថិតក្នុងចំណោមស្ត្រីដែលទទួលបានប្រយោជន៍តិចតួចបំផុត ក្នុងពេលទទួលបានលំនៅឋាន។<br>• ស្ត្រីគ្មានដីធ្លី មានចំនួនច្រើនបំផុត។<br>• មានចំណងទាក់ទងដ៏សំខាន់មួយ រវាងស្ថានភាពគ្មានដីធ្លីរបស់ស្ត្រី ជាមួយនឹងច្បាប់ដែលមានលក្ខណៈរើសអើង | • លំនៅឋានសមរម្យត្រូវតែទទួលបានសម្រាប់ស្ត្រី បុរស និងកុមារគ្រប់រូប។ រដ្ឋភាគី ត្រូវអនុម័តវិធានការចាំបាច់ក្នុងការជម្រុះចោលឧបសគ្គនានាដែលស្ត្រីជួបប្រទះក្នុងការទទួលបានលំនៅឋានសមរម្យ។<br>• ឧទាហរណ៍ រដ្ឋភាគីត្រូវធានាថាស្ត្រីមិនទទួលរងការរើសអើង ពីម្ចាស់ដីសាច់ញាតិជាបុរស ភ្នាក់ងារផ្តល់កម្ចី ឬមន្ត្រីរដ្ឋ ក្នុងការទទួលបានទីអាស្រ័យនៅ ឬ ប្រាក់កម្ចីដែលត្រូវការសម្រាប់ |

| ជាតុផ្សំ | និយមន័យ [ក] | លក្ខខណ្ឌរបស់ស្ត្រី | ទស្សនៈសមភាពជាក់ស្តែង |
|---|---|---|---|
| | បញ្ហា ជនរងគ្រោះដោយសារគ្រោះមហន្តរាយធម្មជាតិ ជនរស់នៅតំបន់ងាយទទួលរងគ្រោះធម្មជាតិ និងជនផ្សេងទៀត គួរជានាឲ្យអាទិភាពក្នុងកម្រិតណាមួយក្នុងការទទួលបានលំនៅឋាន។ ទាំងច្បាប់និងគោលនយោបាយទាក់ទងលំនៅឋាន គួរពិចារណាឲ្យបានពេញលេញអំពីតម្រូវការលំនៅឋាន ជា ពិសេសសម្រាប់ពួកគេ។ នៅក្នុងរដ្ឋជាច្រើន ការបង្កើនសិទ្ធិទទួលបានដីធ្លីដល់ក្រុមដែលគ្មានដីសោះ និងក្រុមជនក្រីក្រនៅក្នុងសង្គម គួររៀបចំបង្កើតជាគោលដៅគោលនយោបាយស្នូលមួយ។ កាតព្វកិច្ច រដ្ឋាភិបាលដែលគេអាចយល់បាននោះ ត្រូវរៀបចំឡើងដោយមានគោលបំណងក្នុងការបង្ហាញឲ្យច្បាស់ អំពីសិទ្ធិមានទីកន្លែងប្រកបដោយសុវត្ថិភាព ដើម្បីរស់នៅក្នុងសន្តិភាពនិងសេចក្តីថ្លៃថ្នូរ សម្រាប់ជនគ្រប់រូប ដោយរាប់បញ្ចូលទាំងសិទ្ធិទទួលបានដីធ្លីជាកម្មសិទ្ធិស្របច្បាប់។ | ទាក់ទងនឹងសិទ្ធិទទួលមរតក និងគំនាបសង្គមផ្សេងៗដែលរារាំងស្ត្រីមិនឲ្យទាមទារសិទ្ធិរបស់ពួកគេក្នុងការទទួលមរតក។ | ទទួលបានការអាស្រ័យនៅ។ ជាពិសេស ស្ត្រីត្រូវទទួលបានការការពារប្រឆាំងនឹងការរើសអើងដោយសារមូលហេតុស្ថានភាពអាពាហ៍ពិពាហ៍ និងស្ថានភាពគ្រួសារ ឬកម្រិត ឬប្រភពប្រាក់ចំណូលនោះទេ។ ក្រឹត្យក្រមវប្បធម៌ ដែលជះឥទ្ធិពលអវិជ្ជមានទៅលើឯករាជ្យភាពរបស់ស្ត្រី ក្នុងការទទួលបានលំនៅឋាន ដូចជា ស្ត្រីចង់ជ្រើសរើសយកការរស់នៅតែឯង ឬចង់គេចចេញពីទំនាក់ទំនាក់ដែលមានអំពើហិង្សា ត្រូវតែមានការផ្លាស់ប្តូរ។<br>• អាទិភាពអំពីលំនៅឋានគួរត្រូវផ្តល់ដល់ក្រុមទទួលប្រយោជន៍តិចតួចទាំងអស់ ដោយរាប់បញ្ចូលទាំង ស្ត្រី ជាពិសេសម្តាយទោល ស្ត្រីចំណាស់ ស្ត្រីជាជនរងគ្រោះដោយអំពើហិង្សា ជនភៀសខ្លួន និងស្ត្រីដែលត្រូវគេបង្ខំឲ្យផ្លាស់ទីលំនៅ កុមារពិការពាងកាយ អ្នកមានជំងឺធ្ងន់ធ្ងរ អ្នកមានមេរោគអេដស៍ អ្នកមានជំងឺត្រូវប្រើថ្នាំជាប្រចាំ ជនពិការផ្នែកសតិបញ្ញា ឬផ្នែក |

| ជាតុផ្សំ | និយមន័យ [ក] | លក្ខខណ្ឌរបស់ស្ត្រី | ទស្សនៈសមភាពជាក់ស្តែង |
|---|---|---|---|
| | | | អភិវឌ្ឍន៍ ជនរងគ្រោះដោយសារគ្រោះមហន្តរាយធម្មជាតិ ជនរស់នៅតំបន់ងាយទទួលរងគ្រោះធម្មជាតិ និងជនផ្សេងទៀត។<br>• នៅក្នុងរដ្ឋភាគីជាច្រើន ការទទួលបានលំនៅឋានសមរម្យ មានចំណងជិតស្និទ្ធទៅនឹងសិទ្ធិទទួលបានដីធ្លី។ រដ្ឋភាគី ត្រូវរៀបចំឲ្យមានគោលនយោបាយកំណែទម្រង់ដីធ្លី ដើម្បីធានាថា សិទ្ធិទទួលបានដីធ្លីជាកម្មសិទ្ធិស្របច្បាប់។ រដ្ឋភាគី ត្រូវយកចិត្តទុកដាក់ជាពិសេស ចំពោះស្ថានភាពស្ត្រីក្នុងបញ្ហានេះ ហើយគួរធ្វើវិសោធនកម្ម ឬ លុបចោលច្បាប់មួយចំនួន និងគាំទ្រដល់ការកែប្រែប្រពៃណីនិងទំនៀមទម្លាប់មួយចំនួនដែលរើសអើងស្ត្រី ឬ បដិសេធស្ត្រីមិនឲ្យមានសិទ្ធិស្មើគ្នាក្នុងការទទួលបាននិងត្រួតត្រាលើដីធ្លី ទ្រព្យសម្បត្តិ និងលំនៅឋាន ហើយរដ្ឋភាគីត្រូវធានាសិទ្ធិរបស់ពួកគេក្នុងការទទួលបានការប្រព្រឹត្តមកលើខ្លួនដោយស្មើភាពគ្នាក្នុងការកែទម្រង់ដីធ្លី និងក្នុងគម្រោងតាំង |

| ធាតុផ្សំ | និយមន័យ [ក] | លក្ខខណ្ឌរបស់ស្ត្រី | ទស្សនៈសមភាពជាក់ស្តែង |
| --- | --- | --- | --- |
| | | | ទីលំនៅលើដីថ្មី។ |

[ក] និយមន័យទាំងអស់នេះ ស្របតាមសេចក្តីពន្យល់ទូទៅលេខ ៤ (១៩៩១) នៃគណៈកម្មាធិការទទួលបន្ទុកសិទ្ធិ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ រដ្ឋភាគី គឺនិយាយសំដៅទៅ រដ្ឋភាគីនៃកតិកាសញ្ញានេះ។ កាតព្វកិច្ចស្រដៀងគ្នាមាននៅក្នុង អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី។

*ប្រភព៖* យកតាមការងាររបស់ លេឡានី ហ្វាហា មជ្ឈមណ្ឌលសម្រាប់សិទ្ធិស្មើគ្នាអំពីទីស្នាក់អាស្រ័យនៅ។

## ខ. សិទ្ធិមានលំនៅឋានសមរម្យ និងការមិនរើសអើងដូចដែលបានតាមដានពិនិត្យមើលដោយស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស

គណៈកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានពន្យល់អំពីអត្ថន័យខ្លឹមសារ នៃសិទ្ធិមានលំនៅឋានសមរម្យ នៅក្នុងសេចក្តីពន្យល់ទូទៅលេខ ៤ (១៩៩១) ស្តីពីសិទ្ធិមានលំនៅឋានសមរម្យ និងលេខ ៧ (១៩៩៧) ស្តីពីសិទ្ធិមានលំនៅឋានសមរម្យ៖ ការបណ្តេញចេញដោយបំពាន។

សេចក្តីពន្យល់ទូទៅលេខ ៤ (១៩៩១) ទទួលស្គាល់ថា សិទ្ធិមានលំនៅឋានសមរម្យ មិនមែនមានន័យត្រឹមតែមានដំបូលនៅពីលើក្បាលនោះទេ។ គណៈកម្មាធិការភ្ជាប់សិទ្ធិនេះទៅនឹងគោលការណ៍គ្រឹះនៃសេចក្តីថ្លៃថ្នូររបស់មនុស្សដែលមានជាប់ពីកំណើតមក ហើយនេះជាគោលការណ៍ដែលកតិកាសញ្ញា បានផ្អែកទៅលើ ដោយកំណត់និយមន័យនៃសិទ្ធិមានលំនៅឋានសមរម្យនេះថាជាសិទ្ធិរស់នៅក្នុងទីកន្លែងដែលមានសុវត្ថិភាព សន្តិសុខ និងសេចក្តីថ្លៃថ្នូរ។ ធាតុទាំងប្រាំពីរ ដែលកំណត់និយមន័យនៃពាក្យ "សមរម្យ" ដែលរួមមាន សុវត្ថិភាពខាងការកាន់កាប់ស្របច្បាប់ ទីកន្លែងដែលមានសេវាកម្ម សម្ភារៈ បរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធ ទីដែលតាំងលំនៅបាន ភាពអាចរស់នៅបាន ភាពអាចលៃលកររកបាន ភាពអាចទទួលបាន និងភាពគ្រប់គ្រាន់ខាងវប្បធម៌ នេះជាការបង្ហាញនូវលក្ខខណ្ឌតម្រូវចាំបាច់ត្រូវតែមានសម្រាប់លំនៅឋាន ដែលត្រូវវិនិច្ឆ័យឲ្យស្របតាមកតិកាសញ្ញានេះ។ ទោះជាយ៉ាងណាក៏ដោយ ដូចមានពន្យល់ក្នុងឯកសារនេះ ភាគច្រើននៃធាតុទាំងអស់នេះមានសារៈសំខាន់ជាពិសេស ឬ មានផលប៉ះពាល់ជាពិសេសទៅលើស្ត្រី។ ឧទាហរណ៍ ស្ត្រីនឹងមានបន្ទុកដោយមិនមានសមាមាត្រ ប្រសិនបើមិនមានសេវាកម្មទឹកគ្រប់គ្រាន់នៅឯផ្ទះ ឬនៅក្បែរផ្ទះ ហើយសុវត្ថិភាពខាងការកាន់កាប់ស្របច្បាប់ ក៏អាចជាក្តីបារម្ភមួយដែរ ចំពោះស្ត្រីដែលគេមិនបានដាក់ឈ្មោះនៅលើឯកសារជួល ឬ ឯកសារទ្រព្យសម្បត្តិដទៃទៀតនោះ។ ដើម្បីធានាឲ្យមានសុវត្ថិភាពខាងការកាន់កាប់ស្របច្បាប់សម្រាប់ស្ត្រី គេត្រូវមានវិធានការផ្លូវច្បាប់ និងគោលនយោបាយ ទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ ឬ សិទ្ធិទទួលមរតក ដើម្បីការពារស្ត្រីពីការបណ្តេញចេញពីផ្ទះ នៅពេលដែលប្តីទទួលមរណភាព។

សេចក្តីពន្យល់ទូទៅលេខ ៧ (១៩៩៧) ស្តីពីការបណ្តេញចេញដោយបំពាន ពន្យល់លម្អិតអំពីកាតព្វកិច្ចដែលរដ្ឋភាគីត្រូវយកចិត្តទុកដាក់នៅក្នុងបរិបទនៃការបណ្តេញចេញដោយបំពាន ដូចជាការពិគ្រោះយោបល់ជាមួយអ្នកទទួលរងផលប៉ះពាល់ ភាពរកបាននៃដំណោះស្រាយ និងសំណង ព្រមទាំងបណ្តឹងនៃលក្ខខណ្ឌតម្រូវផ្នែកនីតិវិធីផ្សេងៗ។ ជាពិសេស គណៈកម្មាធិការយកចិត្តទុកដាក់ជាក់លាក់ទៅលើផល

ប៉ះពាល់ដែលមិនសមាមាត្រទៅលើស្ត្រី ដោយបានកត់សម្គាល់ថា "ស្ត្រីគ្រប់ក្រុមទាំងអស់ មានភាពងាយរងគ្រោះជាពិសេស ដោយសារតែទម្រង់នៃការរើសអើងដែលមាននៅក្នុងច្បាប់ និងក្នុងទម្រង់ផ្សេងៗ ដែលជាញឹកញាប់ អនុវត្តទាក់ទងនឹងសិទ្ធិលើទ្រព្យសម្បត្តិ (រាប់បញ្ចូលទាំងកម្មសិទ្ធិលំនៅឋាន) ឬ សិទ្ធិទទួលបានទ្រព្យសម្បត្តិ ឬ ទីស្នាក់អាស្រ័យនៅ ព្រមទាំងភាពងាយរងគ្រោះជាពិសេសដោយសារអំពើហិង្សា និងការបំពានផ្លូវភេទ នៅពេលដែលពួកគេគ្មានលំនៅឋានរស់នៅ" (កថាខណ្ឌទី ១០)។

សេចក្តីពន្យល់ទូទៅលេខ ១៦ (២០០៥) របស់គណៈកម្មាធិការ មានសារៈសំខាន់ជាពិសេស ដោយសារតែការរំលោភបំពានសិទ្ធិមានលំនៅឋានរបស់ស្ត្រី ច្រើនតែជាលទ្ធផលដែលកើតចេញមកពីច្បាប់ គោលនយោបាយ ទំនៀមទម្លាប់ និងប្រពៃណីដែលមានការរើសអើងលើផ្នែកផ្សេងៗ ហើយដែលនាំឲ្យ វិសមភាពរវាងបុរស និងស្ត្រីទាក់ទងនឹងលំនៅឋាន បានចាក់ឫសយ៉ាងជ្រៅ ។ មាត្រា ២.២ និង មាត្រា ៣ នៃកតិកាសញ្ញា តម្រូវឲ្យធ្វើឲ្យសម្រេចបាននូវសិទ្ធិទាំងអស់ដោយស្មើភាពគ្នា និងមិនមានការរើសអើងដែលផ្អែកលើមូលដ្ឋានភេទ និងមូលដ្ឋានផ្សេងទៀតឡើយ។ ចំណុចនេះក៏មានបញ្ចូលមាត្រា ១១ ដែលទទួលស្គាល់សិទ្ធិមានលំនៅឋានសមរម្យ ថាជាធាតុផ្សំមួយនៃសិទ្ធិមានកម្រិតជីវភាពគ្រប់គ្រាន់។ ប្រការសំខាន់សេចក្តីពន្យល់ទូទៅលេខ ១៦ (២០០៥) បញ្ជាក់ច្បាស់ថា កតិកាសញ្ញា តម្រូវឲ្យមានវិធីសាស្ត្រដែលធ្វើឲ្យសមភាពមានភាពជាក់ស្តែង៖

> *ការទទួលបានសិទ្ធិមនុស្សដោយឈរលើមូលដ្ឋាននៃសមភាពរវាងបុរសនិងស្ត្រី ត្រូវតែមានការយល់ដឹងឲ្យបានទូលំទូលាយ។ ការធានាអំពីការមិនរើសអើង និងសមភាពដែលមានចែងក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ នឹងផ្តល់ឲ្យមានសមភាពទាំងក្នុងការអនុវត្តជាក់ស្តែង និងទាំងក្នុងច្បាប់ (កថាខណ្ឌទី ៧)។*

សេចក្តីពន្យល់ទូទៅនេះបន្តកំណត់អំពីកាតព្វកិច្ចជាក់លាក់របស់រដ្ឋក្នុងការគោរព ការការពារ និងការធ្វើឲ្យទទួលបានពេញលេញនូវសិទ្ធិស្មើគ្នារបស់ស្ត្រីនៅក្រោមកតិកាសញ្ញានេះ។ ឧទាហរណ៍ វាបានបង្ហាញថា វាជាការសំខាន់ដែលរដ្ឋភាគីនៃកតិកាសញ្ញានេះពិចារណាអំពី ឥទ្ធិពលនៃការរើសអើងនានាដែលចេញមកពីច្បាប់ គោលនយោបាយ និងកម្មវិធីដែលមានភាពអព្យាក្រឹត្យភេទ ហើយរដ្ឋភាគីត្រូវរៀបចំឲ្យមានប្រព័ន្ធតាមដាន ព្រមទាំងតាក់តែង និងអនុវត្តកម្មវិធីទាំងឡាយ ដែលមានឥទ្ធិពលរយៈពេលវែងទៅលើសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ស្ត្រី។ ទាក់ទងនឹងលំនៅឋានសមរម្យ សេចក្តីពន្យល់បានកត់សម្គាល់ជាពិសេសដូចខាងក្រោម៖

> *ដើម្បីអនុវត្តមាត្រា ៣ គឺថា កថាខណ្ឌទី ១ នៃមាត្រា ១១ តម្រូវឲ្យ ស្ត្រីមានសិទ្ធិធ្វើជាម្ចាស់ ប្រើប្រាស់ ឬគ្រប់គ្រងលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ ដោយស្មើភាពគ្នាជាមួយនឹងបុរស និងមានសិទ្ធិទទួលបានធនធានចាំបាច់សម្រាប់អនុវត្តសិទ្ធិនោះបាន (កថាខណ្ឌទី ២៨)។*

សេចក្តីពន្យល់នេះក៏បានកត់សម្គាល់ដែរទាក់ទងនឹងមាត្រា១០ នៃកតិកាសញ្ញា ដែលលើកឡើងអំពីសិទ្ធិទាក់ទងនឹងគ្រួសារថា រដ្ឋភាគី ត្រូវ "ផ្តល់ដល់ជនរងគ្រោះដោយសារអំពើហិង្សា ភាគច្រើនជាស្ត្រី នូវការទទួលបានលំនៅឋានមានសុវត្ថិភាព ផ្តល់ដំណោះស្រាយ និងសំណង សម្រាប់ការខូចខាតលើរាងកាយ ផ្លូវចិត្ត និងផ្លូវអារម្មណ៍" (កថាខណ្ឌទី ២៧)។

នៅក្នុងសេចក្តីពន្យល់ទូទៅលេខ ២០ (២០០៩) ស្តីពីការមិនរើសអើងទាក់ទងនឹងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គណៈកម្មាធិការបានបញ្ជាក់សាជាថ្មីម្តងទៀតអំពីបញ្ញត្តិទាំងឡាយដែលមានចែងយ៉ាងច្បាស់នៅក្នុងសេចក្តីពន្យល់ទូទៅលេខ ១៦ (២០០៥) និងបញ្ជាក់ថា ការប្រព្រឹត្តខុសគ្នាទាំងក្នុងទម្រង់ដោយផ្ទាល់និងដោយប្រយោលអាចបង្កជាការរើសអើងក្រោមកតិកាសញ្ញានេះ។ សេចក្តីពន្យល់នេះក៏បានគូសបញ្ជាក់ថា លក្ខណៈនៃការរើសអើងខុសគ្នាតាមបរិបទ និងវិវត្តន៍តាមពេលវេលា ហើយក៏បានសង្កត់ធ្ងន់ថា ការរើសអើងដោយសារមូលដ្ឋាន "ស្ថានភាពដទៃទៀត" ដែលបានហាមឃាត់ក្រោមកតិកាសញ្ញានេះ រាប់បញ្ចូលទាំងស្ថានភាពអាពាហ៍ពិពាហ៍ និងគ្រួសារ។ ឧទាហរណ៍ ការរើសអើងអាចកើតឡើងបាន នៅពេលដែលសមត្ថភាពស្ត្រីក្នុងការប្រើប្រាស់សិទ្ធិមួយក្រោមកតិកាសញ្ញានេះ ត្រូវផ្អែកទៅលើការយល់ព្រមពីប្តីរបស់ស្ត្រីនោះ។

ទោះបីមិនមែនគ្រប់សន្ធិសញ្ញាសិទ្ធិមនុស្សជាមូលដ្ឋានទាំងអស់សុទ្ធតែចែងច្បាស់ជាពិសេសអំពីសិទ្ធិមានលំនៅឋានសមរម្យក្នុងបរិបទសិទ្ធិស្ត្រីក៏ដោយ ក៏គ្រប់សន្ធិសញ្ញាសិទ្ធិមនុស្សជាមូលដ្ឋានទាំងអស់សុទ្ធតែទទួលស្គាល់ថា គោលការណ៍សំខាន់បំផុតនៃសមភាពយេនឌ័រ និងការមិនរើសអើង[14] ត្រូវអនុវត្តចំពោះគ្រប់សិទ្ធិទាំងអស់ដែលមាននៅក្នុងគ្រប់សន្ធិសញ្ញាសិទ្ធិមនុស្សជាមូលដ្ឋានទាំងនោះដែរ។ ចំណុចនេះក៏មានបញ្ជាក់នៅក្នុងសេចក្តីពន្យល់ទូទៅ និងអនុសាសន៍ទាក់ទងនឹងសិទ្ធិមានលំនៅឋានសមរម្យរបស់ស្ត្រី ដោយស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សដទៃទៀតដែរ។

អនុសាសន៍ទូទៅលេខ ២១ (១៩៩៤) នៃគណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី អំពីសមភាពនៃទំនាក់ទំនងអាពាហ៍ពិពាហ៍និងគ្រួសារ ចែងថា "នៅពេលដែលស្ត្រីមិនអាចចូលរួមធ្វើកិច្ចសន្យាបានទាល់តែសោះ ឬអាចទទួលបានឥណទានហិរញ្ញវត្ថុ ឬអាចធ្វើបានលុះត្រាតែធ្វើក្នុងពេលជាមួយគ្នា ឬដោយមានការធានាពីប្តី ឬសាច់ញាតិជាបុរសនោះ មានន័យថា ស្ត្រីនោះត្រូវបានគេបដិសេធនូវស្វ័យភាពតាមផ្លូវច្បាប់របស់គាត់ហើយ។ ការរឹតត្បិតបែបនេះណាមួយក៏ដោយ គឺជាការរារាំងស្ត្រីមិនឲ្យកាន់កាប់ទ្រព្យសម្បត្តិក្នុងនាមជាម្ចាស់តែម្នាក់ឯង [...]។ ការរឹតត្បិតបែបនេះ ជាការដាក់កំហិតទៅលើសមត្ថភាពរបស់ស្ត្រីសម្រាប់ផ្តល់ដល់ស្ត្រីខ្លួនឯងផង និងសម្រាប់អ្នកនៅក្រោមបន្ទុករបស់ខ្លួនផង" (កថាខណ្ឌទី ៧)។

---

[14] អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប មិនបានបញ្ចូលមាត្រាអំពី សមភាពទេ ប៉ុន្តែបានយោងទៅដល់គោលការណ៍សមភាពនៅក្នុងបុព្វកថា។ អនុសញ្ញាអន្តរជាតិស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ក៏បានយោងទៅដល់សមភាព តែក្នុងបុព្វកថាប៉ុណ្ណោះ ហើយនិយមន័យនៃការរើសអើងពូជសាសន៍ មិនបានបញ្ចូលមូលដ្ឋានភេទទេ។ ប៉ុន្តែ ក្នុងអនុសាសន៍ទូទៅ XXV (២០០០) ស្តីពីវិសាលភាពនៃការរើសអើងពូជសាសន៍ទាក់ទងនឹងយេនឌ័រ គណៈកម្មាធិការទទួលស្គាល់បទពិសោធន៍ និងឥទ្ធិពលជាក់លាក់នៃការរើសអើងពូជសាសន៍ទៅលើស្ត្រី។

សិទ្ធិធ្វើជាម្ចាស់ ចាត់ចែង អាស្រ័យផល និងបោះបង់ចោលទ្រព្យណាមួយ ជាសិទ្ធិសំខាន់ណាស់ចំពោះសិទ្ធិស្ត្រីក្នុងការទទួលបានឯករាជ្យភាពផ្នែកហិរញ្ញវត្ថុ ហើយនៅក្នុងប្រទេសជាច្រើន សិទ្ធិនេះសំខាន់ណាស់ទៅលើសមត្ថភាពរបស់ស្ត្រីក្នុងការប្រកបរបរចិញ្ចឹមជីវិត និងក្នុងការផ្តល់លំនៅឋាន និងអាហារូបត្ថម្ភសមរម្យ ដល់ស្ត្រីខ្លួនឯង និងដល់គ្រួសាររបស់ស្ត្រី" (កថាខណ្ឌទី ២៦)។

ទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិនៅពេលចំណងអាពាហ៍ពិពាហ៍រលត់ ឬពេលសាច់ញាតិណាម្នាក់ទទួលមរណភាព គណៈកម្មាធិការបានថ្លែងថា "[...] ច្បាប់ ឬទំនៀមទម្លាប់ណាដែលផ្តល់ឲ្យបុរសនូវទ្រព្យសម្បត្តិច្រើនជាងស្ត្រីនៅពេលចំណងអាពាហ៍ពិពាហ៍បានបញ្ចប់ ឬពេលបញ្ចប់ទំនាក់ទំនងដែលមាននាពេលបច្ចុប្បន្ន ឬនៅពេលសាច់ញាតិណាម្នាក់ទទួលមរណភាពនោះ គឺជាការរើសអើង ហើយវានឹងមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សមត្ថភាពជាក់ស្តែងរបស់ស្ត្រីក្នុងការលែងលះប្តី ក្នុងការគាំទ្រខ្លួនឯងនិងក្រុមគ្រួសារ និងក្នុងការរស់នៅដោយថ្លៃថ្នូរក្នុងនាមជាបុគ្គលឯករាជ្យ" (កថាខណ្ឌទី ២៨)។

គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី ក៏បានរំលេចនូវកាតព្វកិច្ចរបស់រដ្ឋក្នុងការធានាឲ្យមានលក្ខខណ្ឌជីវភាព និងលំនៅឋានសមរម្យ ទាក់ទងនឹងការការពារសិទ្ធិសុខភាពរបស់ស្ត្រី[15]។

យោងតាមសេចក្តីពន្យល់ទូទៅលេខ ២៨ (២០០០) របស់គណៈកម្មាធិការសិទ្ធិមនុស្ស ស្តីពីសមភាពនៃសិទ្ធិរវាងបុរស និងស្ត្រី "មាត្រា ៣ [នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ] ចែងថាមនុស្សគ្រប់រូបគួរទទួលបានសិទ្ធិទាំងអស់ដែលមានចែងនៅក្នុងកតិកាសញ្ញានោះ ដោយស្មើភាពគ្នា និងដោយពេញលេញ។ ឥទ្ធិពលទាំងស្រុងនៃបញ្ញត្តិនេះ នឹងមានការខូចខាត នៅពេលណាក៏ដោយឲ្យតែបុគ្គលណាម្នាក់ត្រូវបានបដិសេធមិនឲ្យប្រើប្រាស់សិទ្ធិណាមួយក្នុងកតិកាសញ្ញានេះដោយពេញលេញ និងស្មើភាពគ្នា។ ដូច្នេះរដ្ឋគួរធានាឲ្យ បុរស និងស្ត្រី ទទួលបានសិទ្ធិទាំងអស់ដែលមានចែងក្នុងកតិកាសញ្ញានេះឲ្យបានស្មើភាពគ្នា" (កថាខណ្ឌទី ២)។ យោងតាមគណៈកម្មាធិការ នេះមានន័យថា រដ្ឋភាគីត្រូវបានតម្រូវឲ្យចាត់វិធានការដើម្បីលុបបំបាត់ឧបសគ្គទាំងឡាយណាដែលរារាំងដល់ការទទួលបានសិទ្ធិទាំងនេះដោយស្មើភាពគ្នា អប់រំប្រជាពលរដ្ឋ និងមន្ត្រីរដ្ឋ និងកែសម្រួលច្បាប់ក្នុងប្រទេស។ បន្ថែមពីលើវិធានការការពារ រដ្ឋភាគីត្រូវអនុម័តវិធានការវិជ្ជមាននានា "ដើម្បីសម្រេចបានការពង្រឹងសិទ្ធិអំណាចស្ត្រីឲ្យមានប្រសិទ្ធភាព និងស្មើភាពគ្នា" (កថាខណ្ឌទី ៣)។ គណៈកម្មាធិការកត់សម្គាល់ថា វិសមភាពសម្រាប់ស្ត្រីក្នុងការទទួលបានសិទ្ធិទាំងនេះភាគច្រើន ចាក់ឫសយ៉ាងជ្រៅនៅក្នុងប្រពៃណី វប្បធម៌ និងសាសនា។ គណៈកម្មាធិការសង្កត់ធ្ងន់ថា "រដ្ឋភាគីគួរធានាថា ឥរិយាបថបែបប្រពៃណី ប្រវត្តិសាស្ត្រ សាសនា និងវប្បធម៌ មិនត្រូវគេយកមកប្រើជាលេសសំអាងក្នុងការប្រព្រឹត្តការរំលោភបំពានទៅលើសិទ្ធិសមភាពរបស់ស្ត្រីនៅចំពោះមុខច្បាប់ និងរំលោភបំពានលើការប្រើប្រាស់សិទ្ធិទាំងអស់ក្នុងកតិកាសញ្ញានេះដោយស្មើភាពគ្នាឡើយ" (កថាខណ្ឌទី ៥)។

គណៈកម្មាធិការកត់សម្គាល់ថា សិទ្ធិរបស់មនុស្សគ្រប់រូបដែលទទួលស្គាល់នៅចំពោះមុខច្បាប់នៅគ្រប់ទីកន្លែងក្នុងនាមជារូបវន្តបុគ្គលចែងថា "សមត្ថភាពរបស់ស្ត្រីក្នុងការមានកម្មសិទ្ធិលើទ្រព្យសម្បត្តិ ក្នុងការ

[15] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី អនុសាសន៍ទូទៅលេខ ២៤ (១៩៩៩) កថាខណ្ឌទី ២៨។

ចូលរួមធ្វើកិច្ចសន្យា ឬ ក្នុងការប្រើប្រាស់សិទ្ធិពលរដ្ឋផ្សេងៗទៀត មិនត្រូវរឹតត្បិតដោយផ្អែកលើស្ថានភាពអាពាហ៍ពិពាហ៍ ឬ មូលដ្ឋានដទៃទៀតដែលមានលក្ខណៈរើសអើងឡើយ។ គណៈកម្មាធិការក៏បញ្ជាក់ថា ស្ត្រីមិនអាចត្រូវបានប្រព្រឹត្តមកលើខ្លួនដូចជាវត្ថុដែលគេផ្តល់ឲ្យគ្រួសាររបស់ប្តី ជាមួយនឹងទ្រព្យផ្សេងទៀតរបស់ប្តីដែលបានស្លាប់នោះទេ" (កថាខណ្ឌទី ១៩)។

គណៈកម្មាធិការក៏សង្កត់ធ្ងន់ថា រដ្ឋត្រូវតែធានាថា របបចំណងអាពាហ៍ពិពាហ៍ត្រូវមានសិទ្ធិនិងកាតព្វកិច្ចស្មើគ្នាសម្រាប់ប្តីប្រពន្ធទាំងពីរ ឧទាហរណ៍ ទាក់ទងនឹងកម្មសិទ្ធិ ឬ ការគ្រប់គ្រងទ្រព្យសម្បត្តិ "ទោះបីជាទ្រព្យនោះជា ទ្រព្យរួម ឬ ទ្រព្យដែលជាកម្មសិទ្ធិដោយឡែករបស់ប្តី ឬប្រពន្ធក៏ដោយ"។ នៅពេលរំលត់ចំណងអាពាហ៍ពិពាហ៍ ការសម្រេចចិត្តទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ គួរតែដូចគ្នាសម្រាប់បុរស និងស្ត្រី ហើយ "ស្ត្រីគួរមានសិទ្ធិស្មើគ្នាជាមួយនឹងបុរស ក្នុងការទទួលមរតក នៅពេលដែលការរលត់ចំណងអាពាហ៍ពិពាហ៍ បណ្តាលមកពីមរណភាពរបស់ប្តី ឬប្រពន្ធ"។ គណៈកម្មាធិការ ចាត់ទុក ពហុពន្ធភាព ថាជាការរើសអើងទៅលើស្ត្រីដែលមិនអាចគិតថាជារឿងត្រឹមត្រូវឡើយ ដោយសារតែវាមិនអនុលោមតាមគោលការណ៍នៃការប្រព្រឹត្តដោយសមភាព (កថាខណ្ឌទី ២៤-២៦)។

មានយន្តការដាក់បណ្តឹងជាបុគ្គលលក្ខណៈអន្តរជាតិជាក់លាក់មួយចំនួន ក្នុងការធានាដល់សិទ្ធិរបស់ស្ត្រី ដូចជា ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី ពិធីសារបន្ថែមទីមួយនៃកតិកាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា ២២ នៃអនុសញ្ញាប្រឆាំងទារុណកម្ម។ ពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក៏មានសក្តានុពលក្នុងការដើរតួនាទីជាមធ្យោបាយដ៏សំខាន់សម្រាប់ការដោះស្រាយ នៅពេលដែលពិធីសារនេះចូលជាធរមាន ហើយនៅពេលដែលយន្តការក្នុងស្រុកទទួលបរាជ័យ។ បញ្ហាស្ត្រី និងលំនៅឋាន ជាពិសេសការផ្តល់ឲ្យមាននូវទីជម្រកសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ ត្រូវយោងទៅពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី នៅក្នុងករណីរបស់ *លោកស្រី អេ.ធី ទល់នឹងប្រទេសហុងគ្រី* [16]។ ក្រោមយន្តការបណ្តឹងនៃអនុសញ្ញាប្រឆាំងទារុណកម្ម គណៈកម្មាធិការប្រឆាំងទារុណកម្មបានសន្និដ្ឋានថាការបណ្តេញចេញពីផ្ទះ និងការបំផ្លិចបំផ្លាញផ្ទះ និងទ្រព្យសម្បត្តិ ក្នុងករណីមួយចំនួន អាចបង្កើតជាការបំពានលើអនុសញ្ញា និងត្រូវគេចាត់ទុកថាជាការប្រព្រឹត្តអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក[17]។

## គ. សន្និសីទជាសកល

សិទ្ធិមានលំនៅឋានសមរម្យក៏ត្រូវបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិ នៅក្នុងសន្និសីទជាច្រើនរបស់អង្គការសហប្រជាជាតិជុំវិញពិភពលោកនាពេលថ្មីៗនេះ ដូចជា សន្និសីទពិភពលោកស្តីពីសិទ្ធិមនុស្សនៅទីក្រុងវីយែន សន្និសីទពិភពលោកលើកទីបួនស្តីពីស្ត្រី សន្និសីទពិភពលោកស្តីពីការប្រឆាំងពូជសាសន៍

---

[16] *បណ្តឹងរវាងលោកស្រី អេ.ធី ទល់នឹង ប្រទេសហុងគ្រី* លេខ ២/២០០៣ អនុម័តកាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ ២០០៥។

[17] *បណ្តឹងរវាង ហាចរីហ្សី ព្រមទាំងអ្នកផ្សេងទៀត ទល់នឹងប្រទេសយូហ្គោស្លាវី* លេខ ១៦១/២០០០ សេចក្តីសម្រេចអនុម័តកាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០២។

ការរើសអើងពូជសាសន៍ និងការស្អប់ខ្ពើមពូជសាសន៍ និងភាពគ្មានមេត្តាដែលពាក់ព័ន្ធ កិច្ចប្រជុំកំពូលពិភពលោកស្តីពីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងសំខាន់បំផុត គឺសន្និសីទអង្គការសហប្រជាជាតិលើកទីពីរស្តីពីលំនៅឋានមនុស្សជាតិ (ចំណុច HABITAT II)។

វេទិកាសកម្មភាពទីក្រុងប៉េកាំង[18] កំណត់ឲ្យរដ្ឋធ្វើការលុបបំបាត់រាល់ឧបសគ្គទាំងអស់ដែលរារាំងដល់ការទទួលបានលំនៅឋានដែលអាចលៃលកករកបាន និងកាទទួលបានដីធ្លីរបស់ស្ត្រី (កថាខណ្ឌទី ៥៥(ខ)) និងក្នុងការកែទម្រង់ច្បាប់ និងរដ្ឋបាល ដើម្បីផ្តល់ឲ្យស្ត្រីនូវការទទួលបានធនធានសេដ្ឋកិច្ចដោយស្មើភាពគ្នា និងផ្តល់ដល់ស្ត្រីនូវសិទ្ធិកម្មសិទ្ធិ និងទទួលមរតកទ្រព្យសម្បត្តិ (កថាខណ្ឌទី ៦១(ខ))។

សេចក្តីប្រកាសទីក្រុងអ៊ីស្តង់ប៊ូល ស្តីពីលំនៅឋានមនុស្សជាតិ និងកម្មវិធីលំនៅឋាន[19] បានបញ្ជាក់សាជាថ្មីអំពីការប្តេជ្ញាចិត្តរបស់រដ្ឋចំពោះសិទ្ធិមានលំនៅឋានសមរម្យ បានបង្ហាញអំពីវិធានការរបស់រដ្ឋក្នុងការធ្វើឲ្យសម្រេចបាននូវសិទ្ធិមានលំនៅឋានសមរម្យ និងបានទទួលស្គាល់តួនាទីរបស់សង្គមស៊ីវិល ដូចខាងក្រោម៖

យើងទទួលស្គាល់កាតព្វកិច្ចរបស់រដ្ឋាភិបាលក្នុងការជួយប្រជាជនឲ្យទទួលបានទីជម្រក និងការការពារ និងការកែលម្អទីជម្រក និងសហគមន៍រស់នៅ។ [...] យើងត្រូវអនុវត្តនិងលើកកម្ពស់គោលបំណងនេះក្នុងលក្ខណៈមួយដែលស្របតាមបទដ្ឋានសិទ្ធិមនុស្សទាំងស្រុង (កម្មវិធីលំនៅឋាន កថាខណ្ឌទី ៣៩)។

កម្មវិធីលំនៅឋាន ក៏បានធ្វើឲ្យរដ្ឋប្តេជ្ញាក្នុងការផ្តល់សុវត្ថិភាពកម្មសិទ្ធិស្របច្បាប់ និងការទទួលបានដីធ្លីដោយស្មើភាពគ្នាដល់មនុស្សគ្រប់រូប រាប់បញ្ចូលទាំង ស្ត្រី និងអ្នកកំពុងរស់នៅក្នុងភាពក្រីក្រ និងក្នុងការធ្វើកំណែទម្រង់ច្បាប់និងរដ្ឋបាល ដើម្បីផ្តល់ឲ្យស្ត្រីនូវការទទួលបានធនធានសេដ្ឋកិច្ចពេញលេញ និងស្មើភាពគ្នា រាប់បញ្ចូលទាំងសិទ្ធិទទួលមរតក និងសិទ្ធិកម្មសិទ្ធិលើដីធ្លី និងទ្រព្យសម្បត្តិផ្សេងទៀត សិទ្ធិទទួលបានឥណទាន ធនធានធម្មជាតិ និងបច្ចេកវិទ្យាសមស្រប (កថាខណ្ឌទី ៤០(ខ))។ ពេលនោះ ក៏មានការអំពាវដល់រដ្ឋទាំងឡាយឲ្យគាំទ្រគម្រោង គោលនយោបាយ និងកម្មវិធីសហគមន៍ ដែលមានគោលបំណងលុបបំបាត់រាល់ឧបសគ្គដែលរារាំងស្ត្រីពីការទទួលបានលំនៅឋានដែលអាចលៃលកករកបាន កម្មសិទ្ធិដីធ្លីនិងទ្រព្យសម្បត្តិ ធនធានសេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសង្គម ព្រមទាំងធានាឲ្យមានការចូលរួមពេញលេញរបស់ស្ត្រីនៅក្នុងការសម្រេចចិត្តទាំងអស់ (កថាខណ្ឌទី ៧៨(ង))។ ជាងនេះទៅទៀត ក៏មានការសំណូមពរឲ្យរដ្ឋទាំងឡាយ លើកកម្ពស់យន្តការសម្រាប់ការពារស្ត្រីដែលប្រឈមនឹងការបាត់បង់លំនៅឋាននៅពេលដែលប្តីទទួលមរណភាព (កថាខណ្ឌទី ៧៨(ធ))។

សេចក្តីប្រកាសស្តីពីទីក្រុងនិងលំនៅឋានមនុស្សជាតិក្នុងសហសវត្សថ្មី (២០០១)[20] ដែលបញ្ជាក់ឡើងវិញអំពីគោលដៅសមភាពយេនឌ័រនៅក្នុងការអភិវឌ្ឍន៍លំនៅឋានមនុស្សជាតិ បានអំពាវនាវឲ្យមានការលើកកម្ពស់សមភាពយេនឌ័រ ជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយក្នុងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ

[18] *របាយការណ៍សន្និសីទពិភពលោកលើកទីបួន ស្តីពីស្ត្រី ក្រុងប៉េកាំង ៤-១៥ កញ្ញា ១៩៩៥* (ការបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ លេខ 96.IV.13)។

[19] *របាយការណ៍សន្និសីទអង្គការសហប្រជាជាតិស្តីពី លំនៅឋានមនុស្សជាតិ* (Habitat II, *ក្រុងអ៊ីស្តង់ប៊ូល ថ្ងៃទី៣-១៤ មិថុនា ១៩៩៦* (ការបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ លេខ E.97.IV.6 ជំពូក១ សេចក្តីសម្រេចលេខ ១ ឧបសម្ព័ន្ធ ១ និង ២)។

[20] សេចក្តីសម្រេចរបស់មហាសន្និបាត S-25/2 ឧបសម្ព័ន្ធ។

(កថាខណ្ឌទី ៤៤) ក៏ដូចជាឲ្យមានការលើកកម្ពស់ការផ្លាស់ប្តូរឥរិយាបថ រចនាសម្ព័ន្ធ គោលនយោបាយ ច្បាប់ និងការអនុវត្តទាំងឡាយ ដែលបង្កើតជាឧបសគ្គក្នុងការសម្រេចបានសមភាពយេនឌ័រ (កថាខណ្ឌទី ៣២) ព្រមទាំងឲ្យមានការលើកកម្ពស់សុវត្ថិភាពនៃការកាន់កាប់ឲ្យកាន់តែប្រសើរឡើងសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ និងកំណែទម្រង់ច្បាប់ រដ្ឋបាល និងសង្គមជាបន្ត ដើម្បីផ្តល់ឲ្យស្ត្រីនូវ "ការទទួលបានធនធានសេដ្ឋកិច្ចពេញលេញនិងស្មើភាព" និង "សិទ្ធិរបស់ស្ត្រីក្នុងការទទួលបានសុវត្ថិភាពនៃការកាន់កាប់ និងសិទ្ធិចូលរួមនៅក្នុងការធ្វើកិច្ចសន្យានានា" (កថាខណ្ឌទី ៤៥ និង ៤៩)។

សេចក្តីប្រកាសសហសវត្សរបស់អង្គការសហប្រជាជាតិ (២០០០)[21] បានកត់ត្រា សមភាពយេនឌ័រក្នុងបញ្ជីថា ជាគុណតម្លៃគ្រឹះមួយក្នុងចំណោមគុណតម្លៃជាច្រើន ដែលមានសារៈសំខាន់ចំពោះទំនាក់ទំនងអន្តរជាតិ (កថាខណ្ឌទី ៦)។ គោលដៅអភិវឌ្ឍន៍សហសវត្សមួយក្នុងចំណោមគោលដៅជាច្រើន ពាក់ព័ន្ធនឹងការលើកកម្ពស់សមភាពយេនឌ័រ និងការពង្រឹងសិទ្ធិអំណាចស្ត្រី ដោយទោះបីជាគោលដៅពាក់ព័ន្ធ ជាប់ទាក់ទិន នឹងសមភាពយេនឌ័រក្នុងវិស័យអប់រំ មានលក្ខណៈមិនទូលំទូលាយក្តី។ អ្នកធ្វើអត្ថាធិប្បាយ បានកត់សម្គាល់អំពីសារៈសំខាន់នៃកង្វល់អំពីការបញ្ជ្រាបយេនឌ័រ ទៅក្នុងគោលដៅអភិវឌ្ឍន៍សហសវត្សទាំងអស់[22] ដោយក្នុងនោះមានរាប់បញ្ចូលទាំងគោលដៅទី៧ ទាក់ទងនឹងការកែលម្អការទទួលបានទឹកស្អាត និងអនាម័យ ក៏ដូចជា ការកែលម្អជីវិតរបស់អ្នករស់នៅក្នុងទីប្រជុំ ដែលមិនទាន់មានលក្ខណៈរៀបរយ។ នៅក្នុងជំនួបកំពូលឆ្នាំ ២០១០ រដ្ឋបានប្តេជ្ញាចិត្តដោយខ្លួនឯងក្នុងការធានាឲ្យមានសមភាពយេនឌ័រ តាមរយៈសកម្មភាពជាច្រើន ដោយរាប់បញ្ចូលទាំង "ការលើកកម្ពស់ និងការការពារដល់ស្ត្រីក្នុងការទទួលបានលំនៅឋានសមរម្យ ដីធ្លី និងទ្រព្យសម្បត្តិ ដោយស្មើភាពគ្នា ដោយរួមទាំងសិទ្ធិទទួលមរតក ព្រមទាំងជួយឲ្យស្ត្រីអាចទទួលបានឥណទាន តាមរយៈវិធានការតាមរដ្ឋធម្មនុញ្ញ តាមច្បាប់ និងតាមបែបរដ្ឋបាលសមរម្យទៀតផង"។[23]

ផែនការសម្រាប់ការអនុវត្តនៃជំនួបប្រជុំកំពូលស្តីពីការអភិវឌ្ឍន៍ដោយនិរន្តរភាព[24] បានទទួលស្គាល់សារៈសំខាន់នៃសិទ្ធិរបស់ស្ត្រីក្នុងការទទួលបានដីធ្លី ដោយរាប់បញ្ចូលទាំងសិទ្ធិទទួលបានមរតក និងសារៈសំខាន់របស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត ក្នុងគោលបំណងដើម្បីសម្រេចបានការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពក្នុងទ្វីបអាហ្វ្រិក និងការសម្រេចបានគោលដៅសហសវត្សពាក់ព័ន្ធផ្សេងទៀត (កថាខណ្ឌទី ៦៧(ខ))។

---

[21] សេចក្តីសម្រេចរបស់មហាសន្និបាត 55/2។

[22] សូមមើល *ការទាមទារគោលដៅអភិវឌ្ឍន៍សហសវត្ស៖ អភិក្រមសិទ្ធិមនុស្ស* (ការបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ លេខ E.08.XIV.6)។

[23] សេចក្តីសម្រេចរបស់មហាសន្និបាត 65/1 កថាខណ្ឌទី៧២ (ដ)។

[24] *របាយការណ៍កិច្ចប្រជុំកំពូលស្តីពីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ក្រុងចូហាន់ណាសប៊ឺក អាហ្វ្រិកខាងត្បូង ថ្ងៃទី២៦ ខែសីហា ដល់ថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ២០០២* ការបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ លេខ E.03.II.A) កថាខណ្ឌទី ៦១(ខ)។

## ឃ. លិខិតុបករណ៍ និងការអភិវឌ្ឍន៍ក្នុងតំបន់

បញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិមានលំនៅឋានសមរម្យ ក៏ត្រូវបានរកឃើញនៅក្នុងឧបករណ៍ក្នុងតំបន់ ដូចតទៅនេះ៖ ធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្សនិងប្រជាជន (មាត្រា ២ និងមាត្រា ១៨ កថាខណ្ឌទី ២ និង ៣) អនុសញ្ញាអឺរ៉ុបសម្រាប់ការការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន (មាត្រា ៥ មាត្រា ៨ និង មាត្រា១៤) វិសោធនកម្មធម្មនុញ្ញសង្គមអឺរ៉ុប (មាត្រា ៣១) សេចក្តីប្រកាសអាមេរិកស្តីពីសិទ្ធិនិងករណីយកិច្ចរបស់មនុស្ស (មាត្រា ១ មាត្រា ២ និងមាត្រា ២៣) អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស (មាត្រា ១ មាត្រា ៧ មាត្រា ២១ និង មាត្រា ២៤) ព្រមទាំងពិធីសារបន្ថែម (មាត្រា ៣)។

ធម្មនុញ្ញអាហ្វ្រិកស្តីពី សិទ្ធិមនុស្ស និងប្រជាជន ចែងថា "រដ្ឋត្រូវធានាឲ្យមានការលុបបំបាត់រាល់ការរើសអើងទៅលើស្ត្រី និងក៏បានធានាឲ្យមានការការពារសិទ្ធិស្ត្រីនិងសិទ្ធិកុមារ ដូចដែលមានចែងក្នុងសេចក្តីប្រកាសអន្តរជាតិ និងអនុសញ្ញាអន្តរជាតិ" (មាត្រា ១៨.៣)។ ក្នុងឆ្នាំ១៩៩១ គណៈកម្មាធិការទ្វីបអាហ្វ្រិក ក៏បានបង្កើតការិយាល័យអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិស្ត្រីក្នុងទ្វីបអាហ្វ្រិក ដើម្បីសិក្សាអំពីការប្រើប្រាស់សិទ្ធិរបស់ស្ត្រីនៅទូទាំងទ្វីបអាហ្វ្រិក និងដើម្បីផ្តល់អនុសាសន៍សម្រាប់ជួយដល់រដ្ឋ ក្នុងការធានាឲ្យមានសិទ្ធិមនុស្សសម្រាប់ស្ត្រី។ ថ្មីៗនេះ ពិធីសារបន្ថែមនៃធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្សនិងប្រជាជន ទៅលើសិទ្ធិស្ត្រីក្នុងទ្វីបអាហ្វ្រិក បានទទួលស្គាល់សិទ្ធិស្មើភាពគ្នារបស់ស្ត្រីក្នុងការទទួលបានលំនៅឋាន និងទទួលបានលក្ខខណ្ឌជីវិតអាចទទួលយកបាន ក្នុងបរិស្ថានដែលមានសុខភាព (មាត្រា ១៦) ក៏ដូចជា សិទ្ធិស្មើភាពគ្នារបស់ស្ត្រីក្នុងការទទួលបានមរតក (មាត្រា ២១)។ ពិធីសារបន្ថែមនេះ បានដើរតួនាទីជាគំរូមួយសម្រាប់ការលើកកម្ពស់ និងការគោរពសិទ្ធិមនុស្សរបស់ស្ត្រីនៅក្នុងតំបន់ផ្សេងទៀត។

លើសពីនេះទៀត ទោះបីជាធម្មនុញ្ញអាហ្វ្រិកស្តីពី សិទ្ធិមនុស្ស និងប្រជាជន មិនមានបញ្ញត្តិចែងយ៉ាងច្បាស់លាស់អំពីសិទ្ធិមានលំនៅឋានសមរម្យក៏ដោយ ក៏គណៈកម្មាធិការទ្វីបអាហ្វ្រិក បានយល់ថា ធម្មនុញ្ញនេះត្រូវការពារសិទ្ធិលំនៅឋាន តាមរយៈសិទ្ធិផ្សេងទៀត ដោយរាប់បញ្ចូលទាំងសិទ្ធិទទួលបានទ្រព្យសម្បត្តិ សិទ្ធិខាងសុខភាព និងសិទ្ធិទទួលបានការការពារគ្រួសារ។ គោលការណ៍ និងគោលការណ៍ណែនាំស្តីពីការអនុវត្តសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលទើបនឹងបានអនុម័តកាលពីពេលថ្មីៗនេះ នៅក្នុងធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្សនិងប្រជាជន បានលើកឡើងជាពិសេសអំពីសិទ្ធិលំនៅឋាន និងបានដាក់បញ្ចូលការយោងដល់ស្ត្រី ទាក់ទងនឹងកម្មសិទ្ធិលើលំនៅឋាននិងដីធ្លី ក៏ដូចជាសិទ្ធិស្មើភាពគ្នាក្នុងការទទួលបានសំណងនៅពេលដែលសិទ្ធិមានលំនៅឋានសមរម្យត្រូវបានគេបំពាន (កថាខណ្ឌ ៧៩ (xvii)-(xviii))។

ក្នុងឆ្នាំ ២០១១ ក្រុមប្រឹក្សាទ្វីបអឺរ៉ុបបានអនុម័តអនុសញ្ញាស្តីពីការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងអំពើហិង្សាលើស្ត្រីនិងអំពើហិង្សាក្នុងគ្រួសារ។ អនុសញ្ញានេះមានបញ្ញត្តិសំខាន់ៗទាក់ទងនឹងកាតព្វកិច្ចរបស់រដ្ឋភាគីក្នុងការធានាថា ជនរងគ្រោះនៃអំពើហិង្សាអាចទទួលបានសេវាកម្ម រាប់ទាំងសេវាកម្មលំនៅឋាន និងធានាថាជនជនរងគ្រោះអាចងាយទទួលបាន និងងាយរកបាន ព្រមទាំងធានាថា អាជ្ញាធរមានអំណាចក្នុងការយកជនល្មើសចេញពីទីស្នាក់អាស្រ័យដែលស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់បន្ទាន់។

***ការអភិវឌ្ឍន៍ក្នុងទ្វីបអឺរ៉ុប***

ធម្មនុញ្ញនៃសិទ្ធិមូលដ្ឋាននៃសហភាពអឺរ៉ុប ការពារសិទ្ធិទទួលបានទ្រព្យសម្បត្តិ (មាត្រា ១៧) និងចែងអំពី "សិទ្ធិទទួលបានជំនួយសង្គម និងលំនៅឋាន ដើម្បីធានាឲ្យការរស់នៅមានភាពសមរម្យសម្រាប់អ្នកដែលខ្វះធនធានគ្រប់គ្រាន់" (មាត្រា ៣៤)។ "សេចក្តីណែនាំអំពីពូជសាសន៍" (សេចក្តីណែនាំរបស់ក្រុមប្រឹក្សាលេខ 2000/43/EC) និង "សេចក្តី ណែនាំអំពីយេនឌ័រ" (សេចក្តីណែនាំរបស់ក្រុមប្រឹក្សាលេខ 2004/113/EC)ត្រូវអនុវត្តគោលការណ៍នៃការប្រព្រឹត្តដោយស្មើភាព ដោយមិនគិតអំពីពូជសាសន៍ ដើមកំណើតជាតិពន្ធុ ឬ ភេទឡើយ ទាក់ទងនឹងការទទួលបានទំនិញ និងសេវាកម្មសាធារណៈ ដោយរាប់បញ្ចូលទាំងលំនៅឋានផង។ សមាជិកគណៈកម្មាធិការដើម្បីសិទ្ធិមនុស្សនៃក្រុមប្រឹក្សាទ្វីបអឺរ៉ុប បានកត់សម្គាល់ថា "ការយល់ដឹងអំពីលំនៅឋានសមរម្យទាក់ទងនឹងស្ត្រី ត្រូវតែពិចារណាអំពីបរិបទ និងលក្ខខណ្ឌលំនៅឋាន និងការរស់នៅរបស់សហគមន៍ និងគ្រួសារដែលស្ត្រីរស់នៅ"។ [ក]

សហភាពអឺរ៉ុប ក៏បានធ្វើវិសោធនកម្មបទប្បញ្ញត្តិនៃឧបករណ៍ហិរញ្ញវត្ថុធំបំផុតទីពីររបស់ខ្លួន គឺមូលនិធិអភិវឌ្ឍន៍តំបន់អឺរ៉ុប ដើម្បីធ្វើឲ្យសហគមន៍ដែលមិនសូវទទួលបានការយកចិត្តទុកដាក់ទាំងឡាយមានសិទ្ធិទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ។ មាត្រា ៧.២ ត្រូវបានគេដាក់បញ្ចូលក្នុងបទប្បញ្ញត្តិរបស់មូលនិធិនេះក្នុងឆ្នាំ២០០៦ ដោយសារតែគេបានចាត់ទុកថា វាមានភាពចាំបាច់នៅក្នុងក្របខ័ណ្ឌប្រតិបត្តិការសមាហរណកម្មតំបន់ទីក្រុង ដើម្បីគាំទ្រដល់សកម្មភាពដ៏មានកម្រិតក្នុងការជួសជុលកែលម្អផ្ទះសម្បែងតាមតំបន់ដែលជួបប្រទះ ឬ ប្រឈមនឹងការចុះអន់ថយផ្នែករូបវន្ត និង ការផាត់ចេញពីសង្គម ក្នុងរដ្ឋទាំងឡាយដែលបានយល់ព្រមចូលក្នុងសហភាពអឺរ៉ុប នៅថ្ងៃ ឬ មុនថ្ងៃទី១ ខែឧសភា ឆ្នាំ២០០៤។ ទោះបីជាការធ្វើវិសោធនកម្មនោះមិនមានចែងបញ្ញត្តិជាក់លាក់សម្រាប់ស្ត្រីក៏ដោយ ក៏វាមានភាពជាប់ពាក់ព័ន្ធដែរ ដោយសារតែបញ្ហាលំនៅឋាននេះបង្កើតជាកត្តាសម្រេចមួយសម្រាប់ការធ្វើសមាហរណកម្មនៅក្នុងរដ្ឋជាច្រើន ជាពិសេសសម្រាប់ស្ត្រីមកពីក្រុមជាតិពន្ធុភាគតិច ឬ ក្រុមមិនសូវទទួលបានការយកចិត្តទុកដាក់ផ្សេងទៀត។

[ក] "សិទ្ធិលំនៅឋាន៖ ករណីកិច្ចធានាឲ្យមានលំនៅឋានសម្រាប់ទាំងអស់គ្នា" អាចរកបានពី https://wcd.coe.int/ViewDoc.jsp?id=1292391&Site=CM (ចូលមើលថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២)។

# • ការរើសអើងទៅលើស្ត្រី ក្នុងវិស័យលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ

ស្ត្រីតំណាងឲ្យចំនួនមិនមានសមាមាត្រក្នុងចំណោមមនុស្សដែលរស់នៅក្នុងភាពក្រីក្រ ដោយមានការប៉ាន់ប្រមាណមួយចំនួនថា មានចំនួនច្រើនរហូតដល់ទៅ ៧០% នៃប្រជាជនក្រីក្រក្នុងពិភពលោកគឺជាស្ត្រី។ ក្នុងតំបន់ជនបទ ស្ត្រីច្រើនតែទទួលខុសត្រូវក្នុងការផលិតស្បៀង គឺថាស្ត្រីផលិតពី ៦០% ទៅ ៨០% នៃស្បៀងក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ប៉ុន្តែ ពួកគេកម្រមានសិទ្ធិទាក់ទងដីធ្លីដែលពួកគេបានធ្វើការដាំដុះនោះខ្លាំងណាស់[25]។ តាមពិតទៅ ក្នុងចំណោមម្ចាស់ដី ១០០នាក់ ក្នុងពិភពលោកយើងនេះ មានតែ ២០នាក់ប៉ុណ្ណោះជាស្ត្រី[26]។

មិនថានៅក្នុងបរិយាកាសច្បាប់ សង្គម ឬ វប្បធម៌បែបណានោះទេ ការរើសអើងគឺជាកត្តាចម្បងមួយទប់ស្កាត់ស្ត្រីពីការទទួលបានដោយពេញលេញនូវសិទ្ធិមានលំនៅឋានសមរម្យ នៅក្នុងតំបន់ជាច្រើនលើពិភពលោកយើងនេះ ទាំងនៅតាមទីក្រុង និង ទីជនបទ។

***ការរើសអើងទៅលើស្ត្រី***

មាត្រា១ នៃអនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី កំណត់និយមន័យអំពីការរើសអើង ថាជា៖

> *ការបែងចែក ការផាត់ចេញ ឬការរឹតត្បិតណាមួយ ផ្អែកលើភេទ ដែលមានអនុភាព ឬមានបំណងធ្វើឲ្យខូចខាត ឬធ្វើឲ្យមោឃភាពនូវការទទួលស្គាល់ ការអាស្រ័យផល ឬការអនុវត្តដោយស្ត្រី ដោយមិនគិតដល់ស្ថានភាពអាពាហ៍ពិពាហ៍របស់គេ ដោយឈរលើមូលដ្ឋានស្មើភាពគ្នារវាងបុរសនិងស្ត្រីនូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងពលរដ្ឋ ឬក្នុងវិស័យផ្សេងៗទៀត។*

គណៈកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានបញ្ជាក់ច្បាស់លាស់បន្ថែមទៀតក្នុងសេចក្តីពន្យល់ទូទៅលេខ ១៦ (២០០៥) ថា៖

> *ការរើសអើសដោយផ្អែកលើភេទ អាចផ្អែកលើការប្រព្រឹត្តផ្សេងគ្នាទៅលើស្ត្រី ដោយសារតែកត្តាជីវសាស្ត្ររបស់ពួកគេ ដូចជា ការបដិសេធមិនផ្តល់ការងារឲ្យដល់ស្ត្រី ដោយសារតែពួកគេអាចមានផ្ទៃពោះ ឬដោយការសន្និដ្ឋានដោយខុសឆ្គងដូចជា ការដាក់ស្ត្រីឲ្យធ្វើការងារកម្រិតទាប ដោយផ្អែកលើការសន្និដ្ឋានថាស្ត្រីមិនមានឆន្ទៈលះបង់ពេលវេលាធ្វើការច្រើនដូចបុរស (កថាខណ្ឌទី ១១)។*

---

[25] ក្រុមការងារគម្រោងសហសវត្សស្តីពីការអប់រំ និងសមភាពយេនឌ័រ *ចាត់វិធានការ៖ ទទួលបានសមភាពយេនឌ័រ និងពង្រឹងសិទ្ធិអំណាចដល់ស្ត្រី* (ក្រុងឡុងដ៏ អ៊ីសស្តែន ឆ្នាំ២០០៥) ទំព័រទី ៧៧។

[26] www.fao.org/docrep/012/al059e/al059e00.pdf (ចូលមើលនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០១២)។

យោងទស្សនៈអំពីសមភាព មនុស្សគ្រប់រូបមានសិទ្ធិមនុស្សទាំងអស់ដោយស្មើភាពគ្នាទាំងអស់គ្នា ហើយគំនិតអំពីសមភាពនេះ ជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងគោលការណ៍មិនរើសអើង។ ទាក់ទងនឹងយេនឌ័រ សមភាព មានន័យថា បុរស និងស្ត្រី គួរទទួលបានសិទ្ធិមនុស្សទាំងអស់ដោយស្មើភាពគ្នា។ សមភាពមានជ្រុងពីរៈ សមភាពពិតជាក់ស្តែង និងសមភាពក្នុងច្បាប់។ ធម្មនុញ្ញជាច្រើនទទួលស្គាល់សមភាពរវាងបុរស និងស្ត្រី នៅក្នុងច្បាប់។ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង វាជារឿងមួយផ្ទុយស្រឡះទៅវិញ ដោយសារថា ស្ត្រី និងបុរស កម្រទទួលបានសមភាពបែបនេះណាស់។ រឿងនេះវារឹតតែច្បាស់ក្រឡែតទៀតក្នុងបញ្ហាលំនៅឋាន ។

ក្នុងតំបន់ជាច្រើនក្នុងពិភពលោកនេះ ជាពិសេសតំបន់ជនបទ ការទទួលបានសិទ្ធិមានលំនៅឋានសមរម្យសម្រាប់ស្ត្រី នៅតែបន្តពឹងផ្អែកលើការទទួលបាន និងការគ្រប់គ្រងដីធ្លី និងទ្រព្យសម្បត្តិ។

ការគិតអំពីលំនៅឋានក្នុងតំបន់ប៉ាស៊ីហ្វិក មានជាប់ទាក់ទងយ៉ាងខ្លាំងទៅនឹងការគិតអំពីដីធ្លី ដូច្នេះដើម្បីផ្តោតទៅលើលំនៅឋាន យើងត្រូវផ្តោតទៅលើដី។

*ប្រភព៖* សក្ខីកម្មប្រមូលបានក្នុងអំឡុងពេលធ្វើការពិគ្រោះយោបល់ថ្នាក់តំបន់នៅតំបន់ប៉ាស៊ីហ្វិក។

ស្ត្រីប្រឈមនឹងការរើសអើងលើទិដ្ឋភាពជាច្រើននៃបញ្ហាលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ ដោយសារមូលដ្ឋានយេនឌ័រ ដែលច្រើនតែធ្វើឲ្យកាន់តែមានសភាពធ្ងន់ធ្ងរឡើងដោយសារកត្តាផ្សេងទៀតដូចជា ភាពក្រីក្រ អាយុ វណ្ណៈ និន្នាការភេទ ឬជាតិពន្ធុ។ សក្ខីកម្មជាច្រើនដែលបានមកពីការពិគ្រោះយោបល់ថ្នាក់តំបន់រំលេចឡើងថា ការរើសអើងបង្កឡើងដោយកត្តាច្រើនផ្នែកបែបនេះ គឺជាឧបសគ្គសំខាន់មួយ ក្នុងការសម្រេចបានសិទ្ធិមានលំនៅឋានសមរម្យ ដោយសារវាច្រើនតែបណ្តាលឲ្យស្ត្រីរស់នៅក្នុងលំនៅឋានមិនសមរម្យ ឬនៅក្នុងសហគមន៍ដាច់ដោយឡែកដែលមិនមានសេវាមូលដ្ឋានផ្សេងៗដូចជា ទឹកស្អាត អនាម័យ ឬអគ្គីសនី។ ស្ត្រីដែលរស់នៅក្នុងភាពក្រីក្របំផុត ឬនៅក្រោមការត្រួតត្រា ស្ត្រីជនជាតិភាគតិច ឬកុលសម្ព័ន្ធ ស្ត្រីមេម៉ាយ

ស្ត្រីចំណាស់ ស្ត្រីពិការ ស្ត្រីជាកម្មករចំណាកស្រុក ស្ត្រីជាអ្នកធ្វើការតាមផ្ទះ ព្រមទាំងស្ត្រីស្រលាញ់ភេទដូចគ្នា ស្ត្រីស្រលាញ់ភេទទាំងពីរ និងស្ត្រីប្តូរភេទ រឹតតែស្ថិតក្នុងសភាពងាយរងគ្រោះជាពិសេស[27]។

***ការរើសអើងបង្កឡើងដោយកត្តាច្រើនផ្នែក***

គណៈកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានកត់សម្គាល់អំពីសារៈសំខាន់នៃការលើកឡើងអំពីការរើសអើងបង្កឡើងដោយកត្តាច្រើនផ្នែកនៅក្នុងសេចក្តីពន្យល់ទូទៅលេខ ១៦ (២០០៥) ថា៖

*ស្ត្រីជាច្រើនជួបប្រទះទម្រង់ផ្សេងៗនៃការរើសអើង ដោយសារតែកត្តាផ្សេងៗបន្ថែមពីលើភេទ ដូចជា ពូជសាសន៍ ពណ៌សម្បុរ ភាសា សាសនា ទស្សនៈនយោបាយ និងទស្សនៈផ្សេងទៀត ដើមកំណើតជាតិសាសន៍ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬ ស្ថានភាពផ្សេងទៀតដូចជា អាយុ ជាតិពន្ធ ពិការភាព ស្ថានភាពអាពាហ៍ពិពាហ៍ ស្ថានភាពជាជនភៀសខ្លួន ឬ ជនចំណាកស្រុក ដែលបណ្តាលឲ្យកើតមានគុណវិបត្តិកាន់តែធ្ងន់ធ្ងរឡើង (កថាខណ្ឌទី ៥)។*

ការរើសអើងអាចមានទម្រង់ជា ការអភិវឌ្ឍន៍គោលនយោបាយដែលមិនបានដាក់បញ្ចូល កង្វះការគ្រប់គ្រងលើធនធានក្នុងគ្រួសារ កង្វះសុវត្ថិភាពនៃការកាន់កាប់ ឬ ការចូលរួមមានកម្រិតក្នុងការធ្វើការសម្រេចចិត្តលើបញ្ហាលំនៅឋាន និងការរៀបចំសហគមន៍។

***សុវត្ថិភាពនៃការកាន់កាន់ និងការរើសអើងទៅលើស្ត្រី***

ស្ត្រីប្រឈមនឹងការរើសអើងទាក់ទងនឹងសុវត្ថិភាពនៃការកាន់កាប់។ ការកាន់កាប់ដែលជាកត្តាគ្រឹះដ៏សំខាន់នៃសិទ្ធិមានលំនៅឋានសមរម្យ អាចមានទម្រង់ផ្សេងៗគ្នានិងអាចពាក់ព័ន្ធនឹងការស្នាក់អាស្រ័យនៅកន្លែងជួល (ទាំងសាធារណៈ និងឯកជន) ផ្ទះសហករណ៍ កន្លែងជួលរយៈពេលវែង កន្លែងដែលគ្រប់គ្រងដោយម្ចាស់ផ្ទះផ្ទាល់ ផ្ទះសម្រាប់គ្រាអាសន្ន និងតំបន់រស់នៅមិនទាន់រៀបរយ។ ទោះបីជាការកាន់កាប់មានលក្ខណៈផ្លូវការ ឬមិនផ្លូវការក៏ដោយ ក៏ជាញឹកញាប់មានការយល់ ការកត់ត្រា ឬការចុះបញ្ជី ក្នុងនាមសាច់ញាតិជាបុរស ដែលជាការដាក់ស្ត្រីឲ្យពឹងផ្អែកលើទំនាក់ទំនងរបស់ពួកគេជាមួយសាច់ញាតិជាបុរស សម្រាប់

[27] របាយការណ៍បេសកកម្មជាច្រើនរបស់អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមានលំនៅឋានសមរម្យ ពិចារណាអំពីការរើសអើងបង្កឡើងដោយកត្តាច្រើនផ្នែកដោយរាប់បញ្ចូលទាំងរបាយការណ៍ស្តីពីប្រទេសម៉ិចស៊ិច (E/CN.4/2003/5/Add.3), សាធារណរដ្ឋឥស្លាមអ៊ីរ៉ង់ (E/CN.4/2006/41/Add.2) និងប្រទេសអូស្ត្រាលី (A/HRC/4/18/Add.2)។

សុវត្ថិភាពនៃការកាន់កាប់។ ទោះបីជាទម្រង់នៃការកាន់កាប់មានលក្ខណៈសមូហភាពអាចមានបញ្ចូលស្ត្រីក៏ដោយ ក៏ដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្ត ច្រើនតែគ្របដណ្ដប់ដោយបុរស។

ការស្រាវជ្រាវបង្ហាញថា វិធីនីមួយៗនៃការកាន់កាប់ (ទទួលមរតក កម្មសិទ្ធិរួម ការទិញ ឬការផ្ទេរពីរដ្ឋតាមរយៈកម្មវិធីកំណែទម្រង់ដីធ្លី ការជួល ការជួលរយៈពេលវែង ផែនការតាំងទីលំនៅថ្មី ឬ កម្មវិធីប្រឆាំងនឹងភាពក្រីក្រ) មានការលម្អៀងយេនឌ័រ ដូចជា ការមានទំនោរទៅរកបុរសក្នុងការទទួលមរតក បុព្វសិទ្ធិបុរសក្នុងអាពាហ៍ពិពាហ៍ វិសមភាពយេនឌ័រលើទីផ្សារដីធ្លី និងលំនៅឋាន និងការលម្អៀងទៅខាងបុរសក្នុងកម្មវិធីបែងចែកដីធ្លីរបស់រដ្ឋ។

កង្វះខាតការកាន់កាប់ដោយសុវត្ថិភាព អាចមានឥទ្ធិពលធ្ងន់ធ្ងរចំពោះស្ត្រី។ ប្រសិនបើគ្មានការគ្រប់គ្រង ឬមានកម្មសិទ្ធិលើលំនៅឋាន ដីធ្លី ឬទ្រព្យសម្បត្តិទេនោះ ស្ត្រីទទួលបានស្វ័យភាពផ្ទាល់ខ្លួន ឬស្វ័យភាពសេដ្ឋកិច្ចតិចតួចណាស់ ហើយដូច្នេះ ស្ត្រីកាន់តែងាយរងគ្រោះដោយសារការបំពាន និងអំពើហិង្សាក្នុងគ្រួសារ ក្នុងសហគមន៍ និងក្នុងសង្គមទូទៅទៀតផង។ នៅពេលដែលការទទួលបានលំនៅឋាន ដីធ្លី ឬទ្រព្យសម្បត្តិរបស់ស្ត្រី ត្រូវពឹងផ្អែកលើភាគីទីបី ដូចជា ប្ដី បងប្អូនប្រុស ឪពុក ឬ សាច់ញាតិប្រុសផ្សេងទៀតនោះ ស្ត្រីអាចងាយរងគ្រោះទៅនឹងភាពគ្មានផ្ទះសម្បែង ភាពក្រីក្រ និងភាពគ្មានអ្វីសោះ ប្រសិនបើទំនាក់ទំនងនេះត្រូវបញ្ចប់។

នៅក្នុងសង្គមជាច្រើន ប្ដីទទួលបានឋានៈជាមេគ្រួសារដោយស្វ័យប្រវត្តិ ហើយប្រការនេះមានឥទ្ធិពលដល់ការកាន់កាប់ទ្រព្យរួមរបស់ស្ត្រី ក្នុងអំឡុងពេលចំណងអាពាហ៍ពិពាហ៍ ឬ នៅពេលបែកគ្នា ឬ នៅពេលលែងលះ។ នៅពេលមិនមានកម្មសិទ្ធិរួមគ្នា ឬ ការកាន់កាប់ដែលមានសុវត្ថិភាពរួមគ្នាបែបនេះ ស្ត្រីជាច្រើនត្រូវគេបណ្ដេញចេញពីផ្ទះ ឬពីដីធ្លី នៅពេលបែកគ្នា ឬពេលលែងលះ។ នៅពេលដែលស្ត្រីមេម៉ាយ ឬ ស្ត្រីដែលនៅបែកពីគ្នា ឬ ស្ត្រីលែងលះគ្នា បាត់បង់ផ្ទះ ឬ ដីធ្លីនោះ ផលវិបាកមានទៅលើស្ត្រីពេញមួយជីវិត ព្រមទាំងមានទៅលើជីវិតកូនរបស់ស្ត្រីទៀតផង។ នៅទីបំផុត ស្ត្រីនោះអាចនឹងត្រូវរស់នៅក្នុងលំនៅឋានដែលគ្មានសេវាមូលដ្ឋាន ដូចជា ទឹកស្អាត និងអនាម័យ។ ស្ត្រីដែលគ្មានផ្ទះសម្បែង ហើយដែលត្រូវរស់នៅតាមផ្លូវ ឬ ក្នុងទីជម្រក ណាមួយនោះ កាន់តែងាយរងគ្រោះកាន់តែខ្លាំងថែមទៀត ដោយសារអំពើហិង្សា ការបំពាន និងការបៀតបៀន ខណៈពេលដែលសមត្ថភាពរបស់គាត់ក្នុងការថែទាំកូន ធានាការអប់រំដល់កូន សុខភាពកូន សុខមាលភាពរាងកាយ និងផ្លូវចិត្តរបស់កូនអាចបាត់បង់យ៉ាងធ្ងន់ធ្ងរ។ សម្រាប់ស្ត្រីជាច្រើន ការបាត់បង់ផ្ទះ ក៏អាចមានន័យថាជាការបញ្ចប់សុវត្ថិភាពស្បៀង និងសេដ្ឋកិច្ចរបស់ពួកគេដែរ។ វាក៏មានឥទ្ធិពល ដល់ការបញ្ចប់ឋានៈក្នុងសង្គម និងបណ្ដាញសង្គមដែលពួកគេពឹងអាស្រ័យដើម្បីការរស់រានប្រចាំថ្ងៃផងដែរ។ ស្ត្រីតាមជនបទក្នុងទ្វីបអាហ្វ្រិក អាស៊ី ឬ អាមេរិកឡាទីន ដែលបានបាត់បង់ផ្ទះ បន្ទាប់ពីការបែកបាក់ទំនាក់ទំនងជាមួយសាច់ញាតិជាបុរស ដូចជា ការលែងលះ ការបដិសេធ ឬ មរណភាពនោះ ច្រើនតែផ្លាស់មករស់នៅតាមទីក្រុង ដើម្បីរកការងារធ្វើ និងរកផ្ទះសម្រាប់រស់នៅ និងចូលរួមជាមួយគ្រួសារដែលមានស្ត្រីជាមេគ្រួសារដែលមានចំនួនកាន់តែច្រើនឡើង នៅក្នុងតំបន់ក្រីក្រតាមទីប្រជុំជន។ តួរលេខអំពីភាពក្រីក្រនៅតាមតំបន់ទីក្រុងក្នុងទ្វីបអាហ្វ្រិកបង្ហាញថា ស្ត្រីនិងកុមារទទួលរងបន្ទុកនៃការដកហូតគ្រប់បែបយ៉ាង។

*ប្រភព៖* គណៈកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សេចក្ដីពន្យល់ទូទៅលេខ ៤ (២០០៥) កម្មវិធីលំនៅឋានមនុស្សជាតិរបស់អង្គការសហប្រជាជាតិ (UN-Habitat) ជម្រើសនៃការកាន់កាប់រួមសម្រាប់ស្ត្រី៖ ទិដ្ឋភាពសកល (ទីក្រុងណៃរ៉ូប៊ី ខែកក្កដា ឆ្នាំ២០០៥) ទំព័រទី V និងក្រុមការងារគម្រោងសហសវត្សស្តីពីការអប់រំនិងសមភាពយេនឌ័រ ការចាត់វិធានការ ទំព័រទី ៧៩។

ការរើសអើងទៅលើស្ត្រី អាចបណ្ដាលមកពីច្បាប់ដែលមានលក្ខណៈរើសអើង ច្បាប់ និងគោលនយោបាយដែលមានលក្ខណៈអព្យាក្រឹត្យយេនឌ័រ ដែលខកខានមិនបានពិចារណាកាលៈទេសៈជាក់លាក់របស់ស្ត្រី ឥទ្ធិពលលើសលុបនៃច្បាប់និងការអនុវត្តតាមបែបទំនៀមទម្លាប់ ភាពលំអៀងខាងផ្នែកតុលាការ និងរដ្ឋបាលសាធារណៈ កង្វះខាតការទទួលបានដំណោះស្រាយ ព័ត៌មាន និងដំណើរការសម្រេចចិត្ត កង្វះការយល់ដឹងអំពីសិទ្ធិ។ ការរើសអើងនេះក៏មានការទ្រទ្រង់ពីកត្តាប្រវត្តិសាស្ត្រ និងរចនាសម្ព័ន្ធផងដែរ។ ការរើសអើងដែលមិនអនុញ្ញាតឲ្យមាននេះ មិនមែនត្រឹមតែជាការរំលោភបំពានស្ដង់ដារសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែ លទ្ធផលដែលកើតចេញពីការរើសអើងនេះ គឺស្ត្រីត្រូវជួបប្រទះនូវការរំលោភបំពានដោយភាពមិនសមាមាត្រ នូវសិទ្ធិមានលំនៅឋានសមរម្យ និងសិទ្ធិមនុស្សជាមូលដ្ឋានផ្សេងទៀតដែរ។

## ក. ច្បាប់ដែលមានលក្ខណៈរើសអើង

ស្ថានភាពខូចខាតប្រយោជន៍របស់ស្ត្រីដោយប្រៀបធៀប ទាក់ទងនឹងសិទ្ធិមានលំនៅឋានសមរម្យ អាចបណ្ដាលមកពីច្បាប់ ដែលរើសអើងដោយផ្ទាល់ទៅលើពួកគេ។

## ១. បញ្ញត្តិក្នុងរដ្ឋធម្មនុញ្ញដែលមានការរើសអើង

ទោះបីជារដ្ឋធម្មនុញ្ញដែលទទួលស្គាល់សិទ្ធិស្មើភាពគ្នា និងគោលការណ៍មិនរើសអើង មានចំនួនកើនឡើងក៏ដោយ ក៏រដ្ឋធម្មនុញ្ញមួយចំនួន នៅតែខកខានមិនទាន់បានធានាគោលការណ៍មូលដ្ឋានបំផុតនៃច្បាប់សិទ្ធិមនុស្សនៅឡើយទេ។ ជាងនេះទៀត ទោះបីជាសិទ្ធិមានលំនៅឋានសមរម្យអាចត្រូវបានទទួលស្គាល់ក្នុងរដ្ឋធម្មនុញ្ញក៏ដោយ ក៏កង្វះខាត ឬការនៅមានកម្រិតនៃគោលការណ៍មិនរើសអើងនិងសមភាពនេះ ជាញឹកញាប់ អាចនៅតែរាំងស្ត្រីពីការប្រើប្រាស់សិទ្ធិរបស់ពួកគេក្នុងការមានលំនៅឋានសមរម្យនេះដោយស្មើភាពគ្នាជាមួយបុរសដដែលដែរ។

*រដ្ឋធម្មនុញ្ញប្រទេស អេត្យូពី៖ សិទ្ធិស្មើភាពគ្នារបស់ស្ត្រី*

មាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញប្រទេសអេត្យូពី ធានាសិទ្ធិស្ត្រីស្មើភាពគ្នាជាមួយនឹងបុរស។ រដ្ឋធម្មនុញ្ញនេះបានចែងបន្ថែមទៀតថា៖

> *ស្ត្រីមានសិទ្ធិទទួលបាន គ្រប់គ្រង កាន់កាប់ ប្រើប្រាស់ និងផ្ទេរទ្រព្យសម្បត្តិ។ ជាពិសេស ស្ត្រីមានសិទ្ធិស្មើភាពគ្នាជាមួយបុរស ទាក់ទងនឹងការប្រើប្រាស់ ការផ្ទេរ ការគ្រប់គ្រង និងកាន់កាប់ដីធ្លី។ ស្ត្រីក៏ត្រូវទទួលបានការប្រព្រឹត្តស្មើភាពគ្នាក្នុងការទទួលមរតកទ្រព្យសម្បត្តិផងដែរ។*

រដ្ឋធម្មនុញ្ញមួយចំនួនចែងថា បញ្ញត្តិច្បាប់អំពីការមិនរើសអើង និងសមភាព ត្រូវផ្អែកទៅលើច្បាប់និងការអនុវត្តបែបតាមទំនៀមទម្លាប់ ដែលនេះជាការរើសអើងលើស្ត្រី ជាពិសេសទាក់ទងនឹងលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ។ ទាក់ទងនឹងបញ្ហានេះ ប្រទេសអ៊ូហ្គង់ដា ជាប្រទេសមួយក្នុងចំណោមប្រទេសតិចតួចបំផុតក្នុងទ្វីបអាហ្វ្រិកដែលរដ្ឋធម្មនុញ្ញបានហាមឃាត់ជាពិសេសការរើសអើងក្រោមច្បាប់ទំនៀមទម្លាប់។

រដ្ឋធម្មនុញ្ញផ្សេងទៀត មិនបានដាក់បញ្ចូលបញ្ហាទាំងឡាយទាក់ទងនឹងផ្នែកឯកជន និងបុគ្គលទេ រួមមានអាពាហ៍ពិពាហ៍ ការលែងលះ ឬ ការផ្ទេរទ្រព្យសម្បត្តិ នៅពេលមានមរណភាព ដើម្បីឲ្យទទួលបានការការពារដោយបញ្ញត្តិច្បាប់ដែលកំណត់អំពីការមិនរើសអើង និងសមភាព។ ការលើកលែងបែបនេះ ច្រើនតែធ្វើឲ្យខូចផលប្រយោជន៍ និងការគ្រប់គ្រងកាន់កាប់របស់ស្ត្រីលើលំនៅឋាន ដី និងទ្រព្យសម្បត្តិ។

## ២. បញ្ញត្តិដែលមានលក្ខណៈរើសអើងក្នុងច្បាប់ជាក់លាក់

ច្បាប់ជាតិ (ឧទាហរណ៍ ក្រមស្តីពីគ្រួសារ ក្រមរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ច្បាប់ភូមិបាល ច្បាប់ស្តីពីកម្មសិទ្ធិ ឬ ទ្រព្យសម្បត្តិ ច្បាប់ស្តីពីលទ្ធកម្ម ច្បាប់ចុះបញ្ជីកម្មសិទ្ធិ ឬច្បាប់ស្តីពីការទទួលមរតក) អាចមានការរើសអើងទៅលើស្ត្រី។

ទោះបីជាសមភាព និងការមិនរើសអើង អាចត្រូវបានធានានៅក្នុងរដ្ឋធម្មនុញ្ញក៏ដោយ ក៏ច្បាប់ជាក់លាក់មួយចំនួន អាចមានចែងពីបញ្ញត្តិដែលមានលក្ខណៈរើសអើង ហើយនេះក៏ជាការរឹតត្បិតដល់ការការពារដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញផងដែរ។ ច្បាប់ដែលដោះស្រាយបញ្ហាទ្រព្យសម្បត្តិទទួលបានក្នុងអាពាហ៍ពិពាហ៍ ការចុះបញ្ជីកម្មសិទ្ធិ ការសម្អាតតំបន់ក្រីក្រតាមទីប្រជុំជន ការទទួលមរតក អំពើហិង្សាទៅលើស្ត្រី ឬលំនៅឋានសម្រាប់ជួល សុទ្ធតែមានសារៈសំខាន់ជាពិសេសសម្រាប់ស្ត្រី និងអាចមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើសិទ្ធិមានលំនៅឋានសមរម្យរបស់ស្ត្រី។ ក្នុងប្រទេសមួយចំនួន ការទទួលបាននិងការគ្រប់គ្រងកាន់កាប់លំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិសម្រាប់ស្ត្រី ត្រូវបានរឹតត្បិតដោយសារច្បាប់ដែលមានការហាមឃាត់ការចុះបញ្ជីកម្មសិទ្ធិដីធ្លីដាក់ឈ្មោះរបស់ស្ត្រី ប្រសិនបើស្ត្រីនោះរៀបការមានទ្រព្យសម្បត្តិរួម ឬហាមឃាត់ដោយច្បាប់ដែលចាត់ទុកស្ត្រីរៀបការរួចជាអនីតិជនតាមផ្លូវច្បាប់។

ច្បាប់ស្តីពីគ្រួសារ និងអាពាហ៍ពិពាហ៍ ច្រើនតែផ្តល់អំណាចអាពាហ៍ពិពាហ៍ ឬឋានៈជាមេគ្រួសារផ្ទេរការឲ្យទៅបុរស ដែលនេះមានន័យថាជាការផ្តល់អំណាចគ្រប់គ្រងកាន់កាប់ លើទ្រព្យសម្បត្តិក្នុងអាពាហ៍ពិពាហ៍ដល់បុរស។ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍អាចមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើសមត្ថភាពរបស់ស្ត្រីក្នុងការសម្រេចបានសិទ្ធិមានលំនៅឋានសមរម្យ ជាពិសេស នៅពេលរស់នៅបែកពីគ្នា លែងលះ ឬ ទទួលមរតក។ នៅពេលដែលច្បាប់ស្តីពីអាពាហ៍ពិពាហ៍ ខកខានមិនបានទទួលស្គាល់ទម្រង់នៃអាពាហ៍ពិពាហ៍បែបប្រពៃណី ឬសាសនានោះ ស្ត្រីដែលរៀបការក្នុងលក្ខខណ្ឌទាំងនេះ នឹងមិនអាចទទួលបានផលប្រយោជន៍ពីការការពារដែលមានចែងក្នុងច្បាប់នោះទេ។ ស្ត្រីក្នុងអាពាហ៍ពិពាហ៍ពហុពន្ធភាព អាចទទួលរងផលប៉ះពាល់នៃការមិន

ទទួលស្គាល់នេះ ពោលគឺក្នុងស្ថានភាពភាគច្រើន ប្រពន្ធទីពីរ និងទីបី ត្រូវបានដកចេញពីច្បាប់ស្តីពីអាពាហ៍ពិពាហ៍ ហើយជាលទ្ធផល ពួកគេមិនអាចទទួលបានផ្ទះ ដីធ្លី ឬ ទ្រព្យសម្បត្តិរបស់ប្តីពួកគេឡើយ។

***ច្បាប់ដែលការពារសិទ្ធិស្ត្រីក្នុងការមានលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ***

ច្បាប់សមភាពសម្រាប់បុគ្គលក្នុងអាពាហ៍ពិពាហ៍ឆ្នាំ១៩៩៦ របស់ប្រទេសណាមីប៊ី ចែងថា ប្តីនិងប្រពន្ធដែលបានរៀបការដោយមានទ្រព្យរួម មានសមត្ថភាពស្មើគ្នាក្នុងការចាត់ចែង និងគ្រប់គ្រងអចលនទ្រព្យរួមគ្នា។ ជាទូទៅ ច្បាប់នេះចែងអំពីសមភាពរវាងប្តីប្រពន្ធ ក្នុងការចាត់ចែងផ្នែកហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិប្តីប្រពន្ធ។

ច្បាប់ភូមិបាល ឆ្នាំ១៩៩៩ របស់សាធារណរដ្ឋតង់ហ្សានី ចែងអំពីកម្មសិទ្ធិរួម ហើយដីធ្លីដែលគ្រប់គ្រងដោយប្តីប្រពន្ធទាំងពីរ ត្រូវសន្មត់ថា បានចុះបញ្ជីរួមគ្នា លើកលែងតែមានការបញ្ជាក់ផ្ទុយពីនេះដោយសហព័ទ្ធទាំងពីរ។

ក្រោមក្រមរដ្ឋប្បវេណីថ្មីរបស់ប្រទេសទួរគី សហព័ទ្ធទាំងពីរជាដៃគូស្មើគ្នា ដែលត្រូវរៀបចំចាត់ចែងចំណងអាពាហ៍ពិពាហ៍ ដោយមានអំណាចធ្វើការសម្រេចចិត្តស្មើភាពគ្នា មានសិទ្ធិស្មើគ្នាលើលំនៅឋានគ្រួសារ និងទ្រព្យសម្បត្តិគ្រួសារ ដែលទទួលបានក្នុងអាពាហ៍ពិពាហ៍។

ច្បាប់ស្តីពី អាពាហ៍ពិពាហ៍និងគ្រួសារ ឆ្នាំ១៩៨៩ របស់ប្រទេសកម្ពុជា ចែងអំពីសិទ្ធិកម្មសិទ្ធិស្មើភាពគ្នារបស់សហព័ទ្ធ។ ទ្រព្យសម្បត្តិដែលទទួលបានក្នុងអាពាហ៍ពិពាហ៍ជាកម្មសិទ្ធិរបស់ទាំងប្តីនិងទាំងប្រពន្ធ ហើយ ត្រូវចែកគ្នាប្រសិនបើពួកគេលែងលះ។

ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ ឆ្នាំ២០០៧ របស់ប្រទេសសេរ៉ាឡេអូន (ច្បាប់ស្តីពីការចុះបញ្ជីអាពាហ៍ពិពាហ៍តាមលក្ខណៈប្រពៃណី និងការលែងលះ ឆ្នាំ២០០៧) តម្រូវឲ្យមានការចុះបញ្ជីចំពោះការរៀបអាពាហ៍ពិពាហ៍តាមបែបប្រពៃណីនិងការលែងលះ។ ច្បាប់នេះក៏បានផ្តល់សិទ្ធិឲ្យប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍តាមលក្ខណៈប្រពៃណីក្នុងការទទួលបាននិងចាត់ចែងទ្រព្យសម្បត្តិ។

***ដំណោះស្រាយចំពោះច្បាប់ដែលមានការរើសអើងក្នុងប្រទេសនេប៉ាល់***

ក្នុងឆ្នាំ១៩៩៣ សកម្មជនស្ត្រី បានដាក់ពាក្យបណ្តឹងនៅចំពោះមុខតុលាការកំពូល ជំទាស់ទៅនឹងច្បាប់មួយដែលចែងថា កូនស្រីត្រូវតែជាកូនដែលមិនទាន់រៀបការ និងមានអាយុលើស ៣៥ ឆ្នាំ ដើម្បីអាចទទួលបានចំណែកនៃទ្រព្យសម្បត្តិរបស់ឪពុកម្តាយ។ នៅក្នុងការសម្រេចចិត្តនោះ តុលាការកំពូលបានប្រកាសថាច្បាប់នោះមានលក្ខណៈរើសអើង និងបានស្នើឲ្យអង្គនិតិបញ្ញត្តិរៀបចំនូវសេចក្តីព្រាងច្បាប់សមស្របមួយដើម្បីនិរាករណ៍ច្បាប់នោះ។ ក្នុងឆ្នាំ២០០២ អង្គនិតិបញ្ញត្តិបាននិរាករណ៍ច្បាប់នេះ ដោយបានអនុម័តច្បាប់វិសោធនកម្មលើកទី១១ ចំពោះក្រមរបស់ប្រទេសនេះក្នុងឆ្នាំ១៩៦៣។ វិសោធនកម្មនេះធ្វើឲ្យមានការទទួលស្គាល់សិទ្ធិទទួលមរតកស្មើភាពគ្នាសម្រាប់កូនស្រី (តាំងពីកំណើត) និងស្ត្រីមេម៉ាយ។

***ច្បាប់ប្រឆាំងការរើសអើងដែលដោះស្រាយជាពិសេសចំពោះការរើសអើងក្នុងបញ្ហាលំនៅឋាន***

ក្រុមសិទ្ធិមនុស្សរបស់ខេត្តអនតារីយ៉ូ នៃប្រទេសកាណាដា មានច្បាប់ដ៏ទូលំទូលាយបំផុតមួយក្នុងចំណោមច្បាប់នានា ដើម្បីការពារអ្នករស់នៅឲ្យរួចផុតពីការអនុវត្តដែលមានលក្ខណៈរើសអើង។ ច្បាប់នេះមិនត្រឹមតែការពារបុគ្គលឲ្យរួចផុតពីការរើសអើងដែលបានហាមឃាត់យ៉ាងច្បាស់ដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដូចជា ដោយសារហេតុផល ពូជសាសន៍ ភេទ ឬ សាសនា នោះទេ ហើយច្បាប់នេះថែមទាំងហាមឃាត់ការរើសអើងដែលផ្អែកលើមូលដ្ឋានទំនោរខាងផ្លូវភេទ ស្ថានភាពអាពាហ៍ពិពាហ៍ ឬស្ថានភាពគ្រួសារទៀតផង។

*បុគ្គលគ្រប់រូប មានសិទ្ធិទទួលបានការប្រព្រឹត្តដោយស្មើភាពគ្នា ទាក់ទងនឹងការកាន់កាប់ទីស្នាក់អាស្រ័យដោយគ្មានការរើសអើងដោយសារមូលហេតុ ពូជសាសន៍ ដើមកំណើតគ្រួសារ ទីកន្លែងកំណើត ពណ៌សម្បុរ ដើមកំណើតជាតិពន្ធុ សញ្ជាតិ ជំនឿ ភេទ ស្ថានភាពអាពាហ៍ពិពាហ៍ ស្ថានភាពគ្រួសារ ពិការភាព ឬ ការទទួលបានជំនួយសាធារណៈនោះទេ (ផ្នែកទី ២(១))។*

*បុគ្គលគ្រប់រូបដែលកាន់កាប់លើទីស្នាក់អាស្រ័យ មានសិទ្ធិទទួលបានសេរីភាពរួចផុតពីការធ្វើទុក្ខបុកម្នេញពីម្ចាស់ផ្ទះ ឬម្ចាស់ដី ឬពីភ្នាក់ងាររបស់ម្ចាស់ផ្ទះ ឬម្ចាស់ដី ឬ ដោយអ្នកកាន់កាប់ណាមួយក្នុងអាគារតែមួយ ដោយសារតែពូជសាសន៍ ដើមកំណើតគ្រួសារ ទីកន្លែងកំណើត ពណ៌សម្បុរ ដើមកំណើតជាតិពន្ធុ សញ្ជាតិ ជំនឿ ភេទ ស្ថានភាពអាពាហ៍ពិពាហ៍ ស្ថានភាពគ្រួសារ ពិការភាព ឬ ការទទួលបានជំនួយសាធារណៈនោះទេ (ផ្នែកទី ២(២))។*

## ខ. ច្បាប់ និងគោលនយោបាយដែលមិនបានពិចារណាអំពីកាលៈទេសៈជាក់លាក់របស់ស្ត្រី

ខណៈពេលដែលការរើសអើងអាចជាលទ្ធផលនៃការខកខានមិនបានអនុម័តច្បាប់ និងគោលនយោបាយនោះ ច្បាប់និងគោលនយោបាយដែលផ្តល់សិទ្ធិស្មើគ្នាដល់ស្ត្រីក្នុងបញ្ហាលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិក៏អាចរើសអើងទៅលើស្ត្រីដែរ ប្រសិនបើច្បាប់ និងគោលនយោបាយទាំងនោះ ខកខានមិនបានទទួលស្គាល់កាលៈទេសៈជាក់លាក់របស់ស្ត្រី ឬដោះស្រាយស្ថានភាពខ្វះឱកាសរបស់ស្ត្រី។ នៅក្នុងប្រទេសភាគច្រើន ច្បាប់និងគោលនយោបាយកំណត់ពីបញ្ហាលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ មានលក្ខណៈអព្យាក្រឹត្យយេនឌ័រយ៉ាងច្បាស់ ហេតុដូច្នេះហើយ នេះជាការខកខានមិនបានដោះស្រាយការរើសអើងក្នុងការអនុវត្តជាក់ស្តែងដែលស្ត្រីប្រឈមក្នុងវិស័យទាំងនេះ។

ឧទាហរណ៍ ខណៈពេលដែលច្បាប់ក្នុងប្រទេសជាច្រើនចែងអំពីសហកម្មសិទ្ធិលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ សហព័ទ្ធទាំងពីរត្រូវយល់ព្រមទៅវិញទៅមកចំពោះបញ្ហានេះ ហើយចាត់វិធានការយ៉ាងសកម្មក្នុងការចុះបញ្ជីជាសហកម្មសិទ្ធិ។ ក្នុងការអនុវត្តជាក់ស្តែង មានតែមួយផ្នែកតូចនៃសង្គម ដែលជាទូទៅជាអ្នកដែលបានទទួលការអប់រំច្រើន ដែលរស់នៅតំបន់ទីក្រុង និងមានទ្រព្យសម្បត្តិប៉ុណ្ណោះ ដែលបានធ្វើរឿងនេះ។ ភាគច្រើន ស្ត្រីកម្រទទួលបានកម្មសិទ្ធិនេះណាស់។ ទោះបីជាមានការផ្តល់កម្មសិទ្ធិរួមគ្នាដល់ស្ត្រីក៏

ដោយ ក៏ស្ត្រីនៅតែមានការលំបាកក្នុងការទទួលបានការគ្រប់គ្រងលើទ្រព្យទាំងនោះ ឬ មានការពិបាកក្នុងការចាត់ចែងដីធ្លី ឬផ្ទះសម្បែងតាមដែលពួកគេប្រាថ្នា ឬ មានការពិបាកក្នុងការអះអាងអំពីចំណែករបស់ខ្លួនក្នុងករណីមានជម្លោះក្នុងអាពាហ៍ពិពាហ៍ណាស់។ ជាញឹកញាប់បំផុត ច្បាប់ដែលតម្រូវថា ផ្ទះដែលត្រូវចុះបញ្ជី ត្រូវដាក់តែឈ្មោះរបស់ "មេគ្រួសារ" នោះ ទំនងជានឹងដកស្ត្រីចេញបាត់ទៅហើយ ដោយសារថាពាក្យ "មេគ្រួសារ" នេះត្រូវបានកំណត់ដោយមើលឃើញច្បាស់ និងដោយប្រយោលថា ជាការសំដៅទៅលើបុរស។ ក្នុងការធ្វើសេចក្តីសន្និដ្ឋានអំពីប្រទេសស្រីលង្កា គណៈកម្មាធិការទទួលបន្ទុកលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី បានកត់សម្គាល់ថា "ការអនុវត្តដោយរើសអើង រារាំងស្ត្រីមិនឲ្យទទួលបានកម្មសិទ្ធិលើដីធ្លី ដោយសារមានតែ "មេគ្រួសារ" ដែលត្រូវគេផ្តល់សិទ្ធិឲ្យចុះហត្ថលេខាលើឯកសារផ្លូវការ ដូចជា វិញ្ញាបនបត្រកម្មសិទ្ធិដីធ្លី និងផ្តល់សិទ្ធិឲ្យទទួលបានដីពីរដ្ឋាភិបាល" ហើយគណៈកម្មាធិការបានផ្តល់អនុសាសន៍ថា រដ្ឋភាគីគួរ "លុបបំបាត់បញ្ញត្តិអំពី "មេគ្រួសារ" នេះចេញពីក្នុងការអនុវត្តរដ្ឋបាល និងទទួលស្គាល់កម្មសិទ្ធិរួមគ្នាទៅលើដី"[28]។

ម្តាយទោល ក៏អាចប្រឈមនឹងស្ថានភាពមួយដែលគ្រួសាររបស់ពួកគេមិនត្រូវបានទទួលស្គាល់ដោយរដ្ឋ ហើយវាបណ្តាលឲ្យម្តាយទោល និងស្ត្រីដែលនៅលីវ ត្រូវគេដកចេញពីកម្មវិធីលំនៅឋាន។

គោលនយោបាយដែលធ្វើឡើងសម្រាប់ផលប្រយោជន៍របស់ស្ត្រី ដូចជាការបែងចែកដីដល់ពួកគេ អាចទទួលបរាជ័យ ប្រសិនបើគេរំពឹងថាស្ត្រីត្រូវផ្តល់របស់បញ្ចាំ ឬ លុយច្រើនជាមុននោះ។ ស្រដៀងគ្នានេះដែរ ឧទាហរណ៍ បញ្ញត្តិអំពីការរក្សាទុកភាគរយលំនៅឋានមួយចំនួនសម្រាប់ស្ត្រី មិនអាចអនុវត្តបាននោះទេ ប្រសិនបើមិនមានបញ្ញត្តិណាមួយចែងអំពីការទទួលបានឥណទានទេនោះ។

ការរើសអើងយេនឌ័រ គួបផ្សំជាមួយប្រាក់ចំណូលទាប និងភាពគ្មានការងារធ្វើ អាចធ្វើឲ្យស្ត្រីមានការលំបាកក្នុងការទទួលបានឥណទានដោយឯករាជ្យ ជាពិសេស នៅពេលដែលស្ត្រីនៅផ្ទះមើលថែទាំកូន។ សម្រាប់ស្ត្រីជាច្រើន ការទទួលបានឥណទាន អាស្រ័យទៅលើការយល់ព្រមពីប្តី។ ដោយសារតែភាពមិនស្មើគ្នាក្នុងការទទួលបានសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ ស្ត្រីច្រើនតែខ្វះរបស់បញ្ចាំដើម្បីទទួលបានឥណទាន។ ក្នុងប្រទេសមួយចំនួន ការទទួលបានហិរញ្ញវត្ថុ អាចមានការលំបាកសម្រាប់អ្នកមានចំណូលទាប អ្នកមិនមានការងារក្នុងប្រព័ន្ធ ឬ អ្នកដែលមានប្រវត្តិឥណទានអវិជ្ជមានពីមុនមក។ កត្តាទាំងនេះ អាចរឹតត្បិតដល់ការទទួលបានកម្ចីសម្រាប់ទិញផ្ទះ ដោយសារតែពួកគេមានប្រាក់ចំណូលទាប ឬ ពួកគេនៅផ្ទះចិញ្ចឹមកូននោះ។

បទបញ្ញា មិនគ្រប់គ្រាន់របស់រដ្ឋាភិបាលដែលគ្រប់គ្រងលើការទទួលបាន ការប្រើប្រាស់ និងភាពអាចលៃលកបានទាក់ទងនឹងលំនៅឋាន ក៏ទំនងជាមានផលប៉ះពាល់ទៅលើស្ត្រីដែលងាយរងគ្រោះ (ដូចជាស្ត្រីពិការ ម្តាយទោលដែលរស់នៅក្នុងភាពក្រីក្រ ឬស្ត្រីមេម៉ាយ) ដែលមិនមានការទទួលបានដោយស្មើភាពគ្នាទៅលើ ការងារ ព័ត៌មាន និងធនធានផ្សេងទៀត។ បុគ្គលដែលទទួលផលប្រយោជន៍សុខុមាលភាព ក៏អាចត្រូវគេរើសអើងចំពោះការជួលជាឯកជន ដោយគេលើកយកហេតុផល "ប្រភពនៃប្រាក់ចំណូល" សម្រាប់បដិសេធការសុំជួលនោះ។ ដោយសារតែស្ត្រីពឹងផ្អែកទៅលើប្រព័ន្ធសុខុមាលភាពច្រើនជាងបុរស ជាពិសេស

---

[28] CEDAW/C/LKA/CO/7 កថាខណ្ឌទី ៣៨ ដល់ ៣៩។

ស្ត្រីមេម៉ាយ និងស្ត្រីលែងលះ និងស្ត្រីនៅលីវនោះ ស្ត្រីទាំងនេះច្រើនត្រូវបានគេបដិសេធ ដោយសារតែស្លាកស្នាមទុរសយសទាក់ទងនឹងការទទួលបានផលប្រយោជន៍ពីប្រព័ន្ធសុខុមាលភាព។

## គ. ច្បាប់និងការអនុវត្តតាមតាមទំនៀមទម្លាប់ ដែលមានការរើសអើង[29]

សូម្បីតែនៅកន្លែងដែលច្បាប់ ឬគោលនយោបាយរដ្ឋមិនរើសអើងស្ត្រីក៏ដោយ ក៏ច្បាប់ ឬការអនុវត្តតាមទំនៀមទម្លាប់អាចនៅមានការរើសអើងដែរ។ ក្នុងកិច្ចការងាររបស់គាត់ស្តីពីស្ត្រី និងសិទ្ធិមានលំនៅឋានសមរម្យ អ្នករាយការណ៍ពិសេសទីមួយ បានរំលេចអំពីភាពរីករាលដាលនៃច្បាប់ ឬ ការអនុវត្តតាមលក្ខណៈប្រពៃណី ដែលបដិសេធសិទ្ធិស្ត្រីក្នុងការមានលំនៅឋានសមរម្យ។ ទង្វើនេះជះឥទ្ធិពលជាពិសេសទៅលើសិទ្ធិកាន់កាប់ ការទទួលមរតក ការគ្រប់គ្រងការចំណាយក្នុងគ្រួសារ និងការទទួលបានហិរញ្ញប្បទានដើម្បីទទួលបានលំនៅឋាន និងការទទួលបានដំណោះស្រាយ។

ខណៈពេលដែលច្បាប់ ឬការអនុវត្តបែបទំនៀមទម្លាប់មួយចំនួន ផ្តោតទៅលើកម្មសិទ្ធិសមូហភាពលើទ្រព្យសម្បត្តិ ដែលក្នុងនោះជានាសិទ្ធិស្ត្រីក្នុងការទទួលបានធនធានរួម មានរាប់ទាំងដីធ្លីផង ប៉ុន្តែឥទ្ធិពលនៃអាណានិគម ប្រព័ន្ធកាន់កាប់ដីធ្លីជាលក្ខណៈបុគ្គល និងសម្ពាធនានាលើទីផ្សារដីធ្លី បានធ្វើឲ្យចុះខ្សោយ និងបានកែប្រែការជានាទាំងនេះ និងទម្រង់នៃសាមគ្គីភាពដែលមាន។

ច្បាប់ និងការអនុវត្តតាមបែបទំនៀមទម្លាប់ ភាគច្រើនមិនមានសរសេរជាលាយលក្ខណ៍អក្សរនោះទេ ហើយមានការផ្លាស់ប្តូរជាប្រចាំ។ ច្បាប់និងការអនុវត្តបែបទំនៀមទម្លាប់ទាំងនេះ កើតមានស្របនឹងច្បាប់រដ្ឋ ហើយភាពស្របច្បាប់កើតចេញមកពីប្រពៃណី វប្បធម៌ ទំនៀមទម្លាប់ ឬសាសនា។ ច្បាប់និងការអនុវត្តបែបទំនៀមទម្លាប់ដែលមានជាទូទៅ ជាពិសេសនៅក្នុងតំបន់ជនបទ បានកំណត់ និងជះឥទ្ធិពលទៅលើបញ្ហាបុគ្គល និងបញ្ហាគ្រួសារ ព្រមទាំងកំណត់ឋានៈរបស់ស្ត្រីនៅក្នុងសង្គម។ ទោះបីជាគេកម្រធ្វើឲ្យទៅជាច្បាប់ក៏ដោយ ក៏ការអនុវត្តទាំងនោះបានគ្រប់គ្រងលើបញ្ហាលំនៅឋាន ការកាន់កាប់ដីធ្លី និងការផ្ទេរកម្មសិទ្ធិដែរ។ ការអនុវត្តភាគច្រើន បានធ្វើឲ្យការទទួលបានលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិរបស់ស្ត្រីត្រូវពឹងផ្អែកទៅលើទំនាក់ទំនងរបស់ពួកគេជាមួយបុរស ជាធម្មតាជាមួយឪពុក បងប្អូនប្រុស ឬ ប្តី តាមវិធីផ្សេងៗគ្នាជាច្រើន។ ប្រការនេះជាញឹកញាប់ បានបង្ខំឲ្យស្ត្រីត្រូវរក្សាទំនាក់ទំនងជាមួយសាច់ញាតិជាបុរសរបស់ខ្លួន ដោយមិនគិតថាការធ្វើបែបនេះមានផលប៉ះពាល់ទៅលើរាងកាយ អារម្មណ៍ និងផ្លូវចិត្តយ៉ាងណានោះទេ។ ជាទូទៅ ស្ត្រីមានឋានៈទាបបែបនេះរួចទៅហើយ ក្នុងប្រទេសជាច្រើន ដែលច្បាប់ ឬការអនុវត្តតាមបែបទំនៀមទម្លាប់នេះ មានការអនុវត្តធ្វើឲ្យបាត់បង់លំនៅឋាន និងស្ថិរភាពសង្គមសេដ្ឋកិច្ចរបស់ពួកគេ ដែលអាចបំផ្លាញដល់ពួកគេ។

*ប្រទេសអាហ្វ្រិកខាងត្បូង៖ ការការពារទំនៀមទម្លាប់ដោយរដ្ឋធម្មនុញ្ញដែលត្រូវតែស្របតាមគោលការណ៍សមភាព និងការមិនរើសអើង*

[29] វាក្យសព្ទដែលប្រើពេញក្នុងផ្នែកនេះសំដៅដល់ ច្បាប់ និងការអនុវត្តតាមលក្ខណៈទំនៀមទម្លាប់។ ពាក្យនេះរួមបញ្ចូលទាំងច្បាប់ និងការអនុវត្តតាមសាសនា ក៏ដូចជាការអនុវត្តតាមបែបវប្បធម៌ និងប្រពៃណី ដែលជះឥទ្ធិពលទៅលើស្ត្រី។

ទោះបីជារដ្ឋធម្មនុញ្ញប្រទេសអាហ្វ្រិកខាងត្បូង តម្រូវឲ្យគោរពតាមកេរ្តិ៍ដំណែលច្បាប់ប្រពៃណីអាហ្វ្រិកក៏ដោយ ក៏រដ្ឋធម្មនុញ្ញចែងថា ការគោរពនេះមិនសំខាន់ដូចសិទ្ធិទទួលបានការប្រព្រឹត្តដោយស្មើភាពគ្នានោះទេ (មាត្រា ៧ មាត្រា ៩ មាត្រា ៣១ មាត្រា ៣៦ និង មាត្រា ២១១)។

នៅពេលដែលច្បាប់ ឬការអនុវត្តតាមទំនៀមទម្លាប់មានមូលដ្ឋានផ្អែកលើសាសនា បញ្ហាទាំងឡាយអំពីឋានៈបុគ្គលរបស់ស្ត្រី ដោយរាប់បញ្ចូលទាំងបញ្ហាទាក់ទងនឹង អាពាហ៍ពិពាហ៍ ការលែងលះ ឬការទទួលមរតកនោះ ជាបញ្ហារសើប និងជាប្រធានបទហាមឃាត់ពីការនិយាយ។ សក្ខីកម្មដែលបានមកពីស្ត្រីក្នុងតំបន់មួយចំនួន ដែលច្បាប់ ឬការអនុវត្តតាមទំនៀមទម្លាប់ មានការរីកសាយភាយនោះ បានរំលេចនូវផលប៉ះពាល់នៃ "វប្បធម៌នៅស្ងៀមមិននិយាយស្តី" ដែលមានជាប់ទាក់ទងនឹងបញ្ហាលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិរបស់ស្ត្រី។

***វប្បធម៌ និងប្រពៃណី ទល់នឹងសិទ្ធិស្ត្រី***

មាននិន្នាការមួយក្នុងការចាត់ទុកច្បាប់ ឬការអនុវត្តតាមបែបទំនៀមទម្លាប់ ដែលរើសអើងទៅលើស្ត្រីនេះថាជាវប្បធម៌ ហើយបានតវ៉ាថា ការអនុវត្តទាំងនេះស្ថិតនៅក្នុងបញ្ញត្តិអំពីការការពារសិទ្ធិខាងការសម្តែងពីវប្បធម៌ ជំនឿ ឬ សាសនារបស់មនុស្ស។

ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ផ្តល់គោលការណ៍ណែនាំអំពីរបៀបដោះស្រាយជម្លោះដែលអាចកើតមានឡើងរវាងវប្បធម៌ ឬសាសនា ជាមួយនឹងសិទ្ធិមនុស្ស។ មាត្រា ៥(ក) នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី តម្រូវឲ្យរដ្ឋ "កែប្រែផ្នត់គំនិតសង្គម និងវប្បធម៌បុរស និងស្ត្រី ដើម្បីសម្រេចបាននូវការលុបបំបាត់ចោល សេចក្តីលំអៀង និងទម្លាប់ និងការអនុវត្តជាទម្លាប់ផ្សេងៗទៀតដែលផ្អែកលើគំនិតស្តីពីភាពអន់ជាង ឬឧត្តមភាពនៃភេទណាមួយ ឬលើតួនាទីជាទម្លាប់របស់បុរស និងស្ត្រី"។ គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី ក៏បញ្ជាក់យ៉ាងច្បាស់ថា ការអនុវត្តតាមវប្បធម៌ដូចជា កាយវិកលកម្មប្រដាប់ភេទស្ត្រី និងការអនុញ្ញាតឲ្យមានពហុពន្ធភាព ជាការអនុវត្តផ្ទុយនឹងអនុសញ្ញា។ មាត្រា ១៨(៣) នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានដាក់កំហិតសិទ្ធិសេរីភាពសាសនា និងជំនឿដូចតទៅ៖ សេរីភាពខាងការសម្តែង ជំនឿ ឬសាសនារបស់ខ្លួននឹងអាចដាក់កម្រិតព្រំដែនបាន លុះត្រាតែមានបញ្ញត្តិដោយច្បាប់ និងចាំបាច់ដល់ការការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ ឬសីលធម៌ ឬសិទ្ធិ និងសេរីភាពមូលដ្ឋានរបស់អ្នកដទៃ"។ នៅក្នុងការស្រាវជ្រាវរបស់គាត់ស្តីពីសេរីភាពសាសនា ឬជំនឿ និងឋានៈរបស់ស្ត្រីទាក់ទងនឹងសាសនា និងប្រពៃណី (E/CN.4/2002/73/Add.2) អ្នករាយការណ៍ពិសេសទទួលបន្ទុកសេរីភាពសាសនា ឬជំនឿ បានថ្កោលទោសចំពោះការរើសអើង និងការមិនសណ្តោសប្រណីដល់ស្ត្រី ដោយផ្អែកលើ ឬជាការទទួលខុសត្រូវតាមបែបសាសនា ឬប្រពៃណី។

*ប្រភព៖* ហ្វ្រង់សេស រ៉ាដាយ "វប្បធម៌ សាសនា និងយេនឌ័រ" *ព្រឹត្តិប័ត្រអន្តរជាតិស្តីពីច្បាប់រដ្ឋធម្មនុញ្ញ* ភាគ១ លេខ ៤

(ខែតុលា ឆ្នាំ២០០៣) ទំព័រ ៦៨១ គេហទំព័ររបស់អ្នករាយការណ៍ពិសេសស្តីពីសេរីភាពសាសនា ឬជំនឿ (សូមមើល www.ohchr.org)

ច្បាប់ និងការអនុវត្តតាមទំនៀមទម្លាប់ដែលមានលក្ខណៈរើសអើង ច្រើនមានការទទួលស្គាល់និងឆ្លុះបញ្ចាំងក្នុងច្បាប់រដ្ឋ ឬមានលើសពីនេះ។ រដ្ឋធម្មនុញ្ញមួយចំនួនដែលទទួលស្គាល់សិទ្ធិស្មើភាពគ្នារបស់ស្ត្រី ក៏អនុញ្ញាតឲ្យមានការលើកលែងមួយចំនួនទាក់ទងនឹងច្បាប់ឬការអនុវត្តតាមបែបទំនៀមទម្លាប់នេះដែរ។

នៅពេលដែលមានភាពខុសប្លែកគ្នារវាងស្ថាប័នច្បាប់ទាំងពីរនេះ ស្ត្រីនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអះអាងទាមទារសិទ្ធិរបស់ខ្លួនក្រោមច្បាប់រដ្ឋ។ ច្បាប់ និងការអនុវត្តតាមបែបទំនៀមទម្លាប់ ក៏ត្រូវបានគេប្រើជាញឹកញាប់ក្នុងការបកស្រាយបញ្ញត្តិច្បាប់រដ្ឋ ដែលធ្វើឲ្យអន្តរាយដល់សិទ្ធិស្ត្រី។ ដូច្នេះ ទោះបីជាច្បាប់រដ្ឋមិនរើសអើងរវាងបុរសនិងស្ត្រី ឬមិនដាក់កំហិតទៅលើសមត្ថភាពរបស់ស្ត្រីក្នុងការទទួលបានលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិក៏ដោយ ក៏ក្នុងការអនុវត្តជាក់ស្តែង ឧបសគ្គចម្បងដែលស្ត្រីរៀបការ និងស្ត្រីមិនទាន់រៀបការជួបប្រទះនោះ គឺច្បាប់ និងការអនុវត្តតាមបែបទំនៀមទម្លាប់ដែលមានការរើសអើង ដែលកំណត់ ឋានៈសង្គមរបស់ស្ត្រី និងកំណត់ពីបញ្ហាគ្រួសារ។

ការមាននូវប្រព័ន្ធទាំងពីរនេះទន្ទឹមពេលគ្នាក៏បង្កើតឲ្យមានការភ័ន្តច្រឡំ ដែលកើតចេញមកពីទំនាស់រវាងប្រព័ន្ធច្បាប់ទាំងពីរនេះ និងចេញមកពីភាពប្រទាញប្រទង់ដែលមានបន្សល់ទុកនៅក្នុងច្បាប់រដ្ឋផងដែរ។ ឧទាហរណ៍ រដ្ឋធម្មនុញ្ញមួយចំនួនការពារទាំងច្បាប់ប្រពៃណីទាក់ទងនឹងដីធ្លី ក៏ដូចជាគោលការណ៍មិនរើសអើង ទាំងសមភាពយេនឌ័រ។ ក្នុងករណីបែបនេះ អ្នកនយោបាយ ចៅក្រម និងអ្នកផ្សេងទៀតដែលអនុម័ត និងបកស្រាយច្បាប់ទាំងនេះ ច្រើនតែត្រឡប់ទៅរកប្រពៃណី ដែលអាចរើសអើងស្ត្រីវិញ។ ក៏ប៉ុន្តែ ក៏មានការវិនិច្ឆ័យវិជ្ជមានមួយចំនួនដែរ។ ឧទាហរណ៍ តុលាការជាន់ខ្ពស់ក្នុងប្រទេសកេនយ៉ា បានតម្កល់សិទ្ធិស្មើភាពរបស់ស្ត្រីក្នុងការទទួលមរតក ដែលមានលក្ខណៈផ្ទុយនឹងច្បាប់ទំនៀមទម្លាប់ដែលចែងផ្ទុយពីនេះ។ ក្នុងការធ្វើដូច្នេះ តុលាការបានបញ្ជាក់ច្បាស់ថា "ច្បាប់ទំនៀមទម្លាប់ដែលបដិសេធសិទ្ធិរបស់កូនស្រីក្នុងការទទួលមរតកអចលនទ្រព្យរបស់ឪពុក មិនអាចអនុវត្តបានទេ ដោយសារតែវាផ្ទុយទៅនឹងគោលការណ៍យុត្តិធម៌ និងសីលធម៌"[30]។

***សាធារណរដ្ឋតង់ហ្សានី៖ ការហាមឃាត់ដាក់លាក់ចំពោះការអនុវត្តច្បាប់ទំនៀមទម្លាប់ ប្រសិនបើការអនុវត្តនោះបដិសេធការទទួលបាន និងការគ្រប់គ្រងដីធ្លីដោយស្មើភាពគ្នារបស់ស្ត្រី***

[30] *Re The Estate of Lerionka Ole Ntutu (ស្លាប់)* [2008] eKLR, តុលាការកំពូលកេនយ៉ា នៅណៃរ៉ូប៊ី ហេតុផលខាងសន្តតិកម្ម ១២៦៣ ក្នុងឆ្នាំ ២០០០ ដែលបានសម្រេចនៅថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៨។

ច្បាប់ដីភូមិ ឆ្នាំ១៩៩៩ មានបញ្ញត្តិជាក់លាក់មួយចំនួនស្តីពីការទទួលបាន និងការគ្រប់គ្រងដីធ្លីដោយស្មើភាពគ្នារបស់ស្ត្រី។ ច្បាប់នេះហាមឃាត់ជាពិសេសចំពោះការអនុវត្តច្បាប់ទំនៀមទម្លាប់ ប្រសិនបើការអនុវត្តនោះ បដិសេធការទទួលបានកម្មសិទ្ធិ ការគ្រប់គ្រង ឬ ការប្រើប្រាស់ដីធ្លី ដោយស្របច្បាប់របស់ស្ត្រី។

*ប្រភព៖* UN-Habitat *សិទ្ធិ និង តថភាព៖ តើសិទ្ធិស្មើភាពគ្នារបស់ស្ត្រីក្នុងការទទួលបានដីធ្លី លំនៅឋាន និងទ្រព្យសម្បត្តិត្រូវបានគេអនុវត្តក្នុងទ្វីបអាហ្វ្រិកខាងកើតដែរឬទេ?* (មេសា ២០០២) ទំព័រ viii, ១១៤-១២២។

ការសម្រេចទាក់ទងលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ ច្រើនត្រូវបានធ្វើឡើងនៅថ្នាក់មូលដ្ឋាន ដែលមន្ត្រីទាំងនោះភាគច្រើនអនុវត្តច្បាប់ ឬអនុវត្តតាមលក្ខណៈប្រពៃណី។ មន្ត្រីមូលដ្ឋាន ក៏ច្រើនតែមានភាពស្ទាក់ស្ទើរក្នុងការចូលរួមពាក់ព័ន្ធក្នុងបញ្ហាលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ ដោយសារតែពួកគេយល់ថា បញ្ហាទាំងអស់នេះជាបញ្ហាគ្រួសារ និងបញ្ហារបស់ញាតិសណ្តាន។ ជាទូទៅ មេដឹកនាំតាមលក្ខណៈប្រពៃណី និងអាជ្ញាធរមូលដ្ឋាន គឺជា អ្នកអនុវត្តច្បាប់ ឬអនុវត្តតាមបែបទំនៀមទម្លាប់។ ចៅក្រមមួយចំនួនក៏អនុវត្តច្បាប់ទំនៀមទម្លាប់ នៅក្នុងដំណើរការនីតិវិធីដែរ ជាពិសេសដំណើរការនីតិវិធីដែលប្រព្រឹត្តទៅនៅតាមតុលាការក្នុងមូលដ្ឋាន។ ស្ត្រីដែលជំទាស់នឹងច្បាប់ និងការអនុវត្តតាមបែបទំនៀមទម្លាប់ ក៏បានទទួលរងការគំរាមកំហែង និងអំពើហិង្សាពីក្រុមគ្រួសារ និងសហគមន៍របស់ខ្លួនដែរ។

***តុលាការធម្មនុញ្ញប្រទេសអាហ្វ្រិកខាងត្បូង ស្តីពីមរតក និងច្បាប់ប្រពៃណី៖ Bhe ទល់នឹង Magistrate Khayelitsha & Ors***

ក្នុងរឿងក្តីរបស់ (Bhe) តុលាការធម្មនុញ្ញប្រទេសអាហ្វ្រិកខាងត្បូងជឿថា ច្បាប់ដែលទទួលស្គាល់ច្បាប់ទំនៀមទម្លាប់ណាដែលរារាំងស្ត្រីមិនឲ្យទទួលបានសិទ្ធិស្មើភាពគ្នាក្នុងការទទួលមរតក គឺជាច្បាប់ដែលមានការរើសអើង ហើយគួរតែលុបបំបាត់ចោល។

ការវិនិច្ឆ័យរបស់តុលាការនេះ ទាក់ទងនឹងរឿងមរតកចំនួនបីករណី។ អ្នកដាក់ពាក្យសុំ និងអង្គការបម្រើផលប្រយោជន៍សាធារណៈបានជំទាស់នឹងផ្នែក ២៣ នៃច្បាប់គ្រប់គ្រងជនជាតិស្បែកខ្មៅ ដែលចែងអំពីការអនុវត្តច្បាប់ប្រពៃណីក្នុងបញ្ហាមរតក។ ច្បាប់ទំនៀមទម្លាប់ក្នុងប្រទេសអាហ្វ្រិកខាងត្បូង លំអៀងទៅរកកូនប្រុសច្បងដែលជាអ្នកត្រូវទទួលមរតកទ្រព្យសម្បត្តិទាំងអស់នៅពេលឪពុកស្លាប់។

តុលាការធម្មនុញ្ញបានប្រកាសអំពីអធម្មនុញ្ញភាពនៃវិធានទំនៀមទម្លាប់អំពី កូនប្រុសច្បងដែលជាអ្នកត្រូវទទួលមរតកទ្រព្យសម្បត្តិទាំងអស់នៅពេលឪពុកស្លាប់ ហើយបានលុបចោលក្របខ័ណ្ឌច្បាប់ទាំងស្រុងអំពីការដាក់បញ្ញត្តិទាក់ទងនឹងអចលនទ្រព្យរបស់អ្នកស្លាប់ដោយគ្មានមតកសាសន៍ សម្រាប់ប្រជាជនអាហ្វ្រិកខាងត្បូងស្បែកខ្មៅ។ យោងតាមតុលាការ ផ្នែកទី២៣ នៃច្បាប់គ្រប់គ្រងជនជាតិស្បែកខ្មៅ មិនត្រឹមត្រូវតាមសម័យកាលទេ ដោយហេតុថា ផ្នែកនេះធ្វើឲ្យច្បាប់ទំនៀមទម្លាប់ "ជាផ្លូវការ" នេះ មិនអាចកែប្រែបាន ហើយវាបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិរបស់ប្រជាជនអាហ្វ្រិកស្បែកខ្មៅ បើធៀបទៅនឹងប្រជាជនស្បែកស។ ទាក់ទងនឹងវិធានច្បាប់ទំនៀមទម្លាប់អំពីកូនប្រុសច្បង ដែលជាអ្នកត្រូវទទួលមរតកទ្រព្យសម្បត្តិទាំងអស់នៅ ពេលឪពុកស្លាប់នោះ តុលាការបានសម្រេចថា វាមានការរើសអើងយ៉ាងអយុត្តិធម៌ទៅលើស្ត្រី ហើយធ្វើឲ្យកូនមិនមាន

ភាពស្របច្បាប់ដោយសារតែមូលហេតុពូជសាសន៍ យេនឌ័រ និងកំណើត។ លទ្ធផលនៃការសម្រេចនេះ គឺថា រាល់អចលនទ្រព្យទាំងអស់របស់អ្នកស្លាប់ នឹងត្រូវស្ថិតនៅក្រោមការគ្រប់គ្រប់ដោយច្បាប់ទទួលមរតក ដែល គ្មានបណ្តាំមរតកលេខ ៨១ ឆ្នាំ១៩៨៧ រហូតដល់មានច្បាប់ផ្សេងបន្ថែមពីលើនេះ ហើយដែលស្ត្រីមេម៉ាយ និងកូន អាចទទួលផលប្រយោជន៍ ដោយមិនគិតពីយេនឌ័រ និងភាពស្របច្បាប់របស់ពួកគេនោះទេ។ តុលាការ ក៏បានចេញបញ្ជាសម្រាប់ការបែងចែកអចលនទ្រព្យ ក្នុងកាលៈទេសៈដែលអ្នកស្លាប់ទៅនោះស្ថិតក្នុងចំណង អាពាហ៍ពិពាហ៍ពហុពន្ធភាព និងមានប្រពន្ធដែលនៅរស់ច្រើនជាងម្នាក់។

*ប្រភព៖* 2005 (1) BCLR 1 (CC) ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៤។

ការទទួលបានធនធានហិរញ្ញវត្ថុ និងគម្រោងធនាគារសម្រាប់ទិញផ្ទះសម្បែង ឬដីធ្លី ក៏អាចត្រូវបាន ដាក់កំហិត ដោយសារការអនុវត្តច្បាប់ឬការអនុវត្តតាមបែបទំនៀមទម្លាប់ទាំងនោះដែរ ឧទាហរណ៍ វាអាច តម្រូវឲ្យស្ត្រីត្រូវមានការអនុញ្ញាតជាផ្លូវការពីសាច់ញាតិជាបុរសដើម្បីទទួលបានគម្រោងធនាគារទាំងនោះ។

ថ្វីត្បិតតែមានការប្រឈមបង្កឡើងដោយច្បាប់ និងការអនុវត្តតាមបែបទំនៀមទម្លាប់ក៏ដោយ ក៏មាន ការអភិវឌ្ឍន៍វិជ្ជមានមួយចំនួនដែលបានកើតឡើងក្នុងវិស័យមួយចំនួន ដែលក្រុមស្ត្រីនិងក្រុមលំនៅឋាន បាន ចាប់ផ្តើមដោះស្រាយបញ្ហាទាំងនេះ។ អង្គការជំនួយផ្នែកច្បាប់ក្នុងតំបន់ជនបទនៃប្រទេសសេរ៉ាឡេអូន ផ្តល់ ដំបូន្មានផ្នែកច្បាប់ដោយមិនគិតកម្រៃដល់ស្ត្រី និងផ្តល់ការសម្រុះសម្រួលរវាងសមាជិកគ្រួសារ និងក្នុង សហគមន៍ ព្រមទាំងផ្តល់សិក្ខាសាលាលើកកម្ពស់ការយល់ដឹងអំពី សិទ្ធិស្ត្រីដល់សមាជិកក្នុងសហគមន៍ មូលដ្ឋាន និងរដ្ឋបាលមូលដ្ឋាន។ អង្គការលើកលែងទោសអន្តរជាតិ បានរកឃើញថា ជាទូទៅ ស្ត្រីនៅតាម ជនបទបានទទួលការពង្រឹងសិទ្ធិអំណាចតាមរយៈជំនួយនេះ និងជឿថា សេវាទាំងនេះមានប្រសិទ្ធភាពក្នុង ក្នុងការដោះស្រាយជម្លោះ។ ស្ត្រីបានយល់ដឹងអំពីសិទ្ធិរបស់ខ្លួន ចេះអំពីរបៀបជំទាស់ ឬប្តឹងជំទាស់ចំពោះការ សម្រេចណាដែលពួកគេមានអារម្មណ៍ថាមិនត្រឹមត្រូវ ឬអយុត្តិធម៌ ព្រមទាំងបានដឹងអំពីសេវាកម្មផ្សេងៗដែល ពួកគេអាចរកបាននៅក្នុងសហគមន៍[31]។

## ឃ. ឥរិយាបថលំអៀង

ការលំអៀងយេនឌ័រក្នុងវិស័យរដ្ឋបាលនិងតុលាការ ក៏បង្កើតជាបញ្ហាធ្ងន់ធ្ងរមួយសម្រាប់ស្ត្រីក្នុងការ ទទួលបានសិទ្ធិមានលំនៅឋានសមរម្យ។ ទោះបីជាច្បាប់និងគោលនយោបាយជាផ្លូវការមួយចំនួន មិនបង្ហាញ កស្តុតាងអំពីការរើសអើងយេនឌ័រក៏ដោយ ក៏ឥរិយាបថរើសអើងយេនឌ័រអាចមានសភាពគ្របដណ្តប់នៅក្នុង រដ្ឋបាលដីធ្លី និងលំនៅឋាន ក្នុងប្រព័ន្ធទាក់ទងនឹងច្បាប់ ឬជាមួយនឹងម្ចាស់ដី ដែលកត្តាទាំងនេះធ្វើឲ្យស្ត្រី មានការលំបាកយ៉ាងក្រៃលែងក្នុងការធានាឲ្យបាននូវសិទ្ធិមានលំនៅឋានសមរម្យក្រោមច្បាប់ជាផ្លូវការ។ បញ្ហា នានាទាក់ទងនឹងអាពាហ៍ពិពាហ៍ មរតក ឬការលែងលះ ច្រើនតែត្រូវគេយល់ថាជាបញ្ហាឯកជន ឬបញ្ហាគ្រួសារ

[31] អង្គការលើកលែងទោសអន្តរជាតិ "*សេរ៉ាឡេអូន៖ ស្ត្រីប្រឈមនឹងការបំពានសិទ្ធិមនុស្សក្នុងវិស័យច្បាប់ក្រៅប្រព័ន្ធ*" បិលិក្រមអង្គការលើកលែងទោសអន្តរជាតិ៖ AFR 51/002/2006 (ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៦)។

ដែលរដ្ឋមិនគួរលូកដៃ។ មេដឹកនាំតាមលក្ខណៈប្រពៃណី ជាពិសេសមនុស្សចាស់ទុំ និងអាជ្ញាធរមូលដ្ឋាន ដែលជាមនុស្សសំខាន់ក្នុងការអនុវត្តច្បាប់ និងការអនុវត្តតាមលក្ខណៈប្រពៃណីនោះ ក៏ទំនងជាមានឥរិយាបថរើសអើងទៅលើស្ត្រីដែរ។ ចៅក្រមក៏អាចមានការជំទាស់ទៅនឹងគំនិតក្នុងការធានាឲ្យស្ត្រីទទួលបាន និងគ្រប់គ្រងលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិដោយស្មើភាពគ្នាដែរ។

ក្នុងប្រទេសមួយចំនួន ស្ត្រីនៅលីវ និងស្ត្រីលែងលះប្តី ដែលមានបំណងចង់ទិញ ឬជួលផ្ទះ នៅតែបន្តប្រឈមនឹងឧបសគ្គជាច្រើន។ ម្ចាស់ដី ឬអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ក៏អាចបដិសេធមិនជួលឲ្យម្តាយដែលមានវ័យជំទង់ ឬស្ត្រីនៃជនភាគតិចដែលមានប្រាក់ចំណូលទាបដែរ។

## ង. កង្វះខាតសិទ្ធិទទួលបានដំណោះស្រាយ និងការយល់ដឹងអំពីសិទ្ធិ

*ប្រសិនបើស្ត្រីដឹងថាពួកគេមានសិទ្ធិ យើងប្រាកដជាមានស្ថានភាពមួយផ្សេង[32]។*

នៅក្នុងប្រទេសជាច្រើន មិនមានដំណោះស្រាយដើម្បីជំនះលើការអនុវត្តដែលមានលក្ខណៈរើសអើងក្នុងបញ្ហាលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិនោះទេ។ នៅពេលដែលមានដំណោះស្រាយអាចរកបាន ស្ត្រីប្រឈមនឹងបញ្ហាធ្ងន់ធ្ងរក្នុងការទទួលបានសំណង ទាំងក្នុងប្រព័ន្ធផ្លូវការ និងប្រព័ន្ធទំនៀមទម្លាប់។ ឥរិយាបថសង្គមដែលបានចាក់ឫសយ៉ាងជ្រៅ ភាពលំអៀងយេនឌ័រក្នុងវិស័យតុលាការ អំពើពុករលួយ ការដាក់ឲ្យនៅដាច់តែឯង កង្វះខាតការយល់ដឹងអំពីសិទ្ធិ ក៏ដូចជា ទំនុកចិត្តដ៏តិចតួចក្នុងការស្វែងរកការទាមទារទាំងអស់នេះ អាចទប់ស្កាត់ស្ត្រីពីការទទួលបានសំណងក្នុងករណីទាក់ទងនឹងលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ។

ជារឿយៗ ស្ត្រីក៏មានធនធានហិរញ្ញវត្ថុ នយោបាយ និងច្បាប់តិចតួច ក្នុងការផ្សព្វផ្សាយ និងជំនះលើការរំលោភបំពាននានានៅចំពោះមុខតុលាការ នៅក្នុងប្រព័ន្ធនយោបាយ ប្រព័ន្ធផ្សព្វផ្សាយ ឬទីកន្លែងផ្សេងទៀត។ ស្ត្រីដែលមានធនធានសង្គម និងសេដ្ឋកិច្ចតិចតួច ច្រើនតែត្រូវបានទប់ស្កាត់មិនឲ្យស្វែងរកការទាមទារតាមផ្លូវច្បាប់ប្រឆាំងនឹងសាច់ញាតិជាបុរសទេ ទោះជាធ្វើឡើងតាមមធ្យោបាយក្រៅប្រព័ន្ធ ឬតាមប្រព័ន្ធច្បាប់រដ្ឋក៏ដោយ ជាពិសេស នៅពេលដែលអវត្តមានជំនួយផ្នែកច្បាប់។ ក្នុងប្រទេសមួយចំនួន ស្ត្រីដែលបង្ហាញមុខនៅតុលាការ ត្រូវតែមានបុរសម្នាក់អមដំណើរទៅជាមួយ ដែលនេះជាការធ្វើឲ្យស្ត្រីស្ថិតក្នុងស្ថានភាពលំបាកមួយ។ ជាទូទៅ មានស្ត្រីតិចតួចណាស់ដែលស្វែងរកការទាមទារសិទ្ធិរបស់ខ្លួនក្នុងការមានលំនៅឋានសមរម្យតទល់ជាមួយសាច់ញាតិជាបុរស ដូចមានយុត្តិសាស្ត្រក្នុងចំនួនដ៏តិចតួចបំផុតដែលបានបង្ហាញឲ្យឃើញ។

ការប្រើប្រាស់ផ្លូវច្បាប់ ឬវិធីផ្សេងទៀតក្នុងការជំទាស់នឹងការសម្រេចចិត្តបែបរើសអើង ដែលប៉ះពាល់ដល់សិទ្ធិមានលំនៅឋានសមរម្យ ត្រូវការថវិកា ពេលវេលា និងចំណេះដឹងនៃប្រព័ន្ធមួយដែលប្រហែលជាស្ត្រីមិនបានដឹង។ សិទ្ធិប្រើប្រាស់នីតិវិធីរដ្ឋបាល ឬតុលាការ ក្នុងការផ្តល់សំណងសម្រាប់ការរំលោភបំពានច្បាប់រដ្ឋអាចជាបញ្ហាមួយរួចស្រេចទៅហើយសម្រាប់ស្ត្រីភាគច្រើន។ ការចំណាយ និងបញ្ហាការិយាធិបតេយ្យ បាន

[32] សក្ខីកម្មបានមកពីប្រទេសតុងហ្គា ដែលបានប្រមូលក្នុងអំឡុងពេលការពិគ្រោះយោបល់ថ្នាក់តំបន់ប៉ាស៊ីហ្វិក។

បញ្ឈប់ស្ត្រីជាច្រើនមិនឲ្យស្វែងរកការទាមទារអំពីបញ្ហាលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ។ ដោយសារតែស្ត្រីមានឧបសគ្គផ្សេងៗទាក់ទងនឹងការទទួលខុសត្រូវប្រចាំថ្ងៃស្រាប់ហើយនោះ ស្ត្រីច្រើនតែមិនអាចទៅតុលាការបានទេ។ ការចំណាយលើសោហ៊ុយធ្វើដំណើរសម្រាប់ស្ត្រីនៅតំបន់ជនបទ រួមជាមួយនឹងការចំណាយសម្រាប់តំណាងផ្នែកច្បាប់បានទប់ស្កាត់ស្ត្រីជាច្រើនមិនឲ្យស្វែងរកដំណោះស្រាយផ្នែកច្បាប់នេះបាន ដោយសារតែកម្មវិធីជំនួយផ្នែកច្បាប់សម្រាប់ស្ត្រី កម្រមានណាស់។ ក្នុងយុត្តាធិការដែលមានផ្តល់ជំនួយផ្នែកច្បាប់មួយចំនួនជារឿយៗ មានការរឹតត្បិតចំពោះរឿងក្តីព្រហ្មទណ្ឌ។ ស្ត្រីមេម៉ាយជនជាតិកេនយ៉ាម្នាក់បាននិយាយថា គាត់ត្រូវចំណាយប្រាក់ ដើម្បីទៅកាន់តុលាការបាន ដែលការចំណាយនេះជាការខ្វះខាតប្រាក់ដែលគាត់ត្រូវការសម្រាប់បង់ថ្លៃសាលារៀន។

នៅពេលដែលស្ត្រីលើកឡើងអំពីបញ្ហាទាក់ទងនឹងការគ្រប់គ្រង និងសិទ្ធិកាន់កាប់លំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ ពួកគេច្រើនតែធ្វើឡើងប្រឆាំងនឹងគ្រួសារ សាច់ញាតិ និងសហគមន៍របស់ខ្លួន។ ជាលទ្ធផលពួកគេអាចប្រឈមនឹងការធ្វើទុក្ខបុកម្នេញធ្ងន់ធ្ងរ អំពើហិង្សា ឬការផាត់ចេញពីសង្គម នៅពេលដែលពួកគេប៉ុនប៉ងទាមទារសិទ្ធិរបស់ខ្លួន។ ការភ័យខ្លាចមានអំពើហិង្សា និងការផាត់ចេញពីសង្គម រួមជាមួយនឹងការគំរាមកំហែង ការធ្វើទុក្ខបុកម្នេញ និងអំពើហិង្សាចេញពីគ្រួសារនិងសហគមន៍ទូទៅផងនោះ អាចជាការរារាំងស្ត្រីពីការស្វែងរកការទាមទារតាមផ្លូវច្បាប់។ ស្ត្រីក៏ប្រឈមនឹងបញ្ហាធ្ងន់ធ្ងរមួយចំនួន ក្នុងការទទួលបានដំណោះស្រាយដែរ នៅពេលដែលបញ្ហាទាក់ទងនឹងលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិត្រូវបានកាត់សេចក្តីដោយគ្រួសារ ឬសាច់ញាតិនោះ។ ជាញឹកញាប់ ជម្លោះបែបនេះត្រូវបានដោះស្រាយនៅថ្នាក់មូលដ្ឋាន ដែលគេប្រើច្បាប់និងការអនុវត្តតាមលក្ខណៈបែបប្រពៃណីលប់លើច្បាប់រដ្ឋ។ ចៅក្រមតាមតុលាការនៅមូលដ្ឋាន ច្រើនតែជាប្រធានមូលដ្ឋាន ហេតុដូច្នេះហើយ ពួកគេច្រើនតែមានជំនាញខាងច្បាប់ទំនៀមទម្លាប់ប៉ុណ្ណោះ ប៉ុន្តែមិនមានជំនាញខាងច្បាប់រដ្ឋនោះទេ។

វេទិកាតាមបែបទំនៀមទម្លាប់ជាច្រើនសម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត និងការផ្តល់សំណង គ្របដណ្តប់ទៅដោយថ្នាក់ដឹកនាំជាបុរស ហើយមិនបានផ្តល់ឱកាសឲ្យស្ត្រីចូលរួមដោយស្មើភាពគ្នានោះទេ។ ទង្វើនេះបង្កើតជាឧបសគ្គដ៏ធ្ងន់មួយសម្រាប់ស្ត្រី ក្នុងការស្វែងរកសំណងដែលកើតឡើងដោយសារការប្រើប្រាស់ប្រពៃណីនេះ ជាពិសេសក្នុងប្រទេសដែលច្បាប់ប្រពៃណីនេះត្រូវបានទទួលស្គាល់ស្របច្បាប់។

កត្តាមួយទៀតដែលប៉ះពាល់ដោយផ្ទាល់ទៅលើការទទួលបានដំណោះស្រាយសម្រាប់ស្ត្រី ក្នុងបរិបទលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ គឺកត្តាចំណេះដឹងមិនគ្រប់គ្រាន់ និងកង្វះការយល់ដឹងអំពីសិទ្ធិរបស់ខ្លួន។ ទោះបីជាការខ្វះខាត ឬការបាត់បង់លំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ ប៉ះពាល់ដល់ពួកគេធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏ជាញឹកញាប់ ស្ត្រីមិនបានដឹងអំពីសិទ្ធិរបស់ខ្លួនដែលមាននៅក្នុងរដ្ឋធម្មនុញ្ញ ឬក្នុងច្បាប់ដទៃទៀតឡើយ នេះមិនទាន់និយាយដល់ច្បាប់សិទ្ធិមនុស្សអន្តរជាតិផង។

## ច. កង្វះការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត

ស្ត្រីច្រើនតែមិនអាចចូលរួមដោយស្មើភាពគ្នា ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តដែលជាប់ពាក់ព័ន្ធនឹងសិទ្ធិមានលំនៅឋានសមរម្យ ទោះជាការសម្រេចចិត្តនោះធ្វើនៅក្នុងកម្រិតគ្រួសារ កម្រិតសហគមន៍ និងកម្រិតរដ្ឋក៏ដោយ។ សក្ខីកម្មដែលប្រមូលបានក្នុងអំឡុងពេលធ្វើការពិគ្រោះយោបល់ថ្នាក់តំបន់ គូសបញ្ជាក់ថា ទោះបីជាសមភាពរវាងបុរស និងស្ត្រីត្រូវបានទទួលស្គាល់ជាផ្លូវការនៅក្នុងច្បាប់ក៏ដោយ ក៏ជំនឿដែលថាស្ត្រីមិនអាចធ្វើការសម្រេចចិត្តសម្រាប់ខ្លួនឯង សម្រាប់គ្រួសារ និងសម្រាប់សហគមន៍ និងថាវាមិនមែនជាតួនាទីសង្គមរបស់ស្ត្រីដែលត្រូវធ្វើ នៅតែបន្តទប់ស្កាត់ស្ត្រីពីការចូលរួមពេញលេញក្នុងការធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិជាដដែល ។

ការចូលរួមរបស់ស្ត្រីក្នុងវេទិកាជាលក្ខណៈប្រពៃណីមានការដាក់កម្រិតខ្លាំង ដោយសារការធ្វើសេចក្តីសម្រេចផ្តល់ឲ្យតែបុរសប៉ុណ្ណោះ។ នៅក្នុងគ្រួសារ ជាញឹកញាប់ ស្ត្រីមិនពាក់ព័ន្ធនឹងលំនៅឋាន និងដីធ្លីជាពិសេស ប្រសិនបើពួកគេពុំមានកូនប្រុស។ ស្ត្រីក៏កម្រមានសិទ្ធិសម្រេចលើរឿងចំណាយក្នុងគ្រួសារ ដែលប៉ះពាល់ដល់លទ្ធភាពក្នុងការធ្វើឲ្យលំនៅឋានមានភាពប្រសើរឡើង។ ការលំអៀងយេនឌ័រនៅក្នុងការគ្រប់គ្រងរដ្ឋបាល ក៏ជាញឹកញាប់ បណ្តាលឲ្យស្ត្រីអវត្តមានពីដំណើរការនៃការបង្កើតគោលនយោបាយរដ្ឋាភិបាលស្តីពីលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ ឧទាហរណ៍ កម្មវិធីទាក់ទងនឹងការកែលំអរសំណង់មិនទាន់រៀបរយ។

កង្វះការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត មានសភាពធ្ងន់ធ្ងរ ជាពិសេស ក្នុងស្ថានភាពក្រោយជម្លោះ នៅពេលដោះស្រាយបញ្ហាសំណងទាក់ទងនឹងលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ។ ស្ត្រីច្រើនតែត្រូវបានគេដកចេញពីការចរចាសន្តិភាព និងកិច្ចព្រមព្រៀងសន្តិភាព។ ជាលទ្ធផល ស្ត្រីដែលត្រូវគេបណ្តេញចេញពីលំនៅឋានក្នុងអំឡុងពេលមានជម្លោះ ច្រើនមានការលំបាក និងមានបញ្ហា ក្នុងការវិលត្រឡប់មកកាន់លំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិដើមរបស់ខ្លួនវិញ។

*គោលការណ៍ស្តីពីការផ្តល់ត្រឡប់ឲ្យវិញនូវលំនៅឋាននិងទ្រព្យសម្បត្តិ ដល់ជនភៀសខ្លួន និងជនដែលចាកចេញដោយបង្ខំចិត្ត* [ក]

១២.២ រដ្ឋគួរធានាថា នីតិវិធី ស្ថាប័ន និងយន្តការនានាសម្រាប់ការផ្តល់ត្រឡប់ឲ្យវិញនូវលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ មានការគិតគូដល់ អាយុ និងវិញ្ញោចយេនឌ័រ ហើយគួរទទួលស្គាល់សិទ្ធិស្មើភាពគ្នារវាងបុរស និងស្ត្រី ក៏ដូចជា សិទ្ធិស្មើភាពគ្នារវាងកុមារា និងកុមារី [...]។

១៤.២ រដ្ឋ និងតួអង្គជាតិ និងអន្តរជាតិពាក់ព័ន្ធផ្សេងទៀត គួរធានាជាពិសេសថា ស្ត្រី [...] ត្រូវមានតំណាងយ៉ាងគ្រប់គ្រាន់ និងត្រូវបានបញ្ចូលទៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តទាំងឡាយ ព្រមទាំងមានមធ្យោបាយ និងព័ត៌មានគ្រប់គ្រាន់សម្រាប់ចូលរួមប្រកបដោយប្រសិទ្ធភាព។ សេចក្តីត្រូវការផ្សេងៗរបស់បុគ្គលងាយរងគ្រោះ រួមមាន [...] ស្ត្រីនៅលីវដែលជាមេគ្រួសារ [...] គួរទទួលបានការយកចិត្តទុកដាក់ជាពិសេស។

[ក] អនុម័តដោយអនុគណៈកម្មាធិការស្តីពីការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ក្នុងឆ្នាំ ២០០៥។

- ## សម្រាំងបញ្ហាសំខាន់ៗ

ការងារ និងការពិគ្រោះយោបល់ដែលធ្វើឡើងដោយអ្នករាយការណ៍ពិសេសស្ដីពី លំនៅឋានសមរម្យ បានរំលេចឡើងថា ការរើសអើងដែលស្ត្រីជួបប្រទះទាក់ទងនឹងលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ ទំនងជាប៉ះពាល់ដល់ស្ត្រីដោយមិនសមាមាត្រក្នុងបរិបទទាំងនេះ ដូចជា មរតក លក្ខខណ្ឌរស់នៅ ការបណ្ដេញចេញដោយបង្ខំ អំពើហិង្សាក្នុងគ្រួសារ មេរោគអេដស៍/ជំងឺអេដស៍ និងគ្រោះមហន្តរាយធម្មជាតិ។

សក្ខីកម្មដែលប្រមូលបានដោយអ្នករាយការណ៍ពិសេស ក៏បានបង្ហាញដែរថា ការរើសអើងនេះ ទំនងជាបង្កើនការរងនូវអំពើហិង្សារបស់ពួកគេនៅក្នុងគ្រួសារ និងក្នុងសង្គម និងបង្កឡើងដោយរដ្ឋ។ សក្ខីកម្មបញ្ជាក់យ៉ាងច្បាស់ថា អំពើហិង្សាបែបនេះ គឺជាការកើតឡើងស្រដៀងគ្នាក្នុងតំបន់ដែលសិទ្ធិស្ត្រីក្នុងការមានលំនៅឋានសមរម្យត្រូវបានអនុវត្តដោយទន់ខ្សោយ ដូចមានពន្យល់បង្ហាញខាងក្រោម។ ក្នុងឧទាហរណ៍ជាច្រើន ស្ត្រីក៏បានលើកឡើងអំពីការលំបាកខ្លាំងក្នុងការប្រាប់ឲ្យគេដឹងជាសាធារណៈអំពីការរំលោភបំពានដែលពួកគេប្រឈម ឬក្នុងការស្វែងរកសំណង និងបានលើកឡើងអំពីរបៀបដែល "វប្បធម៌នៅស្ងៀមមិននិយាយស្តី" បណ្ដោយឲ្យការរំលោភបំពានកើតឡើងដោយមិនមានការដាក់ទោសទណ្ឌ។

## ក. មរតក

*នៅពេលដែលប្ដីខ្ញុំស្លាប់ទៅ សាច់ញាតិរបស់គាត់មកយកអ្វីៗគ្មានសល់ទេ។ ពួកគេប្រាប់ខ្ញុំឲ្យយកសម្លៀកបំពាក់ក្នុងថង់ហើយឲ្យចេញទៅ។ ខ្ញុំក៏ចេញ ពីព្រោះប្រសិនបើខ្ញុំជំទាស់ពួកគេអាចនឹងវាយខ្ញុំ។ សាច់ញាតិប្ដីខ្ញុំប្រាប់ខ្ញុំថា មានអ្នកទទួលមរតកហើយ។ មនុស្សនោះគឺជាជីដូនមួយប្ដីខ្ញុំ។ ពួកគេប្រាប់ខ្ញុំថាឥឡូវនេះ "អ្នកមិនមានតម្លៃទេ ដូច្នេះ យើងនឹងប្រគល់អ្នកទៅនរណាម្នាក់ដែលអាចទទួលយកអ្នកបាន" ។ ខ្ញុំមិនបាននិយាយអ្វីទាំងអស់។ នេះជាទម្លាប់។ សាច់ថ្លៃរបស់ខ្ញុំបានយកអ្វីៗទាំងអស់ ដូចជា ពូក ភួយ របស់របរផ្សេងៗ។ ពួកគេបណ្ដេញខ្ញុំចេញដូចឆ្កែអញ្ចឹង។ ខ្ញុំនិយាយអ្វីមិនចេញទេ[33]។*

[33] អង្គការឃ្លាំមើលសិទ្ធិមនុស្ស Human Rights Watch បទដ្ឋានទ្វេរ៖ ការរំលោភសិទ្ធិទ្រព្យសម្បត្តិរបស់ស្ត្រីនៅកេនយ៉ា (ខែមីនា ឆ្នាំ២០០៣) ទំព័រទី ១៧។

សម្រាប់ស្ត្រីជាច្រើន សុវត្ថិភាពខាងការកាន់កាប់ដែលពួកគេមាន មានកម្រិតទាប គឺដោយសារការរើសអើងដែលពួកគេជួបប្រទះ ទាក់ទងនឹងការទទួលមរតកជាផ្ទះសម្បែង ច្បាប់ និងទ្រព្យសម្បត្តិ។ ការរើសអើងនេះអាចមានក្នុងច្បាប់រដ្ឋ ក៏ដូចជាក្នុងច្បាប់ទំនៀមទម្លាប់ដែលមិនបានទទួលស្គាល់សិទ្ធិស្មើគ្នារបស់ស្ត្រីជាមួយនឹងបុរសទាក់ទងនឹងមរតក។ ជាលទ្ធផល ស្ត្រីទទួលបានចំណែកតិចជាងសាច់ញាតិដែលជាបុរស ឬត្រូវគេចាត់ចែងលើមរតករបស់ប្តី ឬរបស់ឪពុកដែលស្លាប់ទៅ។

សិទ្ធិមិនស្មើគ្នាក្នុងការទទួលមរតកទាក់ទងយ៉ាងជិតស្និទ្ធជាមួយការរើសអើងយ៉ាងទូលំទូលាយចំពោះស្ត្រីទាក់ទងនឹងសិទ្ធិទ្រព្យសម្បត្តិក្នុងចំណងអាពាហ៍ពិពាហ៍។ ច្បាប់និងការអនុវត្តដែលរើសអើងស្ត្រីក្នុងការកាន់កាប់ និងគ្រប់គ្រងទ្រព្យសម្បត្តិក្នុងចំណងអាពាហ៍ពិពាហ៍ត្រូវបានពិភាក្សាលម្អិតក្នុងជំពូកទី២ ផ្នែក "ក" ខាងលើ។

***សិទ្ធិមនុស្ស និង មរតក***

នៅក្នុងអនុសាសន៍ទូទៅលេខ២១ (១៩៩៤) គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីបានថ្លែងថា ៖

*មានប្រទេសជាច្រើនដែលច្បាប់និងការអនុវត្តទាក់ទងមរតក និងទ្រព្យសម្បត្តិ បណ្តាលឲ្យមានការរើសអើងយ៉ាងធ្ងន់ធ្ងរទៅលើស្ត្រីភេទ។ ដោយសារតែការប្រព្រឹត្តមិនឲ្យមានភាពស្មើគ្នានេះ ស្ត្រីអាចនឹងទទួលចំណែកតិចតួចនៃទ្រព្យសម្បត្តិរបស់ស្វាមី ឬរបស់ឪពុកខ្លួននៅពេលពួកគេស្លាប់ទៅ ក្រៅតែពីក្លាយខ្លួនជាស្ត្រីមេម៉ាយ និងទទួលបានកូនប្រុស។ ក្នុងឧទាហរណ៍ខ្លះ ស្ត្រីម៉េម៉ាយត្រូវបានផ្តល់សិទ្ធិ ដែលមានលក្ខណៈដាក់កំហិត និងត្រួតត្រា ហើយទទួលចំណូលបានតែពីទ្រព្យសម្បត្តិរបស់អ្នកស្លាប់ប៉ុណ្ណោះ។ ជារឿយៗ ច្បាប់មរតកសម្រាប់ស្ត្រីមេម៉ាយមិនបានឆ្លុះបញ្ចាំងគោលការណ៍កម្មសិទ្ធិស្មើភាពគ្នា ដែលទទួលបានក្នុងចំណងអាពាហ៍ពិពាហ៍ឡើយ។ បញ្ញត្តិទាំងនេះផ្ទុយនឹងអនុសញ្ញា ដូច្នេះគួរត្រូវលុបចោល (កថាខណ្ឌទី ៣៥)។*

គណៈកម្មាធិការសិទ្ធិមនុស្ស ក្នុងការសេចក្តីពន្យល់ទូទៅលេខ២៨ (២០០២) អំពីសមភាពនៃសិទ្ធិរវាងបុរស និងស្ត្រី ក៏បានថ្លែងផងដែរថា ៖

*[...] ស្ត្រីត្រូវទទួលបានសិទ្ធិមរតកស្មើភាពគ្នាជាមួយនឹងបុរស នៅពេលរំលាយចំណងអាពាហ៍ពិពាហ៍ដោយសារមរណភាពនៃសហព័ទ្ធណាមួយ (កថាខណ្ឌទី ២៦)។*

តាមច្បាប់ និងការអនុវត្តតាមបែបទំនៀមទម្លាប់ លំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ នៅតែត្រូវគេបន្តចាត់ទុកថា ស្ថិតនៅក្រោមការគ្រប់គ្រងរបស់បុរស។ ជាលទ្ធផល ស្ត្រីមេម៉ាយជាច្រើន ត្រូវគេរារាំងមិនឲ្យទទួលបានទ្រព្យសម្បត្តិជាកេរមរតក ត្រូវសាច់ថ្លៃបណ្តេញចេញពីដីធ្លី និងផ្ទះសម្បែង និងត្រូវគេដកហូតយកទ្រព្យសម្បត្តិ។ ស្រដៀងគ្នានេះដែរ កូនស្រីមិនត្រូវបានអនុវត្តឲ្យទទួលទ្រព្យសម្បត្តិជាមរតកស្មើគ្នានឹងបងប្អូនប្រុសខ្លួនឡើយ ដោយយកលេសថា "ពួកគេនឹងមិនត្រូវការទេ" ពួកគេគង់តែរៀបការ។ ពេលខ្លះទៀតស្ត្រីត្រូវបានទទួលទ្រព្យសម្បត្តិ ដូចជា របស់របរក្នុងផ្ទះ ឬគ្រឿងសង្ហារឹម (ចលនទ្រព្យ)។ ជាទូទៅ ការទាមទាររបស់ស្ត្រីដើម្បីទទួលបានមរតក អាចបណ្តាលឲ្យមានការផាត់ចេញពីសង្គម មិនមែនត្រឹមតែបណ្តាលមកពីក្រុមគ្រួសារទេ គឺថែមទាំងបណ្តាលមកពីសហគមន៍ផងដែរ។

អំពើហិង្សាជារឿងធម្មតាក្នុងបរិបទមរតក។ ទ្រព្យសម្បត្តិរបស់ស្ត្រី ជារឿយៗ ត្រូវបានរឹបអូសយកដោយសាច់ញាតិ ជាការប៉ុនប៉ងដែលអាចជាប់ពាក់ព័ន្ធជាមួយការឃាយី ការបំភិតបំភ័យ ការគំរាមកំហែងដល់ រាងកាយ ការវាយដំ ការរំលោភសេពសន្ថវៈ និងឃាតកម្ម។ សូម្បីតែក្នុងករណីដែលស្ត្រីមានសិទ្ធិទទួលចំណែកទ្រព្យសម្បត្តិរបស់ឪពុក ឬរបស់ស្វាមីដែលស្លាប់ទៅក្តី ក៏ស្លាកស្នាមទុរយសក្នុងសង្គម គំនាបគ្រួសារ និងអំពើហិង្សា ជារឿយៗ បង្ខំស្ត្រីឲ្យបោះបង់ចំណែករបស់ខ្លួនទៅឲ្យសាច់ញាតិជាបុរស។ ស្ត្រីអាចមានហានិភ័យកើនឡើងនូវអំពើហិង្សាបង្កឡើងដោយសាច់ញាតិថ្លៃ ឬសមាជិកសហគមន៍ ប្រសិនបើគាត់សម្រេចចិត្តពុះពារដើម្បីជំនះយកចំណែកមរតករបស់ខ្លួន។ អំពើហិង្សានេះជារឿយៗប្រព្រឹត្តឡើងដោយនិទណ្ឌភាព ដោយបញ្ហាទាំងនេះត្រូវបានមើលឃើញថាជាបញ្ហាគ្រួសារ។

### *សេរ៉ាលីអូន ៖ ច្បាប់មរតកថ្មីធានាសិទ្ធិរបស់ស្ត្រី*

ក្នុងខែមិថុនា ឆ្នាំ២០០៧ រដ្ឋសភាប្រទេសសេរ៉ាលីអូនបានអនុម័តច្បាប់មរតកថ្មី (ច្បាប់ចាត់ចែងអចលនទ្រព្យ) ដែលផ្តល់សិទ្ធិដល់សហព័ទ្ធ (រៀបការតាមច្បាប់រដ្ឋប្បវេណី ឬច្បាប់ទំនៀមទម្លាប់) ក៏ដូចជាដៃគូដែលរួមរស់ជាមួយគ្នា មានសិទ្ធិចំពោះមរតក។ ច្បាប់ថ្មីនេះផ្តល់សិទ្ធិដល់ស្ត្រីលើទ្រព្យសម្បត្តិ នៅពេលមរណភាពស្វាមីរបស់ខ្លួន ដោយគ្មានការរំខានហួសហេតុពីសមាជិកគ្រួសារដែលជាសាខាញាតិ។ កាលពីមុនទ្រព្យសម្បត្តិនៃអ្នកស្លាប់គ្មានមតកសាសន៍ អាចផ្ទេរទៅឲ្យឪពុកម្តាយនិងបងប្អូនប្រុស ឯតាមច្បាប់ថ្មីវិញចំណែកភាគច្រើននៃមរតកនឹងផ្ទេរឲ្យស្ត្រីមេម៉ាយ និងកូន។

### *រ៉ាន់ដា ៖ ច្បាប់មរតកថ្មីធានាសិទ្ធិរបស់ស្ត្រី*

ក្រោយអំពើប្រល័យពូជសាសន៍ឆ្នាំ ១៩៩៤ និងការកើតឡើងយ៉ាងរាលដាលនៃបញ្ហាលំនៅឋាន និងដីធ្លី ស្ត្រីដែលប្រឈមមុខនឹងបញ្ហាមិនអាចទាមទារយកមកវិញបាននូវផ្ទះដើមរបស់ខ្លួននោះ ច្បាប់ថ្មីស្តីពី របបប្តីប្រពន្ធ អត្តប្រយោជន៍ និងសន្តតិកម្ម ត្រូវបានអនុម័តក្នុងឆ្នាំ ១៩៩៩។ ស្របពេលនឹងការអនុវត្តច្បាប់យឺតយ៉ាវ វាមានសារៈសំខាន់ក្នុងការទទួលស្គាល់សិទ្ធិមរតកដោយស្មើភាពគ្នាចំពោះកូនស្រី និងកូនប្រុសដោយបង្កើតជម្រើសរបបទ្រព្យសម្បត្តិលើអាពាហ៍ពិពាហ៍ និងដោយអនុញ្ញាតឲ្យស្ត្រីមេម៉ាយគ្រប់គ្រងទ្រព្យសម្បត្តិនោះ។

ក្នុងតំបន់ប៉ាស៊ីហ្វិច កម្មសិទ្ធិដីលើកោះស្ទើរតែទាំងអស់ គឺនៅតែគ្រប់គ្រងក្នុងលក្ខណៈជាកុលសម្ព័ន្ធ ហើយស្ថិតក្នុងដៃសមាជិកកុលសម្ព័ន្ធជាបុរស។ ជាលទ្ធផល ផ្ទះអាពាហ៍ពិពាហ៍ ឬដីកុលសម្ព័ន្ធមិនអាចចុះឈ្មោះដាក់សហព័ទ្ធទាំងពីរទេ ហើយវិភាគទានរបស់ស្ត្រី ទោះជាប្រាក់ក្តី និងមិនមែនប្រាក់ក្តីដល់ផ្ទះ ឬដីកុលសម្ព័ន្ធនោះ មិនត្រូវបានយកមកពិចារណាលើរាល់ការទាមទារណាមួយបានឡើយ។ មេកុលសម្ព័ន្ធជាអ្នកសម្រេចចិត្ត និងនៅស្ទើរតែគ្រប់ទីកន្លែងទាំងអស់ ស្ត្រីមិនអាចក្លាយជាមេកុលសម្ព័ន្ធបានទេ។ ច្បាប់និងការអនុវត្តតាមទំនៀមទម្លាប់បន្តឲ្យមានប្រព័ន្ធបីតានិយម ដែលរើសអើងចំពោះស្ត្រី ជាពិសេស ទាក់ទងនឹងមរតក។ ប្រព័ន្ធកម្មសិទ្ធិកុលសម្ព័ន្ធមានលក្ខណៈរឹងមាំលើបណ្តាកោះជាច្រើន ដែលគេទទួលស្គាល់សូម្បីក្នុងប្រព័ន្ធច្បាប់ផ្លូវការ។

*មរតកនៅប្រទេសតុងហ្កា*

នៅប្រទេសតុងហ្កា ទាំងតាមច្បាប់រដ្ឋ ទាំងច្បាប់ទំនៀមទម្លាប់ ការត្រួតត្រា និងកម្មសិទ្ធិដីធ្លី និងលំនៅឋាន មានភាពជាក់លាស់ចំពោះបុរស ហើយបន្តទៅឲ្យទាយាទជាបុរស។ ស្ត្រីមេម៉ាយមានសិទ្ធិលើទ្រព្យរបស់ស្វាមី រហូតដល់ស្ត្រីនោះស្លាប់ រៀបអាពាហ៍ពិពាហ៍ម្តងទៀត ឬរួមសង្វាសក្រៅចំណងអាពាហ៍ពិពាហ៍។ នៅឆ្នាំ២០១០ គណៈកម្មាធិការភូមិន្ទភូមិបាលបានទទួលអាណត្តិពិនិត្យលើច្បាប់ភូមិបាល និងការអនុវត្តនានា ដើម្បីធ្វើឲ្យការអនុវត្តកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល។ ទាក់ទងនឹងចំណុចនេះ មានការប្រជុំជាច្រើន ដែលបានគ្រោងឡើងក្នុងឆ្នាំ ២០១០ ប៉ុន្តែមកដល់ឆ្នាំ ២០១១ ច្បាប់ភូមិបាលនៅប្រទេសតុងហ្កានៅមិនទាន់បានធ្វើវិសោធនកម្មនៅឡើយ។

នៅបណ្តាប្រទេសអាហ្វ្រិកជាច្រើន មរតក ជាបញ្ហាមួយដែលស្ត្រីជួបប្រទះការរើសអើងយ៉ាងធ្ងន់ធ្ងរ ដោយសារមានចែងទាំងក្នុងច្បាប់រដ្ឋ ក៏ដូចជាក្នុងច្បាប់ និងការអនុវត្តតាមបែបទំនៀមទម្លាប់។ ស្ត្រីមេម៉ាយជាច្រើនត្រូវបានផាត់ចេញពីការទទួលមរតក ហើយកូនស្រីទទួលមរតកដោយកម្រណាស់។ អាត្រាខ្ពស់នៃមេរោគអេដស៍/ជំងឺអេដស៍ ក្នុងតំបន់បានធ្វើឲ្យបញ្ហាទាក់ទងនឹងមរតកនេះកាន់តែធ្ងន់ធ្ងរឡើង។[34] ស្ត្រីមេម៉ាយជាច្រើន ទោះរស់នៅតំបន់ជនបទក្តី ឬតំបន់ទីក្រុងក្តី ត្រូវបានរងការដកហូតទ្រព្យសម្បត្តិរបស់ខ្លួន រួមទាំងដីធ្លី ផ្ទះសំបែង យានជំនិះ សត្វចិញ្ចឹម គ្រឿងសង្ហារឹម និងប្រដាប់ប្រើប្រាស់ក្នុងផ្ទះ ក្រោយពីមរណភាពនៃស្វាមីរបស់ខ្លួន។ មរតករបស់ស្ត្រីមេម៉ាយអាចប្រែប្រួលទៅតាមស្ថានភាព។ ក្នុងករណីមួយចំនួន ស្ត្រីមេម៉ាយអាច

[34] បទដ្ឋានទ្វេរ ទំព័រទី ១៦។

ត្រូវបង្ខិតបង្ខំឲ្យអនុវត្តតាមបែបទំនៀមទម្លាប់ជា "ភរិយាមរតក" ដែលស្ត្រីមេម៉ាយ "ជាមរតក" ត្រូវប្រគល់ឲ្យទៅសាច់ញាតិប្រុសរបស់ស្វាមីដែលស្លាប់។ ស្ត្រីជាច្រើនមិនអាចរស់នៅក្នុងផ្ទះរបស់ខ្លួន ឬលើដីធ្លីរបស់ខ្លួនបានទេ ប្រសិនបើស្ត្រីនោះមិនត្រូវបានគេ "ទទួលយកជាមរតក" នោះ។ ស្ត្រីដែលបដិសេធមិនព្រមឲ្យគេ "យកជាមរតក" ទេ បានក្លាយខ្លួនជាជនក្រៅសង្គម ហើយពិបាកនឹងរស់នៅណាស់ ដោយសារតែពួកគាត់បានបាត់បង់ផ្ទះសំបែង និងដីធ្លី ពោលគឺបាត់បង់ជីវភាពរស់នៅរបស់ពួកគាត់។ បន្ថែមរឿង ភរិយាមរតកនេះ គឺ "ការអនុវត្តលាងជម្រះ" ដែលកើតមានក្នុងសហគមន៍មួយចំនួន។ ដើម្បី "លាងជម្រះ" ឲ្យអស់ព្រលឹងស្វាមីរបស់ខ្លួន ស្ត្រីនោះត្រូវបង្ខំឲ្យរួមរក្សជាមួយជនក្រៅសង្គមម្នាក់ ដែលជននេះត្រូវបានគេបង់ប្រាក់ថ្លៃ "សេវា" រួមរក្សនោះ។ ជារឿយៗ វាជាលក្ខខណ្ឌសម្រាប់ឲ្យស្ត្រីមេម៉ាយនោះ អាចរក្សាផ្ទះសំម្បែង និងរបស់របររបស់គាត់បាន។ ស្ត្រីដែលបដិសេធមិនធ្វើពិធីនោះ ត្រូវរងការបណ្តេញចេញ ដោយសាច់ថ្លៃរបស់នាង។ ដូច្នេះ ជារឿយៗ ជម្រើសគឺវិលត្រឡប់ទៅផ្ទះឪពុកម្តាយរបស់គាត់វិញ ឬទៅកាត់តំបន់ទីក្រុង ភាគច្រើន ជាតំបន់ក្រីក្រមិនរៀបរយតាមទីប្រជុំជន។

***ឧទាហរណ៍អំពីច្បាប់ដែលមានការរើសអើងនៅទ្វីបអាហ្វ្រិកប៉ះពាល់លើសិទ្ធិស្មើភាពគ្នារបស់ស្ត្រីក្នុងការទទួលមរតក***

នៅប្រទេសប៊ូស្វាណា រដ្ឋធម្មនុញ្ញទទួលស្គាល់សមភាពយេនឌ័រជាពិសេស។ ទោះយ៉ាងណាក្តី តាមច្បាប់ទំនៀមទម្លាប់ ស្ត្រីរងការរើសអើងក្នុងការទទួលបានទ្រព្យសម្បត្តិ មរតក និងកត្តាផ្សេងៗទៀត។ នៅពេលស្វាមីរបស់គាត់ស្លាប់ ស្ត្រីមេម៉ាយប្រឈមនឹងការគំរាមកំហែងពីការបាត់បង់ផ្ទះសំបែង និងទ្រព្យសម្បត្តិរបស់គាត់។[ក]

ផ្នែកទី១៦ នៃច្បាប់ស្តីពីការចុះបញ្ជីកម្មសិទ្ធិរបស់ប្រទេសស្វាហ្ស៊ីលែន មិនបានរាប់បញ្ចូលការចុះបញ្ជីបណ្ណកម្មសិទ្ធិដីមានឈ្មោះជាស្ត្រីដែលរៀបការមានទ្រព្យសម្បត្តិរួមនោះទេ ទោះបីជាថ្មីៗនេះ ចៅក្រមបញ្ជាថា បញ្ញត្តិដែលមានការរើសអើងទាំងឡាយនេះ ត្រូវលុបចេញពីច្បាប់ទាំងឡាយរបស់ប្រទេសក្តី។

នៅប្រទេសអ៊ូហ្គង់ដា ទោះបីជា បញ្ញត្តិក្នុងរដ្ឋធម្មនុញ្ញហាមប្រាមការរើសអើងចំពោះស្ត្រី និងកុមារ និងច្បាប់ភូមិបាលដែលផ្តល់សិទ្ធិ និងការការពារចំពោះស្ត្រី និងកុមារក៏ដោយ ក៏តាមច្បាប់ទំនៀមទម្លាប់ចែងថា "ស្ត្រីមិនកាន់កាប់ដីធ្លីទេ"។ ច្បាប់មរតក ផ្តល់មរតកឲ្យស្ត្រីមេម៉ាយចំនួនតែ ១៥ ភាគរយ ប៉ុណ្ណោះ ប្រសិនបើស្វាមីរបស់គាត់ស្លាប់ដោយគ្មានមតកសាសន៍ តែទោះបីជាយ៉ាងនេះក្តី មានការរាយការណ៍ថា គ្មានវិធីណាពង្រឹងឲ្យមានការទទួលបានសិទ្ធិដ៏តិចតួចនេះទេ ប្រសិនបើគ្រួសារខាងស្វាមីជំទាស់នឹងស្ត្រីមេម៉ាយនោះ។[ខ]

មាត្រា ២៣ នៃរដ្ឋធម្មនុញ្ញប្រទេសហ្ស៊ីមបាវេ ធានាការមិនរើសអើងទាំងក្នុងច្បាប់ និងការអនុវត្តជាពិសេស ដោយសារមូលដ្ឋានភេទ ក៏ប៉ុន្តែ រដ្ឋធម្មនុញ្ញនេះធ្វើការលើកលែងរាល់ច្បាប់ទាំងអស់ជាពិសេសទាក់ទងនឹងស្ម័គ្រកូន អាពាហ៍ពិពាហ៍ ការលែងលះ ឬការចាត់ចែងទ្រព្យសម្បត្តិពេលមរណភាព។

មាត្រា ២៣ នៃរដ្ឋធម្មនុញ្ញប្រទេសហ្ស៊ីមបាវេ ការពារសមភាពនិងការមិនរើសអើង។ ក៏ប៉ុន្តែ ផ្នែកទី ២៣(៣) អនុញ្ញាតឲ្យមានការលើកលែងនានា ជាពិសេស ទាក់ទងនឹងបញ្ហានានានៃច្បាប់ផ្ទាល់ខ្លួន និងការអនុវត្ត "ច្បាប់ទំនៀមទម្លាប់អាហ្វ្រិក"។

[ក] UN-Habitat បញ្ជីសារពើភណ្ឌដីធ្លី នៅប៊ូស្វាណា ដំណើរការ និងមេរៀន (ឆ្នាំ២០១០) ទំព័រទី ៤២។

[ខ] UN-Habitat និងUSAID គោលការណ៍ណែនាំស្តីពីច្បាប់ទ្រព្យនៅអ៊ូហ្គង់ដា(ឆ្នាំ២០០៧)ទំព័រទី៤២-៤៣។

នៅអាហ្វ្រិកខាងជើង និងមជ្ឈិមបូព៌ា ស្ត្រីនៅតែបន្តជួបប្រទះការរើសអើង ដោយសារតែការអនុវត្តច្បាប់ និងការអនុវត្តតាមទំនៀមទម្លាប់ ដែលជារឿយៗត្រូវបានឆ្លុះបញ្ចាំងក្នុងច្បាប់រដ្ឋ។ វិធានគ្រប់គ្រងមរតកមានឫសគល់ក្នុងសាសនាឥស្លាម និងការបកស្រាយរបស់សាសនានេះ ដែលក្នុងនោះស្ត្រីទទួលបានចំណែកតិចជាងសមភាគីបុរស ជាធម្មតា ពាក់កណ្តាលនៃចំនួនដែលសាច់ញាតិជាបុរសអាចទទួលបាន ទោះជាជាប់សាច់ញាតិក្នុងកម្រិតដូចគ្នាជាមួយបុគ្គលដែលស្លាប់នោះក៏ដោយ។ ស្ត្រីក៏មានទំនោរបោះបង់ចោលចំណែករបស់ខ្លួន ក្រោមសម្ពាធសង្គម និងគ្រួសារ។ នៅតួកគី ជាប្រទេសដែលលើកតម្កើងច្បាប់រដ្ឋនោះ ស្ត្រី និងបុរសអាចទទួលមរតកទ្រព្យសម្បត្តិដោយស្មើភាពគ្នា។ ទោះជាយ៉ាងណាក្តី ប្រពៃណីបានធ្វើឲ្យការអនុវត្តច្បាប់មានការលំបាក។ ប្រសិនបើស្ត្រីទាមទារសិទ្ធិមរតកដោយស្មើភាពនោះ ពួកគាត់អាចប្រឈមនឹងអំពើហិង្សា ការគំរាមកំហែង ការយាយី ក៏ដូចជាការផាត់ចេញពីសង្គម។ នៅប្រទេសហ្សកដង់ សហគមន៍ខ្លះគិតថាវាជារឿងគួរឲ្យអាម៉ាស់សម្រាប់ស្ត្រីដែលទទូចចង់បានមរតករបស់ខ្លួន ដោយវាបង្ហាញឲ្យឃើញថា បងប្អូនប្រុសរបស់ស្ត្រីនោះ មិនចង់ ឬគ្មានលទ្ធភាពដើម្បីចិញ្ចឹមនាង។ សូម្បីតែស្ត្រីទទួលបានចំណែកសមរម្យរបស់គាត់ហើយក៏ដោយ ក៏ការត្រួតត្រាពិតប្រាកដលើមរតកនោះមិនមែនជារឿងងាយស្រួលឡើយ ហើយប្រសិនបើគាត់ទទូចចង់គ្រប់គ្រងមរតកដោយឯករាជ្យ គាត់អាចបាត់បង់ការគាំទ្រពីមនុស្សដែលគាត់ពឹងពាក់លើរឿងលំនៅឋាន និងប្រាក់កាក់។

*កំណែទម្រង់ក្រមស្តីពីគ្រួសារនៅប្រទេសម៉ារ៉ុក៖ វិសមភាពដែលនៅតែមានទាក់ទងនឹងមរតក*

នៅប្រទេសម៉ារ៉ុក ក្រមស្តីពីគ្រួសារ *(មូដាវ៉ាណា)* អនុម័តក្នុងឆ្នាំ២០០៤ បណ្តាលឲ្យមានកំណែទម្រង់ជាច្រើនក្នុងគោលបំណងបញ្ចូលគោលការណ៍សមភាព និងការមិនរើសអើង។ ទោះយ៉ាងណាក៏ដោយ វិសមភាពរវាងបុរស និងស្ត្រី នៅតែបន្តមានទាក់ទងនឹងការលែងលះ និងមរតក។ ហេតុដូច្នេះហើយ ជាធម្មតា ស្ត្រីទទួលបានចំណែកតិចជាងបុរស។ ក្នុងករណីខ្លះ ស្ត្រីនឹងមិនទទួលបានចំណែកថែមទៀតផង ពីព្រោះ៖ (១)ឪពុកបានឲ្យចំណែកខ្លះ ឬទាំងអស់នៃទ្រព្យសម្បត្តិទៅកូនប្រុសៗមុនគាត់ស្លាប់ (២) ឪពុកបង្កើតមូលនិធិទាយជ្ជទានដែលផ្តល់ប្រយោជន៍ទាំងស្រុងដល់កូនប្រុសៗរបស់គាត់ (៣)ស្ត្រីបោះបង់ចំណែករបស់ខ្លួនឲ្យទៅបងប្អូនប្រុសរបស់ខ្លួន ដោយសារការរងសម្ពាធ ឬដើម្បីរក្សាទំនាក់ទំនងល្អក្នុងគ្រួសាររបស់ខ្លួន។

*ប្រភព៖* មជ្ឈមណ្ឌលស្តីពីសិទ្ធិលំនៅឋាន និងការបណ្តេញចេញ ការតាមស្វែងរកសមភាព៖ ការស្ទង់មតិអំពីច្បាប់ និង

ការអនុវត្តទាក់ទងនឹងសិទ្ធិទទួលបានមរតករបស់ស្ត្រីក្នុងតំបន់មជ្ឈិមបូព៌ា និងអាហ្វ្រិកខាងជើង (ក្រុងហ្សឺណែវ ឆ្នាំ២០០៦) ទំព័រទី ៧៥

*ដែនដីប៉ាគីស្ថានកាន់កាប់ ៖ វិធានការដោះស្រាយការបោះបង់មរតកដោយស្ត្រី*

ដើម្បីបង្អាក់ទឹកចិត្តកុំឲ្យស្ត្រីបោះបង់ចោលចំណែកមរតករបស់ខ្លួនទៅឲ្យសាច់ញាតិជាបុរសក្នុងដែនដីប៉ាគីស្ថានដែលត្រូវបានកាន់កាប់ ប្រធានក្រុមប្រឹក្សាជាន់ខ្ពស់នៃយុត្តាធិការសារីយ៉ា និងប្រធានតុលាការកំពូលសារីយ៉ា បានចេញសេចក្តីជូនដំណឹងមួយក្នុងឆ្នាំ ២០១១ ដែលកំណត់លក្ខខណ្ឌមួយចំនួនមុនស្ត្រីណាម្នាក់ត្រូវបានចាត់ទុកថាអាចបោះបង់ចំណែកមរតករបស់ខ្លួនដោយស្របច្បាប់បាន។ លក្ខខណ្ឌទាំងនោះរួមមាន យ៉ាងហោចណាស់ បួនខែបន្ទាប់ពីមរណភាពរបស់បុគ្គលនោះ មុនពេលដែលការបោះបង់អាចត្រូវបានចុះបញ្ជី។[ក] អាជ្ញាធរពាក់ព័ន្ធក៏តម្រូវឲ្យផ្ទៀងផ្ទាត់តម្លៃពិតប្រាកដនៃមរតកនោះដោយផ្អែកលើរបាយការណ៍ដែលធ្វើដោយអ្នកជំនាញបីរូបដែលត្រូវប្រគល់អំណាចដោយសាលាក្រុង ឬក្រុមប្រឹក្សាមូលដ្ឋាន។

[ក] សេចក្តីជូនដំណឹងលេខ ៥៧/២០១១ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១ ដោយប្រធានក្រុមប្រឹក្សាជាន់ខ្ពស់នៃ យុត្តាធិការសារីយ៉ា និងប្រធានតុលាការកំពូលសារីយ៉ា។

នៅក្នុងគ្រួសារខ្លះដែលមានការកាន់កាប់ដីធំក្នុងតំបន់សិន្ធ និងបុញ្ជាប់ក្រោម នៅប្រទេសប៉ាគីស្ថាន សេចក្តីត្រូវការដែលគេមើលឃើញដើម្បី "រក្សាទ្រព្យសម្បត្តិក្នុងគ្រួសារ" បានបង្ហាញដោយឯកឯងក្នុងពិធីនានាដូចជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬ ហាកបាកស្វាណា (បោះបង់ចោលសិទ្ធរបស់ខ្លួន)។ ក្នុងគ្រួសារដែលស្ត្រីណាម្នាក់មិនអាចរកគូអនាគតបាន ស្ត្រីនោះត្រូវ "រៀបការ" ជាមួយនឹងគម្ពីរកូរអាន ដោយត្រូវស្ថិតនៅជាស្រីសៅកែអស់មួយជីវិត រស់នៅពឹងពាក់លើបងប្អូនប្រុស និងសាច់ញាតិជាបុរស។

នៅប្រទេសហ្សកហ្ស៊ី ច្បាប់តាមទំនៀមទម្លាប់ចែងថា ភាគច្រើនបំផុតនៃទ្រព្យសម្បត្តិគ្រួសារនឹងត្រូវទទួលជាមរតកដោយកូនប្រុស។ នៅប្រទេសអាហ្ស៊ែបៃហ្សង់ នៅពេលកូនស្រីរៀបអាពាហ៍ពិពាហ៍ហើយចាកចេញពីផ្ទះរបស់នាង ឪពុករបស់នាងនិយាយថា "ចាប់ពីពេលនេះតទៅ មានតែសពរបស់ឯងតែប៉ុណ្ណោះទើបអាចត្រឡប់មកផ្ទះវិញបាន"។ ប្រសិនបើកូនស្រីនោះត្រឡប់មកផ្ទះ ឪពុករបស់នាង និងសហគមន៍នឹងដាក់សម្ពាធឲ្យនាងត្រឡប់ទៅកាន់គ្រួសារខាងស្វាមីរបស់នាងវិញ ពីព្រោះឥឡូវ គាត់ជាចំណែកនៃគ្រួសារខាងប្រុស ហើយលែងជា "បន្ទុក" នៃឪពុកម្តាយរបស់គាត់ទៀតហើយ។ តាមរយៈការប្រតិបត្តិវប្បធម៌ទាំងនេះ ស្ត្រីនឹងមិនបានទទួលមរតកជាលំនៅឋាន ឬទ្រព្យសម្បត្តិពីគ្រួសារដែលខ្លួនកើត ឬគ្រួសារដែលខ្លួនរៀបការទៅនៅជាមួយនោះទេ។

*ការទទួលមរតកក្នុងប្រទេស និងសហគមន៍ឥស្លាម*

អ្នករាយការណ៍ពិសេសទីមួយបានពិនិត្យមើលច្បាប់គ្រួសារ និងមរតកក្នុងប្រទេស និងសហគមន៍ឥស្លាម ព្រមទាំងផលប៉ះពាល់ចំពោះសិទ្ធិស្ត្រីក្នុងការមានលំនៅឋានសមរម្យ។ ច្បាប់ដែលកើតចេញពីសាសនា

ឥស្លាម ជាពិសេសច្បាប់សារីយ៉ា និងការបកស្រាយយុត្តិសាស្ត្រ (ហ្វីគ) មានឥទ្ធិពលធំធេងលើជីវិតគ្រួសារ ដោយគ្របដណ្តប់លើបញ្ហាជាច្រើន ដូចជា ការលែងលះ ពហុពន្ធភាព ការដោះស្រាយបញ្ហាទ្រព្យសម្បត្តិទាក់ទងនឹងការលែងលះ និងមរតក។

ការបកស្រាយតាមប្រពៃណីរបស់ច្បាប់ឥស្លាម ដែលជារឿយៗ អនុវត្តតាមច្បាប់រដ្ឋនោះ ជាធម្មតាផ្តល់ឲ្យទាយាទជាស្ត្រីទទួលនូវចំណែកតិចជាងទាយាទជាបុរស។ ការទទួលចំណែកមរតកដោយមិនស្មើភាពគ្នារបស់ស្ត្រីក្នុងប្រទេស និងសហគមន៍កាន់សាសនាឥស្លាម មិនមែនកើតឡើងដោយសារតែសាសនា ឥស្លាមទាំងស្រុង និង/ឬដោយផ្ទាល់នោះទេ ប៉ុន្តែ បានវិវត្តតាមរយៈប្រពៃណីសង្គមវប្បធម៌។ ដូច្នេះហើយ គេអាចមើលឃើញភាពខុសគ្នាយ៉ាងខ្លាំងនៅតាមបណ្តាប្រទេស ឬសហគមន៍កាន់សាសនាឥស្លាម។

យុត្តាធិការនិកាយស៊ីអ៊ិតផ្តល់មរតកទាំងស្រុង ឯការបកស្រាយរបស់និកាយសុននីខ្លះ អនុញ្ញាតឲ្យកូនស្រីទោលដែលនៅរស់ទទួលបានត្រឹមតែពាក់កណ្តាលនៃមរតកទាំងអស់ ឬអនុញ្ញាតឲ្យកូនស្រីដែលមានចំនួនពីរនាក់ ឬច្រើនជាងពីរនាក់ ទទួលបានមរតកច្រើនបំផុតត្រឹមពីរភាគបីប៉ុណ្ណោះ។ នៅសាធារណរដ្ឋឥស្លាមអ៊ីរ៉ង់ អ្នករាយការណ៍ពិសេសបានកត់សម្គាល់ថាជាក្រឹត្យក្រម ស្ត្រីមានសិទ្ធិទទួលបានមរតកចំនួនពាក់កណ្តាលនៃមរតកដែលបុរសអាចនឹងទទួលបាន និងនៅពេលស្ត្រីមេម៉ាយទទួលមរតកពីស្វាមីរបស់គាត់ ស្ត្រីនោះមិនអាចមានសិទ្ធិទទួលមរតកជាដីធ្លីទេ ដោយមានសិទ្ធិទទួលបានត្រឹមតែទ្រព្យសកម្មប៉ុណ្ណោះ។ ចំណែកក្នុងមរតករបស់ស្វាមីដែលជារបស់ស្ត្រីម៉េម៉ាយ គឺមានតែមួយភាគប្រាំបីប៉ុណ្ណោះ ប្រសិនបើគាត់មានកូន ឬបានមួយភាគបួន ប្រសិនបើគាត់មិនមានកូនទេ។

ទន្ទឹមនឹងការទទួលស្គាល់នូវចម្រុះភាពនៃសហគមន៍ឥស្លាមនេះ អ្នករាយការណ៍ពិសេសក៏បានរកឃើញថា វិធីសាស្ត្រទាំងពីរនេះបានប៉ះពាល់ដល់ស្ត្រី៖ ទោះបីជាសាសនាឥស្លាមទទួលស្គាល់សិទ្ធិស្ត្រីក្នុងការទទួលមរតកជាទ្រព្យសម្បត្តិក៏ដោយ ក៏ចំណែកដែលមិនស្មើភាពគ្នារបស់ស្ត្រីក្នុងមរតកប្រៀបធៀបទៅនឹងបុរសនោះ គឺជាការរើសអើង ហើយមិនស្របនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិទេ។ ម្យ៉ាងទៀត តាមទំនៀមទម្លាប់ ជារឿយៗ ស្ត្រីត្រូវគេបង្ខំឲ្យលះបង់សិទ្ធិលើទ្រព្យសម្បត្តិរបស់ខ្លួនទៀតផង។ អ្នកអត្ថាធិប្បាយសាសនាឥស្លាមខ្លះ ដូចជាលោក ស៊ីរិន អេបាឌី ដែលជាជ័យលាភីរង្វាន់សន្តិភាព និងជាអ្នកច្បាប់សិទ្ធិមនុស្ស ព្រមទាំងអ្នកផ្សេងទៀត បានចង្អុលបង្ហាញថា ក្នុងការប្រៀនប្រដៅដើមនៃសាសនាឥស្លាមតាមគម្ពីរកូរអាន និងតាមនិកាយសារីយ៉ា គេមិនឃើញមានអ្វីដែលរារាំងការបកស្រាយដែលផ្តល់ដល់ស្ត្រី និងបុរសនូវសិទ្ធិស្មើភាពគ្នាក្នុងបញ្ហាមរតកនោះឡើយ។

*ប្រភព:* E/CN.4/2006/118.

ខណៈដែលការនិយមចំពោះទាយាទជាបុរស នៅតែជាក្រឹត្យក្រមក្នុងប្រទេសជាច្រើនក្នុងពិភពលោកនោះ ក៏មានវប្បធម៌ខ្លះនិយមជ្រើសរើសយកទាយាទជាស្ត្រីដែរ។ ឧទាហរណ៍ ប្រជាជនខាស៊ី នៅប្រទេសឥណ្ឌាភាគឥសាន អនុវត្តប្រព័ន្ធខ្សែស្រឡាយខាងម្តាយទៅលើមរតក ដែលបញ្ជាក់ថា មានតែកូនស្រីពៅក្នុងគ្រួសារប៉ុណ្ណោះ មានសិទ្ធិទទួលមរតកទ្រព្យសម្បត្តិដូនតា។ នៅប៊ូហ្សាំងវីល៍ ប្រទេសប៉ាពួញូហ្គីនី

ប្រព័ន្ធខ្សែស្រឡាយខាងម្តាយនៃជនជាតិដើមភាគតិច ដែលស្ត្រីកាន់កាប់ និងទទួលមរតក គឺនៅតែអនុវត្តនាពេលបច្ចុប្បន្ន។

## ខ. ការបណ្តេញចេញដោយបំពាន

ការបណ្តេញចេញដោយបំពានធ្វើឡើងតាមកាលៈទេសៈជាច្រើន និងដោយហេតុផលជាច្រើន ដូចជា ដើម្បីគម្រោងអភិវឌ្ឍន៍ និងហេដ្ឋារចនាសម្ព័ន្ធ គម្រោងអភិវឌ្ឍន៍ទីក្រុងឡើងវិញ ឬគម្រោងកែលម្អទីក្រុង ជម្លោះដីធ្លី ការលុបចោល ឬការបន្ថយការឧបត្ថម្ភលំនៅឋានសម្រាប់ក្រុមមនុស្សដែលមានចំណូលតិច ការផ្ទេរប្រជាជនដោយបង្ខំ និងការតាំងទីលំនៅថ្មីដោយបង្ខំ ក្នុងបរិបទជម្លោះប្រដាប់អាវុធ។ គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានកត់សម្គាល់ក្នុងការផ្តល់យោបល់ទូទៅរបស់ខ្លួនលេខ៧ (ឆ្នាំ១៩៩៧) ថា ស្ត្រីទំនងជាទទួលរងផលប៉ះពាល់ដោយមិនសមមាត្រ។

***និយមន័យនៃការបណ្តេញចេញដោយបំពានក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ***

ការការពារប្រឆាំងការបណ្តេញចេញ ជាធាតុសំខាន់នៃសិទ្ធិមនុស្សចំពោះការមានលំនៅឋានសមរម្យ ហើយជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយសុវត្ថិភាពនៃការកាន់កាប់។ ការបណ្តេញចេញដោយបំពានត្រូវបានកំណត់និយមន័យថាជា "ការផ្លាស់ចេញពីលំនៅឋាន ឬដីធ្លីជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្ន ដោយផ្ទុយនឹងឆន្ទៈរបស់បុគ្គលម្នាក់ៗ របស់ក្រុមគ្រួសារទាំងឡាយ និង/ឬរបស់សហគមន៍ទាំងមូល ដែលពួកគាត់កាន់កាប់ដោយគ្មានការការពារតាមច្បាប់សមស្រប ឬគ្មានសិទ្ធិទទួលបាននូវការការពារតាមច្បាប់ ឬតាមមធ្យោបាយផ្សេងៗទៀតឡើយ។"[a]

ដោយមិនគិតពីបុព្វហេតុ ការបណ្តេញចេញដោយបង្ខំត្រូវបានចាត់ទុកថា ជាការរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្ស និងការរំលោភសិទ្ធិមូលដ្ឋានចំពោះសិទ្ធិមានលំនៅឋានសមរម្យ។ ការបណ្តេញចេញទ្រង់ទ្រាយធំជាទូទៅ អាចត្រឹមត្រូវតាមផ្លូវច្បាប់ទៅបានតែក្នុងករណីកាលៈទេសៈពិសេសបំផុតប៉ុណ្ណោះ និងស្របតាមគោលការណ៍ច្បាប់អន្តរជាតិដែលពាក់ព័ន្ធប៉ុណ្ណោះ។

ប្រសិនបើការបណ្តេញចេញនោះអាចត្រឹមត្រូវតាមផ្លូវច្បាប់ ពីព្រោះតែអ្នកកាន់កាប់ មិនអាចបង់ថ្លៃជួលជាប់ៗគ្នា ឬធ្វើឲ្យខូចខាតទ្រព្យសម្បត្តិដោយមិនមានហេតុផលសមរម្យ រដ្ឋត្រូវធានាថា ការបណ្តេញចេញប្រព្រឹត្តដោយស្របច្បាប់ សមហេតុសមផល និងសមាមាត្រ ហើយស្របតាមច្បាប់អន្តរជាតិ។ ឧបាស្រ័យ និងដំណោះស្រាយតាមច្បាប់ត្រូវមានចំពោះបុគ្គលទាំងឡាយដែលត្រូវបណ្តេញចេញ ដោយរួមមានសំណងសមរម្យចំពោះអចលនទ្រព្យ ឬចលនទ្រព្យដែលប៉ះពាល់ដោយការបណ្តេញចេញនោះ។ ការបណ្តេញចេញទាំងឡាយមិនអាចធ្វើឲ្យបុគ្គលណាម្នាក់ក្លាយខ្លួនជាបុគ្គលអត់ផ្ទះសំបែង ឬរងគ្រោះចំពោះការរំលោភសិទ្ធិមនុស្សថែមទៀតឡើយ។

ជាទូទៅ ច្បាប់សិទ្ធិមនុស្សតម្រូវឲ្យរដ្ឋនានាស្រាវជ្រាវរិះរកវិធីទាំងឡាយណាដែលអាចធ្វើបាន មុននឹងអនុវត្តការបណ្តេញចេញ ដើម្បីជៀសវាង ឬយ៉ាងហោចណាស់ បន្ថយជាអប្បបរមា តម្រូវការនៃការប្រើប្រាស់

កម្លាំង។ នៅពេលអនុវត្តការបណ្តេញចេញជាមធ្យោបាយចុងក្រោយ អ្នកដែលរងគ្រោះត្រូវទទួលបាននូវកិច្ចធានាផ្នែកនីតិវិធីប្រកបដោយប្រសិទ្ធភាព ដែលកិច្ចធានានេះអាចមានឥទ្ធិពលរារាំងដល់ការបណ្តេញចេញដែលបានគ្រោងទុក។ ការធានាទាំងនេះរួមមាន៖

- ឱកាសទទួលបានការពិគ្រោះយោបល់ដោយពិតប្រាកដ
- ការជូនដំណឹងគ្រប់គ្រាន់ និងសមហេតុផល
- ការមានព័ត៌មានស្តីពីការបណ្តេញចេញដែលបានស្នើឡើងក្នុងរយៈពេលមួយសមស្រប
- វត្តមានមន្ត្រីរដ្ឋាភិបាល ឬអ្នកតំណាងអំឡុងពេលបណ្តេញចេញ
- ការបង្ហាញអត្តសញ្ញាណជាក់លាក់នៃអ្នកដែលអនុវត្តការបណ្តេញចេញ
- ការហាមឃាត់សកម្មភាពបណ្តេញចេញនៅពេលមានអាកាសធាតុមិនល្អ ឬនៅពេលយប់
- ការមានដំណោះស្រាយតាមផ្លូវច្បាប់
- ការមានជំនួយផ្នែកច្បាប់សម្រាប់អ្នកដែលមានតម្រូវការ ដើម្បីអាចស្វែងរកដំណោះស្រាយតាមផ្លូវតុលាការបាន។

[ក] ការផ្តល់យោបល់ទូទៅលេខ៧ (ឆ្នាំ១៩៩៧) កថាខណ្ឌទី ៣។ គណៈកម្មាធិការកត់សម្គាល់ជាបន្តទៀតថា "ទោះជា យ៉ាងណាក៏ដោយ ការហាមឃាត់ការបណ្តេញចេញដោយបំពានមិនអនុវត្តនោះទេ ចំពោះការបណ្តេញចេញដោយប្រើកម្លាំងស្របតាមច្បាប់ និងស្របតាមបទប្បញ្ញត្តិនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស"។

ជារឿយៗ ស្ត្រីប្រឈមនឹងអំពើហិង្សានិងភាពតានតឹងក្នុងអារម្មណ៍មុនពេល អំឡុងពេល និងក្រោយពេលបណ្តេញចេញ ពីព្រោះតែចំណងទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងផ្ទះ និងតួនាទីរបស់ស្ត្រីនៅក្នុងផ្ទះដែលជាទីកន្លែងផ្តល់ការថែទាំដល់ក្រុមគ្រួសារទាំងមូល [35]។

មុនការបណ្តេញចេញ ភាពតានតឹងផ្លូវចិត្តកើតឡើងនៅពេលដឹងថា ការបណ្តេញចេញអាចធ្វើឲ្យបរិយាកាសគ្រួសារលែងមានលំនឹង ហើយបណ្តាលឲ្យមានអារម្មណ៍ភ័យតក់ស្លុត។ ពេលខ្លះ ការរំលោភសេពសន្ថវៈក៏ត្រូវបានប្រព្រឹត្តិដោយអ្នកទៅបណ្តេញគេចេញផងដែរ ដើម្បីយកឈ្នះលើការមិនព្រមចាកចេញ[36]។

តួនាទីរបស់ស្ត្រីក្នុងការរៀបចំផ្ទះសំបែងមានន័យថា គាត់អាចជាមនុស្សតែម្នាក់ដែលនៅក្នុងផ្ទះ នៅពេលមានការបណ្តេញចេញ ដោយគាត់ត្រូវជជែកតវ៉ា និងប្រឈមមុខនឹងអ្នកទៅបណ្តេញគាត់ចេញ។ ស្ត្រីអាចប្រឈមនឹងអំពើហិង្សាដោយសារពួកគាត់ជាគោលដៅ ដោយមានការគិតទុកជាមុនពីអ្នកទៅអនុវត្ត

[35] COHRE អំពើហិង្សា៖ ផលប៉ះពាល់នៃការបណ្តេញចេញលើស្ត្រីក្នុងប្រទេសប៉ាលេស្ទីន ឥណ្ឌា និងនីហ្សេរីយ៉ា (ឆ្នាំ២០០២) ទំព័រទី ៧៤-៧៥។

[36] "គោលនយោបាយសេដ្ឋកិច្ច និងសង្គម និងផលប៉ះពាល់នៃអំពើហិង្សាលើស្ត្រី" (E/CN.4/2000/68/Add.5 កថាខណ្ឌទី៥២-៥៧)។

ការបណ្តេញចេញ។ អំឡុងពេលបណ្តេញចេញ ការរំលោភបំពានដោយពាក្យសម្តី និងការវាយដំ ការរំលោភសេពសន្ថវៈ និងរហូតដល់ការសម្លាប់ តែងកើតមាន[37]។

ក្រោយពីការបណ្តេញចេញ ជារឿយៗ ស្ត្រីទទួលរងគ្រោះថែមទៀតចំពោះការរំលោភបំពាន។ ការខ្វះជម្រក និងភាពជាឯកជន អាចនាំឲ្យស្ត្រី ប្រឈមកាន់តែខ្លាំងឡើងចំពោះអំពើហិង្សាផ្លូវភេទ និងទម្រង់នៃអំពើហិង្សាដទៃទៀត។ ការបាត់បង់ជំនឿចិត្តលើខ្លួនឯងក្នុងចំណោមបុរស បណ្តាលមកពីការបាត់បង់លំនៅឋាន ដីធ្លី ឬជីវភាព អាចបង្ហាញឲ្យឃើញផងដែរក្នុងអំពើហិង្សាប្រឆាំងស្ត្រី។ ការចុះខ្សោយនៃជំនឿចិត្តលើខ្លួនឯង មានអារម្មណ៍ថាគ្មានការជួយឧបត្ថម្ភគាំទ្រ ការតានតឹងអារម្មណ៍ដែលកើនឡើង និងការភ័យខ្លាចរបស់ស្ត្រីក៏កាន់តែមានភាពខ្លាំងឡើងបន្ទាប់ពីការបណ្តេញចេញពីផ្ទះដោយបំពាន[38]។

***ការបណ្តេញចេញដោយបំពានក្នុងប្រទេសភូមា និងផលប៉ះពាល់លើស្ត្រី***

ជនជាតិសាន ជាង ៣០០០នាក់ មកពីភូមិប្រមាណចំនួន ១៤០០ភូមិ ត្រូវបានបណ្តេញចេញដោយបំពានពីសំណាក់ពួកយោធា ហើយឲ្យទៅតាំងទីលំនៅថ្មីនៅទីតាំងដែលគ្រប់គ្រងដោយយោធា។ មានសេចក្តីរាយការណ៍ថា ស្ត្រីជនជាតិសានត្រូវបានរងការរំលោភសេពសន្ថវៈ នៅមុនពេល អំឡុងពេល និង ក្រោយពេលនៃការតាំងទីលំនៅថ្មី៖ រវាងឆ្នាំ១៩៩៦ និងឆ្នាំ២០០៣ មានរបាយការណ៍ពីឧបទ្ទវហេតុនៃការរំលោភសេពសន្ថវៈ និងទម្រង់នៃអំពើហិង្សាដទៃទៀតប្រឆាំងស្ត្រី ចំនួន៣១១ករណី។

*ប្រភព៖ ការពិគ្រោះយោបល់តំបន់អាស៊ី។*

***ការបណ្តេញចេញដោយបំពាននៅប្រទេសឥណ្ឌូនេស៊ី និងផលប៉ះពាល់លើស្ត្រី***

ភស្តុតាងនានាដែលប្រមូលបាន អំឡុងពេលធ្វើការពិគ្រោះយោបល់ថ្នាក់តំបន់ នៅអាស៊ី បានគូសបញ្ជាក់ថា ការតតាំងគ្នាអំឡុងពេលបណ្តេញចេញដោយបំពានក្នុងប្រទេសឥណ្ឌូនេស៊ី មានពោរពេញទៅដោយអំពើហិង្សាដែលប្រព្រឹត្តិដោយអាជ្ញាធររដ្ឋ ដែលផ្តោតទិសដៅលើស្ត្រី។ អំឡុងពេលបណ្តេញចេញមានសេចក្តីរាយការណ៍ថា ស្ត្រីរងការរំលោភបំពានដោយសម្តី ការវាយដំ ការរំលោភសេពសន្ថវៈ និងការសម្លាប់។

ការបណ្តេញចេញដោយបំពានក៏ទំនងនឹងមានផលប៉ះពាល់ធំធេងលើស្ត្រី ពីព្រោះតែតួនាទីរបស់ស្ត្រីក្នុងផ្ទះ និងការរួមវិភាគទានធំធេង ព្រមទាំងការប្តេជ្ញាចិត្តក្នុងការទ្រទ្រង់គ្រួសារ។ ស្ត្រីមិនមែនរងគ្រោះត្រឹមតែការបាត់បង់ផ្ទះសំបែងរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែក៏មានការបាត់បង់ជីវភាព ទំនាក់ទំនង និងប្រព័ន្ធឧបត្ថម្ភរបស់ខ្លួនថែមទៀតផង។ ការបំផ្លិចបំផ្លាញសហគមន៍ទាំងមូលជះឥទ្ធិពលខ្លាំងណាស់ទៅលើស្ត្រី។ ទីកន្លែងដែលពួកគាត់ធ្លាប់ទៅមកដើម្បីស្វែងរកការឧបត្ថម្ភ និងទំនាក់ទំនងទៅវិញទៅមកក្នុងសង្គម ជារឿយៗ

[37] ដូចខាងលើ។

[38] អំពើហិង្សា៖ ផលប៉ះពាល់នៃការបណ្តេញដោយបំពានលើស្ត្រី ទំព័រទី ៧៤។

ត្រូវបាត់បង់អស់។ អ្នករាយការណ៍ពិសេសទីមួយទទួលបន្ទុកបញ្ហាអំពើហិង្សាលើស្ត្រីភេទបានកត់សម្គាល់ត្រង់ចំណុចនេះថា "នៅពេលដែលគ្រួសារទាំងមូលប៉ះពាល់ដោយការបណ្តេញចេញដោយបំពាន ជាថ្មីម្តងទៀតអ្នកដែលរងគ្រោះបំផុតនោះ គឺស្ត្រី។ ស្ត្រីនឹងត្រូវធ្វើការសម្របខ្លួនទៅនឹងកាលៈទេសៈថ្មី នឹងត្រូវបំពេញការទទួលខុសត្រូវរបស់ខ្លួនដូចពីមុន ប៉ុន្តែជាមួយនឹងមធ្យោបាយតិចតួចនោះ ស្ត្រីចាំបាច់ត្រូវធ្វើការងារខ្លាំងក្លាជាងមុនដើម្បីឲ្យតែបានរស់"[39]។

ប្រសិនបើកញ្ចប់សម្រាប់សំណង និងសម្រាប់ការតាំងទីលំនៅថ្មី ត្រូវបានផ្តល់ដល់អ្នកដែលប៉ះពាល់ដោយការបណ្តេញចេញដោយបំពាននោះ ស្ត្រីច្រើនតែខាតបង់ផលប្រយោជន៍ ដោយសារថា កញ្ចប់ទាំងនេះអាស្រ័យទៅតាមកម្មសិទ្ធិស្របច្បាប់នៃលំនៅឋាន ដីធ្លី ឬទ្រព្យសម្បត្តិ។ ក្នុងសង្គមជាច្រើន ស្ត្រីមិនមានសិទ្ធិស្របច្បាប់លើលំនៅឋាន ដីធ្លី ឬទ្រព្យសម្បត្តិនោះទេ ស្ត្រីមិនអាចមានសិទ្ធិទេ។ ស្ត្រីអាចត្រូវគេផាត់ចេញដោយសារតែនិយមន័យយេនឌ័ររបស់គ្រួសារមានលក្ខណៈលំអៀង ដែលសន្មត់ថា បុរសជាមេគ្រួសារហើយស្ត្រីជាអ្នករស់នៅក្នុងបន្ទុក។

*ប្រទេសកម្ពុជា៖ ការរើសអើងប្រឆាំងស្ត្រីភេទបន្ទាប់ពីការបណ្តេញចេញ*

ក្នុងករណីបណ្តេញចេញ មានរបាយការណ៍ស្តីពីស្ត្រីរងការរើសអើងនៅពេលប្រាស្រ័យទាក់ទងជាមួយមន្ត្រី និងក្រុមហ៊ុនឯកជន ដើម្បីចរចាអំពីសំណង លក្ខខណ្ឌនានាទាក់ទងនឹងការតាំងទីលំនៅថ្មី និងការទទួលបានសេវាមូលដ្ឋានទាំងឡាយ។ សម្រាប់ស្ត្រីជាមេគ្រួសារ ស្ថានភាពកាន់តែមានភាពអាក្រក់ ដោយមានការរាយការណ៍មកថា ស្ត្រីដែលមិនមានបុរសរួមដំណើរទៅជាមួយ បានទទួលសំណងតិច និងត្រូវគេផ្តល់ដីដែលមានទំហំតូចឲ្យនៅកន្លែងតាំងទីលំនៅថ្មី។

ការខ្វះសេវាមូលដ្ឋានទាំងឡាយ ដូចជា ទឹកស្អាត អនាម័យ ឬអគ្គិសនី ជារឿងធម្មតាដែលតែងតែមានបន្ទាប់ពីការបណ្តេញចេញ។ សូម្បីនៅពេលមានការតាំងទីលំនៅថ្មី ស្ត្រីទំនងនឹងក្លាយទៅជាអ្នកទទួលការខុសត្រូវក្នុងការធានាការផ្គត់ផ្គង់ទឹកស្អាតសម្រាប់គ្រួសារខ្លួន ហើយអាចជួបការយាយី ការវាយដំលើរូបកាយនិងការរំលោភសេពសន្ថវៈ នៅពេលធ្វើដំណើរផ្លូវឆ្ងាយទៅរកទឹក។ ការដឹកជញ្ជូនរបស់ធ្ងន់ៗ ក៏អាចបណ្តាលឲ្យមានផលប៉ះពាល់មិនល្អចំពោះសុខភាពរបស់ស្ត្រី។ ការខ្វះមណ្ឌលសុខភាពសមស្របដើម្បីឲ្យមានភាពជាឯកជននៅកន្លែងតាំងទីលំនៅថ្មី អាចបង្កើននូវភាពរងគ្រោះរបស់ស្ត្រីចំពោះអំពើហិង្សាផងដែរ ហើយអាចនាំមកនូវគំនិតស្លាកស្នាមទុរយសក្នុងសង្គម និងភាពឯកោ។

បញ្ហាមួយទៀតគឺថា ស្ត្រីអាចបាត់បង់ជីវភាពប្រចាំថ្ងៃរបស់ខ្លួនដោយសារតែការបណ្តេញចេញ។ ស្ត្រីជាច្រើនដែលរស់នៅតាមតំបន់ក្រីក្រក្នុងទីក្រុង និងតាមតំបន់រស់នៅមិនទាន់រៀបរយ បានប្រកបរបរលក់ដូរ ឬធ្វើការងារសាមញ្ញៗ។ ដោយសារកន្លែងតាំងទីលំនៅថ្មីជាធម្មតាស្ថិតនៅឆ្ងាយពីទីប្រជុំជនក្នុងទីក្រុង ដូច្នេះ

[39] E/CN.4/2000/68/Add.5 កថាខណ្ឌទី ៥៥។

សកម្មភាពទាំងនេះមានបញ្ហា ដោយសារការចំណាយលើមធ្យោបាយធ្វើដំណើរមានតម្លៃខ្ពស់។ ថ្វីត្បិតតែកញ្ចប់ស្តារនីតិសម្បទាក្រោយការបណ្តេញចេញ ពេលខ្លះ អាចរួមមានឱកាសការងារជាជម្រើសផ្សេងក្តី (ឧទាហរណ៍ ផ្តល់ការងារមួយសម្រាប់គ្រួសារមួយជាសំណង) ភាពលំអៀងផ្នែកយេនឌ័រក្នុងគ្រួសារ សហគមន៍ ឬសង្គមទាំងមូល ជាទូទៅ អាចរារាំងស្ត្រីពីការទទួលបានអត្ថប្រយោជន៍នៃឱកាសទាំងនេះ។ ម្យ៉ាងទៀតនោះ ជម្រើសរបស់ស្ត្រីចំពោះការងារផ្សេងអាចមានចំនួនតិចតួច ដោយសារតែកម្រិតទាបនៃជំនាញ ការអប់រំ បទពិសោធន៍ និងភាពបំលាស់ទី។

***គោលការណ៍មូលដ្ឋាន និងគោលការណ៍ណែនាំស្តីពី ការបណ្តេញចេញ និងការចាកចេញដោយបង្ខំចិត្ត ផ្អែកលើការអភិវឌ្ឍ៖ តម្រូវការយេនឌ័រជាក់លាក់***

២៦. រដ្ឋទាំងឡាយត្រូវធានាសិទ្ធិអាស្រ័យផលដោយស្មើភាពគ្នានូវផ្ទះសម្បែងសមរម្យសម្រាប់បុរស និងស្ត្រី។ ការធានានេះតម្រូវឲ្យរដ្ឋអនុម័ត និងអនុវត្តវិធានការពិសេសដើម្បីការពារស្ត្រីពីការបណ្តេញចេញដោយបំពាន។ វិធានការទាំងនេះគួរធានាឲ្យមានការផ្តល់ប័ណ្ណកម្មសិទ្ធិផ្លូវការលើផ្ទះសម្បែង និងដីធ្លីឲ្យដល់ស្ត្រីគ្រប់រូប។

៣៣. ការវាយតម្លៃអំពីផលប៉ះពាល់ត្រូវតែគិតគូរពី ផលប៉ះពាល់ផ្សេងៗគ្នានៃការបណ្តេញចេញដោយបំពានទៅលើស្ត្រី [...]។ ការវាយតម្លៃទាំងនេះគួរតែផ្អែកលើការប្រមូលទិន្នន័យវិភាគ ដែលការធ្វើបែបនេះ អាចធ្វើឲ្យរកឃើញនូវផលប៉ះពាល់ផ្សេងៗគ្នា និងដោះស្រាយបានយ៉ាងត្រឹមត្រូវ ។

៣៨. រដ្ឋទាំងឡាយគួររិះរកជម្រើសគ្រប់បែបយ៉ាង ជំនួសឲ្យការបណ្តេញចេញ។ ក្រុមមនុស្ស និងបុគ្គលដែលអាចរងប៉ះពាល់ទាំងអស់ រួមមានស្ត្រី [...] មានសិទ្ធិទទួលបានព័ត៌មានដែលទាក់ទងនឹងការពិគ្រោះយោបល់ និងការចូលរួមដោយពេញលេញនៅគ្រប់កិច្ចដំណើរការទាំងមូល និងដើម្បីស្នើសុំឲ្យមានជម្រើសផ្សេងៗដែលអាជ្ញាធរគួរតែពិនិត្យពិចារណាឲ្យបានត្រឹមត្រូវ។ ក្នុងករណីមិនអាចឈានដល់ការព្រមព្រៀងគ្នាលើជម្រើសណាមួយដែលបានស្នើឡើងក្នុងចំណោមភាគីពាក់ព័ន្ធ ស្ថាប័នឯករាជ្យមួយដែលមានអំណាចតាមរដ្ឋធម្មនុញ្ញ ដូចជា តុលាការ សាលាជម្រះក្តី ឬមន្ត្រីដោះស្រាយបញ្ហាប្រជាពលរដ្ឋ គួរតែជួយសម្រុះសម្រួលធ្វើមជ្ឈត្តការ និងវិនិច្ឆ័យក្តីតាមដែលអាចទទួលយកបាន។

៤៧. ការបណ្តេញចេញមិនត្រូវអនុវត្តក្នុងលក្ខណៈមួយដែលរំលោភលើសេចក្តីថ្លៃថ្នូរ និងសិទ្ធិរស់រានមានជីវិត និងសន្តិសុខនៃជនទាំងឡាយដែលរងផលប៉ះពាល់ឡើយ។ រដ្ឋទាំងឡាយត្រូវចាត់វិធានការផងដែរដើម្បីធានាថា ស្ត្រីមិនស្ថិតក្នុងកម្មវត្ថុនៃអំពើហិង្សា និងការរើសអើងផ្អែកលើភេទ ក្នុងពេលបណ្តេញចេញឡើយ [...]។

៥៦. [...] ការតាំងទីលំនៅថ្មីត្រូវមានការធានាថា សិទ្ធិមនុស្សរបស់ស្ត្រី [...] ត្រូវបានការពារដោយស្មើភាពគ្នា រួមមានសិទ្ធិកម្មសិទ្ធិរបស់ស្ត្រីលើទ្រព្យសម្បត្តិ និងសិទ្ធិប្រើប្រាស់ធនធាននានា [...]។

៦២. ស្ត្រី និងបុរស ត្រូវតែទទួលផលរួមគ្នានៃកញ្ចប់សំណងទាំងអស់។ ស្ត្រី និងស្រីមេម៉ាយ គួរតែមានសិទ្ធិទទួលបានសំណងរបស់ខ្លួន។

*ប្រភព ៖* A/HRC/4/18 ឧបសម្ព័ន្ធ១។

ប្រភេទមួយបែបទៀតនៃការបណ្តេញចេញដោយបំពានដែលប៉ះពាល់តែទៅលើស្ត្រី គឺការបណ្តេញចេញប្រព្រឹត្តិដោយសមាជិកក្នុងគ្រួសារ ដោយមានការស្រុះស្រួលពីរដ្ឋ។ ក្នុងការផ្តល់យោបល់ទូទៅលេខ ៧ (១៩៩៧) របស់ខ្លួន គណៈកម្មាធិការសិទ្ធសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ បានកត់សម្គាល់នៅត្រង់ចំណុចនេះថា "ស្ត្រី [...] ងាយរងគ្រោះជាពិសេសទៅនឹង [ការបណ្តេញចេញដោយបំពាន] ដោយសារតែវិសាលភាពនៃបទបញ្ញត្តិមានលក្ខណៈរើសអើង ឬទម្រង់នៃការរើសអើងដទៃទៀត ដែលតែងតែត្រូវយកមកអនុវត្តនៅក្នុងរឿងទាក់ទងនឹងសិទ្ធិលើទ្រព្យសម្បត្តិ (រួមទាំងសិទ្ធិកម្មសិទ្ធិ) ឬសិទ្ធិប្រើប្រាស់អចលវត្ថុ ឬការអាស្រ័យនៅ ព្រមទាំងភាពងាយប្រឈមផ្សេងទៀតរបស់ស្ត្រី ចំពោះអំពើហិង្សា និងការរំលោភសេពសន្ថវៈនៅពេលដែលគេគ្មានលំនៅឋានរស់នៅ" (កថាខណ្ឌទី១០)។ ក្នុងករណីបណ្តេញចេញដោយបំពានប្រព្រឹត្តដោយសមាជិកគ្រួសារ ភាពកើតមានឡើងនូវការទទួលខុសត្រូវលើព្យសនកម្មរបស់រដ្ឋ គឺ ទីមួយ បណ្តាលមកពីការធ្វេសប្រហែសដើម្បីធានាសុវត្ថិភាពក្នុងការកាន់កាប់ស្របច្បាប់របស់ស្ត្រី និងទីពីរ បណ្តាលមកពីការខកខានមិនដាក់ទោសអ្នកប្រព្រឹត្តខុស។ ការខ្វះការប្រព្រឹត្តដោយត្រឹមត្រូវដើម្បីទប់ស្កាត់ ចោទប្រកាន់ និងដាក់ទោសចំពោះប្រភេទនៃការបណ្តេញចេញដោយបំពាននេះ អាចដាក់ឲ្យរដ្ឋទទួលខុសត្រូវចំពោះព្យសនកម្មនេះក្រោមច្បាប់អន្តរជាតិ។ អ្នករាយការណ៍ពិសេសបានចង្អុលបង្ហាញត្រង់ចំណុចនេះថា ការបណ្តេញចេញដោយបំពានលើស្ត្រីបណ្តាលមកពីអំពើហិង្សាក្នុងគ្រួសារស្ថិតក្នុងអាណត្តិរបស់គាត់ ហើយក៏មានក្នុងអាណត្តិរបស់អ្នករាយការណ៍ពិសេសទទួលបន្ទុកបញ្ហាអំពើហិង្សាប្រឆាំងស្ត្រីផងដែរ។

***ការបណ្តេញចេញដោយបំពានប្រព្រឹត្តិដោយសមាជិកគ្រួសារ – សក្ខីកម្មពីប្រទេសហ្វីជី***

សារ៉ា បានរៀបការជាមួយ ចូ ហើយពួកគេបានទៅរស់នៅក្នុងភូមិរបស់ចូ។ គ្រួសាររបស់សារ៉ា រកបានការងារមួយឲ្យសារ៉ា ធ្វើនៅទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី។ ពីរបីខែក្រោយមក គ្រួសារនាងរកបានការងារមួយទៀតសម្រាប់ប្តីនាងនៅទីក្រុងស៊ីដនី។ ប្តីប្រពន្ធទាំងពីរបានធ្វើការ និងផ្ញើលុយត្រឡប់ទៅផ្ទះវិញ ហើយបានសង់ផ្ទះជាលំនៅឋានខាងម្តាយរបស់ពួកគេនៅភូមិរបស់ចូ។ សារ៉ាត្រឡប់មកកាន់ភូមិ និងផ្ទះដែលជាលំនៅឋានខាងម្តាយ។ ចូបន្តស្ថិតនៅក្រុងស៊ីដនីហើយមានទំនាក់ទំនងស្នេហាជាមួយអ្នកផ្សេង។ ចូ ឲ្យ សារ៉ា ចាកចេញពីផ្ទះដែលជាលំនៅឋានខាងម្តាយ ហើយតាមយាយីនាង។ សារ៉ា បានសុំជំនួយពីក្រុម *តុ៉ហ្គានីកូវ៉* ប៉ុន្តែ ពួកគេបានប្រាប់នាងឲ្យចាកចេញពីផ្ទះ ពីព្រោះវាជាភូមិរបស់ប្តីនាង។

*ប្រភព ៖* ករណីសិក្សាប្រមូលពីការពិគ្រោះយោបល់ថ្នាក់តំបន់ប៉ាស៊ីហ្វិក។

## គ. លក្ខខណ្ឌលំនៅឋានមិនសមរម្យ

*[ផ្ទះ]មានន័យថា កន្លែងណាមួយដែលមានសុវត្ថិភាព ហើយជាទីដែលខ្ញុំមានកន្លែងដែលជារបស់ខ្ញុំ ដែលគ្មាននរណាផ្សេងទៀតចូលទៅក្នុងទីនោះបាន លុះត្រាតែខ្ញុំចង់ឲ្យពួកគេចូលទៅកាន់ទីកន្លែងនោះ។ វាមានន័យថា មិនមែនជាការរស់នៅលើសាឡុងរបស់គេ [...] ឬត្រូវដេកលើបង់រាល់យប់*

*ហើយភ្លឺឡើង ខ្ញុំអាចទៅកាន់មជ្ឈមណ្ឌលចែកចាយអាហារដើម្បីទទួលទានអាហារ និងផឹកកាហ្វេ ឬដេកមួយស្របក់នោះទេ។ [...] ផ្ទះជាកន្លែងដែលមានសុវត្ថិភាព និងសន្តិសុខ ហើយនិងមិនមាននរណានៅទីនោះដើម្បីធ្វើបាបអ្នកនោះទេ*[40]*។*

លំនៅឋានមិនសមរម្យមានលក្ខណៈជាការរស់នៅកកកុញ មានភាពកខ្វក់ខាងក្នុងផ្ទះ មានសម្ភារៈសំណង់មិនគ្រប់គ្រាន់ និងគ្មានទឹកស្អាត អនាម័យ និងអគ្គិសនី។ ភាពក្រីក្រនៅតំបន់ទីក្រុងមានន័យថា មិនគ្រាន់តែមានចំណូលទាប និងភាពអត់ឃ្លានដែលទាក់ទងគ្នានោះទេ ប៉ុន្តែក៏មានន័យថា មានលក្ខខណ្ឌលំនៅឋានដែលមានមនុស្សរស់នៅកកកុញ ភាពដាច់ឆ្ងាយពីសេវាមូលដ្ឋាន និងឱកាសការងារ និងការប្រឈមមុខនឹងបញ្ហាគ្រោះថ្នាក់ជាច្រើន ដូចជា ទឹកជំនន់ ការបាក់ដី ឬអគ្គីភ័យ។ នៅបណ្តាប្រទេសជាច្រើនក្នុងពិភពលោក ស្ត្រីដែលកំពុងរស់នៅក្នុងលំនៅឋានមិនសមរម្យមានចំនួនកាន់តែកើនឡើង។ អំឡុងបេសកកម្មទៅកាន់ប្រទេសប៉េរូ នៅខែមីនា ឆ្នាំ២០០៣ អ្នករាយការណ៍ពិសេសបានកត់សម្គាល់ថា ស្ត្រីក្នុងចំនួនមិនសមាមាត្រដែលរស់នៅក្នុងលំនៅឋានមិនសមរម្យ និងគ្មានសុវត្ថិភាព ខ្វះខាតនូវទឹកស្អាតអនាម័យ និងសេវាមូលដ្ឋាន។ ម្យ៉ាងទៀត សក្ខីកម្មទាំងឡាយដែលគាត់បានស្តាប់អំឡុងពេលពិគ្រោះយោបល់ថ្នាក់តំបន់នោះ បានគូសបញ្ជាក់ថា កម្មវិធីដែលផ្តោតលើការដោះស្រាយលក្ខខណ្ឌលំនៅឋានមិនសមរម្យ ជារឿយៗ មិនបានបញ្ចូលស្ត្រីនៅលីវ ឬម្តាយទោល នោះទេ។

***ស្ត្រីនៅលីវ ឬ ម្តាយទោល មិនត្រូវបានបញ្ចូលក្នុងកម្មវិធីដែលជាគោលដៅនៃការដោះស្រាយលក្ខខណ្ឌលំនៅឋានមិនសមរម្យទេ***

នៅតំបន់អៀកុតស្ក៍ ក្នុងសហព័ន្ធរុស្ស៊ី មានកម្មវិធីដែលបង្កើតឡើងដើម្បីដោះស្រាយស្ថានភាពលំនៅឋានគ្មានសុវត្ថិភាពនៃគ្រួសារថ្មីថ្មោង ប៉ុន្តែ ម្តាយទោល តែងតែមិនត្រូវបានបញ្ចូលក្នុងកម្មវិធីនេះទេ ដោយសារពួកគាត់មិនត្រូវបានគេគិតថា ជា "គ្រួសារ" ទោះជាតំបន់នោះមានស្ត្រីមេម៉ាយចំណាស់ ស្ត្រីលែងលះប្តី និងស្ត្រីមេម៉ាយ ក្នុងចំនួនដ៏ច្រើនមិនសមាមាត្រក៏ដោយ។

លក្ខខណ្ឌលំនៅឋានមិនសមរម្យមានផលវិបាកជាក់លាក់ និងធំធេងចំពោះស្ត្រី ដោយសារពួកគាត់ត្រូវចំណាយពេលវេលាជាច្រើននៅផ្ទះច្រើនជាងបុរស។ "ផ្ទះ" ជាកន្លែងដែលស្ត្រីទាក់ទងគ្នាទៅវិញទៅមកក្នុងសង្គម និងជាកន្លែងដែលស្ត្រីធ្វើការងារ។ វាក៏ជាកន្លែងដែលពួកគាត់ថែរក្សាកូនៗរបស់ខ្លួន។ ផ្ទះផ្តល់ឲ្យស្ត្រីនូវកន្លែងដែលមានសុវត្ថិភាពដើម្បីរស់នៅ ជានាភាពឯកជន និងការការពារប្រឆាំងការយាយី ឬការវាយដំ។ ផ្ទុយទៅវិញ ស្ត្រីដែលកំពុងរស់នៅតាមដងផ្លូវ កំពុងតែជួបភាពងាយរងគ្រោះកាន់តែខ្លាំងចំពោះអំពើហិង្សា និងការរំលោភបំពានផ្លូវភេទ។ សក្ខីកម្មនានាបានមកពីការពិគ្រោះយោបល់ថ្នាក់តំបន់អាម៉េរិកខាងជើង ចង្អុល

[40] វ៉ាស់ស៊ី រាល "សំឡេងៈ ស្ត្រី ភាពក្រីក្រ និងភាពគ្មានផ្ទះសម្បែង ក្នុងប្រទេសកាណាដា" (រដ្ឋធានី អូតាវ៉ា អង្គការប្រឆាំងភាពក្រីក្រជាតិ ខែឧសភា ឆ្នាំ២០០៤) ទំព័រទី ៣ ដល់ ទី៤។

បង្ហាញអំពីរបាយការណ៍នៃឃាតកម្មជាប្រព័ន្ធ និងការបាត់ខ្លួនស្ត្រីជនជាតិដើមភាគតិចដែលមានទីជម្រកនៅក្នុងប្រទេសកាណាដា។

***ប្រទេសឥណ្ឌា៖ កង្វះខាតលំនៅឋានសមរម្យ និងអំពើហិង្សាទៅលើស្ត្រីពនេចរ***

*ប្រសិនបើយើងមានផ្ទះ យើងអាចចាក់សោ យើងនឹងមានសុវត្ថិភាព។ ឥឡូវ យើងរស់នៅក្រោមដើមឈើ យើងរងគ្រោះជាចំហចំពោះការរំលោភបំពាន និងអំពើហិង្សាលើស្ត្រី...*ដូលី ជាស្ត្រីកុលសម្ព័ន្ធ *ភវារ* នៅប្រទេសឥណ្ឌា។ គោលនយោបាយស្តីពី ឧទ្យានជាតិហាមឃាត់ជនពនេចរមិនឲ្យរស់នៅក្នុងព្រៃតាមបែបប្រពៃណីវប្បធម៌របស់ពួកគេទេ។ ទីកន្លែងណាក៏ដោយដែលពួកគេចង់តាំងទីលំនៅ ជនពនេចរ ជារឿយៗត្រូវយាយីដោយសហគមន៍ក្នុងស្រុក។ ដោយសារបុរសតែងតែត្រូវធ្វើដំណើរទៅរកការងារធ្វើនោះ ស្ត្រីជួបនឹងបញ្ហាយាយីខ្លាំងយ៉ាងខ្លាំង ដែលរួមមានការដុតផ្ទះ និងអំពើហិង្សាផង។ នៅពេលដែលស្ត្រី*ភវារ* ព្យាយាមទៅរកដងទឹកពីទីប្រភពទឹក ពួកគាត់ត្រូវរងការវាយដំ និងចាប់រំលោភសេពសន្ថវៈដោយសមាជិកសហគមន៍ដែលជាអ្នកគ្រប់គ្រងប្រភពទឹក។

*ប្រភព៖* សក្ខីកម្មប្រមូលបានអំឡុងពេលពិគ្រោះយោបល់ថ្នាក់តំបន់អាស៊ី។

ភាពកខ្វក់ក្នុងផ្ទះដែលបណ្តាលមកពីចង្ក្រានដែលមានគុណភាពអន់ និងខ្យល់ចេញចូលមិនគ្រប់គ្រាន់ ការខ្វះការការពារពីអាកាសធាតុក្តៅ និងត្រជាក់ខ្លាំង មុខជានឹងមានផលប៉ះពាល់មិនសមាមាត្រលើស្ត្រី និងសុខភាពរបស់គាត់។ កង្វះទឹកស្អាត អនាម័យ ឬអគ្គិសនីក្នុងផ្ទះ ប៉ះពាល់ដល់ស្ត្រីជាពិសេស ដោយសារស្ត្រីទទួលខុសត្រូវក្នុងការរកទឹក និងប្រេង។ ពេលវេលាដែលចាំបាច់ដើម្បីទៅរក និងដងទឹកយកមកប្រើប្រាស់ គឺជាបន្ទុកដ៏ធ្ងន់ធ្ងរចំពោះស្ត្រី ហើយនេះជាការពន្យល់មួយអំពីគម្លាតយេនឌ័រដ៏ធំ ទាក់ទងនឹងការបានចូលរៀនរបស់ស្ត្រីនៅក្នុងប្រទេសជាច្រើន [41]។

សុវត្ថិភាពរាងកាយអាចជួបគ្រោះថ្នាក់ផងដែរ នៅពេលមានការដាក់កំហិតលើការទទួលបានទឹកស្អាត និងអនាម័យ។ នៅប្រទេសម៉ារុក មានសេចក្តីរាយការណ៍ថា ស្ត្រីងាយរងគ្រោះពីការរំលោភសេពសន្ថវៈដោយសារពួកគាត់ត្រូវដើរផ្លូវឆ្ងាយដើម្បីរកទឹក។ ក្នុងការពិគ្រោះយោបល់ថ្នាក់តំបន់ប៉ាស៊ីហ្វិច ស្ត្រីបានបង្ហាញថា ការខ្វះអនាម័យជាបញ្ហាចម្បងបំផុតចំពោះពួកគាត់ទាក់ទងនឹងលំនៅឋាន។

***ការទទួលបានអនាម័យសមស្រប និងអំពើហិង្សាទៅលើស្ត្រី***

ក្នុងតំបន់រស់នៅមិនទាន់រៀបរយក្នុងទីក្រុងណៃរ៉ូប៊ី ស្ត្រីជួបប្រទះបញ្ហាប្រឈម ជាពិសេសចំពោះសុវត្ថិភាពទាក់ទងនឹងអនាម័យ។ ក្នុងករណីខ្លះ ស្ត្រីប្រើបង្គន់រណ្តៅ ដែលប្រើរួមគ្នាដោយមនុស្សប្រហែល ៥០នាក់ ហើយជារឿយៗ ពួកគាត់ត្រូវដើរឆ្ងាយគួរសមទើបទៅដល់បង្គន់។ ការទៅប្រើប្រាស់បង្គន់សាធារណៈ

[41] កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ របាយការណ៍អភិវឌ្ឍន៍មនុស្សជាតិ ឆ្នាំ ២០០៦៖ លើសពីភាពខ្វះខាត - ថាមពល ភាពក្រីក្រ និង វិបត្តិទឹក ពិភពលោក (ប៉ែស៊ីងស្តូក ចក្រភពអង់គ្លេស កែលហ្ក្រេវ មែកមីលលីន ឆ្នាំ ២០០៦) ទំព័រទី ៤៧។

ត្រូវចំណាយប្រាក់ ដែលស្ត្រីទាំងនេះតែងតែគ្មានប្រាក់បង់ ហើយបង្គន់នេះត្រូវបិទនៅពេលល្ងាច។ ការខ្វះភាពឯកជន ដោយការប្រើបង្គន់រួមគ្នានេះ ប៉ះពាល់ដល់ស្ត្រីមែនទែន ជាពិសេស អំឡុងពេលដែលស្ត្រីមានរដូវ។ ជាទូទៅ ស្ត្រីមិនហ៊ានទៅកាន់បង្គន់សាធារណៈនៅពេលយប់ទេ ពីព្រោះស្ថានភាពគ្រោះថ្នាក់នៃអំពើហិង្សាមានកម្រិតខ្ពស់រួមមានទាំងអំពើហិង្សាផ្លូវភេទ។ ស្ត្រីក៏ទទួលរងផលវិបាកធ្ងន់ធ្ងរផ្នែកសុខភាពដោយសារតែអនាម័យមិនសមស្រប ដោយពួកគេត្រូវថែទាំកូន និងសមាជិកគ្រួសារដទៃទៀតនៅពេលពួកគេឈឺ ហើយត្រូវចេញថ្លៃព្យាបាល។

*ប្រភព៖* អង្គការលើកលែងទោសអន្តរជាតិ "អសន្តិសុខ និងភាពអាម៉ាស់៖ បទពិសោធន៍របស់ស្ត្រីរស់នៅតាមទីកន្លែងក្រីក្រមិនរៀបរយនៃរដ្ឋធានី ណៃរ៉ូប៊ី ប្រទេសកេនយ៉ា លិបិក្រមអង្គការលើកលែងទោសអន្តរជាតិ៖ AFR ៣២/០០២/២០១០ (ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១០)។

*ប្រទេសកម្ពុជា៖ ស្ថានភាពអស្ថិរភាពនៅតាមតំបន់ក្រីក្រក្នុងទីប្រជុំជនប៉ះពាល់យ៉ាងខ្លាំងដល់ស្ត្រី*

អស្ថេរភាពបណ្តាលមកពីលក្ខខណ្ឌរស់នៅមិនសមរម្យ ប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ស្ត្រី។ ដោយសារស្ថានភាពមិនទៀងទាត់នៅតាមតំបន់ក្រីក្រមិនរៀបរយ ស្ត្រីជានិច្ចកាលតែងភ័យខ្លាចពីបញ្ហាអគ្គីភ័យ ឬទឹកជំនន់ ឬបារម្ភពីសុខុមាលភាពកូនៗរបស់ខ្លួន។ ស្ត្រីនៅប្រទេសកម្ពុជាបានផ្តល់សក្ខីកម្មថា មានប្រេកង់មានកម្រិតដែលអាចពិភាក្សាបានជាមួយមន្ត្រីនានា ដើម្បីធ្វើការអភិវឌ្ឍកែលម្អតំបន់រស់នៅ។ ស្ត្រីត្រូវបានប្រាប់ថា ខ្លួនជាអ្នករស់នៅខុសច្បាប់ ហើយដោយហេតុផលនេះ មិនមានការគិតគូធ្វើឲ្យប្រសើរឡើងចំពោះកន្លែងរស់នៅទាំងនេះទេ។

ការខ្វះទីលំហ និងការរស់នៅច្រើនកកកុញ អាចមានផលប៉ះពាល់ផងដែរលើសុខុមាលភាពរាងកាយ និងសុខភាពផ្លូវចិត្តរបស់ស្ត្រី។ អំពើហិង្សាទៅលើស្ត្រីអាចបណ្តាលមកពីលក្ខខណ្ឌលំនៅឋានមិនសមរម្យ។ ទីតាំង និងបរិស្ថាននៃផ្ទះសំបែងក៏អាចជះឥទ្ធិពលលើសុវត្ថិភាពរាងកាយរបស់គាត់ផងដែរ។ ស្ត្រីដែលកំពុងរស់នៅក្នុងតំបន់ទីក្រុងអាចជួបនឹងហានិភ័យខ្ពស់នៃអំពើហិង្សា ការរំលោភសេពសន្ថវៈ និងការរំលោភបំពានផ្នែករាងកាយ និងផ្លូវចិត្ត។ នៅប្រទេសស្រីលង្កា ការសិក្សាស្តីពីអំពើហិង្សាក្នុងគ្រួសារ ក្នុងវិស័យដំណាំចម្ការបានគូសបញ្ជាក់ថា ស្ត្រីដែលកំពុងរស់នៅក្នុងបន្ទប់តែមួយជាមួយក្រុមគ្រួសារទាំងអស់ អាចនឹងរងនូវអំពើហិង្សាក្នុងគ្រួសារ ដោយសារកង្វះខាតទីលំហ ភាពជាឯកជន និងការរស់នៅកៀកជិតគ្នានៃសមាជិកគ្រួសារ។[42]

លំនៅឋានដែលមានការបែងចែក ជាផលវិបាកមួយនៃផលវិបាកចម្បងនៃការរើសអើងច្រើនយ៉ាងដែលមានផលវិបាកជាក់លាក់ចំពោះស្ត្រីផងដែរ។ លំនៅឋានដែលមានការបែងចែក ជារឿយៗ មានលក្ខណៈក្រៅផ្លូវការ ខ្វះខាត និងក្រោមស្តង់ដារ ហើយមានកង្វះខាតសេវាដឹកជញ្ជូនសាធារណៈ និងសេវាមូលដ្ឋាន។

[42] ការពិគ្រោះយោបល់ថ្នាក់តំបន់អាស៊ី។

សក្ខីកម្មនានាពីការពិគ្រោះយោបល់ថ្នាក់តំបន់សម្រាប់ អាស៊ីកណ្តាល និងអឺរ៉ុបខាងកើត បានបញ្ជាក់ក្នុងរបាយការណ៍ពីករណីឡានពេទ្យមិនដឹកស្ត្រីទៅមន្ទីរពេទ្យដើម្បីសម្រាលកូន។ ដោយសារលំនៅឋានដែលមានការបែងចែកនេះមានលក្ខណៈក្រៅផ្លូវការ អ្នករស់នៅក៏ខ្វះអាសយដ្ឋាន ឬការចុះបញ្ជីផ្លូវការដែរ។ ជាលទ្ធផលបញ្ហានេះជាឧបសគ្គបន្ថែមសម្រាប់ស្ត្រីដែលមិនអាចទទួលបានសេវាកម្មមូលដ្ឋានសម្រាប់ខ្លួនឯង ឬសម្រាប់កូនរបស់ខ្លួន។

លំនៅឋានដែលមានការបែងចែកនេះ ក៏នៅឆ្ងាយផងដែរពីមជ្ឈមណ្ឌលទីក្រុង និងនៅឆ្ងាយពីឱកាសការងារ ហើយខ្វះផ្លូវ និងខ្វះការតភ្ជាប់ទៅនឹងប្រព័ន្ធដឹកជញ្ជូនសាធារណៈ។

*លំនៅឋានដែលមានការបែងចែក និងផលប៉ះពាល់លើស្ត្រីរ៉ូម៉ា*

នៅទូទាំងអឺរ៉ុប ជនជាតិ រ៉ូម៉ា កំពុងរស់នៅក្នុងតំបន់តាំងទីលំនៅដែលមានការបែងចែក ជាលំនៅឋានក្រោមស្តង់ដារ ជារឿយៗ ស្ថិតនៅលើទីតាំងដែលមានសារជាតិពុល ជិតផ្លូវធំ កន្លែងចាក់សំរាម តំបន់លិចទឹក ឬតំបន់ងាយរងគ្រោះដោយគ្រោះធម្មជាតិ។ លំនៅខានទាំងនេះ ជារឿយៗ ខ្វះទឹកម៉ាស៊ីន ប្រព័ន្ធបង្ហូរទឹកសម្អុយ អគ្គិសនី ឬកម្តៅ និងនៅឆ្ងាយពីសាលារៀន និងមន្ទីរពេទ្យ។ បញ្ហានេះមិនគ្រាន់តែមានផលប៉ះពាល់លើសុខភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើនបន្ទុកធ្ងន់ធ្ងរដល់ស្ត្រីទៀតផង។

សក្ខីកម្មទទួលបានពីការពិគ្រោះយោបល់ថ្នាក់តំបន់ ក៏បង្ហាញឲ្យឃើញនូវឧទាហរណ៍មួយចំនួនដែលស្ត្រីត្រូវបានគេបំបែកដោយបង្ខំចេញពីកូនរបស់ខ្លួនដោយផ្អែកលើលក្ខខណ្ឌរស់នៅមិនសមរម្យ។ នៅក្នុងប្រទេសជាច្រើនលើពិភពលោក កុមារអាចត្រូវបានដកហូតចេញពីការថែរក្សារបស់ឪពុកម្តាយ ហើយយកទៅដាក់នៅក្រោមការថែរក្សារបស់រដ្ឋ ប្រសិនបើលក្ខខណ្ឌលំនៅឋានរបស់ពួកគេត្រូវបានវិនិច្ឆ័យថា មិនសមរម្យ។ សក្ខីកម្មទាំងឡាយបានបញ្ជាក់ថា នៅប្រទេសកាដាណា ស្ត្រីដែលមិនអាចលៃលករកបានលំនៅឋានសមរម្យ ឬដែលគ្មានផ្ទះសំបែងរស់នៅ ត្រូវបានចាត់ទុកថា មិនអាចថែរក្សាកូនរបស់ខ្លួនបានត្រឹមត្រូវទេ[43]។ បញ្ហានេះកើតឡើងជាពិសេសទៅលើស្ត្រីជនជាតិដើមភាគតិច ដែលអាចជួបប្រទះនឹងរបាំងវប្បធម៌ ក្នុងការទទួលបានទីជម្រកការឧបត្ថម្ភពីរដ្ឋ និងសំណងតាមច្បាប់។ នៅសហរដ្ឋអាមេរិក អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមនុស្សក្នុងការទទួលបានទឹកស្អាតនិងអនាម័យ បង្ហាញកង្វល់ពីការមិនមានលទ្ធភាពបង់វិក្កយបត្រទឹក ដែលនាំឲ្យមានការផ្តាច់ទឹកពីបណ្តាញទឹក។ គ្មានទឹកម៉ាស៊ីន ផ្ទះទាំងនេះអាចត្រូវបានចាត់ទុកថាមិនសមរម្យសម្រាប់រស់នៅ ហើយកុមារត្រូវដកយកចេញពីឪពុកម្តាយ ដោយផ្អែកតែលើមូលដ្ឋាននេះ [44]។

[43] សូមមើល A/HRC/10/7/Add.3 កថាខណ្ឌទី ៦៥។

[44] A/HRC/18/33/Add.4 កថាខណ្ឌទី៥១។

## ឃ. ទំនាក់ទំនងរវាងអំពើហិង្សាក្នុងគ្រួសារ និងសិទ្ធិមានលំនៅឋានសមរម្យរបស់ស្ត្រី

*នៅប្រទេសវ៉ានូអាទូ នៅពេលស្ត្រីរៀបការ នាងត្រូវទៅរស់នៅខាងស្វាមីរបស់នាង។ ការបង្គាប់បញ្ជាណាក៏ដោយចំពោះដីធ្លី ឬលំនៅឋានប្រឆាំងនឹងស្វាមីនាង (សូម្បីក្នុងស្ថានភាពអំពើហិង្សាក្នុងគ្រួសារ) ជួបនឹងអាកប្បកិរិយាប្រទុស្តរ៉ាយជាខ្លាំង ពីព្រោះមានទស្សនៈរួមជាទូទៅថា ដីជារបស់ញាតិសន្តានខាងស្វាមីនាង ហើយនាងកំពុងរស់នៅលើដីនៃញាតិសន្តានខាងស្វាមី និងមិនមានកម្មសិទ្ធិរួមគ្នាឡើយ[45]។*

សក្ខីកម្មដែលប្រមូលដោយអ្នករាយការណ៍ពិសេស បានបង្ហាញឲ្យឃើញអំពីទំនាក់ទំនងដ៏ជិតស្និទ្ធរវាងអំពើហិង្សាក្នុងគ្រួសារ និងសិទ្ធិស្ត្រីក្នុងការមានលំនៅឋានសមរម្យ។ ពាក្យ "អំពើហិង្សាក្នុងគ្រួសារ" សំដៅទៅលើ អំពើហិង្សាដែលកើតមានក្នុងរង្វង់ឯកជន ជាទូទៅ រវាងបុគ្គលដែលជាប់ទាក់ទងគ្នាដោយសាច់សាលោហិត ដោយច្បាប់ ឬដោយភាពស្និទ្ធស្នាល[46]។

***អំពើហិង្សាទៅលើស្ត្រី***

អំពើហិង្សាផ្អែកលើយេនឌ័រ ឬអំពើហិង្សាលើស្ត្រី ត្រូវបានកំណត់និយមន័យដោយគណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រីថាជា "អំពើហិង្សាដែលសំដៅទៅលើស្ត្រី ពីព្រោះគាត់ជាស្ត្រី ឬដែលប៉ះពាល់ដល់ស្ត្រីដោយមិនសមាមាត្រ។ វារួមបញ្ចូលនូវអំពើដែលធ្វើឲ្យមានគ្រោះថ្នាក់ ឬការឈឺចាប់ខាងផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ ការបំភិតបំភ័យនៃអំពើទាំងនេះ ការបង្ខិតបង្ខំ និងការដកហូតសេរីភាពដទៃទៀត"។

អំពើហិង្សាទៅលើស្ត្រីអាចកើតឡើងនៅកម្រិតផ្សេងៗគ្នា អាចនៅក្នុងគ្រួសារ នៅក្នុងសហគមន៍ និងបង្កឡើងដោយរដ្ឋ។ បើយោងតាមគណៈកម្មាធិការ អំពើហិង្សាក្នុងគ្រួសារ គឺជាទម្រង់មួយក្នុងចំណោមទម្រង់នៃការបង្កទុក្ខសោកបំផុតនៃហិង្សាទៅលើស្ត្រី ហើយកង្វះខាតឯករាជ្យភាពខាងផ្នែកសេដ្ឋកិច្ចបានបង្ខំឲ្យស្ត្រីជាច្រើនបន្តរស់នៅក្នុងទំនាក់ទំនងហិង្សាទាំងនោះ។

អំពើហិង្សាទៅលើស្ត្រី គឺជាការបង្ហាញនូវទំនាក់ទំនងអំណាចមិនស្មើភាពគ្នាជាប្រវត្តិសាស្ត្ររវាងស្ត្រីនិងបុរសទាំងជាកម្រិតបុគ្គលទាំងកម្រិតសហគមន៍។ អំពើហិង្សា និងការគំរាមកំហែងបែបហិង្សាទៅលើស្ត្រីធ្វើឲ្យមានជាបន្តនូវទំនាក់ទំនងអំណាចមិនស្មើភាពគ្នាទាំងនេះ។ ក្នុងសេចក្តីប្រកាសឆ្នាំ ១៩៩៣ ស្តីពីការលុបបំបាត់រាល់អំពើហិង្សាទៅលើស្ត្រី ថ្លែងថា "អំពើហិង្សាទៅលើស្ត្រី គឺជាយន្តការសង្គមសំខាន់មួយក្នុងចំណោមយន្តការទាំងឡាយដែលស្ត្រីត្រូវបានបង្ខំឲ្យមានឋានៈបន្ទាប់បន្សំបើប្រៀបធៀបជាមួយបុរស"។

*ប្រភព៖* គណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី អនុសាសន៍ទូទៅលេខ ១៩ (ឆ្នាំ១៩៩២) កថាខណ្ឌទី៦ និង២៣ និងបុព្វបទនៃសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ ៤៨/១០៤។

[45] សក្ខីកម្មប្រមូលបានអំឡុងការពិគ្រោះយោបល់ថ្នាក់តំបន់ប៉ាស៊ីហ្វិច។

[46] E/CN.4/1996/53/ កថាខណ្ឌទី២៣។

ការខ្វះការការពារសិទ្ធិស្ត្រីក្នុងការមានលំនៅឋានសមរម្យ អាចឲ្យស្ត្រីកាន់តែងាយរងគ្រោះចំពោះអំពើហិង្សាក្នុងគ្រួសារ។ ជាពិសេស ទំនាក់ទំនងដ៏រឹងមាំរវាងការខ្វះសិទ្ធិកាន់កាប់ដោយសុវត្ថិភាព និងអំពើហិង្សាក្នុងគ្រួសារបានបង្ហាញតាមរយៈការងាររបស់អ្នករាយការណ៍ពិសេសទាំងពីរ។ ច្បាប់ដែលទទួលស្គាល់ចំណងទាក់ទងរវាងអំពើហិង្សាទៅលើស្ត្រី ជាពិសេស អំពើហិង្សាក្នុងគ្រួសារ និងសិទ្ធិស្ត្រីក្នុងការមានលំនៅឋានសមរម្យកំពុងចាប់ផ្តើមលេចត្រដែតឡើង រួមបញ្ចូលទាំងច្បាប់ស្តីពី អំពើហិង្សាក្នុងគ្រួសារក្នុងប្រទេសម៉ុងហ្គោលី ក៏ដូចជា ច្បាប់ស្តីពីវិធានគ្រប់ជ្រុងជ្រោយប្រឆាំងអំពើហិង្សាផ្អែកលើយេនឌ័រ (Ley de medidas de protección integral contra la violencia degénero) ឆ្នាំ ២០០៤ ដែលចែងថា ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារត្រូវបានផ្តល់អាទិភាពដើម្បីទទួលបានលំនៅឋានសាធារណៈ និងត្រូវទទួលបានជម្រកពិសេស។ ប្រទេសកម្ពុជា ប្រទេសប្រេស៊ីល ប្រទេសឥណ្ឌា និងប្រទេសស៊ែប៊ី អនុម័តច្បាប់ក្នុងប្រទេសរៀងៗខ្លួន ដោយផ្តល់សិទ្ធិដល់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារឲ្យបន្តរស់នៅក្នុងផ្ទះជារបស់គ្រួសារ ហើយដកហូតអ្នកប្រព្រឹត្តបទល្មើសនោះចេញពីផ្ទះ។ ក្នុងឆ្នាំ២០០៩ ស្នងការសិទ្ធិមនុស្សនៃក្រុមប្រឹក្សាអឺរ៉ុប បានចេញអនុសាសន៍របស់ខ្លួនស្តីពីការអនុវត្តសិទ្ធិលំនៅឋានដែលគាត់ផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើជនរងគ្រោះនៃអំពើហិង្សាជាស្ត្រី។ គាត់កត់សម្គាល់ថា "នៅប្រទេសភាគច្រើន អំពើហិង្សាក្នុងគ្រួសារ គឺជាមូលហេតុសំខាន់នៃការគ្មានផ្ទះសំបែងរបស់ស្ត្រី ហើយជាការគំរាមកំហែងចំពោះសុវត្ថិភាពបុគ្គល និងសុវត្ថិភាពនៃការកាន់កាប់ទៀតផង"[47] ។

ការបដិសេធការកាន់កាប់ដោយសុវត្ថិភាពតាមរយៈច្បាប់ គោលនយោបាយ បទបញ្ញា ឬច្បាប់ទំនៀមទម្លាប់ និងការអនុវត្តដែលមានលក្ខណៈលំអៀងយេនឌ័រ ក៏អាចធ្វើឲ្យស្ត្រីងាយរងគ្រោះកាន់តែច្រើនឡើងចំពោះអំពើហិង្សាក្នុងគ្រួសារ។ ប្រសិនបើស្ត្រីមិនទទួលបានសុវត្ថិភាពនៃការកាន់កាប់ទេ នោះគេប្រហែលជាមិនអាចចាកចេញពីទំនាក់ទំនងដែលរំលោភបំពានបានទេ។ ពួកគាត់អាចមានជម្រើសរវាងការក្លាយខ្លួនជាអ្នកគ្មានផ្ទះសម្បែង ដែលជារឿយៗមានកូនជាប់មកជាមួយផង ឬការប្រឈមមុខនឹងអំពើហិង្សាលើរាងកាយនិងផ្លូវចិត្តនៅផ្ទះ។ នៅពេលដែលស្ត្រីដែលរងការវាយដំនោះ មិនអាចរកជម្រកបាន ស្ត្រីជាច្រើនដែលចាកចេញពីផ្ទះរបស់ខ្លួន ងាយរងគ្រោះចំពោះការគ្មានផ្ទះ ហើយជាលទ្ធផល អាចរងអំពើហិង្សាថែមទៀត។ ទោះបីជាមានសុវត្ថិភាពនៃការកាន់កាប់ក្តី ដោយសារស្ត្រីគ្មានលទ្ធភាពក្នុងការធ្វើឲ្យអ្នកប្រព្រឹត្តបទល្មើសចាកចេញពីផ្ទះបាន ពីព្រោះតែគ្មានការគាំទ្រពីគ្រួសារ ពីសហគមន៍ ឬពីរដ្ឋ ឬ គ្មានច្បាប់ជាក់លាក់ណាមួយចែងអំពីបញ្ហានេះ នោះវាបានរឹតត្បិតយ៉ាងធ្ងន់ធ្ងរទៅលើសមត្ថភាពរបស់ស្ត្រីក្នុងការគេចចេញពីទំនាក់ទំនងហិង្សាទាំងនោះ។

[47] ផ្នែក ៤.៣.៦. អនុសាសន៍អំពាវនាវយ៉ាងជាក់លាក់ដល់រដ្ឋទាំងឡាយ "ឲ្យអនុម័តបញ្ញត្តិប្រឆាំងនឹងអំពើហិង្សានៅក្នុងច្បាប់ និងគោលនយោបាយលំនៅឋាន និងដើម្បីធានាថា ច្បាប់អំពើហិង្សាក្នុងគ្រួសារ រួមទាំងបញ្ញត្តិការពារសិទ្ធិលំនៅឋានរបស់ស្ត្រី រួមទាំងសិទ្ធិជាឯកជន និងសុវត្ថិភាព" (ផ្នែកទី ៥)។

*អំពើហិង្សាក្នុងគ្រួសារ នៅប្រទេស អេហ្ស៊ីប*

អាហ្សា បានរៀបអាពាហ៍ពិពាហ៍អស់រយៈពេល ១២ឆ្នាំមកហើយ នៅពេលដែលស្វាមីរបស់នាងបានបណ្តេញនាង និងកូនស្រីពីរនាក់ចេញពីផ្ទះ ពីព្រោះនាងមិនយល់ស្របនឹងអាកប្បកិរិយាហិង្សារបស់ស្វាមី។ នាងរស់នៅក្នុងផ្ទះទ្រុឌទ្រោមមួយ នៅក្នុងក្រុងជីហ្សា ដែលគ្មានទឹកផឹក ហើយថ្លៃឈ្នួលផ្ទះមានតម្លៃពីរដងលើសពីអ្វីដែលនាងអាចរកបានមកពីការលក់សម្ភារៈសិប្បកម្ម។ បុរសដែលលែងលះប្រពន្ធម្នាក់ដែលរស់នៅក្នុងអាគារជាមួយ បានបៀតបៀននាង ហើយព្យាយាមទម្លុះទ្វារចូលបន្ទប់ស្នាក់នៅរបស់នាង។ នាងបានហៅរកជំនួយពីនគរបាល រួចនគរបាលនាំពួកគេទាំងពីរនាក់ទៅកាន់ប៉ុស្តិ៍នគរបាល។ អ្នកជិតខាងបានឃុបឃិតជាមួយនឹងស្វាមីនាង ហើយនាំគ្នានិយាយថា នាងធ្លាប់រៀបការច្រើនដងមកហើយ។ នាងត្រូវបានចោទប្រកាន់ពីបទពហុពន្ធភាព ហើយនគរបាលបានឃាត់ខ្លួននាង។ ដោយសារតែស្លាកស្នាមទុរយសក្នុងសង្គម ដែលកើតឡើងពីបទចោទប្រកាន់ទៅលើនាងដោយខុសឆ្គងនោះ ម្ចាស់ដីរបស់អាហ្សា បានបណ្តេញនាងចេញ បន្ទាប់ពីនាងជួលស្នាក់នៅបានពីរខែ ទោះបីជានាងមានកិច្ចសន្យាជួលរយៈពេលប្រាំឆ្នាំក៏ដោយ។

*ប្រភព៖* សក្ខីកម្មទទួលបានពីការពិគ្រោះយោបល់ថ្នាក់តំបន់មជ្ឈិមបូព៌ា និងនិងអាហ្វ្រិកខាងជើង។

អ្នកចូលរួមក្នុងការពិគ្រោះយោបល់ថ្នាក់តំបន់បានជឿជាក់យ៉ាងមុតមាំថា ប្រសិនបើស្ត្រីជាម្ចាស់នៃផ្ទះរបស់ខ្លួន អំពើហិង្សាក្នុងគ្រួសារនឹងថយចុះ។ ការស្រាវជ្រាវនៅក្នុងរដ្ឋកេរឡា នៃប្រទេសឥណ្ឌា បានរកឃើញថា ៤៩ ភាគរយ នៃស្ត្រីដែលមិនមានទ្រព្យសម្បត្តិ ត្រូវបានរាយការណ៍ថា រងអំពើហិង្សាលើរាងកាយ ក្នុងខណៈពេលដែលស្ត្រីមានទ្រព្យសម្បត្តិ រងអំពើហិង្សាតែ ៧ ភាគរយ ប៉ុណ្ណោះ[48]។ ក្នុងការសិក្សាដែលធ្វើឡើងក្នុងរដ្ឋវេសបេងហ្គ័ល នៃប្រទេសឥណ្ឌា ស្ត្រីជួបប្រទះនឹងអំពើហិង្សាក្នុងគ្រួសារប្រហាក់ប្រហែលគ្នា បានបង្ហាញអំពីភាពជាម្ចាស់លើដីថា ជាកត្តាសំខាន់ដែលអាចឲ្យស្ត្រីតវ៉ាប្រឆាំងអំពើហិង្សាក្នុងគ្រួសារបានលឿនជាងនេះ[49]។ ការសិក្សាស្រដៀងគ្នាមួយធ្វើឡើងក្នុងប្រទេសស្រីលង្កា បានបញ្ជាក់ថា ទោះបីជាស្ត្រីមិនបានលើកឡើងថា ការមានទ្រព្យសម្បត្តិបានការពារខ្លួនពួកគេពីអំពើហិង្សាក្នុងគ្រួសារក៏ដោយ ក៏ពួកគេបានលើកឡើងអំពីអត្ថប្រយោជន៍នៃទ្រព្យសម្បត្តិក្នុងការជួយខ្លួនដោះស្រាយទប់ទល់នឹងស្ថានភាពហិង្សាផងដែរ ពោលគឺជាការផ្តល់សន្តិសុខផ្នែកសេដ្ឋកិច្ច[50] ។

*ការគ្រប់គ្រងលើលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ និងភាពងាយរងគ្រោះទៅនឹងអំពើហិង្សាក្នុងគ្រួសារ*

[48] Pradeep Panda " យុទ្ធសាស្ត្រផ្អែកលើសិទ្ធិនៅក្នុងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ" ឯកសារលេខ ៣៨៤ (មណ្ឌលសម្រាប់ការសិក្សាអភិវឌ្ឍន៍ ខែមីនា ឆ្នាំ២០០៣) ទំព័រទី ៦១-៦២ មានក្នុងគេហទំព័រ www.cds. edu. ។

[49] មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការស្រាវជ្រាវពីបញ្ហាស្ត្រី កម្មសិទ្ធិទ្រព្យសម្បត្តិ និងសិទ្ធិទទួលមរតករបស់ស្ត្រី សម្រាប់ការការពារផ្នែកសង្គម៖ បទពិសោធន៍អាស៊ីខាងត្បូង របាយការណ៍សំយោគនៃការសិក្សាទាំងនេះ (ឆ្នាំ២០០៦) ទំព័រទី ៤។

៖ បទពិសោធន៍អាស៊ីខាងត្បូង របាយការណ៍សំយោគនៃការសិក្សាទាំងនេះ (ឆ្នាំ២០០៦) ទំព័រទី ៤។

[50] ដូចខាងលើ ទំព័រទី ៩។

នៅលើកោះយុកអាយឡិនស៍ ស្ត្រីមានសិទ្ធិដីធ្លីនៅតំបន់វាលភក់ ដែលជាប្រភពសំខាន់នៃអាហារ ដូច្នេះហើយស្ត្រីត្រូវបានចាត់ទុកជាអ្នកផ្គត់ផ្គង់គ្រួសារ។ ខ្ញុំរស់នៅភូមិ ភូ នៅលើកោះធំនេះអស់រយៈពេល២០ឆ្នាំមកហើយ។ ភូមិនេះចែកជាពីរ គឺអ្នកកោះ ពូកាពូកា រស់នៅផ្នែកម្ខាង (ខាងវាលភក់) ហើយអ្នកកោះ រាតុងហ្កា រស់នៅផ្នែកម្ខាងទៀត។ អំពើហិង្សាក្នុងគ្រួសារមានតិចតួច និងស្ទើរតែគ្មានចំពោះអ្នកពូកាពូកា ចំណែកអ្នកកោះរាតុងហ្កា មានអំពើហិង្សាច្រើនណាស់។ មូលហេតុចំពោះភាពខុសគ្នានេះអាចមកពីស្ត្រីដែលមានសិទ្ធិលើដីធ្លីដ៏មានតម្លៃរបស់អ្នកពូកាពូកា (ដីវាលភក់)។ ដូច្នេះហើយ សុវត្ថិភាពមានកម្រិតខ្ពស់ណាស់ចំពោះស្ត្រីទាំងនេះ។

*ប្រភព៖* សក្ខីកម្មប្រមូលបានអំឡុងពេលពិគ្រោះយោបល់ថ្នាក់តំបន់ប៉ាស៊ីហ្វិក។

ដូចដែលបានលើកឡើងខាងលើ ដោយសារមិនមានសិទ្ធិកាន់កាប់ដោយសុវត្ថិភាពនោះ អំពើហិង្សាក្នុងគ្រួសារ អាចបង្កើនភាពងាយរងគ្រោះរបស់ស្ត្រីចំពោះភាពគ្មានផ្ទះសំបែងកាន់តែខ្លាំងឡើង ជាពិសេសនៅពេលពួកគេមិនត្រូវបានការពារដោយមន្ត្រីពង្រឹងការអនុវត្តច្បាប់ ឬដោយប្រព័ន្ធច្បាប់តែម្តង។ ការសន្មត់តាមវប្បធម៌ដ៏រីកសាយខ្លះអំពីការដែលស្ត្រីត្រូវ "ចាកចេញ" ពីផ្ទះដែលមានអំពើហិង្សា ជាជាងការតម្រូវឲ្យដៃគូប្រព្រឹត្តិហិង្សានោះជាជាអ្នកចាកចេញពីផ្ទះ បានធ្វើឲ្យស្ត្រីបាត់បង់ការទទួលបានសិទ្ធិមានលំនៅឋានសមរម្យ។

ដូចគ្នានេះដែរ ការរស់នៅកកកុញមានផលវិបាកធ្ងន់ធ្ងរសម្រាប់បុគ្គលទាំងឡាយ និងសម្រាប់គ្រួសារទាំងឡាយ។ ក្នុងរបាយការណ៍បេសកកម្មរបស់គាត់ពីប្រទេសម៉ាល់ឌីវ លោកស្រីអ្នករាយការណ៍ពិសេសទទួលបន្ទុកលំនៅឋានសមរម្យកត់សម្គាល់ឃើញថា "ការលំបាកនេះក៏បង្កើតជាលក្ខខណ្ឌងាយស្រួលសម្រាប់បង្កអំពើហិង្សាក្នុងគ្រួសារ និងការរំលោភបំពានផ្លូវភេទ។ ក្នុងផ្ទះដែលរស់នៅកកកុញ ស្ត្រី និងកុមាររងាយរងគ្រោះដោយសារអំពើហិង្សា និងការរំលោភបំពានផ្លូវភេទណាស់។ តាមការស្ទង់មតិដែលធ្វើឡើងដោយក្រសួងសុខាភិបាល និងគ្រួសារក្នុងឆ្នាំ ២០០៦ ស្ត្រីម្នាក់ក្នុងចំណោមស្ត្រីបីនាក់ ដែលមានអាយុពី១៥ឆ្នាំ ដល់៤៩ឆ្នាំធ្លាប់រងការរំលោភបំពានលើរាងកាយ និងផ្លូវភេទ ចំណែកស្ត្រីម្នាក់ក្នុងចំណោមស្ត្រីប្រាំមួយនាក់ត្រូវបានរាយការណ៍ថា រងការរំលោភបំពានផ្លូវភេទមុនអាយុ ១៥ឆ្នាំ"[51]។

*សក្ខីកម្មពីម្តាយទោល អាយុ ៣៧ ឆ្នាំ មកពីសហគមន៍ជនបទ នៅប្រទេសអាហ្វ្រិកខាងត្បូង*

"[...] នៅពេលកូនយំខ្លាំង ប្តីខ្ញុំវាយខ្ញុំ ហើយប្រាប់ខ្ញុំថា ខ្ញុំមិនចេះធ្វើការដែលខ្ញុំកំពុងធ្វើទេ... ហើយគាត់ថា ខ្ញុំនេះជាម្តាយអន់ [...]។

"ពេលដែលខ្ញុំត្រូវប្តីវាយកាន់តែខ្លាំង កូនខ្ញុំកាន់តែយំខ្លាំង ហើយពេលកូនខ្ញុំយំកាន់តែខ្លាំងឡើង ខ្ញុំក៏ត្រូវប្តីវាយកាន់តែខ្លាំងតទៅទៀត។ រឿងហ្នឹងកើតឡើងយូរមកហើយ។ កូនខ្ញុំភ័យខ្លាំងណាស់ គ្រប់ពេលដែលប្តីខ្ញុំវាយខ្ញុំ។

[51] A/HRC/13/20/Add.3, កថាខណ្ឌទី៤៧។

"ខ្ញុំមានផ្ទៃពោះម្តងទៀត បីឆ្នាំក្រោយមក ប៉ុន្តែលើកនេះ ពួកយើងមានទីកន្លែងរស់នៅខ្លួនឯង។ ទីកន្លែងរស់នៅនោះតូចទេ ប៉ុន្តែយ៉ាងហោចណាស់ក៏ខ្ញុំប្រាស្រ័យទាក់ទងជាមួយតែប្តីខ្ញុំប៉ុណ្ណោះ។ ឥឡូវនេះ គាត់កាន់តែផឹកស្រាច្រើនឡើងៗ។ នៅពេលកូនក្រោយនេះអាយុបាន ៧ ខែ គាត់វាយខ្ញុំខ្លាំងមែនទែន។ ខ្ញុំរកនឹកមិនឃើញមូលហេតុអ្វីទេ។ រឿងរ៉ាវច្រើនពេកបានកើតឡើងនៅថ្ងៃនោះ។ គាត់លើកកូនបងឡើង ហើយនិយាយថា យកកូនមួយទៀតទៅ ពីព្រោះគាត់ចោទខ្ញុំថាមានកូនជាមួយប្រុសផ្សេង។ គាត់និយាយថា ឲ្យខ្ញុំចាកចេញពីផ្ទះទៅរកឪពុកក្មេងនោះទៅ ហើយឲ្យប្រុសនោះចិញ្ចឹមកូនទៅ។ ខ្ញុំគ្មានប្រុសណាទៀតនោះទេ។ ខ្ញុំចាំបានថា កាលនោះគឺនៅក្នុងខែកក្កដា មេឃត្រជាក់ណាស់។ ខ្ញុំបានទៅកាន់ទីកន្លែងរបស់ឪពុកម្តាយខាងប្តីរបស់ខ្ញុំ ហើយពួកគាត់បាននិយាយថា ខ្ញុំជាប្រពន្ធមិនល្អ ហើយត្រូវចំណាយច្រើន ហើយឲ្យខ្ញុំទៅនៅជាមួយឪពុកម្តាយរបស់ខ្ញុំវិញទៅ។ យប់ណាស់ទៅហើយ ដូច្នោះហើយ ខ្ញុំមិនអាចទៅបានទេ។

"ខ្ញុំចេះតែដើរទៅៗ។ ខ្ញុំឃើញមានក្អមចាស់មួយជាកំណាត់អេប៉ុង ជិតគំនរសំរាម ហើយក៏រើសវាយកមក និងបីកូនខ្ញុំទៅកាន់ទីវាលមួយ។ កូនខ្ញុំត្រជាក់ខ្លួន ហើយចេះតែយំ ដូច្នោះហើយ ខ្ញុំក៏ឱបនាងជាប់នឹងខ្លួន។

"នៅពេលខ្ញុំភ្ញាក់ឡើង ខ្លួនកូនខ្ញុំគ្មានកម្រើកអ្វីសោះ។ ខ្ញុំដឹងថា នាងស្លាប់បាត់ហើយ។ ប្តីខ្ញុំ និងគ្រួសាររបស់គាត់បានស្តីបន្ទោសខ្ញុំថាជាអ្នកសម្លាប់កូន។ ខ្ញុំមានអារម្មណ៍កណ្តោចកណ្តែងជាខ្លាំង ព្រោះខ្ញុំមិនដឹងជាទៅរកអ្នកណាឲ្យជួយខ្ញុំទេ"។

*ប្រភព៖* លីលាន អាតហ្ស៍, "ការទទួលបានភាពយុត្តិធម៌សម្រាប់ស្ត្រីនៅជនបទ៖ ការផ្តោតជាពិសេសលើអំពើហិង្សាទៅលើស្ត្រី" (ទីក្រុង ខេប ថោន វិទ្យាស្ថានឧក្រិដ្ឋកម្មវិទ្យា សាកលវិទ្យាល័យ ខេប ថោន ឆ្នាំ ១៩៩៨)។

នៅសាធារណរដ្ឋអ៊ីរ៉ង់ ទោះបីជាស្ត្រីគិតចង់ចាកចេញពីស្វាមី ដោយសារតែស្វាមីរបស់គាត់ បង្កការគម្រាមកំហែងចំពោះសុវត្ថិភាពរបស់គាត់ក៏ដោយ ក៏ភាពលំបាកដែលនាងនឹងជួបប្រទះនៅពេលចង់ជួល ឬទិញផ្ទះថ្មី និងការគ្មានលំនៅឋានផ្សេងទៀត បូកផ្សំនឹងការអនុវត្តការឃុំឃាំងដោយរើសអើងនោះ អាចនឹងជំរុញឲ្យស្ត្រីនោះរស់នៅតទៀតក្នុងទំនាក់ទំនងដែលប្រកបដោយការរំលោភបំពាននេះ។ មិនមានជម្រកគ្រប់គ្រាន់សម្រាប់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារទេ ហើយក៏មិនមានចែងក្នុងច្បាប់អំពីការធានាឲ្យមានការនាំយកស្វាមីចេញភ្លាមៗពីផ្ទះរបស់គ្រួសារដែរ ប្រសិនបើគាត់អាចនឹងបង្កគ្រោះថ្នាក់ដល់សុខុមាលភាពផ្លូវកាយ និង/ឬផ្លូវចិត្តរបស់ស្ត្រី។ ប្រសិនបើស្ត្រីចាកចេញពីផ្ទះរបស់គ្រួសារ ទោះជាដោយសារអំពើហិង្សាក្នុងគ្រួសារក្តី ក៏ប្រការនេះអាចត្រូវបានគិតថាជាការបោះបង់ចោលផ្ទះសម្បែង និងអាចជាមូលហេតុសម្រាប់ប្រឆាំងនឹងស្ត្រីបាន ប្រសិនបើស្វាមីដាក់ពាក្យបណ្តឹងលែងលះ[52]។

នៅទ្វីបអឺរ៉ុបខាងកើត និងអាមេរិកខាងជើង ស្ត្រីប្រឈមនឹងការគ្មានផ្ទះសម្បែងរស់នៅ ប្រសិនបើស្ត្រីគេចវេះពីទំនាក់ទំនងប្រកបដោយហិង្សាដែលកើតមានក្នុងផ្ទះ។ ការខ្វះជម្រកសមរម្យ ឬច្បាប់ជាក់លាក់ដែល

[52] E/CN.4/2006/41/Add.2 កថាខណ្ឌទី៩៨-៩៩។

អនុញ្ញាតឲ្យគេនាំយកអ្នកប្រព្រឹត្តបទល្មើសចេញពីផ្ទះ ផ្តល់នូវជម្រើសតិចតួចណាស់សម្រាប់ស្ត្រីក្នុងការសម្រេចចិត្តចាកចេញពីស្វាមីរបស់នាង។ នៅពេលស្ត្រីបាត់បង់លំនៅពិតប្រាកដរបស់ខ្លួន ស្ត្រីក៏អាចប្រឈមនឹងហានិភ័យនៃការដកហូតយកកូនចេញពីខ្លួនពីសំណាក់សេវាសុខុមាលភាពផងដែរ។

***អំពើហិង្សាក្នុងគ្រួសារ និងភាពគ្មានផ្ទះសម្បែង***

នៅសហរដ្ឋអាមេរិក ស្ត្រីដែលគ្មានផ្ទះសម្បែងជាច្រើនកំពុងគេចចេញពីអំពើហិង្សាក្នុងគ្រួសារ។ ក្នុងការពិគ្រោះយោបល់ថ្នាក់តំបន់អាមេរិកខាងជើង ស្ត្រីដែលរងអំពើហិង្សាក្នុងគ្រួសារបានសង្កត់ធ្ងន់ថា បញ្ហាមានការជាប់ទាក់ទងនឹងការទទួលបានដីកាការពារប្រឆាំងនឹងដៃគូដែលប្រើអំពើហិង្សា និងការរក្សាបានការរស់នៅក្នុងផ្ទះជួល។ ដីកាការពារធ្វើឲ្យស្ត្រីប្រឈមនឹងហានិភ័យនៃការដកហូតយកកូនរបស់ខ្លួនទៅដាក់នៅក្រោមការថែរទាំរបស់រដ្ឋ ដោយសារនគរបាលមុខជានឹងរាយការណ៍ពីស្ថានភាពនេះទៅផ្នែកសេវាថែរទាំកុមារ។ ការប្រឈមនឹងការបាត់បង់កូនរបស់ខ្លួន ធ្វើឲ្យស្ត្រីមិនរាយការណ៍ពីអំពើហិង្សា ដើម្បីអាចទទួលបានដីកាការពារនោះទេ។ ស្ត្រីក៏បានរាយការណ៍ផងដែរអំពីកង្វះទីជម្រក និងអំពីការអនុញ្ញាតឲ្យស្នាក់នៅជាអតិបរមាដែលមានរយៈពេលខ្លីនៅទីនោះ។ មានរបាយការណ៍ថា ស្ត្រីជនជាតិដើមភាគតិចគ្មានទំនោរទៅរស់នៅក្នុងទីជម្រកនោះទេ ដោយពួកគាត់មើលឃើញពី "អវិភាពខាងវប្បធម៌"។ សក្ខីកម្មនានាក៏បានបង្ហាញផងដែរថា ស្ត្រីដែលមានប្រវត្តិរស់នៅក្នុងទីជម្រក ត្រូវគេរើសអើង ដោយគេបដិសេធមិនជួលកន្លែងស្នាក់នៅឲ្យទេ ដោយសារតែហេតុផលមួយនេះគត់ ហើយដែលរឹតតែដាក់កំហិតលើជម្រើសមានលំនៅឋានរបស់ពួកគាត់។

*ប្រភព៖* មជ្ឈមណ្ឌលច្បាប់ជាតិស្តីពីភាពគ្មានផ្ទះសំបែង និងភាពក្រីក្រ "ភាពគ្មានផ្ទះសំបែងក្នុងសហរដ្ឋអាមេរិក និងសិទ្ធិមនុស្សក្នុងការមានលំនៅឋាន" (វ៉ាស៊ីនតោនឌីស៊ី ខែមករា ឆ្នាំ២០០៤) ទំព័រទី១០ និងការពិគ្រោះយោបល់ថ្នាក់តំបន់អាមេរិកខាងជើង។

## ង. មេរោគអេដស៍/ជំងឺអេដស៍

*ជាធម្មតាស្ត្រីនិងក្មេងស្រីតែងទទួលការរើសអើង ទាក់ទងទៅនឹងការទទួលបានការអប់រំ ការងារឥណទាន សេវាសុខភាព ដីធ្លី និងមរតក។ [...] ទំនាក់ទំនងជាមួយបុរស [..] អាចជាឱកាសសំខាន់បំផុតសម្រាប់ សន្តិសុខផ្នែកហិរញ្ញវត្ថុ និងសង្គមកិច្ច ឬសម្រាប់ការបំពេញបំណងប្រាថ្នាផ្នែកសម្ភារៈ។ [...] ការរួមផ្សំគ្នារវាងភាពពឹងផ្អែក និងការស្ថិតក្រោមបង្គាប់គេ អាចធ្វើឲ្យមានការលំបាកចំពោះក្មេងស្រី និងស្ត្រីដើម្បីទាមទារការរួមភេទមានសុវត្ថិភាព (សូម្បីតែពីស្វាមីរបស់ខ្លួន) ឬ ដើម្បីបញ្ចប់ទំនាក់ទំនងដែលពោរពេញទៅដោយការគំរាមកំហែងនៃការឆ្លងរោគ។*[53]

ស្ថិតិពីអង្គការសហប្រជាជាតិប្រឆាំងជំងឺអេដស៍បង្ហាញថា នៅទូទាំងពិភពលោក ស្ត្រីមានចំនួន ៥០ ភាគរយ នៃមនុស្សពេញវ័យដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ស្របពេលដែលស្ត្រីជិត ៦០ ភាគរយ នៃ

[53] កម្មវិធីរួមអង្គការសហប្រជាជាតិស្តីពីមេរោគអេដស៍/ជំងឺអេដស៍ (យូអិនអេដស៍) និង អង្គការសុខភាពពិភពលោក បច្ចុប្បន្នភាពនៃការរីករាលដាលជំងឺអេដស៍ (ទីក្រុងហ្សឺណែវ ខែធ្នូ ឆ្នាំ២០០២) ទំព័រទី ១៨។

មនុស្សពេញវ័យដែលឆ្លងជំងឺនេះរស់នៅក្នុងតំបន់អាហ្វ្រិកសាប់សាហារ៉ា។ វិសមភាពយេនឌ័រ គឺជា មូលហេតុមួយនៃភាពងាយរងគ្រោះរបស់ស្ត្រីចំពោះមេរោគអេដស៍/ជំងឺអេដស៍។ ស្ត្រីដែលខ្វះការគ្រប់គ្រងលើសេដ្ឋកិច្ចនៃទ្រព្យសម្បត្តិរបស់ខ្លួន រួមមានលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ និងពឹងផ្អែកផ្នែកសេដ្ឋកិច្ចលើដៃគូជាបុរស គឺមានការពិបាកខាងជីវភាពផ្លូវភេទណាស់ ហើយបញ្ហានេះធ្វើឲ្យខ្លួនកាន់តែងាយរងគ្រោះឡើង ចំពោះមេរោគ/ជំងឺអេដស៍។

កង្វះខាតរបស់ស្ត្រីក្នុងការទទួលបាន និងគ្រប់គ្រងលំនៅដ្ឋាន ដីធ្លី និងទ្រព្យសម្បត្តិ ជារឿយៗ ធ្វើឲ្យជម្រើសផ្នែកសេដ្ឋកិច្ចកាន់រួមតូចដែលអាចបន្ថយអំណាចតវ៉ារបស់ស្ត្រីចំពោះបញ្ហាផ្លូវភេទ។ មានភស្តុតាងកាន់តែច្រើនឡើងបង្ហាញថា ការការពារសិទ្ធិរបស់ស្ត្រីក្នុងការមានលំនៅឋានសមរម្យ បង្កើនសន្តិសុខខាងសេដ្ឋកិច្ច និងការផ្តល់អំណាចខាងសេដ្ឋកិច្ចរបស់ស្ត្រី នឹងកាត់បន្ថយភាពងាយរងគ្រោះរបស់ស្ត្រីចំពោះការរួមភេទមិនមានសុវត្ថិភាព[54]។ ក្នុងសេចក្តីរាយការណ៍ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងភាពងាយរងគ្រោះរបស់ស្ត្រីចំពោះមេរោគអេដស៍/ជំងឺអេដស៍ក្នុងប្រទេសអ៊ូហ្កង់ដា អង្គការឃ្លាំមើលសិទ្ធិមនុស្សបានសម្ភាសន៍ស្ត្រីដែលបង្ខំចិត្តបន្តរស់នៅក្នុងទំនាក់ទំនងជាមួយបុរសមានផ្ទុកមេរោគអេដស៍ ដែលបានវាយដំធ្វើបាប និងរំលោភលើខ្លួន ពីព្រោះតែស្ត្រីទាំងនេះភ័យខ្លាចត្រូវគេបណ្តេញចេញឲ្យទៅរស់នៅក្រៅផ្ទះ ឬឲ្យចេញពីដីធ្លី[55]។

ដូចនេះ ផលប៉ះពាល់នៃមេរោគអេដស៍/ជំងឺអេដស៍ទៅលើសន្តិសុខនៃលំនៅឋានរបស់ស្ត្រី មិនអាចមិនគិតគូនោះទេ។ ការរីករាលដាលនៃមេរោគអេដស៍/ជម្ងឺអេដស៍អាចគំរាមកំហែងដល់ការទទួលបាន និងការគ្រប់គ្រងរបស់ស្ត្រីទៅលើលំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ ក្នុងបរិបទដែលពួកគេមិនអាចទទួលបានមរតកលើមូលដ្ឋានស្មើគ្នានឹងបុរស។ ជាទូទៅ ការរីករាលដាលនៃជំងឺនេះ បានធ្វើឲ្យស្ត្រីកាន់តែងាយរងគ្រោះដោយមិនអាចទទួលបានមរតក (ព័ត៌មានលម្អិត សូមមើលផ្នែក ក ខាងលើ)។ ស្ត្រីមេម៉ាយដែលសហព័ទ្ធរបស់ខ្លួនស្លាប់ដោយសារមេរោគអេដស៍/ជំងឺអេដស៍ អាចស្ថិតក្នុងស្ថានភាពដែលទ្រព្យសម្បត្តិរបស់ខ្លួនត្រូវគេលួច ឬថយចុះ ដោយសារសាច់ញាតិថ្លៃរបស់ខ្លួន។ ក្នុងករណីដទៃទៀត ស្ត្រីមេម៉ាយត្រូវគេទម្លាក់កំហុសលើថាបានសម្លាប់ស្វាមីរបស់ខ្លួន ដោយការធ្វើឲ្យស្វាមីខ្លួនមានមេរោគអេដស៍/ជំងឺអេដស៍ ហើយសាច់ថ្លៃប្រើចំណុចនេះជាលេសដើម្បីដកហូតទ្រព្យសម្បត្តិទាំងនេះ។ ក្នុងករណីខ្លះទៀត សាច់ញាតិពន្យារពេលការគ្រប់គ្រងលើមរតក ដោយរង់ចាំឲ្យអ្នកទទួលប្រយោជន៍ពីមរតកនោះស្លាប់សិន។[56] ជាទូទៅ ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ នាំឲ្យមានកំណើនក្នុងករណីដែលសាច់ថ្លៃបណ្តេញស្ត្រីមេម៉ាយក្រោយពីមរណភាពនៃស្វាមីរបស់ខ្លួន ជាពិសេសក្នុងតំបន់អាហ្វ្រិកសាប់សាហារ៉ា។

---

[54] សម្ព័ន្ធភាពពិភពលោកស្តីពី ស្ត្រី និងជំងឺអេដស៍ សន្តិសុខផ្នែកសេដ្ឋកិច្ចចំពោះស្ត្រីដែលប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍ លេខ៣ ទំព័រទី ១ រីឆាដ ស្ទ្រិកលែន "មានសិទ្ធិ និងគ្រប់គ្រង៖ សិទ្ធិទ្រព្យសម្បត្តិ និងមរតករបស់ស្ត្រីក្នុងបរិបទមេរោគអេដស៍/ជំងឺអេដស៍នៅតំបន់អាហ្វ្រិកសាប់សាហារ៉ា" អត្ថបទបច្ចេកទេស (មជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវស្តីពីស្ត្រី ខែមិថុនា ឆ្នាំ២០០៤)។

[55] អង្គការឃ្លាំមើលសិទ្ធិមនុស្ស ស្លាប់ដោយស្ងៀមស្ងាត់៖ អំពើហិង្សា និងភាពងាយរងគ្រោះរបស់ស្ត្រីចំពោះមេរោគអេដស៍ ក្នុងប្រទេសអ៊ូហ្កង់ដា (ខែសីហា ឆ្នាំ២០០៣) ទំព័រទី ៣៧។

[56] UN- Habitat ច្បាប់ ការកាន់កាប់ដីធ្លី និងការត្រួតពិនិត្យយេនឌ័រ៖ អាហ្វ្រិកខាងត្បូង ណាមីប៊ី (ណៃរ៉ូប៊ី ឆ្នាំ២០០៥) ទំព័រទី ២២។

ច្បាប់និងការអនុវត្តតាមទំនៀមទម្លាប់ដែលមានការរើសអើង ដូចជា "ប្រពន្ធមរតក" និង "ការលាងជម្រះ" ដែលពេលខ្លះ ជាការចាំបាច់សម្រាប់ស្ត្រីត្រូវបំពេញ ដើម្បីអាចរស់នៅក្នុងផ្ទះ ឬបន្តរស់នៅលើដីរបស់ខ្លួនបាននោះ អាចរួមចំណែកដល់ការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ផងដែរ (ព័ត៌មានលម្អិតអំពីការអនុវត្តបែបនេះ សូមមើលផ្នែក ក ខាងលើ)។ ច្បាប់និងការអនុវត្តតាមទំនៀមទម្លាប់ ឬច្បាប់រដ្ឋដែលរារាំងស្ត្រីពីការទទួលបានមរតកដោយភាពស្មើគ្នាជាមួយបុរស អាចធ្វើឲ្យស្ត្រីមេម៉ាយជួបហានិភ័យខ្ពស់ក្នុងការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ ពីព្រោះតែវាអាចបង្ខំស្ត្រីឲ្យប្រព្រឹត្តការរួមភេទមិនមានសុវត្ថិភាពដើម្បីធ្វើយ៉ាងណាឲ្យតែជានាបានសន្តិសុខផ្នែកសេដ្ឋកិច្ចរបស់ខ្លួននោះ។ ភាពងាយរងគ្រោះនៃស្ត្រីដែលមានផ្ទុកមេរោគអេដស៍កាន់តែដុនដាបទៅទៀត នៅពេលដែលស្ត្រីត្រូវគេបណ្តេញចេញពីដី និងផ្ទះ បន្ទាប់ពីមរណភាពនៃស្វាមីរបស់ខ្លួន ដោយសារស្ត្រីបាត់បង់មធ្យោបាយដើម្បីថែទាំខ្លួន និងកូនរបស់ខ្លួន ចំពេលដែលខ្លួនត្រូវការធនធានបំផុតនោះ។ ស្ត្រីមិនត្រឹមតែបាត់ទ្រព្យសម្បត្តិដែលខ្លួនអាចប្រើដើម្បីថែទាំសុខភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបាត់បង់ផ្ទះសម្បែងដែលខ្លួនត្រូវការជ្រកកោន ដើម្បីតស៊ូទប់ទល់នឹងផលប៉ះពាល់នៃមេរោគអេដស៍/ជំងឺអេដស៍ទៀតផង។ ស្ត្រីដែលសារភាពថា មានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ក៏ជួបនឹងហានិភ័យដោយត្រូវផាត់ចេញពីសង្គម និងត្រូវបណ្តេញចេញពីផ្ទះរបស់ខ្លួនដែរ ជាពិសេស ក្នុងប្រទេសដែលច្បាប់លែងលះខកខានមិនបានទទួលស្គាល់សិទ្ធិរបស់ស្ត្រីក្នុងការមានលំនៅឋានសមរម្យ ឬក្នុងករណីនៃអាពាហ៍ពិពាហ៍តាមទំនៀមទម្លាប់ដែលមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍។

*មេរោគអេដស៍ /ជំងឺអេដស៍ និង ផលប៉ះពាល់នៃប្រតិបត្តិការ មូរ៉ែមបាត់ស៊ីណា (Murambatsvina)*

ប្រតិបត្តិការដែលមានឈ្មោះថា មូរ៉ែមបាត់ស៊ីណា ផ្តួចផ្តើមគំនិតដោយរដ្ឋាភិបាល ហ្ស៊ីមបាវេ នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៥ បាននាំឲ្យមានការបណ្តេញចេញដោយបំពានទៅលើមនុស្សរហូតដល់ទៅ ៧០០.០០០នាក់។ របាយការណ៍ជាច្រើនបានគូសបញ្ជាក់អំពីការដែលការបណ្តេញចេញដោយបំពាននោះរំខានដល់ការទទួលបានការថែទាំសុខភាពសម្រាប់មនុស្សដែលរស់នៅជាមួយមេរោគអេដស៍/ជំងឺអេដស៍ និងការបង្កើនហានិភ័យនៃការឆ្លងមេរោគអេដស៍ ក្នុងចំណោមប្រជាជនដែលទទួលរងផលប៉ះពាល់។

ការស្ទង់មតិជាតិមួយធ្វើឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០៥ លើគ្រួសារចំនួន៥.៤០៧គ្រួសារ បានរកឃើញថា ៦១ ភាគរយ នៃអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍បានបាត់បង់ឱកាសទទួលបានការថែទាំតាមផ្ទះ ៤៦ ភាគរយ បានបាត់បង់ការទទួលបានការព្យាបាលដោយថ្នាំពន្យាជីវិត ៤៥ ភាគរយ បានបាត់បង់ការព្យាបាលជំងឺឱកាសនិយម និង ២២ ភាគរយ បានបាត់បង់ការទទួលបានការគាំពារផ្នែកសុខភាពបន្តពូជ។

ភាពងាយរងគ្រោះចំពោះការឆ្លងមេរោគអេដស៍ ក៏កើនឡើងផងដែរ បន្ទាប់ពីការបណ្តេញចេញ ជាពិសេសចំពោះស្ត្រី។ មានការរាយការណ៍ថា ស្ត្រីដែលត្រូវគេបណ្តេញចេញមួយចំនួន មានទំនាក់ទំនងផ្លូវភេទជាថ្នូរនឹងអ្វីមួយ ឧទាហរណ៍ដូចជា ការដោះដូរការរួមភេទ ជាមួយនឹងការទទួលបានទីជម្រក ឬធ្វើការងាររកស៊ីផ្លូវភេទ ពីព្រោះតែការបាត់បង់ជីវភាព ដោយសារការបណ្តេញចេញ។

*ប្រភព៖* អង្គការឃ្លាំមើលសិទ្ធិមនុស្ស គ្មានអនាគតភ្លឺស្វាងទេ៖ ភាពខកខានរបស់រដ្ឋាភិបាល ការរំលោភបំពានសិទ្ធិ

និងការកើនឡើងភាពខ្វះខាតក្នុងការប្រយុទ្ធប្រឆាំងជំងឺអេដស៍នៅប្រទេសហ្ស៊ីមបាវេ (ខែកក្កដា ឆ្នាំ២០០៦) ទំព័រទី ២៣-២៦ អង្គការអេកសុនអេដ(ActionAid) ការសិក្សាស៊ីជម្រៅលើផលប៉ះពាល់នៃប្រតិបត្តិការមូរ៉េមបាត់ស្វីណា/ស្តារសណ្តាប់ធ្នាប់ក្នុងប្រទេសហ្ស៊ីមបាវេ (ខែវិច្ឆិកា ឆ្នាំ ២០០៥) ទំព័រទី ២១-២២។

## ច. គ្រោះមហន្តរាយធម្មជាតិ និងបម្រែបម្រួលអាកាសធាតុ

ផលប៉ះពាល់មិនសមាមាត្រទៅលើស្ត្រីនៃគ្រោះធម្មជាតិ និងបម្រែបម្រួលអាកាសធាតុ ត្រូវបានសង្កេតឃើញមានក្នុងបរិបទគ្រោះមហន្តរាយមួយចំនួនក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ដូចជា រលកសមុទ្រស៊ូណាមិក្នុងមហាសមុទ្រឥណ្ឌា ចុងឆ្នាំ ២០០៤ ការរញ្ជួយដីធំៗក្នុងតំបន់អាស៊ីខាងត្បូង ក្នុងខែតុលា ឆ្នាំ២០០៥ ព្យុះកាទ្រីណានៅសហរដ្ឋអាមេរិក ឆ្នាំ ២០០៥ និងការរញ្ជួយដីដ៏ធំនៅហាយទី ឆ្នាំ ២០១០។ បទពិសោធន៍ទាំងនេះបានបង្ហាញថា ស្ត្រីរងហានិភ័យកាន់តែខ្លាំងឡើងដោយពួកគេបានក្លាយខ្លួនទៅជាអ្នកគ្មានផ្ទះសម្បែង និងរងនូវអំពើហិង្សាដែលជាលទ្ធផលនៃគ្រោះមហន្តរាយទាំងនេះ។ ចំណុចនេះមួយផ្នែកបណ្តាលមកពីស្ត្រីមានចំនួនច្រើនពេកក្នុងចំណោមអ្នកដែលរស់នៅក្នុងលក្ខខណ្ឌលំនៅឋានមិនសមរម្យនេះរួចស្រាប់ទៅហើយ ដូច្នោះហើយនៅពេលមានការវាយប្រហារដោយគ្រោះមហន្តរាយ ស្ត្រីអាចនឹងរងផលវិបាកយ៉ាងធ្ងន់ធ្ងរ។

ទំនាក់ទំនងរវាងភាពក្រីក្រ និងភាពងាយរងគ្រោះ ជាទំនាក់ទំនងមិនអាចប្រកែកបាន ហើយដែលមានវិសាលភាពយេនឌ័រច្បាស់ក្រឡែតណាស់។ គ្រោះធម្មជាតិ ប្រែក្លាយជាគ្រោះមហន្តរាយដ៏ធំសម្រាប់ប្រជាជនដែលងាយរងគ្រោះបំផុត ដែលការមានលំនៅឋានសមរម្យ ទឹក អនាម័យ សុខភាព អគ្គិសនី ដីធ្លី និងធនធានដទៃទៀតរបស់ពួកគេស្ថិតក្នុងស្ថានភាពដ៏មានកម្រិតរួចស្រាប់ទៅហើយ។ ម្យ៉ាងវិញទៀត ការឆ្លើយតបមិនគ្រប់គ្រាន់ចំពោះគ្រោះមហន្តរាយទាំងនេះ និងកង្វះខាតការពិចារណាអំពីសិទ្ធិមនុស្សសម្រាប់អ្នករងផលប៉ះពាល់ បង្កើតជាសោកនាដកម្មបង្កឡើងដោយមនុស្សដែលធ្វើឲ្យ ទុក្ខវេទនាមានកាន់តែខ្លាំងឡើងចំពោះអ្នកដែលកំពុងរងគ្រោះស្រាប់ ហើយអាចធ្វើឲ្យកើនវិសមភាពយេនឌ័រដែលមានស្រាប់មុនគ្រោះមហន្តរាយកើតមានឡើង [57]។

ការស្នាក់អាស្រ័យបណ្តោះអាសន្នមិនសមរម្យក្នុងស្ថានភាពក្រោយគ្រោះមហន្តរាយ ក៏ធ្វើឲ្យស្ត្រីងាយរងគ្រោះចំពោះអំពើហិង្សាផ្លូវភេទ និងយេនឌ័រផងដែរ។ សេចក្តីរាយការណ៍ជាច្រើនបានកត់ត្រាអំពីកំណើនអំពើហិង្សាបែបនេះទៅលើស្ត្រីនៅហៃទី ក្រោយពីការរញ្ជួយដីដ៏បំផ្លិចបំផ្លាញនៅទីនោះនាដើមឆ្នាំ ២០១០[58]។ ឆ្លើយតបនឹងការរកឃើញទាំងនេះ គណៈកម្មាធិការសិទ្ធិមនុស្សអន្តរអាមេរិក បានផ្តល់អនុសាសន៍ជាក់លាក់មួយចំនួនឲ្យទៅរដ្ឋាភិបាលហៃទី ដើម្បីកែលម្អសុវត្ថិភាពសម្រាប់ស្ត្រីនិងក្មេងស្រីដែលរស់នៅក្នុងជំរំទាំងឡាយដែលមានខ្លឹមសារដូចខាងក្រោម ៖

[57] A/64/255 កថាខណ្ឌទី ២១។

[58] សូមមើលឧទាហរណ៍ អង្គការលើកលែងទោសអន្តរជាតិ "បញ្ហាក្រោយព្រឹត្តិការណ៍៖ ស្ត្រីងើបឡើងនិយាយប្រឆាំងអំពើហិង្សាផ្លូវភេទក្នុងជំរំហៃទី" លិបិក្រមអង្គការលើកលែងទោសអន្តរជាតិ៖ AMR 36/001/2011 (ថ្ងៃទី៦ ខែមករា ឆ្នាំ ២០១១)។

*ត្រូវធានាឲ្យមានវត្តមានកម្លាំងសន្តិសុខជុំវិញ និងក្នុងជំរំ [ដែលមានមនុស្សផ្លាស់ទីលំនៅ] ជាពិសេសកម្លាំងសន្តិសុខជាស្ត្រី និងជាពិសេស នៅជិតបន្ទប់ទឹក ត្រូវដាក់ភ្លើងបំភ្លឺឲ្យបានច្រើនឡើងក្នុងជំរំ ត្រូវអនុវត្តវិធានការសម្រួលដល់ការដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌ និងត្រូវធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធផលនៃការស៊ើបអង្កេតតាមផ្លូវតុលាការ ដោយរួមបញ្ចូល ជាពិសេស ការបណ្តុះបណ្តាលមន្ត្រីនគរបាលដែលកំពុងបំពេញភារកិច្ចរបស់ខ្លួនទាក់ទងនឹងករណីអំពើហិង្សាទៅលើស្ត្រី និងត្រូវផ្តល់ជំនួយដោយឥតគិតថ្លៃដោយវេជ្ជបណ្ឌិតឯកទេសដែលមានបទពិសោធន៍ក្នុងការព្យាបាល ជនរងគ្រោះដោយអំពើហិង្សាផ្លូវភេទ[59]* ។

វត្តមានកងកម្លាំងយោធាក្នុងជំរំមួយចំនួនដែលអ្នករស់រានមានជីវិតពីរលកយក្សស៊ូណាមីកំពុងរស់នៅ និងកង្វះភាពជាឯកជនក្នុងទីជម្រកបណ្តោះអាសន្នទាំងនេះក៏ជាកង្វល់ដ៏ធ្ងន់ធ្ងរទាក់ទងនឹងសុវត្ថិភាពរាងកាយរបស់ស្ត្រីផងដែរ ហើយប្រការទាំងនេះក៏បានបង្កើនភាពងាយរងគ្រោះរបស់ស្ត្រីចំពោះអំពោះហិង្សារាងកាយ និងផ្លូវភេទទៀតផង[60]។ ក្នុងបរិបទគ្រោះមហន្តរាយ ករណីអំពើហិង្សាក្នុងគ្រួសារក៏អាចមានការកើនឡើងដែរផង។ ឧទាហរណ៍ ក្នុងប្រទេសនីការ៉ាហ្គ័រ ស្ត្រី ២៧ ភាគរយ និងបុរស ២១ ភាគរយ ដែលជាជនរងគ្រោះដោយសារព្យុះមីតធ៍ បានរាយការណ៍អំពីការកើនឡើងនៃអំពើហិង្សាក្នុងគ្រួសារ[61]។

បន្ទាប់ពីគ្រោះមហន្តរាយ ស្ត្រីមួយចំនួនត្រូវស្ថិតក្នុងលក្ខខណ្ឌរស់នៅមិនសមរម្យ គឺថា ជាញឹកញាប់ស្ត្រីត្រូវរស់នៅក្នុងទីស្នាក់អាស្រ័យបណ្តោះអាសន្ន ឬពេលខ្លះ រហូតដល់គ្មានផ្ទះស្នាក់នៅក៏មានដែរ។ ជំរំ និងទីកន្លែងស្នាក់អាស្រ័យនានា ជារឿយៗ មិនមានទឹកប្រើប្រាស់ និងអនាម័យគ្រប់គ្រាន់នោះទេ ហើយស្ថានភាពនេះជាការដាក់បន្ទុកដ៏ធ្ងន់ធ្ងរលើស្ត្រី។ មួយឆ្នាំក្រោយពីរលកយក្សស៊ូណាមី នៅមហាសមុទ្រឥណ្ឌា អ្នករាយការណ៍ពិសេសទីមួយ បានទាញចំណាប់អារម្មណ៍អំពី ការយកចិត្តទុកដាក់តិចតួចលើស្ត្រី ក្នុងដំណើរការស្តារនីតិសម្បទា និងការស្ថាបនាឡើងវិញ ហើយប្រការទាំងនេះបណ្តាលឲ្យស្ត្រីជាច្រើនត្រូវរស់នៅក្នុងលក្ខខណ្ឌក្រោមស្តង់ដារ មិនត្រូវតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិនោះទេ[62]។

នៅសហរដ្ឋអាមេរិក បន្ទាប់ពីព្យុះកាទ្រីណា បានវាយប្រហារទីក្រុងញូអលីនស៍ នៃរដ្ឋល្វីហ្សីអែណា ក្នុងឆ្នាំ ២០០៥ កិច្ចប្រឹងប្រែងក្នុងការស្ថាបនាឡើងវិញបានផ្តោតជាសំខាន់ទៅលើភាពជាម្ចាស់ ជាជាងទៅលើភាពជាអ្នកជួល សូម្បីមុនពេលគ្រោះមហន្តរាយ ប្រជាជនក្រុងញូអលីនស៍ ច្រើនជាងពាក់កណ្តាល គឺជា

---

[59] សេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី១៨ ខែ វិច្ឆិកា ឆ្នាំ២០១០ “IACHR សំដែងការព្រួយបារម្ភណ៍ពីស្ថានភាពនៅជំរុំសម្រាប់ជនគ្មានទីជម្រកនៅហាយទី”។

[60] សូមមើលសេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី ១៩ ខែ ធ្នូ ២០០៥ អង្គការសហប្រជាជាតិ “អ្នកជំនាញការអង្គការសហប្រជាជាតិថ្លែងថា ការខិតខំប្រឹងប្រែងខាងផ្នែកជំនួយ និងស្តារនីតិសម្បទា នៅតែជាបញ្ហា មួយឆ្នាំបន្ទាប់ពីរលកយក្សស៊ូណាមីនៅ អាស៊ី”។

[61] វូមេនស៍ អិដ្យ កូលីសិន (Women's Edge Coalition) “ស្ត្រី គ្រោះមហន្តរាយធម្មជាតិ និងការស្តារឡើងវិញ” ប័ណ្ណព័ត៌មាន។ មាននៅគេហទំព័រ៖ http://womenthriveworldwide.org/index.php?option=com_kb&page=articles&articleid=5 (ចូលមើលនៅថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០១២)។

[62] សូមមើលសេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០០៥ អង្គការសហប្រជាជាតិ “អ្នកជំនាញការអង្គការសហប្រជាជាតិថ្លែងថា ការខិតខំប្រឹងប្រែងខាងផ្នែកជំនួយ និងស្តារនីតិសម្បទា នៅតែជាបញ្ហា មួយឆ្នាំបន្ទាប់ពីរលកយក្សស៊ូណាមីនៅអាស៊ី”។

អ្នកជួល។ កិច្ចប្រឹងប្រែងក្នុងការស្តាបនាឡើងវិញនេះក៏ធ្វេសប្រហែសមិនបានគិតគូរដល់សេចក្តីត្រូវការក្នុងការមានលំនៅឋានសមរម្យសម្រាប់អ្នកមានចំណូលទាបទេ។ ទោះបីជាបានគ្រប់គ្រងលំនៅឋានសាធារណៈចំនួន ៧៧ ភាគរយ និងគ្រប់គ្រងលំនៅឋានដែលមានការឧបត្ថម្ភធនចំនួន ៨៨ ភាគរយ ក៏ដោយ ក៏ស្ត្រីនៅតែរងផលប៉ះពាល់ដោយមិនសមាមាត្រ ដោយសារតែមិនមានលទ្ធភាពទទួលបានលំនៅឋានសមរម្យដែលអាចលៃលករកបានក្រោយពីព្យុះនោះដដែល[63]។ កិច្ចប្រឹងប្រែងក្នុងការស្តារឡើងវិញ បន្ទាប់ពីរលកយក្សស៊ូណាមីនៅមហាសមុទ្រឥណ្ឌា បានបញ្ជាក់បង្ហាញប្រហាក់ប្រហែលគ្នាអំពី ការមិនយល់ដឹងពីបញ្ហាយេនឌ័រទាល់តែសោះ ក្នុងករណីមួយចំនួន ឧទាហរណ៍ ការផាត់ស្ត្រីចេញពីជំនួយឧបត្ថម្ភផ្នែកជីវភាព ហើយជួនកាល បន្ទាបសិទ្ធិដែលស្ត្រីមានពីមុនគ្រោះមហន្តរាយនោះទៀត ដូចជាសិទ្ធិរបស់ស្ត្រីក្នុងការមានលំនៅឋាន ឬដីធ្លី ក្នុងសហគមន៍ខាងម្តាយទៀតផង [64]។

អ្នករាយការណ៍ពិសេសទីពីរស្តីពីលំនៅឋានសមរម្យ ក៏បានទាញចំណាប់អារម្មណ៍ទៅលើឥទ្ធិពលបម្រែបម្រួលអាកាសធាតុលើសិទ្ធិមានលំនៅឋានសមរម្យដែរ។ ក្នុងបរិបទនៃការតាំងទីលំនៅតាមទីប្រជុំជន លោកស្រីបានសង្កេតឃើញថា "ភាពតានតឹងលើបញ្ហាទឹកដែលមានការកើនឡើង បានបណ្តាលឲ្យការទទួលបានទឹក និងអនាម័យមានការថយចុះ ហើយដោយសារប្រភពទឹករីងស្ងួត ប្រជាជនត្រូវបង្ខំចិត្តធ្វើដំណើរកាន់តែឆ្ងាយដើម្បីទៅរកទឹកសម្រាប់ទទួលទាន ដាំស្ល និងអនាម័យ។ បញ្ហានេះមានផលប៉ះពាល់ពិសេសលើស្ត្រី និងក្មេងស្រីដែលទទួលបន្ទុករកទឹក ហើយជាលទ្ធផល ពួកគេច្រើនរងការប៉ះពាល់លើសុខភាពរបស់ខ្លួន និងខកខានមិនបានទទួលការអប់រំ"។ ក្នុងបរិបទតាំងទីលំនៅថ្មី លោកស្រីក៏បានបញ្ជាក់អំពីទំនោរទាក់ទងនឹងការស្តារនីតិសម្បទា និងការស្តាបនាឡើងវិញបន្ទាប់ពីគ្រោះមហន្តរាយធម្មជាតិ គឺថាស្ត្រីជួបប្រទះបញ្ហាទាក់ទងនឹងកង្វះនូវសិទ្ធិកាន់កាប់ និងសិទ្ធិលើទ្រព្យសម្បត្តិ និងជារឿយៗ មិនត្រូវបានគេគិតគូរទេក្នុងដំណើរការកសាងជីវភាពឡើងវិញនេះ [65]។

## ឆ. វិបត្តិហិរញ្ញវត្ថុ

វិបត្តិហិរញ្ញវត្ថុបច្ចុប្បន្ន ដែលបានចាប់ផ្តើមក្នុងឆ្នាំ ២០០៧ មានផលប៉ះពាល់នៅទូទាំងពិភពលោកលើការទទួលបានសិទ្ធិមានលំនៅឋានសមរម្យ។ នៅសហរដ្ឋអាមេរិក និងប្រទេសដទៃទៀតដែលវិបត្តិដ៏គំហុកនៃកម្ចីទិញផ្ទះបានវាយប្រហារទៅលើវិបត្តិហិរញ្ញវត្ថុនោះ ទំនាក់ទំនងនៃវិបត្តិនេះទៅនឹងសិទ្ធិមានលំនៅឋានសមរម្យ គឺជាបញ្ហាដ៏ស្មុគស្មាញ ជាពិសេស។ ការពិគ្រោះយោបល់តាមអ៊ីនធឺណិតដែលរៀបចំដោយអ្នករាយការណ៍ទីពីរស្តីពីសិទ្ធិមានលំនៅឋានសមរម្យ ដើម្បីរៀបចំរបាយការណ៍ឆ្នាំ ២០១២ របស់លោកស្រីស្តីពីស្ត្រី និងសិទ្ធិមានលំនៅឋានសមរម្យបានរកឃើញថា វិបត្តិហិរញ្ញវត្ថុដែលជាបញ្ហាប៉ះពាល់ដល់វិស័យនានានោះ មានឥទ្ធិពលដល់គ្រប់តំបន់ក្នុងពិភពលោក។ សូម្បីតែមុនវិបត្តិចាប់ផ្តើម ស្ត្រីជាច្រើនកំពុងរស់នៅក្នុង

---

[63] វិទ្យាស្ថានប្រ៊ូកឃីញ និងសាលាសេដ្ឋកិច្ចឡុងដ៍ ឆ្នាំនៃការរស់នៅប្រកបដោយគ្រោះថ្នាក់៖ ការពិនិត្យមើលគ្រោះមហន្តរាយធម្មជាតិក្នុងឆ្នាំ ២០១០ (ខែមេសា ឆ្នាំ២០១១) មានក្នុងគេហទំព័រ www.brookings.edu។

[64] A/66/270 កថាខណ្ឌទី ១៩។

[65] A/64/255 កថាខណ្ឌទី ១៥ និង ៥៩។

ស្ថានភាពហិរញ្ញវត្ថុដ៏គ្រោះថ្នាក់រួចស្រេចទៅហើយ។ ព្រឹត្តិការណ៍ថ្មីៗទាំងនេះ កាន់តែធ្វើឲ្យមានហានិភ័យខ្លាំងឡើងនៃការរំលោភសិទ្ធិមានលំនៅឋាន និងសិទ្ធិស្មើភាពគ្នា ។

ការសិក្សាបានបង្ហាញថា ស្ត្រី និងសមាជិកនៃក្រុមប្រជាជនភាគតិចមួយចំនួន ជាជនរងគ្រោះពីការឲ្យខ្ចីលុយបែបកេងចំណេញហួសហេតុ មានន័យថា ពួកគេត្រូវទទួលកម្ចីដែលមានអត្រាការប្រាក់ខ្ពស់ និងជាលទ្ធផល មានការប្រឈមនឹងហានិភ័យខ្ពស់នៃការរឹបអូស និងភាពគ្មានផ្ទះសម្បែងរស់នៅ។ ឧទាហរណ៍ ស្ត្រីនៅសហរដ្ឋអាមេរិក និងជាពិសេស ស្ត្រីជនជាតិដើមភាគតិច ចំនួន៣២ ភាគរយ ច្រើនជាងបុរសជាអ្នកដែលត្រូវបានពួកអ្នកផ្តល់កម្ចីបែបកេងចំណេញហួសហេតុនេះ ផ្តោតគោលដៅលើច្រើនជាង ទោះបីជាពួកគេមានពិន្ទុឥណទានខ្ពស់ជាមធ្យមក្តី[66]។ អ្នករាយការណ៍ពិសេសរូបនេះ បានសង្កេតឃើញក្នុងរបាយការណ៍ឆ្នាំ ២០១២ របស់លោកស្រីស្តីពី ស្ត្រី និងលំនៅឋានសមរម្យថា "ផលវិបាកនៃការរឹបអូសដោយបង្ខំពីស្ត្រី គឺប្រហាក់ប្រហែលនឹងអ្វីដែលបានកត់ត្រាទុកទាក់ទងនឹងផលប៉ះពាល់នៃការបណ្តេញចេញដោយបំពាន ដូចជា ភាពរស់នៅដាច់ពីគេក្នុងសង្គមដែលមានចំនួនកាន់តែកើនឡើង ការប្រឈមនឹងអំពើហិង្សាក្នុងគ្រួសារកាន់តែកើនឡើង និងភាពក្រីក្រដែលកាន់តែធ្ងន់ធ្ងរទៅ" [67]។

វិបត្តិសេដ្ឋកិច្ចដែលកើតមានកន្លងមកនេះ មានផលប៉ះពាល់ដល់ការទទួលបានសិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ច ដោយរួមបញ្ចូលទាំងសិទ្ធិមានលំនៅឋានសមរម្យ នៅទូទាំងពិភពលោកទៀតផង។ ជាពិសេស រដ្ឋទាំងឡាយ បានកាត់កម្មវិធីសង្គមកិច្ច ដោយរាប់ទាំងកម្មវិធីលំនៅឋានជាច្រើនទៀតផង។ ការអនុវត្តនេះមានផលប៉ះពាល់មិនសមាមាត្រលើស្ត្រី ដែលតំណាងសំឡេងភាគច្រើននៃអ្នកទទួលប្រយោជន៍ពីកម្មវិធីទាំងនេះ។ នៅក្នុងឆ្នាំ ២០១១ សហរដ្ឋអាមេរិក បានកាត់ទឹកប្រាក់ចំនួន ២,៨ ពាន់លានដុល្លារអាមេរិក ពីកម្មវិធីលំនៅឋានសហព័ន្ធ[68]។ នៅទូទាំងអឺរ៉ុប វិធានការសន្សំសំចៃ ក៏បានកាត់បន្ថយការរកបាន និងការលៃលករកបានសម្រាប់លំនៅឋានសាធារណៈផងដែរ។ គួបផ្សំនឹងគម្លាតដ៏ពុំរ៉ៃ ដូចជា គម្លាតនៃប្រាក់កម្រៃដែលផ្អែកលើយេនឌ័រ ផងនោះ[69] បញ្ហានេះបណ្តាលឲ្យមានការលំបាកកាន់តែខ្លាំងឡើងចំពោះស្ត្រី។

ការពិគ្រោះយោបល់តាមអ៊ីនធឺណិតរបស់លោកស្រីអ្នករាយការណ៍ពិសេសរូបនេះ ក៏បានបង្ហាញផងដែរថា នៅទ្វីបអាហ្វ្រិក "ការថយចុះជំនួយបរទេស ក៏ដូចជា ការវិនិយោគផ្ទាល់ពីបរទេស និងការផ្ញើលុយពីបរទេស បណ្តាលឲ្យមានការកាត់បន្ថយយ៉ាងខ្លាំងក្នុងកម្មវិធីលំនៅឋានថ្នាក់ជាតិ។ ជាងនេះទៅទៀត កំណើនថ្មីៗក្នុងការចាប់យកដី និងការលក់អតីតដីសហគមន៍ឲ្យទៅអ្នកវិនិយោគបរទេស បានធ្វើឲ្យការទទួលបានដីធ្លី

---

[66] ក្រុមប្រឹក្សាជាតិដើម្បីការស្រាវជ្រាវពីស្ត្រី "បញ្ហាធំចំនួនប្រាំរបស់ NCRW៖ ស្ត្រី ភាពជាម្ចាស់ផ្ទះ និងកម្ចីទិញផ្ទះ-សេចក្តីត្រូវការដើម្បីការប្រតិបត្តិកម្ចីប្រាក់ដោយយុត្តិធម៌)" ប័ណ្ណព័ត៌មាន។ មានក្នុងគេហទំព័រ www.ncrw.org/sites/ncrw.org/files/Subprime%20mortgages.pdf (ចូលមើលថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២)។

[67] A/HRC/19/53 កថាខណ្ឌទី ១៥។

[68] ផ្នែកការពារជាតិ និងច្បាប់បែងចែកថវិកាពេញមួយឆ្នាំ ឆ្នាំ២០១១។

[69] នៅសហភាពអឺរ៉ុប ជាឧទាហរណ៍ មានគម្លាតនៃការផ្តល់ប្រាក់ឈ្នួលផ្អែកលើយេនឌ័រ ១៨ ភាគរយ ជាមធ្យម ("គម្លាតការផ្តល់ប្រាក់ឈ្នួលផ្អែកលើយេនឌ័រ ក្នុងរដ្ឋជាសមាជិកនៃសហភាពអឺរ៉ុប៖ សូចនាករបែបបរិមាណ និងគុណភាព" របាយការណ៍នាំមុខមកពីប្រទេសបែលហ្ស៊ិកឆ្នាំ ២០១០ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០១០)។

សម្រាប់ស្ត្រីកាន់តែពិបាកឡើងៗ ហើយក៏ [ធ្វើឲ្យគ្រោះថ្នាក់] ដោយផ្ទាល់ចំពោះសិទ្ធិរបស់ស្ត្រីក្នុងការមានលំនៅឋានសមរម្យ ទឹក និងអនាម័យ អាហារ និងសុខភាព”[70]។

[70] A/HRC/19/53 កថាខណ្ឌទី ១៦។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ការងារដែលបានធ្វើដើម្បីដោះស្រាយសិទ្ធិមានលំនៅឋានសមរម្យរបស់ស្ត្រី ដោយរាប់បញ្ចូលទាំងការងារដែលធ្វើដោយអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិទទួលបន្ទុកបញ្ហាលំនៅឋានសមរម្យ បានបង្ហាញយ៉ាងច្បាស់ថា នៅមានគម្លាតដ៏ធំរវាងការទទួលស្គាល់សិទ្ធិរបស់ស្ត្រីក្នុងការមានលំនៅឋានសមរម្យក្នុងច្បាប់អន្តរជាតិ និងច្បាប់ជាតិ ព្រមទាំងតថភាពនៃការមិនទាន់សម្រេចបានសិទ្ធិទាំងនេះ [71]។

មានកន្លែងដ៏ច្រើនសន្ធឹកសន្ធាប់ ដែលបន្តមានទៅដោយច្បាប់ និងគោលនយោបាយរើសអើងយ៉ាងច្បាស់ដែលបដិសេធស្ត្រីនូវសិទ្ធិរបស់ពួកគេក្នុងការមានលំនៅឋានសមរម្យ។ ច្បាប់ទាំងនេះត្រូវនិរាករណ៍ និងធ្វើឲ្យស្របតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ។ រដ្ឋត្រូវពិនិត្យឡើងវិញទៅលើច្បាប់ និងគោលនយោបាយរបស់ខ្លួន ដើម្បីកំណត់ពីករណីទាំងឡាយដែលច្បាប់មានលក្ខណៈអព្យាក្រឹត្យផ្នែកយេនឌ័រ ដូចជា ច្បាប់ទាំងឡាយណាដែលប្រើគំនិត "មេគ្រួសារ" នៅក្នុងនោះ ដែលវាអាចមានឥទ្ធិពលនៃការរើសអើងលើស្ត្រី។ បន្ថែមពីលើការលុបបំបាត់បញ្ញត្តិទាំងឡាយដែលមានការរើសអើង ទោះបីជានៅក្នុងច្បាប់រដ្ឋ ឬច្បាប់ទំនៀមទម្លាប់ក៏ដោយ ក៏រដ្ឋត្រូវដាក់ចេញនូវវិធានការជាក់លាក់ ដើម្បីធានាដល់ការទទួលបានសិទ្ធិមានលំនៅឋានសមរម្យរបស់ស្ត្រី។ ចំណុចនេះរួមមានការទទួលស្គាល់ដោយច្បាស់លាស់នូវសិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងការមិនរើសអើង បញ្ញត្តិជាក់លាក់ដែលពន្យល់យ៉ាងល្អិតល្អន់ពីការចូលរួមរបស់ស្ត្រី ការអនុវត្តច្បាប់ គោលនយោបាយ និងកម្មវិធីនានា និងការតាមដាន ការបង្កើតយន្តការគណនេយ្យភាពដែលស្ត្រីអាចទៅប្រើប្រាស់បាន ព្រមទាំងការផ្តោតចំគោលដៅលើក្រុមដែលងាយរងគ្រោះបំផុត និងមានការយកចិត្តទុកដាក់តិចតួចបំផុតដោយមានទាំងស្ត្រីមកពីក្រុមទាំងនេះផង។ ច្បាប់ និងគោលនយោបាយជាតិ ក៏ត្រូវយោងទៅដល់កាតព្វកិច្ចជាអន្តរជាតិ ព្រមទាំងផ្តល់យន្តការ ដើម្បីអនុវត្តអនុសាសន៍ទាំងឡាយរបស់ស្ថាប័នសិទ្ធិមនុស្សនានាផងដែរ។ ម្យ៉ាងវិញទៀត ត្រូវមានកិច្ចប្រឹងប្រែងនានាដែលចាំបាច់ដើម្បីធានាថា ស្ត្រីដឹងពីសិទ្ធិរបស់ខ្លួន និងត្រូវបានពង្រឹងសិទ្ធិអំណាចដើម្បីទាមទារសិទ្ធិទាំងនេះ។

ប៉ុន្មានឆ្នាំថ្មីៗនេះ មានការវិវត្តជាច្រើនក្នុងការវិភាគថវិកាផ្អែកលើយេនឌ័រ និងការវិភាគថវិកាផ្អែកលើសិទ្ធិមនុស្ស។ ឧបករណ៍ទាំងនេះគួរត្រូវបានប្រើប្រាស់ ដើម្បីប៉ាន់ប្រមាណកម្រិតដែលរដ្ឋត្រូវបែងចែកធនធានរដ្ឋជាអតិបរមា សំដៅធានាសិទ្ធិរបស់ស្ត្រីក្នុងការមានលំនៅឋានសមរម្យ។ ក្នុងន័យនេះ វាមានសារៈសំខាន់នឹងរំឭកថា លក្ខខណ្ឌចាំបាច់តម្រូវមិនឲ្យមានការរើសអើង គឺជាកាតព្វកិច្ច ក្រោមច្បាប់អន្តរជាតិដែលត្រូវចូលជាធរមានភ្លាម។ ការខកខានបង្កើតឲ្យមាននូវកម្មវិធីដើម្បីធានាឲ្យមានសិទ្ធិស្មើភាពគ្នារបស់ស្ត្រីក្នុងការមានលំនៅឋានសមរម្យ អាចជាសញ្ញាបញ្ជាក់យ៉ាងច្បាស់ពីការមិនអនុលោមតាមស្តង់ដារសិទ្ធិមនុស្ស។

[71] ចំពោះសេចក្តីសន្និដ្ឋាន និងអនុសាសន៍នានា សូមមើលរបាយការណ៍នៃអ្នករាយការណ៍ពិសេស (E/CN.4/2003/55 កថាខណ្ឌទី ៧៤-៨១ E/CN.4/2005/43 កថាខណ្ឌទី ៧២-៧៩ E/CN.4/2006/118 កថាខណ្ឌទី ៧៩-៨៧ និង A/HRC/7/16 កថាខណ្ឌទី ៣៦-៤១)។

ការធានាឲ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាពចំពោះសិទ្ធិមានលំនៅឋានសមរម្យ ក៏តម្រូវឲ្យមានការតាមដានដែលផ្អែកលើទិន្នន័យដែលមាន។ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស បានបង្កើតក្របខ័ណ្ឌមួយសម្រាប់កំណត់អំពីសូចនាករសិទ្ធិមនុស្ស ដោយរួមបញ្ចូលទាំងសូចនាករពន្យល់មួយចំនួនទាក់ទងនឹងសិទ្ធិមានលំនៅឋានសមរម្យ[72]។ វាមានសារៈសំខាន់ក្នុងការបែងចែកទិន្នន័យតាមយេនឌ័រ និងតាមមូលដ្ឋាននៃការរើសអើងដទៃទៀត ដើម្បីសម្រួលឲ្យមានការយល់ដឹងទូលំទូលាយអំពីក្រុមដែលត្រូវគេដកហូតលំនៅឋានសមរម្យ។ ការកំណត់សូចនាករ និងការប្រមូលទិន្នន័យទាក់ទងនឹងលំនៅឋានសមរម្យ ត្រូវធ្វើតាមលក្ខណៈដែលមានការចូលរួម ជាពិសេស ត្រូវប្រើប្រាស់ព័ត៌មានតាមបទពិសោធស្ត្រី[73] ។

យន្តការសិទ្ធិមនុស្សអន្តរជាតិ និងថ្នាក់តំបន់ ដើរតួនាទីជាមេដឹកនាំក្នុងការទាញចំណាប់អារម្មណ៍ និងការឆ្លើយតបចំពោះការបដិសេធសិទ្ធិស្ត្រីក្នុងការមានលំនៅឋានសមរម្យ។ អ្នករាយការណ៍ពិសេសបានធ្វើការងារយ៉ាងសំខាន់ទាក់ទងនឹងចំណុចនេះ។ ស្ថាប័នសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ ជាពិសេសគណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី និងគណៈកម្មការស្តីពីសិទ្ធិសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌ ក៏បានបង្ហាញកង្វល់ទាក់ទងនឹងសិទ្ធិរបស់ស្ត្រីក្នុងការមានលំនៅឋានសមរម្យដល់រដ្ឋភាគីផងដែរ។ ចំណុចប្រសព្វរវាងបញ្ញត្តិនៃសន្ធិសញ្ញាទាំងពីរនេះ គឺជាចំណុចដែលត្រូវធ្វើការស្រាវជ្រាវបន្តទៀតដើម្បីផ្តល់ការណែនាំលម្អិតស្តីពីកាតព្វកិច្ចសិទ្ធិមនុស្សជាក់លាក់ទាក់ទងនឹងស្ត្រី និងសិទ្ធិមានលំនៅឋានសមរម្យ។ ក្រុមការងារស្តីពីបញ្ហារើសអើងលើស្ត្រីដែលទើបបង្កើតថ្មី គឺជាយន្តការមួយផ្សេងទៀតដែលអាចរួមចំណែកធ្វើឲ្យកាន់តែមានភាពច្បាស់លាស់ផ្នែកបញ្ញត្តិថែមទៀតក្នុងបញ្ហានេះ។

សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល ដើរតួនាទីយ៉ាងសំខាន់ក្នុងការតាមដានអនុសាសន៍របស់យន្តការសិទ្ធិមនុស្សទាក់ទងនឹងសិទ្ធិរបស់ស្ត្រីលើលំនៅឋាន។ អង្គការទាំងនេះអាចជាស្ថាប័នគន្លឹះក្នុងការវាយតម្លៃពីភាពរីកចម្រើន និងក្នុងការកំណត់រកឲ្យឃើញនូវបញ្ហាដែលកំពុងលេចឡើង[74]។

សិទ្ធិរបស់ស្ត្រីក្នុងការមានលំនៅឋានសមរម្យ ក៏ទាក់ទងគ្នាយ៉ាងជិតស្និទ្ធលើបញ្ហាដីធ្លី និងទ្រព្យសម្បត្តិផងដែរ។ ក្នុងបរិបទនេះ ការកាន់កាប់មិនមានសុវត្ថិភាព ការបណ្តេញចេញដោយបំពាន សំណងបដិទានជាលំនៅឋាន និងដីធ្លី បន្ទាប់ពីបន្លាស់ទីលំនៅ គឺជាក្តីបារម្ភផ្នែកសិទ្ធិមនុស្សដែលទទួលបានការយកចិត្តទុកដាក់កាន់តែច្រើនឡើង។ បញ្ហាសកលដែលកំពុងលេចឡើង ដូចជា សុវត្ថិភាពស្បៀងអាហារ បម្រែបម្រួលអាកាសធាតុ និងនគរូបនីយកម្មដ៏ឆាប់រហ័ស បានធ្វើឲ្យរដ្ឋ ឬផ្នែកឯកជន បន្តមានការចាប់អារម្មណ៍ឡើងវិញចំពោះដីធ្លី ការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងដីធ្លី និងកម្មសិទ្ធិ។ ក៏ប៉ុន្តែ មានការសិក្សាស្រាវជ្រាវតិចតួចណាស់ដែលគេបានធ្វើឡើង ដើម្បីកំណត់ឲ្យឃើញអំពីផលប៉ះពាល់ជាក់លាក់នៃស្ថានភាពទាំងនេះទៅលើ

[72] សូមមើល HRI/MC/2008/3។

[73] ការផ្តួចផ្តើមសង្គមស៊ីវិលដែលចាប់អារម្មណ៍ខ្លះមាននិយាយក្នុង Benjamín Groulx, Género, Vivienda y Hábitat (Red Hábitat, 2010)។

[74] ឧទាហរណ៍ អង្គការសង្គមស៊ីវិលនៅប្រទេសប៉េរូបានធ្វើរបាយការណ៍លើដំណើរការបីឆ្នាំបន្ទាប់ពីទស្សនកិច្ចរបស់អ្នករាយការណ៍ពិសេសស្តីពីលំនៅឋានសមរម្យ៖ *Situación del Derecho a la Vivienda en el Perú*។

ស្ត្រី និងវិធីដោះស្រាយផលប៉ះពាល់ទាំងនេះ។ ភាពសំខាន់យេនឌ័រចំពោះដីធ្លី ជាបញ្ហាសិទ្ធិមនុស្ស និងសិទ្ធិស្មើភាពគ្នារបស់ស្ត្រី នៅត្រង់ចំណុចដែលការទទួលបាន ការប្រើប្រាស់ និងការគ្រប់គ្រងលើដីធ្លី ជាការងារបន្ថែមដែលត្រូវធ្វើជាច្រើនបន្តទៅទៀត។

ការបង្កើតឧបករណ៍នានា ដែលអាចដាក់បញ្ចូលបាននូវទស្សនៈយេនឌ័រយ៉ាងពេញលេញ ដូចជាការវាយតម្លៃពីផលប៉ះពាល់នៃការបណ្តេញចេញ ឬវិធីសាស្ត្រតាមដានមើលលើសុវត្ថិភាពនៃការកាន់កាប់ អាចរួមចំណែកដល់ ការដោះស្រាយផលប៉ះពាល់ជាក់លាក់នៃស្ថានភាពមួយចំនួនទៅលើស្ត្រីប្រកបដោយប្រសិទ្ធផល។

ដូចមានបង្ហាញជាភស្តុតាងនៅក្នុងការបោះពុម្ពផ្សាយនេះ សិទ្ធិរបស់ស្ត្រី ជារឿយៗ ត្រូវបានរំលោភបំពានដោយបុគ្គលមិនមែនជារដ្ឋ។ ស្តង់ដារត្រួតពិនិត្យដ៏ត្រឹមត្រូវ ដែលតម្រូវឲ្យរដ្ឋត្រូវទប់ស្កាត់ ស៊ើបអង្កេត ដាក់ទណ្ឌកម្ម និងផ្តល់សំណង ចំពោះការរំលោភសិទ្ធិមនុស្ស ក៏ដូចជាទប់ស្កាត់និទណ្ឌភាព ផ្តល់ការណែនាំអំពីកាតព្វកិច្ចរបស់រដ្ឋ។ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី បានតម្រូវជាពិសេសឲ្យរដ្ឋ "កែប្រែផ្នត់គំនិតឥរិយាបថសង្គម និងវប្បធម៌របស់បុរស និងស្ត្រី ដើម្បី សម្រេចបាននូវការលុបបំបាត់ចោលសេចក្តីលំអៀង និងទម្លាប់ និងការអនុវត្តជាទម្លាប់ផ្សេងៗទៀត ផ្អែកលើគំនិតស្តីពីភាពទាបជាង ឬខ្ពស់ជាងរបស់ភេទណាមួយ ឬលើតួនាទីជាទម្លាប់សម្រាប់បុរស និងស្ត្រី" (មាត្រា៥)។ ការដោះស្រាយបញ្ហាបុរេនិច្ឆ័យ និងតួនាទីជាទម្លាប់ ដែលជាឧបសគ្គចំពោះស្ត្រី និងដែលចាក់ឫសយ៉ាងជ្រៅនៅស្ទើរគ្រប់វប្បធម៌ក្នុងពិភពលោកនេះ ជាកិច្ចការដ៏ប្រឈមបំផុតមួយ ដើម្បីសម្រេចឲ្យបានសិទ្ធិទាំងឡាយរបស់ស្ត្រី។ តួអង្គមិនមែនរដ្ឋដើរតួនាទីសំខាន់ក្នុងការរក្សា និងបន្តឥរិយាបថលំអៀងចំពោះស្ត្រី។ ការផ្លាស់ប្តូរគំនិតដែលជាវប្បធម៌អំពីភាពទាបជាង និងគំនិតជាទម្លាប់ចំពោះតួនាទីស្ត្រីក្នុងគ្រួសារ និងក្នុងសង្គម មានសារៈសំខាន់ក្នុងការធានាដល់សិទ្ធិស្ត្រីក្នុងការមានលំនៅឋានសមរម្យ ក៏ដូចជាសិទ្ធិមនុស្សជាមូលដ្ឋានដទៃទៀត។ គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្នុងសេចក្តីពន្យល់ទូទៅលេខ ២០ (២០០៩) ស្តីពីការមិនរើសអើងទាក់ទងនឹងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានទទួលស្គាល់កាតព្វកិច្ចជាបន្ទាន់ដើម្បី "ទប់ស្កាត់ បន្ថយ និងលុបបំបាត់លក្ខខណ្ឌ និងឥរិយាបថ ដែលបណ្តាលឲ្យ និងបន្តឲ្យមានការរើសអើងយ៉ាងខ្លាំង ឬយ៉ាងជាក់ស្តែង" និងបានអំពាវនាវឲ្យមាន "វិធីសាស្ត្រដែលមានលក្ខណៈរស់រវើកមួយដើម្បីលុបបំបាត់ការរើសអើងជាប្រព័ន្ធ"។ គោលការណ៍ណែនាំនេះបញ្ជាក់ច្បាស់ថា រដ្ឋទាំងឡាយមានកាតព្វកិច្ចជាក់លាក់ក្នុងការដោះស្រាយកត្តាវប្បធម៌ដែលជំរុញឲ្យមានការរើសអើងប្រឆាំងស្ត្រី។ ជំហានដែលចាំបាច់ក្នុងលើកិច្ចការនេះ នឹងប្រែប្រួលទៅតាមប្រទេសជាតិ និងវប្បធម៌ផ្សេងៗគ្នា ប៉ុន្តែ ការប្រតិបត្តិណាដែលល្អគួររំលេចឡើងឲ្យកាន់តែមានលក្ខណៈជាប្រព័ន្ធឡើង។ គួរមានការធ្វើវិភាគឲ្យបានកាន់តែច្រើនឡើង ដើម្បីវាយតម្លៃថា តើកិច្ចប្រឹងប្រែងបច្ចុប្បន្នដើម្បីផ្លាស់ប្តូរឥរិយាបថជាវប្បធម៌ចំពោះស្ត្រីបានគ្រប់គ្រាន់ហើយឬនៅ។

ក្រៅពីកាតព្វកិច្ចរបស់រដ្ឋ ការងារស្តីពីការទទួលខុសត្រូវរបស់ធុរកិច្ច ចំពោះការរំលោភបំពានសិទ្ធិមនុស្ស គឺជាប្រធានបទដ៏សំខាន់នៃការពិភាក្សាជាអន្តរជាតិ ក្នុងរយៈប៉ុន្មានឆ្នាំចុងក្រោយនេះ។ ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានអនុម័តគោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស ក្នុងឆ្នាំ ២០១១

និងបានបង្កើតក្រុមការងារថ្មីស្តីពីបញ្ហាសិទ្ធិមនុស្ស និងសាជីវកម្មឆ្លងដែន និងសហគ្រាសពាណិជ្ជកម្មផ្សេងទៀត ដើម្បីលើកកម្ពស់ការផ្សព្វផ្សាយ និងការអនុវត្តគោលការណ៍ណែនាំទាំងនេះ។ ការសិក្សាស្រាវជ្រាវ និងការតស៊ូមតិ អាចពិនិត្យរកមើលបន្ថែមទៀតពីការអនុវត្តគោលកាណ៍ណែនាំទាំងនេះ សម្រាប់ស្ថានភាពដែលតួអង្គឯកជនជាអ្នកកាន់កាប់តំណែងដែលផ្តល់ដល់ពួកគេនូវការទទួលខុសត្រូវធ្វើឲ្យសម្រេចបានសិទ្ធិមនុស្សជាក់លាក់ណាមួយ (ដូចជា ម្ចាស់ដី និងធនាគារ ឬស្ថាប័នផ្តល់ប្រាក់កម្ចីដទៃទៀត)[75]។

ខណៈពេលដែលកាងារសំខាន់ត្រូវបានបំពេញ ដើម្បីរំលេចឲ្យឃើញអំពី វិសាលភាពយេនឌ័រដ៏ជាក់លាក់នៃសិទ្ធិមានលំនៅឋានសមរម្យហើយក៏ដោយ ក៏នៅមានការងារច្រើនទៀតដែលត្រូវធ្វើ ដើម្បីស្ត្រីទទួលបាននូវសិទ្ធិនេះ និងសិទ្ធិពាក់ព័ន្ធដទៃទៀត នៅក្នុងការអនុវត្តជាក់ស្តែង។ វិស័យមួយចំនួនសម្រាប់ការងារក្នុងពេលអនាគត ត្រូវបានបង្ហាញឡើងខាងលើ។ សិទ្ធិរបស់ស្ត្រី ក្នុងការមានលំនៅឋានសមរម្យ តម្រូវឲ្យមានការយកចិត្តទុកដាក់កម្រិតអន្តរជាតិ កម្រិតជាតិ និងកម្រិតមូលដ្ឋានជាបន្តទៀត ហើយវាជាប់ទាក់ទងទាំងស្រុងជាមួយកិច្ចការដ៏ធំនិងជាបន្ទាន់នៃការលុបបំបាត់ការរើសអើងយេនឌ័រដែលរីករាលដាល។ ដើម្បីធានាឲ្យបានពេញលេញនូវសិទ្ធិរបស់ស្ត្រីក្នុងការមានលំនៅឋានសមរម្យនោះ ជំហានសំខាន់ៗអាចត្រូវធ្វើឡើងដើម្បីលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី។

[75] សូមមើលរបាយការណ៍អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិទទួលបានទឹកស្អាត និងអនាម័យ អំពីការផ្តល់សេវាដោយអង្គភាពមិនមែនរដ្ឋ ដែលលោកស្រីបានកត់សម្គាល់ថា "ប្រៀបធៀបទៅនឹងសកម្មភាពធុរកិច្ចដទៃទៀត ការផ្តល់សេវាទឹក និងអនាម័យមានលក្ខណៈពិសេស៖ សេវាទាំងនោះទាក់ទងដោយផ្ទាល់ទៅនឹងការសម្រេចបាននូវសិទ្ធិមនុស្ស។ នៅពេលដែលតួអង្គមិនមែនរដ្ឋស្ថិតក្នុងឋានៈដ៏សមស្របមួយក្នុងការរួមចំណែកជាវិជ្ជមានដល់ការធ្វើឲ្យសម្រេចបានសិទ្ធិអនាម័យ និងទឹក តាមរយៈការផ្តល់សេវានោះ សកម្មភាពទាំងឡាយនៃអ្នកផ្តល់សេវា ទោះបីតាមរយៈសកម្មភាពរបស់ខ្លួនផ្ទាល់ ឬដោយការខកខានមិនគោរពតាមអាណត្តិដែលផ្តល់ឲ្យពួកគេក្តី ក៏អាចធ្វើឲ្យមានការរំលោភបំពានលើសិទ្ធិទទួលបានទឹកស្អាត និងអនាម័យផងដែរ។ ត្រង់ចំណុចនេះ សកម្មភាពរបស់ពួកគេជាប់ទាក់ទងយ៉ាងស្អិតរមួតនឹងការសម្រេចបានសិទ្ធិមនុស្ស ដូច្នេះហើយ ពួកគេត្រូវគោរពតាមលក្ខខណ្ឌតម្រូវនានានៅក្នុងការអនុវត្តប្រកបដោយត្រឹមត្រូវ (A/HRC/15/31 កថាខណ្ឌទី ២៨)។

# ធនធានបន្ថែម៖

## ច្បាប់កម្ពុជាដែលកំពុងអនុវត្តចំពោះសិទ្ធិ មានលំនៅឋានសមរម្យរបស់ស្ត្រី

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ (ជំពូកទី៤)
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩
- ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
- ច្បាប់ភូមិបាល ឆ្នាំ១៩៩២ កែសម្រួលថ្មី ឆ្នាំ២០០១
- អនុក្រឹត្យ ឆ្នាំ២០០៣ ស្តីពីការទទួលមរតកសង្គម
- ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២

## សេចក្តីសន្និដ្ឋានចុងក្រោយរបស់ គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) លើរបាយការណ៍តាមកាលកំណត់លើកទីបួន និងទីប្រាំ របស់កម្ពុជា (ឆ្នាំ២០១៣)

- http://cambodia.ohchr.org/WebDOCs/DocTreatyBodies/CEDAW/CEDAW_Concluding_Observations_ENG_2013.pdf

## សេចក្តីសន្និដ្ឋានចុងក្រោយរបស់គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) ទាក់ទងនឹងសិទ្ធិស្ត្រី ក្នុងការមានលំនៅឋានសមរម្យនៅកម្ពុជា (ឆ្នាំ២០១៣)

៤៣. គណៈកម្មាធិការ ជម្រុញរដ្ឋភាគីនានាឲ្យ៖

(ក) ពង្រឹងលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានដីធ្លី និងសុវត្ថិភាពក្នុងការកាន់កាប់ ធានាថាការទទួលបានដីធ្លីសម្រាប់សម្បទានសេដ្ឋកិច្ច និងសម្បទានដទៃទៀត អនុវត្តតាមនីតិវិធីត្រឹមត្រូវ និងត្រូវមានការផ្តល់សំណងសមរម្យ បន្ទាប់ពីដំណើរការពិគ្រោះយោបល់គ្រប់គ្រាន់

(ខ) ទទួលស្គាល់ថា ការបណ្តេញចេញដោយបង្ខំ គឺមិនមែនជាហេតុការណ៍ដែលអព្យាក្រឹតយេនឌ័រនោះទេ ប៉ុន្តែជាហេតុការណ៍ដែលប៉ះពាល់ស្ត្រីដោយមិនសមាមាត្រ ហើយចាត់វិធានការជាបន្ទាន់ដើម្បីការពារស្ត្រី និងកុមារី ពីការបណ្តេញចេញតទៅទៀត

(គ) ត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់ ហើយប្រសិនជាសមស្រប ត្រូវនាំយកមកកាត់ទោសនូវមន្ត្រីអនុវត្តច្បាប់ដែលបានបំភិតបំភ័យ និងគំរាមកំហែងដល់អ្នកការពារសិទ្ធិមនុស្សជាស្ត្រីដែលតស៊ូមតិដើម្បីសិទ្ធិដីធ្លី និង

(ឃ) ធានាថា សហគមន៍ដែលត្រូវបានបណ្តេញចេញ ត្រូវបានទៅតាំងទីលំនៅថ្មីនៅទីកន្លែងដែលអាចឱ្យស្ត្រីងាយធ្វើដំណើរទៅកន្លែងធ្វើការងារ សាលារៀន មណ្ឌលថែទាំសុខភាព (រួមទាំងសេវាគាំពារសុខភាព

ផ្លូវភេទ និងសុខភាពបន្តពូជ) មជ្ឈមណ្ឌលសហគមន៍ និងសេវា និងបរិក្ខារផ្សេងទៀត ដែលចាំបាច់ក្នុងការធានាដល់ការទទួលបានសិទ្ធិរបស់ពួកគេ នៅក្រោមអនុសញ្ញានេះ។[76]

រាជរដ្ឋាភិបាលកម្ពុជា ផ្ញើរបាយការណ៍ទៅគណៈកម្មាធិការនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (ឆ្នាំ២០១១)[77]៖

- http://cambodia.ohchr.org/WebDOCs/DocTreatyBodies/CEDAW/CEDAW-C-KHM-4-5.pdf

ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី៖

- http://cncw.gov.kh/contactus.php

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ឆ្នាំ២០១១) គោលនយោបាយ ដីធ្លី និងយេនឌ័រ៖

- http://women.open.org.kh/files/strategies/Land%20Management%202011-2013.pdf

គេហទំព័រធនធាន ស្ត្រី និងលំនៅឋាននៃការិយាល័យ OHCHR៖

- http://www.ohchr.org/EN/Issues/Housing/Pages/WomenAndHousing.aspx

ស្ត្រី និងលំនៅឋានសមរម្យ។ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមានលំនៅឋានសមរម្យជាផ្នែកមួយនៃសិទ្ធិមានកម្រិតជីវភាពរស់នៅគ្រប់គ្រាន់ និងសិទ្ធិមិនមានការរើសអើង មីលូន កូថារី។ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម ឆ្នាំ២០០៦៖

- http://daccess-dds-ny.un.org/doc/UNDOC/GEN/G06/111/66/PDF/G0611166.pdf?OpenElement

កម្មសិទ្ធិស្មើគ្នារបស់ស្ត្រី លទ្ធភាពទទួលបាន និងការគ្រប់គ្រងដីធ្លី និងសិទ្ធិស្មើគ្នាក្នុងការធ្វើជាម្ចាស់នៃទ្រព្យសម្បត្តិ និងសិទ្ធិមានលំនៅឋានសមរម្យ។ សេចក្តីសម្រេចចិត្តសិទ្ធិមនុស្សលេខ ២០០៥/២៥ ឆ្នាំ២០០៥៖

- http://www.ohchr.org/EN/Issues/Housing/Pages/WomenAndHousing.aspx

កម្មសិទ្ធិស្មើគ្នារបស់ស្ត្រី លទ្ធភាពទទួលបាន និងការគ្រប់គ្រងដីធ្លី និងសិទ្ធិស្មើគ្នាក្នុងការធ្វើជាម្ចាស់ទ្រព្យសម្បត្តិ និងសិទ្ធិមានលំនៅឋានសមរម្យ។ របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ដាក់ជូនស្របតាមសេចក្តីសម្រេចចិត្តរបស់គណៈកម្មាធិការលេខ ២០០១/៣៤ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម ឆ្នាំ២០០២៖

- http://www.ohchr.org/EN/Issues/Housing/Pages/WomenAndHousing.aspx

ការបណ្តេញចេញ និងការតាំងទីលំនៅថ្មីនៅក្នុងប្រទេសកម្ពុជា៖ តម្លៃជាមនុស្ស ផលប៉ះពាល់ និងដំណោះស្រាយ។ ការិយាល័យ OHCHR ប្រចាំកម្ពុជា ឆ្នាំ២០១២៖

[76] CEDAW/C/KHM/CO/4-5
[77] CEDAW/C/KHM/4-5

- http://cambodia.ohchr.org/WebDOCs/DocProgrammes/Resettlement_Study-28_Feb_2012_Eng.pdf

**អង្គការមិនមែនរដ្ឋាភិបាល និងរបាយការណ៍ពាក់ព័ន្ធផ្សេងទៀត៖**


អង្គការលើកលែងទោសអន្តរជាតិ (ឆ្នាំ២០១១) *ការបណ្តេញចេញ និងការតស៊ូនៅកម្ពុជា ស្ត្រីប្រាំនាក់រៀបរាប់រឿងរ៉ាវរបស់ខ្លួន* លេខាធិការដ្ឋានអង្គការលើកលែងទោសអន្តរជាតិ៖ ទីក្រុងឡុងដ៍៖

- http://www.amnesty.org/en/library/info/ASA23/006/2011

វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា(ឆ្នាំ២០០៧) *របាយការណ៍អង្កេតទិន្នន័យមូលដ្ឋាន អំពីការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីនៅកម្ពុជា* CDRI៖ រាជធានីភ្នំពេញ៖

- http://www.cdri.org.kh/webdata/confpap/landtitlingrural.htm

មជ្ឈមណ្ឌលស្តីពីសិទ្ធិលំនៅឋាន និងការបណ្តេញចេញ (ឆ្នាំ២០១១) *ការរស់នៅក្រោមការគំរាមកំហែងដោយគ្មានទីកន្លែងត្រូវទៅ៖* ការស្ទង់មតិមួយស្តីពីផលប៉ះពាល់នៃការបណ្តេញចេញដោយបង្ខំទៅលើស្ត្រីនៅក្នុងរាជធានីភ្នំពេញ COHRE៖ រាជធានីភ្នំពេញ។
ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ឆ្នាំ២០១១) *គោលនយោបាយ ដីធ្លី និងយេនឌ័រ៖*

- http://landportal.info/sites/default/files/cohre_impact_on_forced_eviction_on_women.pdf

ហ្គ្រីមសឌិស្ទ, អិម, កុល អិល & ស៊ារចាន់ ឌី (ឆ្នាំ២០១២) *លទ្ធភាពទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីនៅកម្ពុជា៖* ការសិក្សាស្តីពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធក្នុងខេត្តក្រុង ចំនួនបី នៅកម្ពុជា អង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា៖ រាជធានីភ្នំពេញ៖

- http://www.ngoforum.org.kh/index.php/en/component/jdownloads/finish/15/69

មេរ៉ា អិម ឆាយ យេ និង ម៉ាយ អេស (ឆ្នាំ២០០៨) ទស្សនៈវិស័យរបស់ស្ត្រី៖ ករណីសិក្សាស្តីពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធនៅកម្ពុជារបស់អង្គការ Heinrich Boell Foundation (HBF) និងអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា៖ រាជធានីភ្នំពេញ៖

- http://www.boell.de/en/navigation/asia-5975.html

អិមស៍ជីន្ទ ស៊ី (ឆ្នាំ២០១៣) *"រៀងរាល់ថ្ងៃមានការលំបាកទាំងផ្លូវកាយ និងផ្លូវចិត្តរបស់ខ្ញុំ" ការបណ្តេញចេញដោយបង្ខំនៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា៖ ការរៀបរាប់របស់ស្ត្រីអំពីហានិភ័យ និងភាពអត់ធន់* សាកលវិទ្យាល័យកូឡុំប៊ី៖

- http://academiccommons.columbia.edu/catalog/ac%3A166594

ស្ថានភាពដីធ្លីនៅកម្ពុជា ឆ្នាំ២០១៣ អង្គការអាដហុក ខែមេសា ឆ្នាំ២០១៤៖

- http://www.adhoc-cambodia.org/wp-content/uploads/2014/05/ADHOC-Land-Report-2013_website_spread2.pdf

រចនា និងបោះពុម្ពដោយផ្នែកបោះពុម្ពអង្គការសហប្រជាជាតិ ទីក្រុងហ្សឺណែវ

GE.12.42276 – ខែកក្កដា ឆ្នាំ២០១២ – 5,459 – HR/PUB/11/2

បោះពុម្ពឡើងវិញនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ខែតុលា ឆ្នាំ ២០១៤
ការបោះពុម្ពរបស់អង្គការសហប្រជាជាតិ